# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗ នៃ
# ក្រមរដ្ឋប្បវេណី

## ភាគ ៥ : គន្ថីទី ៧

រៀបចំដោយ

ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី

និង

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១០

# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ក្រមរដ្ឋប្បវេណី

## ភាគ ៥ : គន្ថីទី ៧

រៀបចំដោយ

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី

និង

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១០

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ

ដោយការិយាល័យកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា

នៅឆ្នាំ ២០១០។

កម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

គឺជាកម្មវិធីសហប្រតិបត្តិការបច្ចេកទេស

រវាងក្រសួងយុត្តិធម៌ និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

សិទ្ធិនិពន្ធ © ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

ISBN: 9789995083397

| | អ្នកនិពន្ធ |
|---|---|
| ជំពូកទី ១ និង ជំពូកទី ៣ និង<br>កថាភាគីទី ២ ជំពូកទី ៤ | លោកសាស្ត្រាចារ្យ **Tanamura Masayuki** |
| កថាភាគីទី ១ ជំពូកទី ៤ និង<br>ជំពូកទី ៥ ទៅ ជំពូកទី ៨ | លោកសាស្ត្រាចារ្យ **Motoyama Atsushi** |

<u>កំណត់សម្គាល់</u>

នៅក្នុងសេចក្តីកំណត់នៃមាត្រានីមួយៗ មានសេចក្តីកំណត់ខ្លះដែលមានការបង្ហាញអំពីការបកស្រាយរបស់អ្នកដែលបានរៀបចំសេចក្តីព្រាងដើមនៃមាត្រានោះ ។ សូមចាត់ទុកការបកស្រាយនោះជាទស្សនៈមួយក្នុងចំណោមការបកស្រាយជាច្រើនដែលអាចមាន ដើម្បីយកទៅចាត់ចែងកិច្ចការជាក់ស្តែងនៅប្រទេសកម្ពុជា ។

# មាតិកា


**គន្ថីទី ៧ ញាតិ ---------------------------------------------------------------------------១**

**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ ----------------------------------------------------------------១**

**ជំពូកទី ២ កំជាប់ពាក្យ ----------------------------------------------------------------------៦**

**ជំពូកទី ៣ អាពាហ៍ពិពាហ៍ -----------------------------------------------------------------៨**

ផ្នែកទី ១ ការបង្កើតអាពាហ៍ពិពាហ៍ ----------------------------------------------------------៨

កថាភាគទី ១ ល័ក្ខខ័ណ្ឌនៃអាពាហ៍ពិពាហ៍ -----------------------------------------------៨

កថាភាគទី ២ មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍ ---------------------------១៩

ផ្នែកទី ២ អានុភាពនៃអាពាហ៍ពិពាហ៍ ---------------------------------------------------- ២៦

ផ្នែកទី ៣ ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ---------------------------------------- ២៨

កថាភាគទី ១ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ------------------------------------ ២៨

កថាភាគទី ២ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ---------------------------- ៣០

ផ្នែកទី ៤ ការលែងលះគ្នា -------------------------------------------------------------- ៣៨

កថាភាគទី ១ មូលហេតុនៃការលែងលះគ្នា----------------------------------------- ៣៩

កថាភាគទី ២ នីតិវិធីនៃការលែងលះគ្នា ------------------------------------------- ៤៣

**ជំពូកទី ៤ ឪពុកម្ដាយ និង កូន --------------------------------------------------------៤៥**

ផ្នែកទី ១ បុត្តភាព--------------------------------------------------------------------------៤៥

កថាភាគទី ១ បទប្បញ្ញត្តិទូទៅ -------------------------------------------------------៤៥

កថាភាគទី ២ ការសម្រេចអំពីបុត្តភាព -------------------------------------------------៤៨

កថាភាគទី ៣ ការទទួលស្គាល់ ---------------------------------------------------------៥៤

កថាភាគទី ៤ បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព --------------------- ៦១

កថាភាគទី ៥ បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព -------------------- ៦៣

ផ្នែកទី ២ សុំកូន ------------------------------------------------------------------------៦៦

កថាភាគទី ១ សុំកូនពេញលេញ -------------------------------------------------------៦៦

កថាភាគទី ២ សុំកូនធម្មតា -----------------------------------------------------------៧៩

**ជំពូកទី ៥ អំណាចមេបា------------------------------------------------------------------------៨៩**

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ -------------------------------------------------------------------------៩០

ផ្នែកទី ២ ការសម្រេចអំពីអ្នកមានអំណាចមេបា ក្នុងករណីលែងលះគ្នា និង ការទទួលស្គាល់--------៩២

ផ្នែកទី ៣ សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា ---------------------- ១០០

ផ្នែកទី ៤ ការព្យួរ និង ការដកហូតអំណាចមេបា--------------------------------------- ១០៤

ផ្នែកទី ៥ សិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ------------------------------ ១០៨

ផ្នែកទី ៦ ការព្យួរ និង ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ --------------- ១១៤

ផ្នែកទី ៧ ការយកមកអនុវត្តដូចគ្នានៃជំពូកនេះ ---------------------------------------- ១១៨

**ជំពូកទី ៦ អាណាព្យាបាល ------------------------------------------------------------ ១១៨**

ផ្នែកទី ១ អាណាព្យាបាលសម្រាប់អនីតិជន --------------------------------------- ១១៩

កថាភាគទី ១ ការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន---------------------- ១១៩

កថាភាគទី ២ អ្នកអាណាព្យាបាលសម្រាប់អនីតិជន---------------------------- ១២០

កថាភាគទី ៣ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន------------------ ១២៥

កថាភាគទី ៤ តួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន -------------------- ១២៨

កថាភាគទី ៥ ការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ----------------------១៤៣

កថាភាគទី ៦ ការយកមកអនុវត្តដូចគ្នា ចំពោះកូនរបស់អនីតិជន នៅក្រោមអាណាព្យាបាល - ១៥០

ផ្នែកទី ២ អាណាព្យាបាលទូទៅ --------------------------------------------- ១៥១

កថាភាគទី ១ ការចាប់ផ្តើមអាណាព្យាបាលទូទៅ ------------------------------ ១៥១

កថាភាគទី ២ អ្នកអាណាព្យាបាលទូទៅ------------------------------------ ១៥២

កថាភាគទី ៣ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ-------------------------- ១៥៥

កថាភាគទី ៤ តួនាទីរបស់អ្នកអាណាព្យាបាលទូទៅ ---------------------------- ១៥៧

កថាភាគទី ៥ ការបញ្ចប់អាណាព្យាបាលទូទៅ -------------------------------- ១៦៧

**ជំពូកទី ៧ ហិតូបត្ថម្ភ-------------------------------------------------------------- ១៧០**

**ជំពូកទី ៨ អាហារកាតព្វកិច្ច -------------------------------------------------------- ១៧៥**

**សមាសភាពនៃគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណីកម្ពុជា :**

| | |
|---|---|
| ឯកឧត្តម **អង្គ វង្ស វឌ្ឍានា** | រដ្ឋមន្ត្រី, ក្រសួងយុត្តិធម៌ ( ប្រធាន) |
| ឯកឧត្តម **ស៊ុយ នូ** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ (អាណត្តិទី ១) |
| ឯកឧត្តម **អ៊ី ជន** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ (អាណត្តិទី ២) |
| ឯកឧត្តម **ហ៊ី សោភា** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| លោកជំទាវ **ចាន់ សុន្ធារី** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **យូ ប៊ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ |
| ឯកឧត្តម **គង់ ស្រ៊ីម** | អនុប្រធានតុលាការកំពូល |
| ឯកឧត្តម **ប៊ុន ហ៊ុន** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **កើត រិទ្ធ** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ជួន តេជ** | អគ្គាធិការរង, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ម៉ែន ពេជ្រសាលី** | អគ្គនាយកអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ផូវ សំភី** | អគ្គនាយកអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, ក្រសួងយុត្តិធម៌ |
| លោក **ម៉ុង មុន្នីចរិយា** | ប្រធានសាលាដំបូងខេត្តព្រះសីហនុ |
| លោក **យូរ ឧត្តរា** | ចៅក្រមតុលាការកំពូល |
| លោក **សិរិទ្ធ សុផល** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោក **សាលី ធារ៉ា** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោកស្រី **ខៀវ សុខា** | អគ្គនាយករងអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| លោក **សឹង បញ្ញាវុឌ្ឍ** | ចៅក្រមតុលាការកំពូល |
| លោក **ហ៊ិង ធីឫទ្ធិ** | ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង |
| លោក **ទូច ថាវរិទ្ធិ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ |
| លោក **និត្យ ឫទ្ធី** | ចៅក្រមក្រសួងយុត្តិធម៌ |

**សមាសភាពនៃក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី :**

| | |
|---|---|
| លោក **Morishima Akio** | សាស្ត្រាចារ្យកិត្តិយស, សកលវិទ្យាល័យ Nagoya ( ប្រធាន) |
| លោក **Kamata Kaoru** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Matsumoto Tsuneo** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Hitotsubashi |
| លោក **Minami Toshifumi** | ចៅក្រម, សាលាឧទ្ធរណ៍នៃតំបន់ Tokyo |

| | |
|---|---|
| លោក **Motoyama Atsushi** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Ritsumeikan |
| លោក **Niimi Ikufumi** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Meiji |
| លោក **Nomi Yoshihisa** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Tokyo |
| លោក **Nomura Toyohiro** | ព្រឹទ្ធបុរស និង សាស្ត្រាចារ្យ, សកលវិទ្យាល័យ Gakushuin |
| លោក **Sato Keita** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Chuo |
| លោក **Tanamura Masayuki** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Urakawa Michitaro** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Yamamoto Yutaka** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Kyoto |
| លោក **Hatanaka Hisaya** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Fukuoka |

**ជំនាញការ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន** (JICA) **ប្រចាំក្រសួងយុត្តិធម៌ :**

| | |
|---|---|
| លោក **Sakano Issei** | ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Yamada Yoichi** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Imaizumi Manabu** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោកស្រី **Homma Yoshiko** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kai Mineo** | អតីតអ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kamiki Atsushi** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **Manabe Kana** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **Terauchi Kozue** | អ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kiyohara Hiroshi** | ទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |

**អ្នកបកប្រែ :**

| | |
|---|---|
| លោក **សរ សិនិរា** | អតីតជំនួយការជាន់ខ្ពស់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **ហេង ឆាយ** | អ្នកបកប្រែជាប់កិច្ចសន្យា |
| លោក **ស៊ឹម ធីរៈ** | អ្នកបកប្រែជាប់កិច្ចសន្យា |
| លោក **អ៊ឹ សំភី** | អ្នកបកប្រែជាប់កិច្ចសន្យា |
| លោក **កែវ ទ៉ាន្នី** | ជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Sakano Issei** | ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |

# គន្ថីទី ៧ ញាតិ

## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ៩៣៨**.- ទំហំរបស់ញាតិ

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ គឺជាញាតិ :

ក-ញាតិលោហិតក្នុង ៦ (ប្រាំមួយ) ថ្នាក់

ខ-សហព័ទ្ធ

គ-ញាតិពន្ធក្នុង ៣ (បី) ថ្នាក់

(កំណត់)

មាត្រានេះបញ្ញត្តិអំពីទំហំរបស់ញាតិ ។ អានុភាពផ្លូវច្បាប់ជាច្រើនកើតចេញពីភាពជាញាតិនេះ ហើយក៏មានការចែងដោយឡែកៗពីគ្នាផងដែរនូវបញ្ញត្តិស្តីពីការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិដែលជិត និង បញ្ញត្តិស្តីពីអាហារកាតព្វកិច្ច ។ នៅប្រទេសជប៉ុន មានការទិតៀនយ៉ាងខ្លាំងក្លាចំពោះបញ្ញត្តិនេះ ដោយសំអាងថា ទោះបីជាមិនដាក់បញ្ចូលនូវបទប្បញ្ញត្តិដ៏ទូលំទូលាយក៏ដោយ ក៏អាចឆ្លើយតបដោយបញ្ញត្តិដោយឡែកៗបានដែរ និង ការរិះគន់ថា ពុំមានប្រទេសច្រើនទេដែលមានបញ្ញត្តិទូទៅអំពីទំហំនៃញាតិ និង ការរិះគន់ថា ពុំមានប្រទេសច្រើនទេដែលសហព័ទ្ធត្រូវបានបញ្ចូលនៅក្នុងញាតិ ។ ក៏ប៉ុន្តែ ចំពោះទំហំរបស់ញាតិ មានការចែងជាបទប្បញ្ញត្តិទូទៅជាពិសេស ដែលជាវិធានទូទៅទូលំទូលាយមួយ ដើម្បីឱ្យមានភាពងាយស្រួល ដោយមិនមែនទុកឱ្យតែច្បាប់នីមួយៗ ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ និង ក្រមនីតិវិធីរដ្ឋប្បវេណី ជាដើម ចែងដាច់ដោយឡែកប៉ុណ្ណោះទេ ។ នៅកម្ពុជាក៏ដូចគ្នាដែរ ដោយយកលំនាំតាមក្រមរដ្ឋប្បវេណីជប៉ុន និង ដោយពិចារណាលើការអនុវត្តជាប្រពៃណីនៅប្រទេសកម្ពុជា បទប្បញ្ញត្តិទូលំទូលាយបែបដូចគ្នានេះត្រូវបានតាក់តែងឡើង ។

ញាតិលោហិត សំដៅលើបុគ្គលដែលមានទំនាក់ទំនងសាច់សារលោហិតពីកំណើតជាមួយបុគ្គលម្នាក់ទៀត (ញាតិលោហិតពីកំណើត) ឬ បុគ្គលដែលត្រូវបានចាត់ទុកដោយច្បាប់ថា មានទំនាក់ទំនងសាច់សាលោហិតជាមួយបុគ្គលជាក់លាក់ម្នាក់ទៀតនោះ (ញាតិលោហិតដែលកំណត់ដោយច្បាប់) ។ ញាតិខ្សែផ្ទាល់ គឺជាទំនាក់ទំនងខ្សែលោហិតដែលត្រង់ផ្ទាល់ រីឯសាខាញាតិវិញ គឺសំដៅលើទំនាក់ទំនងញាតិដែលបានបែកចេញជាពីរសាខាពីបុព្វញាតិតែមួយ ។ បុព្វញាតិ គឺជាញាតិក្នុងជំនាន់មុនដោយរាប់បញ្ចូលទាំងជំនាន់ដូចគ្នានឹងជំនាន់ឪពុកម្តាយខ្លួន ឬ ជំនាន់ឪពុកម្តាយរបស់សហព័ទ្ធរបស់ខ្លួន រីឯបុគ្គលជំនាន់ក្រោយដូចជាកូនរបស់ខ្លួន ឬ កូនរបស់សហព័ទ្ធរបស់ខ្លួន និង បុគ្គលក្នុងជំនាន់ក្រោយដោយរាប់បញ្ចូលទាំងជំនាន់ដូចគ្នានឹងកូនៗទាំងនោះ ហៅថា បច្ឆាញាតិ ។ ទោះបីជាញាតិលោហិតត្រូវរាប់ដល់ទៅប្រាំមួយថ្នាក់អញ្ចឹងមែនក៏ដោយ ក៏ជាក់ស្តែង ញាតិលោហិតខ្សែផ្ទាល់ដែលចាប់ពីថ្នាក់ទីបួនទៅ កម្រនឹងនៅរស់រានមានជីវិត

ណាស់ក្នុងជំនាន់ដូចគ្នានោះ ហើយទោះបីជាមានសាខាញាតិលោហិតមួយចំនួន អាចជាជនដែលរស់នៅក្នុងជំនាន់ជាមួយគ្នាក៏ដោយ ក៏មានករណីជាច្រើនដែលទំនាក់ទំនងជីវភាពក្នុងសង្គមរវាងពួកគេមានសភាពដាច់ឆ្ងាយពីគ្នាដែរ ។ ដោយឡែកញាតិពន្ធវិញ សំដៅលើទំនាក់ទំនងរវាងខ្លួនជាមួយនឹងញាតិលោហិតរបស់សហព័ទ្ធរបស់ខ្លួន ឬ ទំនាក់ទំនងរវាងញាតិលោហិតរបស់ខ្លួនជាមួយនឹងសហព័ទ្ធរបស់ខ្លួន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧២៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៣៩.-** ការគណនាថ្នាក់ញាតិ

១-ថ្នាក់ញាតិ ត្រូវកំណត់ដោយគណនាចំនួននៃតំណពូជរវាងញាតិ ។

២-ដើម្បីកំណត់ថ្នាក់ញាតិនៃសាខាញាតិ ត្រូវគណនាចំនួននៃតំណពូជ គិតចាប់ពីជននោះ ឬ សហព័ទ្ធរបស់ជននោះ ឡើងទៅដល់បុព្វជនដូចគ្នា និង ចំនួននៃតំណពូជ គិតចាប់ពីបុព្វជនរបស់ជននោះ ចុះរហូតមកដល់ជនម្នាក់ទៀត ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីថ្នាក់ញាតិ និង អំពីរបៀបគណនាថ្នាក់ញាតិ ។ ថ្នាក់ញាតិគឺជាឯកតាបង្ហាញពីរូបភាពនៃទំនាក់ទំនងញាតិ ។ ប្រសិនបើលេខលំដាប់ថ្នាក់ញាតិកាន់តែតូច ទំនាក់ទំនងញាតិក៏កាន់តែជិតដែរ ។ រវាងញាតិលោហិតខ្សែផ្ទាល់ដែលជាទំនាក់ទំនងខ្សែលោហិតពីលើចុះក្រោម ឬ ពីក្រោមឡើងលើ ថ្នាក់ញាតិត្រូវគណនាដោយការរាប់ចំនួនតំណពូជរបស់ពួកគេ ។ ជាឧទាហរណ៍ ឪពុក និង កូនគឺជាញាតិថ្នាក់ទីមួយ រីឯជីដូនជីតា និង ចៅ គឺជាញាតិថ្នាក់ទីពីរ ។ ចំពោះថ្នាក់នៃសាខាញាតិដែលជាទំនាក់ទំនងលោហិតដែលបានបែកចេញជាពីរសាខាពីបុព្វញាតិតែមួយ ថ្នាក់ញាតិត្រូវគណនាចំនួនតំណពូជដោយគិតចាប់ពីជននោះ ឬ សហព័ទ្ធរបស់ជននោះឡើងទៅដល់បុព្វញាតិដូចគ្នា និង ចំនួននៃតំណពូជគិតចាប់ពីបុព្វញាតិនោះ ចុះរហូតមកដល់ជនម្នាក់ទៀត ។ ឧទាហរណ៍ ពូមីង និង ក្មួយស្ថិតក្នុងថ្នាក់ទីបីនៃសាខាញាតិលោហិត រីឯបងប្អូនជីដូនមួយវិញស្ថិតក្នុងថ្នាក់ទីបួននៃសាខាញាតិលោហិត ។ វិធីសាស្ត្រគណនានេះ ត្រូវបានហៅថាវិធីសាស្ត្ររ៉ូម៉ាំង (Roman Method) ។ ក្រៅពីវិធីសាស្ត្រនេះ មានវិធីសាស្ត្រគណនាមួយផ្សេងទៀតដែលហៅថាវិធីសាស្ត្រកាណុង (Canon Method) ដែលយកតាមច្បាប់ព្រះវិហារសាសនាគ្រិស្ត (Canon Law) ។ របៀបគណនាថ្នាក់ញាតិតាមវិធីសាស្ត្រកាណុង គឺខុសគ្នាពីរបៀបគណនាតាមវិធីសាស្ត្ររ៉ូម៉ាំង ដោយត្រូវរាប់ចំនួនតំណពូជចាប់ពីសាខាញាតិនីមួយៗ ឡើងរហូតដល់បុព្វញាតិរួម ហើយចំនួននៃតំណពូជកាន់តែច្រើនដែលត្រូវគណនា ត្រូវចាត់ទុកថាជាថ្នាក់ញាតិនៃសាខាញាតិលោហិត ។ ជាឧទាហរណ៍ តាមវិធីសាស្ត្រកាណុងនេះ បងប្អូនបង្កើតជាញាតិក្នុងថ្នាក់ទីមួយ រីឯពូនិងក្មួយជាញាតិក្នុងថ្នាក់ទីពីរ ហើយបងប្អូនជីដូនមួយវិញនឹងក្លាយជាញាតិក្នុងថ្នាក់ទីពីរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧២៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៤០.-** ការកើតមានឡើងនូវទំនាក់ទំនងញាតិភាពដោយការសុំកូន

ទំនាក់ទំនងរវាងកូនចិញ្ចឹម និង ឪពុក ម្ដាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ នឹងត្រូវបង្កើតនូវញាតិភាព ដូចគ្នានឹងញាតិលោហិត គិតចាប់ពីថ្ងៃដែលបានសុំកូន ។

(កំណត់)

មាត្រានេះកំណត់អំពីការកើតឡើងនូវទំនាក់ទំនងញាតិលោហិតដែលកំណត់ដោយច្បាប់ និង ទំនាក់ទំនងញាតិភាពដោយសុំកូន ។ ទំនាក់ទំនងនៃឪពុកម្ដាយ និង កូន តាមច្បាប់ ត្រូវកើតឡើងរវាងឪពុកម្ដាយចិញ្ចឹម និង កូនសុំ ចាប់ពីថ្ងៃបង្កើតសុំកូន ហើយទំនាក់ទំនងញាតិភាពរវាងកូនសុំជាមួយញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹម ដែលដូចគ្នាទៅនឹងទំនាក់ទំនងញាតិលោហិតពីកំណើត ក៏ត្រូវកើតឡើងដែរ ។ ប៉ុន្តែ ទំនាក់ទំនងញាតិភាពរវាងញាតិលោហិតរបស់កូនសុំជាមួយនឹងឪពុកម្ដាយចិញ្ចឹម និង រវាងញាតិលោហិតរបស់កូនសុំជាមួយនឹងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹម មិនកើតឡើងទេ ។ ក្នុងករណីសុំកូនពេញលេញ ទំនាក់ទំនងរវាងកូនសុំ និង ញាតិលោហិតរបស់កូនសុំដែលមានមុនសុំកូនត្រូវរលត់ (សុំកូនផ្ដាច់ (disassociating adoption)) ។ ក្នុងករណីសុំកូនធម្មតា ទំនាក់ទំនងញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត និង ញាតិលោហិតរបស់គេមិនរលត់ទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧២៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៩៤១.-** ការរលត់ទំនាក់ទំនងញាតិពន្ធ

១-ទំនាក់ទំនងញាតិពន្ធ ត្រូវបញ្ចប់ដោយការលែងលះគ្នា ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់ បានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ឬ បានបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីការរលត់ទំនាក់ទំនងញាតិពន្ធដែលបានកើតឡើងដោយការរៀបអាពាហ៍ពិពាហ៍ ។ ច្បាប់ក្នុងប្រទេសលោកខាងលិចជាច្រើនចែងថា ទំនាក់ទំនងញាតិពន្ធត្រូវបញ្ចប់ ប្រសិនបើទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានរំលាយ ទោះបីជាការរំលាយនេះជាការរំលាយដោយសារការលែងលះដែលជាការរំលាយនៅពេលសហព័ទ្ធសងខាងនៅរស់

ក៏ដោយ ជាការរំលាយដោយសារការទទួលមរណភាពរបស់សហព័ទ្ធណាម្នាងក៏ដោយ ។ ផ្ទុយទៅវិញ តាមក្រមរដ្ឋប្បវេណីជប៉ុន ការបញ្ចប់ដោយសារមរណភាពរបស់សហព័ទ្ធណាម្ខាង ខុសគ្នាពីការបញ្ចប់ទំនាក់ទំនងញាតិពន្ធដោយសារការលែងលះ ហើយក្នុងករណីដែលសហព័ទ្ធណាម្ខាងទទួលមរណភាព ដើម្បីបញ្ចប់ទំនាក់ទំនងញាតិពន្ធ សហព័ទ្ធដែលនៅរស់ត្រូវធ្វើការបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធជាមួយញាតិរបស់សហព័ទ្ធដែលបានទទួលមរណភាពនោះ ។ ដូចគ្នាដែរ នៅប្រទេសកម្ពុជា ដោយសារតែមានករណីជាច្រើនដែលសហព័ទ្ធដែលនៅរស់ នៅតែបន្តស្នាក់នៅជាមួយគ្រួសាររបស់សហព័ទ្ធដែលទទួលមរណភាព និង មើលថែទាំឪពុកម្តាយរបស់សហព័ទ្ធដែលបានទទួលមរណភាពនោះ ដូច្នោះទើបមានការសម្រេចថា ទុកឱ្យសហព័ទ្ធដែលនៅរស់ជាអ្នកសម្រេចអំពីការរលត់ទំនាក់ទំនងញាតិពន្ធនោះទៅ ដើម្បីកុំឱ្យពួកគេជាប់ចំណងដោយមិនសមហេតុផល ។ ក៏ប៉ុន្តែ ប្រសិនបើសហព័ទ្ធដែលនៅរស់រៀបអាពាហ៍ពិពាហ៍ម្តងទៀត នោះទំនាក់ទំនងញាតិជាមួយនឹងញាតិរបស់សហព័ទ្ធថ្មីនឹងកើតឡើងដែលធ្វើឱ្យទំនាក់ទំនងញាតិមានភាពស្មុគស្មាញ ទើបមាត្រានេះចែងថា ទំនាក់ទំនងញាតិពន្ធត្រូវបញ្ចប់ដោយសារការរៀបអាពាហ៍ពិពាហ៍ថ្មី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧២៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៥៩០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៩៤២.- ការរលត់ញាតិភាព ដោយការកាត់កាល់[១]

ញាតិភាពរវាងកូនចិញ្ចឹម សហព័ទ្ធរបស់ជននោះ បច្ឆាញាតិផ្ទាល់ និង សហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ ជាមួយនឹងឪពុកម្តាយចិញ្ចឹម និង ញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ដោយការកាត់កាល់ ។

(កំណត់)

ទំនាក់ទំនងញាតិលោហិតដែលកំណត់ដោយច្បាប់តាមរយៈការសុំកូន នឹងត្រូវចាត់ទុកដូចគ្នានឹងញាតិលោហិតពីកំណើតដែរ ប៉ុន្តែដោយសារញាតិលោហិតដែលកំណត់ដោយច្បាប់ជាញាតិដែលច្បាប់ជាអ្នកសន្មត ញាតិលោហិតដែលកំណត់ដោយច្បាប់នេះ ត្រូវរលត់ដោយការកាត់កាល់ ។ ការកាត់កាល់ មិនត្រឹមតែរំលត់ញាតិលោហិតភាពរវាងឪពុកម្តាយចិញ្ចឹម និង កូនចិញ្ចឹមនោះទេ ក៏ប៉ុន្តែ វាក៏រំលត់ញាតិភាពរវាងកូនចិញ្ចឹមជាមួយនឹងញាតិលោហិតផ្ទាល់របស់ឪពុកម្តាយចិញ្ចឹមនោះផងដែរ ។ លើសពីនេះទៀត ទំនាក់ទំនងរវាងសហព័ទ្ធ របស់កូនចិញ្ចឹម បច្ឆាញាតិផ្ទាល់របស់កូនចិញ្ចឹមនោះ និងសហព័ទ្ធបច្ឆាញាតិផ្ទាល់របស់កូនចិញ្ចឹម ជាមួយនឹងឪពុកម្តាយ ចិញ្ចឹម និង ជាមួយញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម ក៏នឹងត្រូវរលត់ដែរ ។ ក៏ប៉ុន្តែ ចំពោះការសុំកូនពេញលេញដែលត្រូវបានបង្កើតឡើងដើម្បីសុខុមាលភាពរបស់កូនចិញ្ចឹមដែលជាអនីតិជនវិញ ដោយឈរលើស្មារតីនៃសុខុមាលភាពរបស់ កូនចិញ្ចឹមដែលជាអនីតិជនបែបនេះ ការកាត់កាល់

[១] ចំណងជើង និង បញ្ញត្តិនៃមាត្រា ៩៤២ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

នឹងអាចអនុញ្ញាតឱ្យធ្វើបាន តែក្នុងករណីដែល ការសុំកូនអាចប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់កូនចិញ្ចឹម ដោយសារការធ្វើទុក្ខបុកម្នេញពីសំណាក់ឪពុកម្តាយ ចិញ្ចឹម និង ក្នុងករណីដែលឪពុកម្តាយបង្កើតអាចមើលថែរក្សាកូននោះវិញបាន ជាដើម តែប៉ុណ្ណោះ ។ ក្នុងករណីបែបនេះ ញាតិភាពរវាងកូនចិញ្ចឹម និង ឪពុកម្តាយបង្កើត និង ញាតិលោហិតរបស់កូននោះ នឹងត្រូវបង្កើតឱ្យមានឡើងវិញចាប់ពីថ្ងៃ ដែលការកាត់កាល់បានកើតឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧២៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៤៣.-** ករណីយកិច្ចគោរពគ្នារវាងញាតិ និង ការបង្ការអំពើហិង្សាក្នុងគ្រួសារ

១-សមាជិកម្នាក់ៗនៅក្នុងក្រុមគ្រួសារ ត្រូវគោរពសិទ្ធិ និង សេរីភាពរវាងគ្នាទៅវិញទៅមក ហើយត្រូវសង្គ្រោះគ្នាទៅវិញទៅមក ។

២-សមាជិកម្នាក់ៗនៅក្នុងក្រុមគ្រួសារ ត្រូវបង្ការកុំឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ និង ត្រូវធ្វើយ៉ាងណាកុំឱ្យកើតមានឡើង នូវការរំលោភសិទ្ធិមនុស្ស ។

(កំណត់)

មាត្រានេះតម្រូវឱ្យសមាជិកគ្រួសារមានករណីយកិច្ចគោរពសិទ្ធិ និង សេរីភាពរវាងគ្នាទៅវិញទៅមក និង ជួយសង្គ្រោះគ្នាទៅវិញទៅមក ។ មាត្រានេះបញ្ជាក់ឱ្យច្បាស់ថា សិទ្ធិមនុស្សរបស់សមាជិកម្នាក់ៗនៅក្នុងគ្រួសារ ត្រូវបានការពារ ហើយព្រមជាមួយគ្នានេះដែរ បញ្ជាក់ពីស្មារតីនៃកាតព្វកិច្ចជួយគ្នាទៅវិញទៅមក ក្នុងគ្រួសារដែលជាសហគមន៍ដែលមានជីវភាពរួមគ្នា ។ នៅប្រទេសកម្ពុជា អំពើហិង្សាក្នុងគ្រួសារមានសភាពធ្ងន់ធ្ងរ ហើយមានករណីខ្លះដែលការជួញដូរ និង រំលោភបំពានលើកុមារ ត្រូវបានយល់ច្រឡំថាជាសិទ្ធិអំណាចរបស់ឪពុកម្តាយ ។ ក៏ប៉ុន្តែ មាត្រានេះដាក់បន្ទុកលើសមាជិកគ្រួសារម្នាក់ៗនូវករណីយកិច្ចក្នុងការធានាសុវត្ថិភាព និង សន្តិភាពក្នុងគ្រួសារ ដោយកំណត់ឱ្យមាននូវករណីយកិច្ចក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង ការរំលោភសិទ្ធិមនុស្ស ។ នៅប្រទេសកម្ពុជា ក៏ដូចគ្នានឹងប្រទេសផ្សេងៗដែរ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ បើកលទ្ធភាពក្នុងការដាក់ពាក្យសុំឱ្យតុលាការចេញដីកាការពារដើម្បីទប់ស្កាត់អំពើហិង្សា រារាំងការមកជិត និង ចេញឆ្ងាយពីលំនៅឋាន ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៣០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាពីសហព័ទ្ធ និង កិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៤ របស់ប្រទេសជប៉ុន, មាត្រា ៤ នៃច្បាប់ស្តីពីការទប់ស្កាត់ការរំលោភបំពានលើកុមារ ឆ្នាំ ២០០៤ របស់ប្រទេសជប៉ុន, សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិឆ្នាំ ២០០៣ ស្តីពីការលុបបំបាត់អំពើហិង្សាប្រឆាំងស្ត្រី, មាត្រា ១ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះរបស់ប្រទេសកម្ពុជា ។

## ជំពូកទី ២ កំជាប់ពាក្យ

**មាត្រា ៩៤៤.-** ការបង្កើតកំជាប់ពាក្យ

កំជាប់ពាក្យ ត្រូវបង្កើតឡើង តាមសេចក្ដីសន្យារវាងបុរស នារី ថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នា នាពេលអនាគត និង ដោយធ្វើពិធីកំជាប់ពាក្យ ។

(កំណត់)

តាមទំនៀមទម្លាប់នៅប្រទេសកម្ពុជា ក្រៅពីការសន្យារវាងគូភាគីនៃកំជាប់ពាក្យ ពិធីដែលសង្គមចាត់ទុកថាជាចាំបាច់សម្រាប់ភាគីនៃកំជាប់ពាក្យ (ពិធីលើកស្លា) ក៏ជាល័ក្ខខ័ណ្ឌចាំបាច់ដែរដើម្បីបង្កើតកំជាប់ពាក្យ ។ មាត្រានេះចែងយ៉ាងច្បាស់ថា កំជាប់ពាក្យនឹងមានសុពលភាព ដរាបណាភាគីបានសន្យាថា នឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា នាពេលអនាគត និង ធ្វើពិធីកំជាប់ពាក្យ ។ នៅប្រទេសកម្ពុជា ក្នុងករណីខ្លះ កំជាប់ពាក្យត្រូវបានបង្កើតឡើង ដោយមិនគោរពតាមឆន្ទៈរបស់ជនដែលពាក់ព័ន្ធទេ គឺបែរជាតាមឆន្ទៈរបស់ឪពុកម្ដាយទៅវិញ ។ ក៏ប៉ុន្តែ មាត្រានេះកំណត់ថា កំជាប់ពាក្យត្រូវបង្កើតឡើងដោយឆន្ទៈសេរីរបស់ភាគី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៦ និង ១០៧ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា

**មាត្រា ៩៤៥.-** ការសងជំនូន

ក្នុងករណីដែលកំជាប់ពាក្យបានរលាយ ភាគីដែលបានលើកជំនូននៅពេលកំជាប់ពាក្យ ដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារឱ្យភាគីម្ខាងទៀត សងជំនូននោះមកវិញបាន ។

(កំណត់)

នៅប្រទេសកម្ពុជាក៏ដូចជានៅប្រទេសមួយចំនួនទៀតដែរ តាមទំនៀមទម្លាប់ មានករណីជាច្រើនដែលការជូនដល់ភាគីម្ខាងទៀតនូវប្រាក់កាស និង ទ្រព្យ (ជំនូន) ត្រូវបានធ្វើឡើងនៅពេលដែលមានគម្រោងរៀបអាពាហ៍ពិពាហ៍ ។ ក៏ប៉ុន្តែ មាត្រានេះចែងជាពិសេសអំពីការដែលភាគីម្ខាងអាចទាមទារឱ្យភាគីម្ខាងទៀតសងជំនូនមកវិញបាន នៅក្នុងករណីដែលកំជាប់ពាក្យត្រូវបានរលាយ ។ មាត្រា ១១២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាចែងថា ជនណាដែលបានទទួលជំនូនទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍នាពេលអនាគត មិនទទួលខុសត្រូវចំពោះសំណងនៃការខូចខាតទេ ប្រសិនបើជននោះទទួលមរណភាព ហើយដូច្នេះកំជាប់ពាក្យបានរលាយ ប៉ុន្តែ ភាគីដែលនៅរស់មានសិទ្ធិទាមទារឱ្យភាគីម្ខាងទៀតប្រគល់ជំនូនមកវិញ ។ មាត្រានេះត្រូវបានរៀបរៀងឡើងដើម្បីអនុញ្ញាតឱ្យជនដែលប្រគល់ជំនូនទៅភាគីម្ខាងទៀត

អាចទាមទារជំនួននោះមកវិញបាន ទោះបីជាកំជាប់ពាក្យបានរលាយ ដោយហេតុផលផ្សេងក្រៅពីមរណភាពរបស់ភាគីម្ខាងទៀតក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១២ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា

**មាត្រា ៩៤៦.-** ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ

ក្នុងករណីដែលភាគីណាម្ខាងបានបដិសេធកំជាប់ពាក្យដែលបានភ្ជាប់រវាងភាគីចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការបដិសេធចោលនោះបាន ។

(កំណត់)

កំជាប់ពាក្យគឺជាដំណើរការសង្គមដែលជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍តាមច្បាប់ ហើយមានអត្ថន័យតាមផ្លូវច្បាប់លើសពីអ្វីដែលគ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញ ។ ហេតុដូច្នេះ ក្នុងករណីដែលភាគីម្ខាងបដិសេធចោលកំជាប់ពាក្យដោយមិនត្រឹមត្រូវ ភាគីនោះត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ។ មានប្រទេសលោកខាងលិចកាន់តែច្រើនឡើងដែលដាក់កម្រិតលើការទទួលខុសត្រូវចំពោះសំណងនៃការខូចខាតដោយសារការរំលោភបំពានលើកំជាប់ពាក្យ ។ ជាពិសេស ចំពោះការទាមទារថ្លៃខូចខាតផ្លូវចិត្តដោយសារការបំពានកំជាប់ពាក្យ មានទំនោរនៃការបកស្រាយអវិជ្ជមានកាន់តែខ្លាំងឡើង ដោយសារមូលដ្ឋាននៃការគណនាសំណងមានភាពមិនច្បាស់លាស់ ហើយការដាក់ការទទួលខុសត្រូវចំពោះសំណងនៃការខូចខាតផ្លូវចិត្តនោះ បង្ខំដោយប្រយោលឱ្យភាគីរៀបអាពាហ៍ពិពាហ៍ និង យកល្អគួរតែដោះស្រាយបញ្ហាកំជាប់ពាក្យនោះឱ្យបានឆាប់រហ័ស ប្រសើរជាង ។ ក៏ប៉ុន្តែ ដោយសារតែនៅប្រទេសកម្ពុជា ស្ត្រីស្ថិតក្នុងស្ថានភាពខ្សោយនៅឡើយ និង ដោយសារតែផលខូចខាតដែលបណ្តាលមកពីការបដិសេធកំជាប់ពាក្យដោយមិនត្រឹមត្រូវ នៅមានលក្ខណៈធ្ងន់ធ្ងរនៅឡើយនោះ មាត្រានេះបញ្ជាក់ច្បាស់អំពីការទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ។ ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះការបដិសេធដោយមិនត្រឹមត្រូវ អាចធ្វើការទាមទារសំណងនៃការខូចខាត ដោយយកមូលដ្ឋាននៃការមិនអនុវត្តកាតព្វកិច្ច ឬ ដោយយកមូលដ្ឋាននៃអំពើអនីត្យានុកូលក៏បាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១០ និង ១១១ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា

**មាត្រា ៩៤៧.-** អំឡុងពេលដាក់ពាក្យបណ្តឹង

បណ្តឹងដែលទាក់ទងទៅនឹងមាត្រា ៩៤៥ (ការសងជំនូន) ឬ មាត្រា ៩៤៦ (ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ) ខាងលើនេះ ត្រូវប្តឹងនៅក្នុង

អំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះ បានរលាយ ។

(កំណត់)

មាត្រានេះកំណត់អំពីអំឡុងពេលសម្រាប់ដាក់ពាក្យបណ្ដឹង ដើម្បីដោះស្រាយបណ្ដឹងទាក់ទងនឹងកំជាប់ពាក្យឱ្យបានឆាប់ ។ មាត្រា ១១៣ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា កំណត់អាជ្ញាយុកាលថាជារយៈពេលមួយឆ្នាំ ហេតុដូច្នេះ មាត្រានេះបានអនុលោមតាមមាត្រា ១១៣ នេះដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៣ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា

# ជំពូកទី ៣ អាពាហ៍ពិពាហ៍

## ផ្នែកទី ១ ការបង្កើតអាពាហ៍ពិពាហ៍

### កថាភាគទី ១ លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍

**មាត្រា ៩៤៨.-** អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍

បុរស និង នារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ ។

(កំណត់)

ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បាន មាត្រា ៥ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ តម្រូវឱ្យបុរសមានអាយុយ៉ាងតិច ២០ ឆ្នាំ និង នារីមានអាយុយ៉ាងតិច ១៨ ឆ្នាំ ។ ប៉ុន្តែ ទោះបីជាបុរសមិនទាន់ដល់អាយុ ២០ ឆ្នាំ ហើយនារីមិនទាន់ដល់អាយុ ១៨ ឆ្នាំក៏ដោយ ក្នុងករណីដែលនារីមានផ្ទៃពោះ បុរស និង នារីនោះអាចរៀបអាពាហ៍ពិពាហ៍បាន ដោយមានការអនុញ្ញាតពីឪពុកម្ដាយ ឬ អ្នកអាណាព្យាបាល ។

មាត្រា ១១៦ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា បានកំណត់អាយុអប្បបរមាសម្រាប់រៀបអាពាហ៍ពិពាហ៍ ១៧ ឆ្នាំ ចំពោះបុរស និង ១៤ ឆ្នាំ ចំពោះនារី ។ អាពាហ៍ពិពាហ៍ គឺជាសម្ព័ន្ធភាពមួយជីវិតរវាងបុរស និង នារី ដូច្នេះ បុរស និង នារីនោះចាំបាច់ត្រូវបានពេញវ័យទាំងផ្នែកសេដ្ឋកិច្ច សង្គម ផ្លូវចិត្ត និង ផ្លូវកាយ ។ ហេតុដូច្នេះហើយបានជាច្បាប់នៃប្រទេសនីមួយៗ តែងតែកំណត់អំពីអាយុអប្បបរមាដែលសមរម្យសម្រាប់រៀបអាពាហ៍ពិពាហ៍ ដោយឡែកនៅ

ប្រទេសកម្ពុជាវិញក៏ដូចគ្នាដែរ ដោយមាត្រានេះកំណត់យក ១៨ ឆ្នាំ ដែលជាអាយុដល់នីតិភាព មកជាអាយុអប្បបរមាដែលសមរម្យអាចរៀបអាពាហ៍ពិពាហ៍បាន ។ ក៏ប៉ុន្តែ ដោយសារនៅតាមតំបន់ជនបទ មានអាពាហ៍ពិពាហ៍របស់អនីតិជនជាច្រើន ទើបមាត្រានេះតម្រូវឱ្យមានការយល់ព្រមរបស់ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ដើម្បីបំពេញបន្ថែមលើការខ្វះនូវសមត្ថភាពយល់ព្រមរបស់អនីតិជនដើម្បីឱ្យអាចរៀបអាពាហ៍ពិពាហ៍បាន ។ ប្រសិនបើមានករណីជាច្រើនដែលអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំរបស់ឪពុកម្តាយ អាចគិតពិចារណាអំពីការរៀបចំច្បាប់ដែលតម្រូវឱ្យតុលាការចូលទៅពាក់ព័ន្ធក្នុងអាពាហ៍ពិពាហ៍ដែរ ។

បញ្ហាដែលថា តើអាយុអប្បបរមាដែលអាចរៀបអាពាហ៍ពិពាហ៍បាននោះ ត្រូវកំណត់ដូចម្តេចនោះ គឺអាស្រ័យទៅលើគោលនយោបាយនីតិកម្មនៃប្រទេសនីមួយៗ ។ ជាឧទាហរណ៍ នៅប្រទេសចិនដែលអនុវត្តគោលនយោបាយកូនតែមួយ អាយុអប្បបរមាដែលអាចរៀបអាពាហ៍ពិពាហ៍បាន ត្រូវបានកំណត់ខ្ពស់រហូតដល់ទៅ ២២ ឆ្នាំ ចំពោះបុរស និង ២០ ឆ្នាំ ចំពោះនារី ដោយឡែកនៅប្រទេសបារាំងវិញគឺ ១៨ ឆ្នាំ សម្រាប់បុរស និង ១៥ ឆ្នាំ សម្រាប់នារី ដែលមានគំលាតរវាងអាយុនៃបុរស និង នារី ។ នៅប្រទេសអង់គ្លេស ទាំងបុរស និង នារី អាចរៀបអាពាហ៍ពិពាហ៍បាននៅអាយុ ១៦ ឆ្នាំដូចគ្នា រីឯប្រទេសអ៊ីតាលី រុស្ស៊ី និង អាល្លឺម៉ង់ ជាដើមវិញ កំណត់យកអាយុ ១៨ ឆ្នាំ ទាំងបុរស និង នារី ។ ដោយពិចារណាលើទំនោរនៃប្រទេសទាំងនោះ និង ដោយផ្អែកទៅលើស្មារតីនៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ទើបប្រទេសកម្ពុជា ដូចបានចែងក្នុងមាត្រានេះ ជាគោលការណ៍កំណត់យកអាយុ ១៨ ឆ្នាំ ថាជាអាយុដែលសមរម្យអាចរៀបអាពាហ៍ពិពាហ៍បាន ដោយពុំមានការបែងចែករវាងអាយុសម្រាប់បុរស និង នារីឡើយ ។

ម្យ៉ាងទៀត ចំពោះអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍ ការកំណត់អំពីអាយុដែលអាចរៀបអាពាហ៍ពិពាហ៍បានដោយគិតពីភាពពេញវ័យតាមធម្មជាតិ ដូចមាត្រា ១៤៤ នៃក្រមរដ្ឋប្បវេណីបារាំងនាពេលបច្ចុប្បន្ន និង មាត្រា ៧៣១ នៃក្រមរដ្ឋប្បវេណីជប៉ុន ជាដើម គឺជាគោលការណ៍នីតិកម្មជាទូទៅមួយ ។ ដូច្នេះ មាត្រាដែលត្រូវបានស្នើឡើងរួចហើយមកនេះបញ្ញត្តថា អាយុដែលអាចរៀបអាពាហ៍ពិពាហ៍បាន ជាគោលការណ៍ គឺ ១៨ ឆ្នាំ ដែលជាអាយុដល់នីតិភាពនៅប្រទេសកម្ពុជា ប៉ុន្តែ ជាករណីលើកលែង ការរៀបអាពាហ៍ពិពាហ៍នៃជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់តិចជាង ១៨ ឆ្នាំ ក៏អាចធ្វើទៅបានដែរ ប្រសិនបើល័ក្ខខ័ណ្ឌជាក់លាក់មួយចំនួនត្រូវបានបំពេញ ។

ប្រសិនបើអានុភាពនៃអត្តាធីនភាព ត្រូវបានបកស្រាយថា ជនដែលទទួលអត្តាធីនភាព មានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងនីតិជន ហើយប្រសិនបើមាត្រានេះកំណត់យកអាយុធម្មជាតិជាក់លាក់ (១៨ ឆ្នាំ) ជាអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍ បញ្ញត្តិបែបនេះនឹងបិទលទ្ធភាពឱ្យ ជាឧទាហរណ៍ ជនដែលមានអាយុ ១៧ ឆ្នាំ ដែលបានទទួលអត្តាធីនភាពអាចរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈខ្លួនបានឡើយ ។ មានន័យថា ដើម្បីរៀបអាពាហ៍ពិពាហ៍ ជននោះចាំបាច់ត្រូវទទួលការយល់ព្រមពីឪពុកម្តាយ ជាអាទិ៍ ប៉ុន្តែ ដោយសារតែជនដែលបានទទួលអត្តាធីនភាព ត្រូវមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងនីតិជនដែរ ទើបការយល់ព្រមរបស់ឪពុកម្តាយមិនចាំបាច់ ។

កថាខណ្ឌទី ៤ នៃមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា បញ្ញត្តថា "អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ" ។ មានន័យថា កថាខណ្ឌនេះជ្រើសរើសយកគោលការណ៍នៃអាពាហ៍ពិពាហ៍តាមច្បាប់ ហើយយកការព្រមព្រៀងរបស់ភាគីនៃអាពាហ៍ពិពាហ៍ មកធ្វើជាល័ក្ខខ័ណ្ឌចាំបាច់នៃអាពាហ៍ពិពាហ៍ ។ ការជ្រៀតជ្រែក ឬ អន្តរាគមន៍របស់តតិយជន ត្រូវបានជៀសវាងជាដាច់ខាត ចំពោះសកម្មភាពដែលឆន្ទៈសេរីរបស់បុគ្គលត្រូវតែគោរព ដូចជាការរៀបអាពាហ៍ពិពាហ៍ ។ ប្រសិនបើចាត់ចែងចំពោះជនដែលបានទទួលអត្តាធីនភាព តាមរយៈការប្រកាសរបស់តុលាការ ដូចគ្នានឹងនីតិជន ប៉ុន្តែ តម្រូវឱ្យមានការយល់ព្រមពីឪពុកម្តាយ ចំពោះអាពាហ៍ពិពាហ៍ដែលជាសកម្មភាពមួយដែលសេរីភាពបុគ្គលគួរតែត្រូវបានគោរពដែរនោះ ចំណុចនេះហាក់ដូចជាមានភាពផ្ទុយគ្នា ។ ប្រសិនបើមានការដាក់កម្រិតបែបនេះ យ៉ាងហោចណាស់ក៏ត្រូវមានបញ្ញត្តិច្បាស់លាស់ជាចាំបាច់ដែរ (សូមមើលកថាខណ្ឌទី ២ នៃមាត្រា ៤៨១ នៃក្រមរដ្ឋប្បវេណីបច្ចុប្បន្នរបស់ប្រទេសបារាំង) ។

ផ្តើមចេញពីទស្សនៈបែបនេះហើយបានជាឈានទៅដល់ការសម្រេចថា មាត្រា ៩៤៨ នេះគួរតែចែងដោយប្រើពាក្យ "នីតិជន" គឺមិនមែនអាយុពេញវ័យតាមធម្មជាតិទេ ដើម្បីបញ្ជាក់ឱ្យច្បាស់ថា នីតិជន ឬ ជនដែលចាត់ទុកថា បានដល់នីតិភាព គឺជាជនដែលមានអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍ ហើយអាពាហ៍ពិពាហ៍អាចធ្វើទៅបានទៅតាមឆន្ទៈរបស់ជននោះ ។ ពាក្យ "នីតិភាព" ដែលប្រើក្នុងឃ្លាថា "មិនទាន់បានដល់នីតិភាព" នៅក្នុងមាត្រានេះ សំដៅទៅលើទាំងជនដែលបានដល់អាយុ ១៨ ឆ្នាំ ហើយបានដល់នីតិភាព តាមអាយុតាមធម្មជាតិ និង ជនដែលត្រូវបានចាត់ទុកថាបានដល់នីតិភាពដោយអត្តាធីនភាព ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ១១៦ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា

## មាត្រា ៩៤៩.- ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព

បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ ។

(កំណត់)

ដោយសារការអនុម័តយករបបឯកពន្ធភាព បុរសត្រូវបានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយនារីលើសពីម្នាក់ ហើយនារីក៏មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយបុរសលើសពីម្នាក់បានដែរ ។ មាត្រា ៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ហាមឃាត់មិនឱ្យមានទ្វេពន្ធភាព ។ មាត្រា ១៣៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ទទួលស្គាល់ការរៀបអាពាហ៍ពិពាហ៍ទី ១ និង អាពាហ៍ពិពាហ៍ទី ២ ដែលជាពហុអាពាហ៍ពិពាហ៍ (របបដែលប្តីម្នាក់ដែលមានប្រពន្ធច្រើននាក់) ក៏ប៉ុន្តែ នារីអាចរៀបអាពាហ៍ពិពាហ៍ជាមួយបុរសបានតែម្នាក់ប៉ុណ្ណោះ (មាត្រា ១៤០ នៃក្រមរដ្ឋប្បវេណីចាស់) ។ ទោះជាដូច្នេះក៏ដោយ របបនេះមានលក្ខណៈជាការរើសអើងយ៉ាងខ្លាំងដោយបុរសអាចរៀបអាពាហ៍-

ពិពាហ៍តាមច្បាប់ជាមួយនឹងនារីដល់ទៅ ២ នាក់ ។ មាត្រានេះត្រូវបានតាក់តែងឡើង ដើម្បីហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍តាមច្បាប់ដែលជាន់គ្នា ។ ប៉ុន្តែ មាត្រានេះគ្រាន់តែទប់ស្កាត់អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ដែលជាន់គ្នាប៉ុណ្ណោះ រីឯអាពាហ៍ពិពាហ៍តាមសភាពជាក់ស្តែងវិញមិនអាចពិនិត្យតាមដានដោយមាត្រានេះបានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ របស់ប្រទេសកម្ពុជា, មាត្រា ៧៣២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៤៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៩៥០.-** អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

១-នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ (មួយរយម្ភៃ) ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬ លុបចោល ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ហើយបានសម្រាលកូន ឬ ចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះ ពីវេជ្ជ-បណ្ឌិត ។

(កំណត់)

មាត្រា ៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា បញ្ញត្តថា នារីមិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតទេ រហូតដល់ផុតរយៈពេល ៣០០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលមរណភាពរបស់ប្តី ថ្ងៃប្រកាសសាលក្រមដែលសម្រេចអំពីមោឃភាពនៃអាពាហ៍ពិពាហ៍ ឬ ថ្ងៃប្រកាសសាលក្រមស្ថាពរនៃការលែងលះ ។ ច្បាប់នេះមានបញ្ញត្តិដែលចែងថា ក្នុងករណីដែលនារីរៀបអាពាហ៍ពិពាហ៍ថ្មីទៀតក្នុងរយៈពេល ៣០០ ថ្ងៃ ប្តីដែលនារីនោះរៀបអាពាហ៍ពិពាហ៍ថ្មី នឹងត្រូវបានចាត់ទុកថាជាឪពុករបស់កូនដែលកើតក្នុងអាពាហ៍ពិពាហ៍ថ្មីនោះ លើកលែងមានការជំទាស់ពីប្តីមុន ។

អំឡុងពេលហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ត្រូវបានកំណត់ឡើងសម្រាប់នារី ដើម្បីជៀសវាងការប្រកួតប្រជែងទាក់ទងនឹងការសន្មតបិតុភាពរបស់កូន ដែលមានន័យថា តើកូនដែលកើតមកគួរត្រូវសន្មតថាជាកូនរបស់ប្តីមុន ឬប្តីក្រោយ ។ តាមគម្រោងវិសោធនកម្មក្រមរដ្ឋប្បវេណីជប៉ុន អំឡុងពេលដែលការសន្មតបិតុភាពការប្រកួតប្រជែងគ្នានឹងត្រូវកាត់បន្ថយ (ករណីប្រទេសជប៉ុន គឺ ១០០ថ្ងៃ) ។ ដោយហេតុថា នៅប្រទេសកម្ពុជា អំឡុងពេលប្រកួតប្រជែងគ្នានេះ គឺ ១២០ ថ្ងៃ ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍ថ្មីនៅក្នុងអំឡុងពេលនោះត្រូវបានកម្រិត ។ នៅប្រទេសជប៉ុនមានមតិឱ្យលុបចោល និង កែប្រែអំឡុងពេលនេះ ក៏ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានទស្សនៈខ្លាំងដែលអះអាងថា ការធ្វើការរឹតត្បិតតែទៅលើសិទ្ធិរៀបអាពាហ៍ពិពាហ៍របស់នារី មិនមែនជាការសមរម្យទេ ។ នៅប្រទេសអាល្លឺម៉ង់

បញ្ហានេះត្រូវបានដោះស្រាយ តាមរយៈវិសោធនកម្មក្រមរដ្ឋប្បវេណីនៅឆ្នាំ ១៩៩៨ ដោយលុបចោលការកម្រិតអំឡុងពេល (១០ ខែ) សម្រាប់រៀបអាពាហ៍ពិពាហ៍ថ្មីរបស់នារី ហើយរៀបចំបញ្ញត្តិដែលចែងថា កូនដែលកើតក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍ក្រោយ ត្រូវបានសន្មតថាជាកូនរបស់ប្តីក្រោយ ។

ក្នុងករណីដែលអាចជៀសវាងការប្រកួតប្រជែងទាក់ទងនឹងការសន្មតបិតុភាពបាន ការរៀបអាពាហ៍ពិពាហ៍ថ្មីអាចត្រូវបានអនុញ្ញាត ។ ដូច្នេះ បញ្ញត្តិស្តីពីអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត មិនត្រូវយកមកអនុវត្តទេ ចំពោះករណីដែលគ្មានការប្រកួតប្រជែង ឬ គ្មានការភ័ន្តច្រឡំណាមួយទាក់ទងនឹងការសន្មតបិតុភាព ។ នៅប្រទេសអាល្លឺម៉ង់ និង បារាំង ធ្លាប់មានការបញ្ញត្តរយៈពេល ៣០០ ថ្ងៃថាជាអំឡុពេលហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ថ្មី ឬ អំឡុងពេលរង់ចាំដើម្បីរៀបអាពាហ៍ពិពាហ៍ ក៏ប៉ុន្តែ ប្រសិនបើមានលិខិតបញ្ជាក់អំពីភាពគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបាន ។ កថាខណ្ឌទី ២ នៃមាត្រានេះបញ្ជាក់ច្បាស់លាស់ថា បញ្ញត្តិស្តីពីអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគ្មានការប្រកួតប្រជែងអំពីការសន្មតបិតុភាពកើតឡើងទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ២២៨ និង មាត្រា ២៩៦ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៩៥១.- ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ រវាងញាតិលោហិត

១-អាពាហ៍ពិពាហ៍ មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតក្នុង ៣ (បី) ថ្នាក់ រាប់ទាំង ថ្នាក់ទី ៣ (បី) ផង ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ នៅក្រោយពេលដែលទំនាក់ទំនងញាតិ ត្រូវបានបញ្ចប់ ដោយបញ្ញត្តិនៃមាត្រា ១០១៤ (ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត) មាត្រា ១០១៦ (ការកាត់កាល់កូនសុំពេញលេញ) ឬ មាត្រា ១០៣២ (អានុភាពនៃការកាត់កាល់កូនសុំធម្មតា) នៃក្រមនេះ ។

(កំណត់)

ការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតគ្នាត្រូវបានហាមឃាត់ ដោយសារមូលហេតុនៃសុជាតិវិទ្យា និង មូលហេតុសីលធិមសង្គម ។ ចំពោះមូលហេតុសុជាតិវិទ្យា ការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិត ងាយនឹងបណ្តាលឱ្យពន្ធុខ្សោយជាប់គ្នា ហើយលទ្ធភាពនៃពិការភាពចំពោះកូនដែលកើតមកកើនឡើងខ្ពស់ ។ ក៏ប៉ុន្តែ ការហាមឃាត់នូវអាពាហ៍ពិពាហ៍ចំពោះញាតិថ្នាក់ជិតបែបនេះ បានបណ្តាលមកពីហេតុផលសីលធមិសង្គមច្រើនជាងហេតុផលសុជាតិវិទ្យា ។

ជាឧទាហរណ៍ ការរៀបអាពាហ៍ពិពាហ៍បែបនេះ នឹងបង្កឱ្យមានការរង្កៀសចិត្តគ្នាខាងផ្លូវភេទ ក្នុងចំណោមញាតិថ្នាក់ជិតទាំងនោះ ហើយពីទិដ្ឋភាពនៃការចូលរួមក្នុងសង្គម និង បរិយាកាសនៃការចិញ្ចឹមបីបាច់កូន ក៏មិនមែនជាការគួរឱ្យប្រាថ្នា ហើយក៏នឹងបណ្ដាលឱ្យមានផលប៉ះពាល់ដល់ភាពសុខសាន្តក្នុងគ្រួសារដែរ ។ ជាការពិតណាស់ ការរៀបអាពាហ៍ពិពាហ៍រវាងឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម និង កូនសុំក៏ត្រូវបានហាមឃាត់ផងដែរ ។

ទោះបីជាទំនាក់ទំនងញាតិរវាងកូនសុំ និង ឪពុកម្ដាយបង្កើតត្រូវបានកាត់ផ្ដាច់ដោយសារការបង្កើតស្មុំកូនពេញលេញក៏ដោយ ក៏ទំនាក់ទំនងលោហិតតាមធម្មជាតិមិនរលត់ដែរ ហេតុនេះបានជាការហាមឃាត់ចំពោះអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតនៅតែមានដដែល ។ ដូច្នេះ កថាខណ្ឌទី ២ នៃមាត្រានេះបានបញ្ញត្តថា អាពាហ៍ពិពាហ៍រវាងបុគ្គលដែលធ្លាប់មានទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ ឬ សាខាញាតិលោហិតក្នុងថ្នាក់ទី ៣ នៅមុនពេលបង្កើតស្មុំកូនពេញលេញ និង កូនសុំ ត្រូវបានហាមឃាត់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ៧៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៥២.- ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

១-អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធនៃខ្សែផ្ទាល់ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាដែរ នៅក្រោយពេលដែលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ ដោយបញ្ញត្តិមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិពន្ធ) ឬ មាត្រា ១០១៦ (ការកាត់កាល់នៃស្មុំកូនពេញលេញ) នៃក្រមនេះ ។

២-អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ (បី) ផង ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្រោយពេលបានបញ្ចប់ទំនាក់ទំនងញាតិពន្ធ តាមបញ្ញត្តិនៃមាត្រា ៩៤១ (ការរលត់ទំនាក់ទំនងញាតិពន្ធ) ខាងលើនេះ ។ ប៉ុន្តែ បើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់ អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់បាន ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់ និង រវាងជនដែលធ្លាប់ជាញាតិពន្ធនៃខ្សែផ្ទាល់ ។ ដោយសារញាតិលោហិតនៃខ្សែផ្ទាល់របស់សហព័ទ្ធមានទំនាក់ទំនងប្រហាក់ប្រហែលនឹងញាតិលោហិតខ្សែផ្ទាល់របស់ខ្លួនផ្ទាល់ ដែលស្រដៀងគ្នាទៅនឹងទំនាក់ទំនងឪពុកម្ដាយ និង កូន ដូច្នេះ តាមសីលធម៌សង្គម

ក៏អាពាហ៍ពិពាហ៍បែបនេះមិនមែនជាការគួរដែរ ។

ម៉្យាងវិញទៀត កថាខណ្ឌទី ២ ចែងថា ទោះបីជាសាខាញាតិពន្ធក្នុង ៣ ថ្នាក់ ដោយរាប់ទាំងថ្នាក់ទីបីផងក៏ដោយ ក៏អាពាហ៍ពិពាហ៍រវាងបុគ្គលទាំងនោះត្រូវបានហាមឃាត់ដែរ ដោយសារតែនៅក្នុងសង្គមកម្ពុជា សាខាញាតិពន្ធនេះមាននិន្នាការបង្កើតទំនាក់ទំនងញាតិជារួមដែលមានលក្ខណៈជិតស្និទ្ធស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និង សាខាញាតិលោហិតដែរ ។ ក៏ប៉ុន្តែ ដោយសារតែតាមទំនៀមទម្លាប់ក្នុងប្រទេសកម្ពុជា មានករណីអាពាហ៍ពិពាហ៍ជាមួយបងប្អូនថ្លៃ ដូចជាករណីដែលប្តីបានទទួលមរណភាពទៅ ហើយប្រពន្ធបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយបង ឬ ប្អូនប្រុសដែលនៅលីវរបស់សពប្តី ឬ ករណីដែលប្រពន្ធបានទទួលមរណភាព ហើយប្អូនស្រី ឬ បងស្រីរបស់សពប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ដើម្បីមើលថែទាំកូនរបស់បុគ្គលដែលទទួលមរណភាពនោះ ជាដើម ហើយម៉្យាងវិញទៀត ការរៀបអាពាហ៍ពិពាហ៍រវាងបងប្អូនបង្កើតរបស់ប្តី និង បងប្អូនបង្កើតរបស់ប្រពន្ធ ក៏ឃើញមានផងដែរនោះ ទើបវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ត្រូវបានបញ្ញត្តឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ១៦១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៧៣៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៥៣.- ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

១-ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជននោះ ។

២-បើអ្នកដែលមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាង ជាការគ្រប់គ្រាន់ហើយ ។

៣-ក្នុងករណីដែលអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជនបដិសេធការយល់ព្រមដោយគ្មានមូលហេតុសមរម្យ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឱ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន ។

(កំណត់)

សិទ្ធិផ្តល់ការយល់ព្រមរបស់ឪពុកម្តាយចំពោះកូនដែលជាអនីតិជន គឺជាការយល់ព្រមដែលមានលក្ខណៈជាការគ្រប់គ្រងថែរក្សា ដើម្បីបង្គ្រប់ភាពខ្វះខាតខាងការវិនិច្ឆ័យរបស់អនីតិជននោះ ។ ដោយសារគោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបារួម ចាំបាច់មានការយល់ព្រមពីឪពុកម្តាយទាំងពីរ ។ ក៏ប៉ុន្តែ ប្រសិនបើឪពុក ឬ ម្តាយណាម្នាក់

មិនយល់ព្រមទេ ការយល់ព្រមត្រឹមតែពីសំណាក់ឪពុក ឬ ម្តាយម្នាក់ទៀតគឺជាការគ្រប់គ្រាន់ហើយ ។ ម្យ៉ាងវិញទៀត តាមកថាខណ្ឌទី ៣ នៃមាត្រានេះ ក្នុងករណីដែលឪពុកម្តាយ ឬ អ្នកអាណាព្យាបាលបដិសេធការយល់ព្រម ដោយគ្មានមូលហេតុសមរម្យទេ អនីតិជនដែលមានគម្រោងរៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឱ្យធ្វើការសម្រេចសេចក្តីជំនួសការយល់ព្រមរបស់ឪពុកម្តាយ ឬ របស់អ្នកអាណាព្យាបាលនោះបាន ។

ចំពោះករណីដែលការយល់ព្រមរបស់ឪពុកម្តាយមានភាពចាំបាច់សម្រាប់អាពាហ៍ពិពាហ៍របស់អនីតិជន តាំងពីដើមដំបូងមក ការបកស្រាយពាក្យ "ឪពុកម្តាយ" បានបង្កឱ្យមានការចោទសួរដេញដោលគ្នា ។ ដោយសារវិនិច្ឆ័យថាគួរតែបញ្ជាក់ឱ្យច្បាស់លាស់អំពីបុគ្គលដែលមានសិទ្ធិផ្តល់ការយល់ព្រម មានការសន្និដ្ឋានថា គួរតែប្រើពាក្យ "អ្នកមានអំណាចមេបា" ជំនួស "ឪពុកម្តាយ" ។

ក្នុងករណីដែលប្រើពាក្យ "ឪពុកម្តាយ" មានបញ្ហាដូចតទៅ : ជាឧទាហរណ៍ ចំពោះអនីតិជនអាយុ ១៧ ឆ្នាំដែលមានឪពុកម្តាយលែងលះគ្នា ហើយឪពុកគឺជាអ្នកដែលមានអំណាចមេបាលើអនីតិជន ។ អនីតិជននោះចង់រៀបអាពាហ៍ពិពាហ៍ ប៉ុន្តែ ត្រូវឪពុកបដិសេធ ។ ក្នុងករណីបែបនេះ ប្រសិនបើមាត្រានេះតម្រូវឱ្យមានការយល់ព្រមរបស់ "ឪពុកម្តាយ" នោះអាចមានការបកស្រាយថា អនីតិជនអាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីម្តាយដែលគ្មានអំណាចមេបា ។ ប៉ុន្តែ ការសម្រេចធ្វើដូច្នេះទំនងជាមិនសមរម្យទេ ។

ម្យ៉ាងទៀត មានស្មុំកូនធម្មតាលើអនីតិជនអាយុ ១៧ ឆ្នាំ ហើយរស់នៅជាមួយនឹងឪពុកម្តាយចិញ្ចឹម ។ អនីតិជននោះចង់រៀបអាពាហ៍ពិពាហ៍ ឪពុកម្តាយចិញ្ចឹមបានបដិសេធ ។ យើងអាចគិតឃើញថា ក្នុងករណីបែបដូច្នេះ ប្រសិនបើមានការយល់ព្រមពីឪពុកម្តាយបង្កើតណាម្នាក់ដែលអនីតិជនមិនបានរស់នៅជាមួយ កូនស្មុំនោះអាចរៀបអាពាហ៍ពិពាហ៍បាន ។ ការសម្រេចយកបែបនេះ ក៏មិនសមរម្យដែរ ។

នៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ អនីតិជនត្រូវរួចផុតពីអំណាចមេបា ដោយចាត់ទុកជានីតិជន ។ ទោះបីជាអ្នកមានអំណាចមេបាមិនបានផ្តល់ការយល់ព្រមក៏ដោយ ក៏ឋានៈជាអ្នកមានអំណាចមេបានឹងត្រូវបាត់បង់ ដោយសារតែការយល់ព្រមរបស់អ្នកដែលគ្មានអំណាចមេបាដែរ ។ ដោយការយល់ឃើញបែបនោះ បុគ្គលដែលមានសិទ្ធិផ្តល់ការយល់ព្រមចំពោះអាពាហ៍ពិពាហ៍របស់អនីតិជន គួរតែជាឪពុកម្តាយដែលមានអំណាចមេបា ។ ផ្តើមចេញពីទស្សនទាននោះទើបមានការសម្រេចធ្វើការចែងមាត្រានេះ ដើម្បីបញ្ជាក់ឱ្យច្បាស់នូវខ្លឹមសារនោះ ដោយប្រើពាក្យ "អ្នកមានអំណាចមេបា" ។ ម្យ៉ាងទៀត មាត្រានេះបានកំណត់ឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនថាជាអ្នកដែលមានសិទ្ធិផ្តល់ការយល់ព្រមចំពោះអាពាហ៍ពិពាហ៍របស់អនីតិជនដែរ ក្នុងករណីដែលគ្មានអ្នកមានអំណាចមេបា ។ ដោយសារតែអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងអ្នកមានអំណាចមេបាដែរនោះ (កថាខណ្ឌទី ១ នៃមាត្រា ១០៧៩) ទោះបីជាប្រើពាក្យ "ឪពុកម្តាយ" ជំនួស "អ្នកមានអំណាចមេបា" នៅក្នុងមាត្រានេះក៏ដោយ ក៏អាចមានការបកស្រាយដូចមានរៀបរាប់ខាងលើបានដែរ ។ ក៏ប៉ុន្តែ ចំពោះបញ្ហាដែលពាក់ព័ន្ធទៅនឹងអាពាហ៍ពិពាហ៍ដែលជារបបបង្កើតនូវមូលដ្ឋាននៃសង្គម គួរតែបញ្ជាក់ឱ្យច្បាស់ដោយចែងជាមាត្រា ដោយមិនបាច់អាស្រ័យទៅលើ

ការបកស្រាយទេ ។

ផ្អែកលើការរៀបរាប់ខាងលើ ទំនាក់ទំនងនៃអត្តាធីនភាព ការរៀបអាពាហ៍ពិពាហ៍ និង ការយល់ព្រមឱ្យរៀបអាពាហ៍ពិពាហ៍ អាចត្រូវបានរៀបចំបាន ដូចតារាងខាងក្រោម :

| | ភាគីម្ខាងនៃអាពាហ៍ពិពាហ៍ | ភាគីម្ខាងទៀតនៃអាពាហ៍ពាហ៍ | ការយល់ព្រមឱ្យរៀបអាពាហ៍ពិពាហ៍ |
|---|---|---|---|
| (i) | នីតិជន ( ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ) * | នីតិជន ( ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ) | មិនចាំបាច់ |
| (ii) | នីតិជន ( ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ) | អនីតិជន ( អាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ) | ចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន |
| (iii) | ជនដែលបានទទួលអត្តាធីនភាព ( អាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ) | នីតិជន ( ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ) | មិនចាំបាច់ |
| (iv) | ជនដែលបានទទួលអត្តាធីនភាព ( អាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ) | អនីតិជន ( អាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ) | ចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន |
| (v) | ជនដែលបានទទួលអត្តាធីនភាព ( អាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ) | ជនដែលបានទទួលអត្តាធីនភាព ( អាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ) | មិនចាំបាច់ |

* លេខក្នុងវង់ក្រចកបញ្ជាក់អំពីអាយុតាមធម្មជាតិ ។

ម្យ៉ាងទៀត ប្រសិនបើលែងមានអ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន ក្លាយទៅជាអ្នកដែលមានសិទ្ធិផ្តល់ការយល់ព្រមនេះ ។ ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនទាន់ត្រូវបានជ្រើសតាំងទេ មិនមែនមានន័យថា ការយល់ព្រមមិនចាំបាច់នោះទេ គឺត្រូវធ្វើការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវផ្តល់ការយល់ព្រមលើការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៧៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

**មាត្រា ៩៥៤.-** ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែល

មានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរិមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ ។ ក្នុងករណីនេះ មិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ ។

(កំណត់)

ទោះបីជាបុគ្គលម្នាក់ជានីតិជនដែលមានសមត្ថភាពមិនគ្រប់គ្រាន់ក្នុងការធ្វើការវិនិច្ឆ័យក៏ដោយ ឱ្យតែមានស្ថានភាពដែលអាចបង្ហាញឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍បាន ការសម្រេចចិត្តផ្ទាល់ខ្លួនរបស់បុគ្គលនោះ ត្រូវបានគោរព ហើយអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៣៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៥៥.-** ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីអាពាហ៍ពិពាហ៍

១-អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

២-ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយផ្អែកតាមនីតិវិធីដែលកំណត់ក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង បទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ។[២]

(កំណត់)

នៅប្រទេសកម្ពុជា បុគ្គលដែលចង់រៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ជាលាយល័ក្ខណ៍អក្សរ ហើយមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ នឹងពិនិត្យមើលដើម្បីឱ្យច្បាស់ថា មានការព្រមព្រៀងដោយសេរី (ឆន្ទៈរៀបអាពាហ៍ពិពាហ៍) របស់បុគ្គលដែលពាក់ព័ន្ធ និង គ្មានមូលហេតុដែលរារាំងដល់អាពាហ៍ពិពាហ៍នោះទេ ហើយក្រោយអំឡុងពេល ១០ ថ្ងៃ នៃការជូនដំណឹងជាសាធារណៈបានកន្លងផុតទៅ កិច្ចសន្យាអាពាហ៍ពិពាហ៍នឹងត្រូវបានធ្វើឡើង ហើយអាពាហ៍ពិពាហ៍នឹងត្រូវបានចុះបញ្ជី ។

មាត្រានេះប្រកាសថា ការបង្កើតអាពាហ៍ពិពាហ៍ត្រូវឆ្លងកាត់ដំណាក់កាលជាខ្សែសង្វាក់ដោយចាប់ផ្តើមពីការដាក់ពាក្យសុំ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជី ។ មាត្រានេះទាមទារឱ្យមាន

[២] កថាខណ្ឌទី ២ នៃមាត្រា ៩៥៥ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ទម្រង់បែបបទបច្ចុប្បន្ននៃប្រទេសកម្ពុជា ចាប់តាំងពីការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ រហូតដល់ការចុះបញ្ជី ។
(មាត្រាពាក់ព័ន្ធ)
ចាប់ពីមាត្រា ១១ ទៅ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់កម្ពុជា, ចាប់ពីមាត្រា ២៨ ទៅ នៃអនុក្រឹត្យ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន

**មាត្រា ៩៥៦.-** ការទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំអាចទទួលយកបានឡើយ បើបានទទួលស្គាល់ថា អាពាហ៍ពិពាហ៍នោះ ផ្ទុយនឹងបញ្ញត្តិចាប់ពីមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍-ពិពាហ៍) រហូតដល់មាត្រា ៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណា-ព្យាបាលទូទៅ) ខាងលើនេះ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។

(កំណត់)
ទាក់ទងនឹងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅឃុំ សង្កាត់ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិពិនិត្យមើលភាពសារធាតុនៃអាពាហ៍ពិពាហ៍ថា តើអាពាហ៍ពិពាហ៍នោះមានភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានស្តីពីអាពាហ៍ពិពាហ៍ដែរ ឬទេ ។ មាត្រានេះក៏បញ្ញត្តផងដែរថា បន្ទាប់ពីបានទទួលពាក្យសុំ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យថា តើអាពាហ៍ពិពាហ៍មានភាពផ្ទុយនឹងល័ក្ខខ័ណ្ឌតម្រូវផ្សេងៗដែរ ឬទេ ។
(មាត្រាពាក់ព័ន្ធ)
មាត្រា ៧៣៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២៨ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

**មាត្រា ៩៥៧.-** ទម្រង់នៃអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែលរស់នៅបរទេស

១-បើមានបំណងចង់រៀបអាពាហ៍ពិពាហ៍រវាងគ្នា ពលរដ្ឋខ្មែរដែលរស់នៅបរទេស អាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជូនដំណឹងជាសាធារណៈ ចុះកិច្ចសន្យាអាពាហ៍-ពិពាហ៍ និង ចុះបញ្ជីអាពាហ៍ពិពាហ៍នោះ នៅចំពោះមុខឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុល របស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសនោះ ។

២-ការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើដោយបិទនៅបញ្ជររបស់ស្ថានទូត ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសនោះ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីទម្រង់បែបបទរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនៅបរទេស ។ មានន័យថា មាត្រានេះគឺជាបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍នៅចំពោះមុខភារធារី ឬ កុងស៊ុល ។ មាត្រា ៧៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង មាត្រា ៣២ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានចែងថា ការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ ឬ រវាងពលរដ្ឋខ្មែរ និង ជនបរទេសដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃស្ថានទូត ឬ ស្ថានកុងស៊ុល ឬ ស្ថានអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសដែលគូភាគីមានទីលំនៅ ហើយក្នុងករណីដែលអាពាហ៍ពិពាហ៍នោះ បានប្រព្រឹត្តតាមទម្រង់ដែលបានចែងនៅក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ អាពាហ៍ពិពាហ៍នោះត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនផ្ទុយនឹងបទប្បញ្ញត្តិច្បាប់របស់កម្ពុជាទេ ។ ក្នុងករណីណាក៏ដោយ ការចាត់ចែងចំពោះអាពាហ៍ពិពាហ៍ជាអន្តរជាតិនាពេលបច្ចុប្បន្ន ក៏ត្រូវបានរក្សាទុកក្នុងមាត្រានេះដែរ ក៏ប៉ុន្តែ ត្រូវតែអនុលោមទៅតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ និង អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន រហូតដល់មានបទប្បញ្ញត្តិពិសេសដោយឡែក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ, មាត្រា ៣២ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

## កថាភាគទី ២ មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

**មាត្រា ៩៥៨.-** មោឃភាពនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ នឹងត្រូវចាត់ទុកជាមោឃៈ តែក្នុងករណីដូចកំណត់ខាងក្រោមនេះ :

ក-ប្រសិនបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគី ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និង មូលហេតុផ្សេងៗទៀត ។

ខ- ប្រសិនបើភាគី មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ។ ប៉ុន្តែ ប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍-ពិពាហ៍នេះ មិនត្រូវបានរារាំងដោយសារហេតុនោះឡើយ ។

(កំណត់)

មាត្រា ២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជាចែងថា ការរៀបអាពាហ៍ពិពាហ៍ដែលគូរស្រករនៅក្មេងពេក (ការរៀបអាពាហ៍ពិពាហ៍រវាងកុមារ) និង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំត្រូវហាមឃាត់

ជាដាច់ខាត ។ មោឃភាពនៃអាពាហ៍ពិពាហ៍ចង្អុលបង្ហាញនូវករណីដែលមានកម្រិតខ្ពស់ និង អត្ថន័យខ្លាំងក្នុងការបដិសេធនូវអានុភាពនៃអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដោយឡែកចំពោះការលុបចោលអាពាហ៍ពិពាហ៍វិញ អាពាហ៍ពិពាហ៍នោះនឹងត្រូវបានចាត់ចែងជាអាពាហ៍ពិពាហ៍ដែលមានសុពលភាពរហូតដល់ពេលលុបចោល ។ "ការភាន់ច្រឡំលើមនុស្ស" អាចនិយាយបានថាជាករណីភាន់ច្រឡំអំពីអត្តសញ្ញាណរបស់មនុស្ស ដូចជាការភាន់ច្រឡំលើកូនភ្លោះ ជាដើម រីឯ "ការបង្ខំ" សំដៅលើករណីដែលជនដែលត្រូវរៀបអាពាហ៍ពិពាហ៍គ្មានសេរីភាពជ្រើសរើសទាល់តែសោះ ។ នៅពេលខ្វះឆន្ទៈរៀបអាពាហ៍ពិពាហ៍ ក្នុងករណីណាមួយក៏ដោយ បញ្ញត្តិនេះប្រកាសថា អាពាហ៍ពិពាហ៍បែបនោះ ត្រូវចាត់ទុកជាមោឃៈ ។ មាត្រា ២១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ បានបញ្ញត្តអំពីមោឃភាពនៃអាពាហ៍ពិពាហ៍ ក្នុងករណីដែលខ្វះសមត្ថភាពក្នុងការវិនិច្ឆ័យ ឬ ករណីដែលមានវិបត្តិផ្នែកបញ្ញាស្មារតី ក៏ប៉ុន្តែ អាពាហ៍ពិពាហ៍នោះនឹងក្លាយទៅជាមានសុពលភាព ប្រសិនបើហេតុផលទាំងនោះរលាយទៅវិញ ។

ចំណុច ខ ចែងថា អាពាហ៍ពិពាហ៍នឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មិនបានធ្វើការជូនដំណឹងជាសាធារណៈ មិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ។ ប៉ុន្តែ វាក្យខណ្ឌទី ២ នៃចំណុច ខ នេះបញ្ញត្តថា ទោះបីជាមានកំហុសឆ្គង ឬ វិការៈខាងទម្រង់បន្តិចបន្តួចលើនីតិវិធីក៏ដោយ ក៏អាពាហ៍ពិពាហ៍នោះមិនក្លាយជាមោឃៈដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២ និង មាត្រា ២១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ១៦៥ ដល់មាត្រា ១៦៩ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៩៥៩.- ការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ ត្រូវធ្វើ ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៩៦០ (ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនស្របច្បាប់ ជាអាទិ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬ គំរាមកំហែង) ខាងក្រោមនេះ ។

(កំណត់)

មាត្រានេះបញ្ជាក់ថា ការលុបចោលអាពាហ៍ពិពាហ៍ត្រូវធ្វើតាមបញ្ញត្តិចាប់ពីមាត្រាបន្ទាប់ និង បញ្ញត្តិទាក់ទងនឹងការលុបចោលការបង្ហាញឆន្ទៈ នៅក្នុងគន្ថីទី ៤ មិនត្រូវយកមកអនុវត្តទេ ។ មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍អាចបែងចែកជាពីរប្រភេទ ។ ប្រភេទទី ១ គឺមូលហេតុនៃការលុបចោលដែលមានលក្ខណៈជាផលប្រយោជន៍សាធារណៈ ដូចជាការលុបចោលអាពាហ៍ពិពាហ៍នៃជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ (មាត្រា ៩៤៨) ទ្វេពន្ធភាព (មាត្រា ៩៤៩) អាពាហ៍ពិពាហ៍ដែលបានធ្វើឡើងក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត (មាត្រា

៩៥០) និង អាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិត (មាត្រា ៩៥១ ដល់មាត្រា ៩៥៣) ។ រីឯប្រភេទទី ២ គឺជាមូលហេតុដែលមានលក្ខណៈជាផលប្រយោជន៍ឯកជន ដូចជាការឆបោក និង គំរាម (មាត្រា ៩៦៣) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៦០.-** ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ជាអាទិ៍

១-អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិចាប់ពីមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥២ (ការហាមឃាត់មិនឱ្យរៀបអាពាហ៍-ពិពាហ៍រវាងញាតិពន្ធ) នៃក្រមនេះ ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬ តំណាងអយ្យការ អាចទាមទារទៅតុលាការឱ្យលុបចោលបាន ។ ប៉ុន្តែ នៅក្រោយពេលដែលភាគីណាម្ខាងបានទទួលមរណភាពហើយ តំណាងអយ្យការពុំអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះ បានឡើយ ។

២-ចំពោះអាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) ឬ មាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍-ពិពាហ៍ថ្មីទៀត) នៃក្រមនេះ សហព័ទ្ធរបស់ភាគី ឬ សហព័ទ្ធមុននោះ ក៏អាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ ។

(កំណត់)

មាត្រានេះកំណត់អំពីមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ ដោយផ្អែកលើមូលហេតុដែលមានលក្ខណៈជាផលប្រយោជន៍សាធារណៈ និង អំពីបុគ្គលដែលមានសិទ្ធិទាមទារឱ្យលុបចោល ហើយក៏កំណត់ផងដែរថា ការទាមទារត្រូវធ្វើឡើងដោយការដាក់ពាក្យបណ្ដឹងទៅតុលាការ ដោយសារតែអានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ចាំបាច់ត្រូវធ្វើការកំណត់ជាស្ថាពរឱ្យមានលក្ខណៈជាឯកសណ្ឋាន ។ នៅប្រទេសជប៉ុន ក៏មានទ្រឹស្ដីប្រកបដោយអំណះអំណាងខ្លាំងក្លាដែលលើកឡើងផងដែរថា គួរតែលុបចោលការបំពានអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី ចេញពីមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ទៅ ពីព្រោះវាពុំមានប្រយោជន៍អ្វីដល់ការទប់ស្កាត់ការប្រកួតប្រជែងអំពីការសន្មតបិតុភាពនោះទេ នៅពេលដែលពាក្យសុំរៀបអាពាហ៍ពិពាហ៍ថ្មីនោះត្រូវបានទទួល ហើយវាខុសគ្នាជាមួយនឹងមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ដែលមានភាពផ្ទុយនឹងសង្គម និង សីលធម៌ ដូចជាទ្វេពន្ធភាព ឬ អាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិត ។

ចំពោះអាពាហ៍ពិពាហ៍រវាងជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ ឬ អាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិត បុគ្គលដែលមានសិទ្ធិទាមទារឱ្យលុបចោល គឺជាភាគីណាមួយនៃអាពាហ៍ពិពាហ៍ ញាតិរបស់ជននោះ ឬ តំណាងអយ្យការ

រីឯចំពោះករណីទ្វេពន្ធភាព ឬ ការបំពានអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីវិញ សហព័ទ្ធរបស់ភាគី ឬ សហព័ទ្ធនៃអាពាហ៍ពិពាហ៍មុន ក៏អាចទាមទារឱ្យលុបចោលបានដែរ ។ ប៉ុន្តែ ចំពោះតំណាងអយ្យការដែលជាអ្នកតំណាងឱ្យផលប្រយោជន៍សាធារណៈ សិទ្ធិទាមទារឱ្យលុបចោលរបស់តំណាងអយ្យការនោះត្រូវរលត់ ប្រសិនបើសហព័ទ្ធម្ខាងទទួលមរណភាព ។ បញ្ញត្តិនេះមានប្រភពចេញមកពីមាត្រា ១៩០ នៃក្រមរដ្ឋប្បវេណីបារាំង ហើយត្រូវបានរៀបចំឡើងក្នុងក្រមនេះ ដោយសារអង្គហេតុបំពានប្រយោជន៍សាធារណៈ ត្រូវបានធ្វើឱ្យបាត់បង់ទៅវិញ ដោយសារការរលាយនូវចំណងអាពាហ៍ពិពាហ៍ដោយសារមរណភាពរបស់សហព័ទ្ធនោះ ហើយគ្មានប្រយោជន៍អ្វីទៀតឡើយ ក្នុងការលុបចោលនៅក្រោយមរណភាពនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៦១.- ការរលត់សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ដែលភាគីមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍

១-អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) នៃក្រមនេះ ប្រសិនបើជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ពុំអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានឡើយ ។

២-ក្រោយពេលជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ជននោះក៏នៅតែអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន នៅក្នុងអំឡុងពេល ៣ (បី) ខែ ចាប់ពីពេលដែលជននោះបានគ្រប់អាយុ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើជននោះបានធ្វើសច្ចានុមតិ បន្ទាប់ពីបានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ ។

(កំណត់)

ការរៀបអាពាហ៍ពិពាហ៍របស់ជនមិនទាន់គ្រប់អាយុ ត្រូវចាត់ទុកថា មានភាពផ្ទុយនឹងផលប្រយោជន៍សាធារណៈ ដូច្នេះ អាពាហ៍ពិពាហ៍នេះគឺជាកម្មវត្ថុនៃការលុបចោល ។ ក៏ប៉ុន្តែ ក្នុងករណីដែលជនមិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍បានដល់អាយុរៀបអាពាហ៍ពិពាហ៍ សិទ្ធិទាមទារឱ្យលុបចោលត្រូវរលត់ ដោយមានមូលហេតុថា ការបំពានលើល័ក្ខខ័ណ្ឌសម្រាប់ការរៀបអាពាហ៍ពិពាហ៍ត្រូវបានជួសជុលហើយ ដូច្នេះលែងប្រឆាំងនឹងសង្គមទៀតហើយ ហើយទោះបីជាជនក្រៅពីភាគីអនុវត្តសិទ្ធិលុបចោលអាពាហ៍ពិពាហ៍ក៏ដោយ ក៏ភាគីនៃអាពាហ៍ពិពាហ៍នោះនៅតែអាចរៀបអាពាហ៍ពិពាហ៍

សាឡើងវិញបានដែរ ដូច្នេះ គ្មានផលប្រយោជន៍ជាក់ស្តែងក្នុងការលុបចោលទេ ។ បើទោះជាដូច្នេះក្តី ជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិលុបចោល និង សិទ្ធិធ្វើសច្ចានុមតិ ក្នុងអំឡុងពេលបីខែ បន្ទាប់ពីជននោះដល់អាយុរៀបអាពាហ៍ពិពាហ៍ ។ ដោយសារមូលហេតុនៃការលុបចោលនេះគឺជាមូលហេតុសម្រាប់ផលប្រយោជន៍ឯកជន សិទ្ធិលុបចោលត្រូវរលត់ ដោយសារការធ្វើសច្ចានុមតិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៦២.- ការលុបចោលអាពាហ៍ពិពាហ៍ធ្វើនៅក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ ពុំអាចទាមទារឱ្យលុបចោលបានឡើយ ប្រសិនបើរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃ បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍-ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ឬ ប្រសិនបើនារីមានផ្ទៃពោះ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ។

(កំណត់)

មាត្រានេះហាមឃាត់នារីមិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតក្នុងរយៈពេល ១២០ ថ្ងៃបន្ទាប់ពីការរលាយ ឬ ការលុបចោលអាពាហ៍ពិពាហ៍មុន ដើម្បីជៀសវាងការប្រកួតប្រជែងលើការសន្មតបិតុភាព ។ បញ្ញត្តិនេះចែងថា អាពាហ៍ពិពាហ៍ដែលពាក្យសុំត្រូវបានទទួលដោយរំលោភលើការហាមឃាត់នេះ ត្រូវលុបចោល ។ ប៉ុន្តែ ទន្ទឹមនឹងនេះដែរ បើគិតពីគោលបំណងនៃបញ្ញត្តិនេះ សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ ក៏ត្រូវរលត់ នៅពេលដែលលែងមានភាពចាំបាច់ក្នុងការលុបចោលអាពាហ៍ពិពាហ៍ ។ សិទ្ធិលុបចោលនឹងត្រូវរលត់ នៅពេលដែលរយៈពេល ១២០ ថ្ងៃបានកន្លងផុត ដោយនារីគ្មានផ្ទៃពោះ ទោះបីជានារីនោះរៀបអាពាហ៍ពិពាហ៍ក្នុងរយៈពេលកំណត់ឱ្យរង់ចាំក៏ដោយ ដោយសារបញ្ហាទាក់ទងនឹងការប្រកួតប្រជែងលើការសន្មតបិតុភាពនឹងមិនកើតឡើងឡើយ ។ សិទ្ធិលុបចោលក៏ត្រូវរលត់ផងដែរ ក្នុងករណីដែលនារីមានផ្ទៃពោះក្រោយរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៩៦៣.- ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬ ការគំរាម

១-បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម អាចទាម

ទារទៅតុលាការ ឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន ។

២-សិទ្ធិលុបចោលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរលត់ បើភាគីបានរកឃើញការឆបោក ឬ បើអំឡុងពេល ៣ (បី) ខែ បានកន្លងផុត ក្រោយពីបានរួចខ្លួនផុតពីការគំរាម ឬ បើបានធ្វើសច្ចានុមតិ ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិលុបចោល ក្នុងករណីដែលមានវិការៈចំពោះឆន្ទៈរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម ។ បញ្ញត្តិនេះគឺជាការកំណត់អំពីមូលហេតុនៃការលុបចោលដែលមានលក្ខណៈជាផលប្រយោជន៍ឯកជន ដើម្បីការពារផលប្រយោជន៍របស់ភាគីនៃអាពាហ៍ពិពាហ៍ ។ ចំពោះវិសាលភាពនៃបុគ្គលដែលមានសិទ្ធិលុបចោល និង ការធ្វើសច្ចានុមតិ មានភាពខុសគ្នានឹងមូលហេតុផ្សេងទៀតនៃការលុបចោលអាពាហ៍ពិពាហ៍ ។ ដោយសារតែបញ្ញត្តិនេះជាបញ្ញត្តិដើម្បីការពារជនដែលបានរៀបអាពាហ៍ពិពាហ៍ ដោយសារការឆបោក ឬ ការគំរាម សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ ត្រូវបានផ្ដល់ឱ្យតែភាគីនៃអាពាហ៍ពិពាហ៍ដែលបានទទួលការឆបោក ឬ ការគំរាមប៉ុណ្ណោះ ។ ភាគីម្ខាងទៀតនៃការលុបចោល គឺជាភាគីម្ខាងទៀតនៃអាពាហ៍ពិពាហ៍ ដោយរាប់បញ្ចូលទាំងករណីនៃការឆបោក ឬ ការគំរាមដែលត្រូវបានធ្វើឡើងដោយតតិយជនផង ។

ការឆបោក ឬ ការគំរាមគឺសំដៅលើការធ្វើឱ្យភាគីម្ខាងទៀតយល់ព្រមរៀបអាពាហ៍ពិពាហ៍ដោយសារមធ្យោបាយខ្លាំងក្លាមួយដែលខុសច្បាប់ ដោយការបោកប្រាស់ឱ្យជននោះធ្លាក់ទៅក្នុងការភាន់ច្រឡំ ឬ ការធ្វើឱ្យជននោះធ្វើតាមដោយការជូនដំណឹងអំពីភាពអាក្រក់ទៅភាគីម្ខាងទៀត ។ ការឆបោក ឬ ការគំរាមចាំបាច់ត្រូវមានភាពផ្ទុយច្បាប់ដែលមានកម្រិតខ្ពស់ ។ វាអាចមានករណីដូចជាអាពាហ៍ពិពាហ៍ដែលត្រូវបានកើតឡើង ដោយសារមធ្យោបាយដែលត្រូវបានប្រើប្រាស់ដែលមានលក្ខណៈឆបោក ពាក់ព័ន្ធទៅនឹងអសមត្ថភាពផ្លូវភេទ ឬ ចំណុចសំខាន់ៗផ្សេងទៀតជាសត្យានុម័ត ឬជាអត្តនោម័ត ឬ ដោយពាក្យសម្ដី ឬ អំពើគំរាមកំហែង ជាដើម ។

ដោយសារការឆបោក ឬ ការគំរាមគឺជាមូលហេតុនៃការលុបចោលដែលមានលក្ខណៈជាផលប្រយោជន៍ឯកជន សិទ្ធិលុបចោលត្រូវរលត់ នៅពេលមានការធ្វើសច្ចានុមតិ ឬ បើអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលភាគីបានរកឃើញការឆបោក ឬ រួចខ្លួនផុតពីការគំរាម បានកន្លងផុតទៅ ។ មាត្រានេះគិតគូរដល់ស្ថិរភាពអាពាហ៍ពិពាហ៍ឱ្យមានអាទិភាពជាងការការពារផលប្រយោជន៍របស់ភាគីដែលជាជនរងគ្រោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨០ និង ១៨១ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៩៦៤.- អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

១-ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលឡើយ ។

២-ភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍-ពិពាហ៍ ប្រសិនបើបានទទួលទ្រព្យសម្បត្តិ ដោយការរៀបអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិនោះ ត្រឹមកម្រិតនៃផលប្រយោជន៍ដែលបានទទួល ។

៣-ភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ ត្រូវសងផលប្រយោជន៍ទាំងអស់ ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ ។ ប្រសិនបើភាគីម្ខាងទៀតសុចរិតវិញ ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ ។

៤-បញ្ញត្តិនៃមាត្រា ៩៨៨ (ការសន្មតបិតុភាព) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះកូនដែលមានកំណើតរវាងភាគីនៃអាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន ។

៥-បញ្ញត្តិនៃមាត្រា ៩៨០ (ការបែងចែកទ្រព្យសម្បត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីនៃការរំលាយអាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន ។

(កំណត់)

ខណៈដែលអានុភាពប្រតិសកម្មត្រូវបានទទួលស្គាល់ចំពោះការលុបចោលនូវសកម្មភាពគតិយុត្តជាទូទៅ មាត្រានេះបដិសេធអានុភាពប្រតិសកម្មនៃការលុបចោលអាពាហ៍ពិពាហ៍ ដោយពិចារណាដល់គុណវិបត្តិដែលត្រូវកើតឡើងចំពោះភាគី កូន និង តតិយជន ប្រសិនបើអាពាហ៍ពិពាហ៍នោះត្រូវបានចាត់ទុកជាមោឃៈដោយមានអានុភាពប្រតិសកម្ម ។ ក៏ប៉ុន្តែ ចំពោះផលប្រយោជន៍លើទ្រព្យសម្បត្តិដែលទទួលបានតាមរយៈអាពាហ៍ពិពាហ៍ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃមាត្រានេះ ចែងអំពីករណីយកិច្ចប្រគល់មកវិញ ដូចបញ្ញត្តិទាក់ទងនឹងសេចក្ដីចម្រើនដោយឥតហេតុទូទៅ ។

អាពាហ៍ពិពាហ៍ត្រូវមានសុពលភាព រហូតដល់សេចក្ដីសម្រេចរបស់តុលាការដែលសម្រេចលុបចោល ចូលជាស្ថាពរ ហើយទោះបីជាសេចក្ដីសម្រេចរបស់តុលាការបានចូលជាស្ថាពរហើយក៏ដោយ ក៏ការលុបចោលនឹងគ្មានអានុភាពទៅលើអតីតកាលទេ ពោលគឺគ្រាន់តែមានអានុភាពរំលាយអាពាហ៍ពិពាហ៍ឆ្ពោះទៅអនាគតប៉ុណ្ណោះ ។ ដូច្នេះ ចំពោះការសន្មតបិតុភាព កូនដែលបានកើតនៅមុនពេលលុបចោលអាពាហ៍ពិពាហ៍ ត្រូវបានសន្មតថាជាកូនរបស់ប្ដីមុនពេលលុបចោលអាពាហ៍ពិពាហ៍ ហើយបញ្ញត្តិស្ដីពីការបែងចែកទ្រព្យសម្បត្តិនៅក្រោយពេលលែងលះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបែងចែកទ្រព្យសម្បត្តិក្រោយការលុបចោលអាពាហ៍ពិពាហ៍នោះ ។

ទ្រព្យសម្បត្តិដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍ រួមមានទ្រព្យសម្បត្តិដែលត្រូវបានធ្វើប្រទានកម្មនៅពេលរៀបអាពាហ៍ពិពាហ៍ និង ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈសន្តតិកម្ម និង អច្ច័យទាន និង ផលប្រយោជន៍ពីការធានារ៉ាប់រងជីវិត ជាអាទិ៍ រីឯផលប្រយោជន៍ដែលបានទទួលដោយការរៀប

អាពាហ៍ពិពាហ៍ រួមមានផលប្រយោជន៍លើទ្រព្យសម្បត្តិទាំងអស់ ដូចជាលំនៅ ថ្លៃចំណាយលើម្ហូបអាហារ និង ការកំសាន្ត ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២០១ និង មាត្រា ២០២ នៃក្រមរដ្ឋប្បវេណីបារាំង ។

## ផ្នែកទី ២ អានុភាពនៃអាពាហ៍ពិពាហ៍

**មាត្រា ៩៦៥.-** នាមត្រកូលរបស់ប្ដី ប្រពន្ធ

ផ្អែកតាមការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្ដី ប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្ដី ឬ ប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន ។

(កំណត់)

មាត្រានេះចែងថា ប្ដីប្រពន្ធអាចប្រើប្រាស់នាមត្រកូលប្ដី ឬ ប្រពន្ធក៏បាន ឬ នាមត្រកូលរៀង១ខ្លួនដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ក៏បាន ។ មាត្រានេះគោរពសិទ្ធិស្វ័យសម្រេចចំពោះនាមត្រកូល និង សិទ្ធិបុគ្គល និង ធានារបបដែលប្ដីប្រពន្ធអាចជ្រើសរើសប្រើនាមត្រកូលខុសគ្នា ។ ជាគោលការណ៍ ប្ដីប្រពន្ធនៅប្រទេសកម្ពុជា ប្រើនាមត្រកូលខុសគ្នា ដោយសារតែនាមត្រកូលបង្ហាញឱ្យតំណខ្សែលោហិត និង ឫសគល់នៃឪពុកម្ដាយ និង ដូនតា ហើយដោយសារតែវាមានតួនាទីសម្គាល់អត្តសញ្ញាណរបស់ជនគ្រប់រូបជាមួយនឹងនាមខ្លួន ទើបយើងសម្រេចយកយន្តការដែលជនគ្រប់រូបអាចជ្រើសរើសដោយសេរីនូវនាមត្រកូល បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច ។ នៅប្រទេសកម្ពុជា កូនកើតមក តាមទំនៀមទម្លាប់ គឺដាក់ឈ្មោះតាមឪពុក ជីតា ឬ បុព្វជនដែលចាស់ជាងនេះទៀត ក៏ប៉ុន្តែ ការអនុវត្តយកនាមត្រកូលគ្រួសារពុំច្បាស់លាស់ទេ ។ ប៉ុន្តែ រាជវង្ស និង ជនដែលមានតំណែងខ្ពង់ខ្ពស់ក្នុងសង្គមមានត្រកូល ហើយលក្ខណៈ និង និយមន័យនៃនាមត្រកូល មានភាពស្មុគស្មាញគួរសម ។ ទោះជាដូច្នេះក្ដី ផ្នែកដំបូងនៃឈ្មោះហាក់ដូចជាត្រូវបានចាត់ទុកថាជានាមត្រកូល ឬ ត្រកូល ហើយនៅពេលចុះបញ្ជី ក៏ចាំបាច់ត្រូវធ្វើការបែងចែកនាមត្រកូល និង នាមខ្លួន ហើយដោយផ្អែកលើលទ្ធផលនៃការសួរមតិយោបល់ដែលថា ការទទួលស្គាល់ការជ្រើសរើសឈ្មោះរបស់ប្ដីប្រពន្ធជាការសមរម្យ ទើបយើងសម្រេចថា ការប្រើនាមត្រកូលរួម ឬ នាមត្រកូលដោយឡែកក៏មិនមានបញ្ហាអ្វីដែរ ។

(មាត្រាពាក់ព័ន្ធ)

គម្រោងវិសោធនកម្មក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៦៦.-** ករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក

ប្ដីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក ។

(កំណត់)

អាពាហ៍ពិពាហ៍គឺជាសម្ព័ន្ធភាពផ្លូវចិត្ត រាងកាយ និង សេដ្ឋកិច្ច នៃប្តីប្រពន្ធ ដូច្នេះ មាត្រានេះប្រកាសថា ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយសហការ និង សង្គ្រោះគ្នាទៅវិញទៅមក ។ មាត្រា ២៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជាគាំទ្រថា ប្តីប្រពន្ធត្រូវមានភាពស្មើភាពគ្នាលើគ្រប់ទស្សនៈ ហើយមាត្រា ៣០ ចែងថា ប្តីប្រពន្ធមានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និង ជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយ មានសាមគ្គីភាព និង ប្រកបដោយសុភមង្គល ។ មាត្រានេះកំណត់យ៉ាងច្បាស់ថា ប្តីប្រពន្ធដែលជាបុគ្គលឯករាជ្យ និង ស្មើភាពគ្នា ត្រូវមានករណីយកិច្ចសហការគ្នា ដើម្បីថែរក្សាជីវភាពអាពាហ៍ពិពាហ៍រួម ហើយទន្ទឹមគ្នានេះ ដើម្បីឆ្លើយតបទៅនឹងករណីយកិច្ចនេះ គឺពួកគេមានសិទ្ធិស្មើៗគ្នា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ៧៥២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៩០ នៃក្រមរដ្ឋប្បវេណីទូទៅរបស់ប្រទេសអូទ្រីស

## មាត្រា ៩៦៧.- សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង សិទ្ធិចូលរួមក្នុងសកម្មភាពសង្គម

ប្តី ប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន ។

(កំណត់)

ដើម្បីសម្រេចឱ្យបានជាក់ស្តែងនូវភាពស្មើគ្នា មាត្រា ៣១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា ទទួលស្គាល់ឱ្យប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង សិទ្ធិចូលរួមប្រាស្រ័យដោយសេរីក្នុងសកម្មភាពនយោបាយ វប្បធម៌ និង សង្គម ។ មាត្រានេះក៏ទទួលយកបន្តនូវស្មារតីនោះ ដោយគោរពនូវសិទ្ធិបុគ្គលចំពោះសេរីភាពក្នុងការជ្រើសរើសការចូលរួមក្នុងវិជ្ជាជីវៈក្នុងនាមជាដៃគូជាមួយភាគីម្ខាងទៀត សិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ និង សង្គម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ៩១ នៃក្រមរដ្ឋប្បវេណីទូទៅរបស់ប្រទេសអូទ្រីស

## មាត្រា ៩៦៨.- ការចាត់ទុកជានីតិជន ដោយអាពាហ៍ពិពាហ៍

ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថា បាន

ដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ ក្នុងការអនុវត្តក្រមរដ្ឋប្បវេណីនេះ ។

(កំណត់)

មាត្រានេះចែងថា អនីតិជនត្រូវបានចាត់ទុកថាបានដល់នីតិភាព នៅពេលដែលបានរៀបអាពាហ៍ពិពាហ៍ ។ មាត្រា ១៦ ឡើងទៅ នៃផ្នែកទី ៤ នៃគន្ថីស្តីពីបុគ្គលនៃក្រមរដ្ឋប្បវេណីនេះ ចែងអំពីបញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងសមត្ថភាពក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ឯកជន ក៏ប៉ុន្តែ មាត្រានេះបញ្ជាក់ច្បាស់ថា អនីតិជនដែលចាត់ទុកថាជានីតិជន អាចមិនត្រឹមតែទទួលបានសមត្ថភាពក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ទាក់ទងនឹងទ្រព្យសម្បត្តិនោះទេ តែថែមទាំងអាចធ្វើសកម្មភាពឋានៈបុគ្គល ក៏ដូចជាសកម្មភាពក្នុងជីវភាពអាពាហ៍ពិពាហ៍ផ្សេងទៀត ដោយឯករាជ្យ ដោយមិនចាំបាច់មានអន្តរាគមន៍ពីឪពុកម្តាយ ជាដើម ឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៥៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៤៧៦ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ២ មាត្រា ១៤ នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសស្វីស

## ផ្នែកទី ៣ ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

### កថាភាគទី ១ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

**មាត្រា ៩៦៩.-** កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

១-ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន ។ ប៉ុន្តែ កិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ ។

២-បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាភាគទី ២ (ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់) ។

(កំណត់)

កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និង ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីទំនាក់ទំនងសិទ្ធិ និង ករណីយកិច្ចរបស់ប្តីប្រពន្ធ ។ ទំនាក់ទំនងជាក់ស្តែងរវាងប្តីប្រពន្ធមានលក្ខណៈច្រើនបែបច្រើនយ៉ាង ហើយបញ្ញត្តិនេះផ្តល់លទ្ធភាពឱ្យប្តីប្រពន្ធនូវជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាម

ភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់ ។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ក៏មានអានុភាពសម្របសម្រួលការពិភាក្សាអំពីអនាគតរបស់ប្តីប្រពន្ធផងដែរ ។ ក្រមរដ្ឋប្បវេណីជប៉ុនក៏មានបញ្ញត្តិអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចាប់ពីមាត្រា ៧៥៥ ដល់មាត្រា ៧៥៩ ផងដែរ ។

មានបញ្ហាថា តើគួរទទួលស្គាល់នូវសេរីភាពក្នុងការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រឹមកម្រិតណា ។ មានន័យថា ផ្តើមចេញពីការពិចារណាលើភាពខុសគ្នានៃសមត្ថភាពចរចា និង ទំនាក់ទំនងអំណាចរវាងប្តីប្រពន្ធ តើត្រូវធានាភាពយុត្តិធម៌ក្នុងខ្លឹមសារនៃកិច្ចសន្យាយ៉ាងដូចម្តេច ហើយថា តើត្រូវទទួលស្គាល់អានុភាពនៃកិច្ចសន្យានោះត្រឹមកម្រិតណា ចំពោះទំនាក់ទំនងនៃសុវត្ថិភាពនៃការជួញដូរ និង ទំនាក់ទំនងជាមួយតតិយជន ។ នៅប្រទេសជប៉ុន ជាគោលការណ៍ ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានដោយសេរី លុះត្រាតែកិច្ចសន្យានោះមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ឬ បញ្ញត្តិដែលត្រូវអនុវត្តដាច់ខាត ។ នៅប្រទេសបារាំង ខណៈដែលគូភាគីមានសិទ្ធិកំណត់ដោយសេរីនូវខ្លឹមសារនៃកិច្ចសន្យាស្តីពីប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ក៏ប៉ុន្តែ ដើម្បីភាពងាយស្រួលរបស់ភាគី ទម្រង់កិច្ចសន្យាគំរូដែលភាគីអាចជ្រើសរើសប្រើបានត្រូវបានកំណត់ឡើង ដូចជាទម្រង់កិច្ចសន្យាគំរូចំពោះប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ប្រព័ន្ធបញ្ចូលប្រាក់ចំណូលទៅក្នុងទ្រព្យសម្បត្តិរួម និង ប្រព័ន្ធកម្មសិទ្ធិរួមដែលកំណត់ដោយច្បាប់ដែលមានការកែប្រែខ្លះៗ ជាអាទិ៍ ។ ប្រទេសស្វីស អាល្លឺម៉ង់ និង អ៊ីតាលី ធ្វើការកម្រិតចំពោះទម្រង់កិច្ចសន្យាគំរូដែលអាចជ្រើសរើសបានក្នុងចំណោមប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ប្រព័ន្ធទ្រព្យសម្បត្តិរួម និង ប្រព័ន្ធដែលកែសម្រួលចំណុចខ្លះនៃប្រព័ន្ធទ្រព្យសម្បត្តិរួម ។

ចំពោះខ្លឹមសារវិញ ច្បាប់ប្រទេសបារាំង និង រដ្ឋល្វីស៊ីយ៉ានណា (Louisiana) របស់សហរដ្ឋអាមេរិក ចែងថា កិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ មិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយមិនត្រូវផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិ និង ករណីយកិច្ចដែលកើតចេញពីអាពាហ៍ពិពាហ៍ អំណាចមេបា អាណាព្យាបាល និង ការហាមឃាត់ការផ្លាស់ប្តូរលំដាប់នៃសន្តតិកម្មដែលកំណត់ដោយច្បាប់ឡើយ រីឯប្រទេសស្វីស ក៏ធ្វើការហាមឃាត់ការតាក់តែងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបំពានលើបញ្ញត្តិដែលពាក់ព័ន្ធនឹងការការពារម្ចាស់បំណុល និង ភាគបម្រុងដែរ ។ ប្រទេសជាច្រើនមិនទទួលស្គាល់កិច្ចសន្យាណាដែលលះបង់ ឬ កម្រិតសិទ្ធិជាមូលដ្ឋាន ដូចជាការថែរក្សាជីវភាពគ្រួសារ ភាពស្មើគ្នា និង ឯករាជ្យភាពរបស់ប្តីប្រពន្ធ ជាដើម ។ ដូច្នេះ មាត្រានេះក៏ទទួលស្គាល់សេរីភាពរបស់ប្តីប្រពន្ធ ក្នុងការធ្វើកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ប៉ុន្តែ ទន្ទឹមគ្នានេះ ដាក់កម្រិតមួយចំនួនលើសេរីភាពក្នុងការធ្វើកិច្ចសន្យា ដូចជាការលះបង់សិទ្ធិលើអាហារកាតព្វកិច្ច សិទ្ធិលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ និង ការលះបង់សិទ្ធិពាក់ព័ន្ធនឹងសន្តតិកម្មដូចជាភាគបម្រុងដែលកំណត់ដោយច្បាប់ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៨៧ ដល់មាត្រា ១៣៩៤ ជាអាទិ៍ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៨ ដល់មាត្រា ១៨១ នៃក្រមរដ្ឋប្បវេណីរបស់ប្រទេសស្វីស, មាត្រា ៧៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៧០.-** ភាពចាំបាច់នៃទម្រង់ជាលាយលក្ខណ៍អក្សរនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង លក្ខខណ្ឌតតាំង

១-កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

២-ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យា ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះបញ្ញត្តអំពីទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយតម្រូវឱ្យកិច្ចសន្យានេះធ្វើជាលាយលក្ខណ៍អក្សរ ដោយសារកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះនាំឱ្យមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងនៃសិទ្ធិ និង ករណីយកិច្ចលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ ។ កថាខណ្ឌទី ២ តម្រូវឱ្យចុះបញ្ជីកិច្ចសន្យានេះ ក្នុងករណីដែលធ្វើខុសពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ដើម្បីជៀសវាងនូវផលប៉ះពាល់អាក្រក់ចំពោះផលប្រយោជន៍របស់តតិយជន ។ កាលពីអតីតកាល ប្រទេសជាច្រើនអនុម័តយកគោលការណ៍មិនអនុញ្ញាតឱ្យកែប្រែកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បន្ទាប់ពីកិច្ចសន្យានេះត្រូវបានធ្វើរួចហើយនោះឡើយ ប៉ុន្តែ នាពេលបច្ចុប្បន្ននេះ ដោយសារវិសោធនកម្មនូវបទប្បញ្ញត្តិដែលពាក់ព័ន្ធទាំងនេះ ការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្រោយអាពាហ៍ពិពាហ៍ ឬ ការកែប្រែកិច្ចសន្យានៅក្រោយអាពាហ៍ពិពាហ៍ ត្រូវបានទទួលស្គាល់ ។ នៅក្នុងច្បាប់នៃប្រទេសដែលទទួលស្គាល់ការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ការកែប្រែកិច្ចសន្យានៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ក៏ត្រូវបានទទួលស្គាល់ដែរ ប៉ុន្តែ ដើម្បីការពារតតិយជន ប្រទេសកាណាដា និង អេស្ប៉ាញ ជាដើម ហាមឃាត់ការធ្វើកិច្ចសន្យា និង ការកែប្រែណាដែលប៉ះពាល់ដល់សិទ្ធិតតិយជន ។ ដោយឡែកនៅប្រទេសបារាំង ក៏ដូចជានៅប្រទេសបែលហ្ស៊ិកដែរ ដែលមិនទទួលស្គាល់ការធ្វើកិច្ចសន្យានៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ការកែប្រែកិច្ចសន្យានៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ត្រូវបានទទួលស្គាល់ដែរ ។ នៅប្រទេសបារាំង ប្តីប្រពន្ធត្រូវតែទទួលការអនុញ្ញាតពីតុលាការ ដើម្បីកែប្រែកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយតុលាការអនុញ្ញាតឱ្យធ្វើការកែប្រែបែបនេះ លុះត្រាតែការកែប្រែនេះមិនបំពានលើផលប្រយោជន៍គ្រួសារ និង មិនធ្វើឱ្យខូចប្រយោជន៍របស់តតិយជន ។ ការទាមទារការអនុញ្ញាតពីតុលាការ និង សាលក្រមអនុញ្ញាត ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងព្រឹត្តិប័ត្រដែលធ្វើការបោះពុម្ពផ្សាយការជូនដំណឹងជាសាធារណៈអំពីចំណុចគតិយុត្តផ្សេងៗ ហើយដើម្បីតតាំងនឹងតតិយជន ចាំបាច់ត្រូវធ្វើការចុះនៅលើរឹមទំព័រនៃសំបុត្រអាពាហ៍ពិពាហ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤៤៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៧៥៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ២ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

**មាត្រា ៩៧១.-** ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត ។

(កំណត់)

មាត្រានេះចែងអំពីបន្ទុកនៃសោហ៊ុយដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតម្រូវឱ្យប្តីប្រពន្ធចែករំលែកសោហ៊ុយទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈក្នុងសង្គម និង មុខរបរ ជាដើម របស់ប្តីប្រពន្ធ ។ សោហ៊ុយអាពាហ៍ពិពាហ៍ទាំងនោះ មិនសំដៅលើត្រឹមតែសោហ៊ុយចាំបាច់ដែលចំណាយលើការស្លៀកពាក់ ម្ហូបអាហារ និង ការស្នាក់នៅប៉ុណ្ណោះទេ តែរាប់បញ្ចូលទាំងសោហ៊ុយលើថ្លៃព្យាបាល ការសិក្សា និង ថែទាំកូនផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៣៦០ មាត្រា ១៣៦០a មាត្រា ១៣៦០b និង មាត្រា ១៣៦១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៧៦០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៩៧២.-** ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ :

ក-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ។

ខ-ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

គ-ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះ ។

(កំណត់)

មាត្រានេះកំណត់អំពីវិសាលភាពនៃទ្រព្យសម្បត្តិដោយឡែក ។ ទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និង ទ្រព្យដែលទទួលបានតាមរយៈការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀត នឹងត្រូវរាប់ជាទ្រព្យសម្បត្តិដោយឡែក ។ នៅពេលដែលជីវភាពអាពាហ៍ពិពាហ៍បន្តកាន់តែយូរទៅ មានករណីជាច្រើនដែលទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក្លាយទៅជាមិនអាចបែងចែកច្បាស់លាស់ថា តើជាទ្រព្យដោយឡែក (ទ្រព្យសម្បត្តិ

ផ្ទាល់ខ្លួនបុគ្គល) ឬ ជាទ្រព្យរួម ហើយក៏ក្លាយទៅជាវិវាទ ។ ដូច្នេះ វាជាការល្អក្នុងការធ្វើជាបញ្ជីទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ដើម្បីបញ្ជាក់ឱ្យច្បាស់ជាមុនថា តើទ្រព្យសម្បត្តិណាខ្លះជាទ្រព្យសម្បត្តិដោយឡែក ហើយទ្រព្យសម្បត្តិណាខ្លះជាទ្រព្យសម្បត្តិរួម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

## មាត្រា ៩៧៣.- ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុច ខ និង ចំណុច គ នៃមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ ។

(កំណត់)

នៅប្រទេសកម្ពុជា ប្រព័ន្ធទ្រព្យសម្បត្តិរួមត្រូវបានអនុម័តជាគោលការណ៍ ហើយមាត្រានេះបញ្ញត្តអំពីនិយមន័យនៃទ្រព្យសម្បត្តិរួម ។ ទ្រព្យសម្បត្តិរួម គឺទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដោយឡែក ។ មាត្រា ១៤០២ នៃក្រមរដ្ឋប្បវេណីបារាំងចែងថា ទ្រព្យទាំងអស់ដែលជាចលនវត្ថុ ឬ អចលនវត្ថុត្រូវចាត់ទុកជាទ្រព្យដែលទទួលបានក្រោយអាពាហ៍ពិពាហ៍ដែលត្រូវស្ថិតនៅក្នុងចំណោមទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ហើយសហព័ទ្ធដែលអះអាងថាជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ ។ មាត្រា ៨០៣ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ាចែងថា ទ្រព្យសម្បត្តិត្រូវសន្មតជាទ្រព្យសម្បត្តិរួម ឬ ទ្រព្យសម្បត្តិដោយឡែក អាស្រ័យលើឈ្មោះរបស់ម្ចាស់កម្មសិទ្ធិនៅពេលដែលធ្វើលទ្ធកម្មនូវទ្រព្យនោះ ហើយបុគ្គលដែលតវ៉ាត្រូវធ្វើការបញ្ជាក់ផ្ទុយពីនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ១៤០២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៧៦០ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ា

## មាត្រា ៩៧៤.- ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិ

១-ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម ។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន ។

២-សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព ។

៣-សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា ។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន ។

៤-បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធមិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ។

(កំណត់)

ដោយយោងតាមករណីប្រទេសបារាំង អេស្ប៉ាញ និង រដ្ឋចំនួន ៩ របស់សហរដ្ឋអាមេរិកដែលអនុម័តប្រព័ន្ធទ្រព្យសម្បត្តិរួម និង ស្របតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់កម្ពុជា មាត្រានេះចែងអំពីបញ្ញត្តិពិសេសទាក់ទងនឹងការគ្រប់គ្រង និង ប្រើប្រាស់នូវទ្រព្យសម្បត្តិរួម និង ទ្រព្យសម្បត្តិដោយឡែក ក្រៅពីបញ្ញត្តិអំពីកម្មសិទ្ធិអវិភាគ ក្នុងផ្នែកទី ៥ "កម្មសិទ្ធិអវិភាគ" ជំពូកទី ២ "កម្មសិទ្ធិ" គន្ថីទី ៣ "សិទ្ធិប្រត្យក្ស" ។ មានន័យថា កថាខណ្ឌទី ២ នៃមាត្រានេះបញ្ញត្តថា ប្តីប្រពន្ធមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម ក្នុងទំហំដែលចាំបាច់ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព (ចាំបាច់សម្រាប់ផ្គត់ផ្គង់គ្រួសារ) ។ ម្យ៉ាងទៀត កថាខណ្ឌទី ៣ អនុម័តយកគោលការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា ដោយតម្រូវឱ្យប្តីប្រពន្ធគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា និង ចែងថា សហព័ទ្ធម្ខាងមានសិទ្ធិទាមទារឱ្យភាគីម្ខាងទៀតធ្វើចំណាត់ការដែលចាំបាច់សម្រាប់ថែរក្សាទ្រព្យសម្បត្តិរួម ។ ជាឧទាហរណ៍ ក្នុងករណីដែលអចលនវត្ថុដែលជាទ្រព្យសម្បត្តិរួម ត្រូវបានចុះបញ្ជីក្រោមឈ្មោះសហព័ទ្ធម្ខាង សហព័ទ្ធម្ខាងទៀតអាចទាមទារសហព័ទ្ធនោះដែលត្រូវបានចុះបញ្ជីថាជាម្ចាស់កម្មសិទ្ធិ ឱ្យសហការចុះបញ្ជីអចលនវត្ថុនោះជាកម្មសិទ្ធិអវិភាគបាន ។ កថាខណ្ឌទី ៤ ចែងថា ប្រសិនបើប្តីប្រពន្ធ មិនអាចពិគ្រោះយោបល់គ្នាអំពីការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួម ភាគីម្ខាងណាមួយអាចទាមទារទៅតុលាការ ឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ដើម្បីដោះស្រាយវិវាទលើការគ្រប់គ្រងទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ ។

ជាព័ត៌មាន កថាខណ្ឌទី ១ មាត្រា ១៤២១ នៃក្រមរដ្ឋប្បវេណីបារាំង អនុម័តយកប្រព័ន្ធទ្រព្យសម្បត្តិរួមជាប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ក៏ប៉ុន្តែ ទោះបីជាទ្រព្យសម្បត្តិរួមក៏ដោយ ជាគោលការណ៍ ប្តីប្រពន្ធនីមួយៗមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមទាំងមូលដោយឯករាជ្យ ដោយមិនចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតទេ ។ ប៉ុន្តែចំពោះទីស្នាក់នៅសម្រាប់គ្រួសារ (គេហដ្ឋានគ្រួសារ) ក្រមរដ្ឋប្បវេណីបារាំងតម្រូវឱ្យមានការគ្រប់គ្រងរួមគ្នា ដោយផ្អែកលើការព្រមព្រៀងទៅវិញទៅមករបស់ប្តីប្រពន្ធ ដើម្បីការពារផលប្រយោជន៍រួមរបស់គ្រួសារ ។ ក្នុងករណីដែលសហព័ទ្ធណាម្ខាងបានធ្វើកិច្ចសន្យាខ្ចី ឬ ធានា ប្រសិនបើមិនមានការយល់ព្រមជាក់លាក់ពីសហព័ទ្ធម្ខាងទៀតទេ ទំហំនៃទ្រព្យសម្បត្តិទទួលខុសត្រូវ គឺកម្រិតត្រឹមតែទ្រព្យសម្បត្តិដោយឡែក និង ប្រាក់ចំណូលរបស់ប្តី ឬ ប្រពន្ធដែលបានធ្វើសកម្មភាព

នោះប៉ុណ្ណោះ ហើយការរឹបអូសរបស់ម្ចាស់បំណុលមិនអាចលាតសន្ធឹងរហូតដល់គេហដ្ឋានគ្រួសារបានទេ (មាត្រា ១៤១៥ នៃក្រមរដ្ឋប្បវេណីបារាំង) ប្រសិនបើគេហដ្ឋានគ្រួសារដែលជាទ្រព្យសម្បត្តិរួម ត្រូវបានចាត់ចែងដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ ការចាត់ចែងនោះត្រូវចាត់ទុកជាមោឃៈ ហើយភាគីដែលមិនបានផ្តល់ការយល់ព្រម អាចអះអាងអំពីមោឃភាពនោះបាន ក្នុងអំឡុងពេល ២ ឆ្នាំក្រោយពេលដែលបានដឹងអំពីសកម្មភាពនោះ (មាត្រា ១៤២៧) ។ លើសពីនេះទៀត ដោយមិនគិតអំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលប្តីប្រពន្ធបានជ្រើសរើស សហព័ទ្ធម្ខាងមិនអាចចាត់ចែងគេហដ្ឋានគ្រួសារ ឬ គ្រឿងសង្ហារិមតុបតែងភ្ជាប់ជាមួយគេហដ្ឋាននោះ (meubles meublants) បាន ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ (កថាខណ្ឌទី ៣ នៃមាត្រា ២១៥) ។ ការចាត់ចែងទាំងឡាយណាដែលមិនបានទទួលការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ ត្រូវចាត់ទុកជាមោឃៈ ហើយសហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាចអះអាងអំពីមោឃភាពនោះបាន ក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយពេលដែលបានដឹងអំពីសកម្មភាពចាត់ចែងនោះ ។ ម៉្យាងវិញទៀត មានបទប្បញ្ញត្តិដែលចែងថា ក្នុងករណីដែលការបដិសេធរបស់សហព័ទ្ធម្ខាងមិនមានភាពត្រឹមត្រូវចំពោះ "ផលប្រយោជន៍របស់គ្រួសារ" ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យផ្តល់ការអនុញ្ញាត ជំនួសការយល់ព្រមរបស់សហព័ទ្ធនោះបាន (កថាខណ្ឌទី ១ នៃមាត្រា ២១៧) ។ លើសពីនេះទៀត សិទ្ធិជួលដើម្បីអាស្រ័យនៅរបស់ប្តីប្រពន្ធ គឺជាសិទ្ធិរួមរបស់សហព័ទ្ធទាំងសងខាង (មាត្រា ១៧៥១) ហើយក្នុងករណីដែលសហព័ទ្ធម្ខាងបានចាត់ចែងសិទ្ធិជួលនោះដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ក៏សហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការធ្វើឱ្យមោឃៈការចាត់ចែងនោះបាន ក្នុងអំឡុពេល ៥ ឆ្នាំ ដែរ (មាត្រា ១៣០៤) ។ ដូចបានរៀបរាប់ខាងលើ នៅប្រទេសបារាំង ក៏តម្រូវឱ្យមានការគ្រប់គ្រងរួមគ្នា និង កម្រិតចំពោះការចាត់ចែងដែលគ្មានការយល់ព្រមពីភាគីម្ខាងទៀត ចំពោះអចលនវត្ថុសម្រាប់អាស្រ័យនៅ ដោយធានាការអាស្រ័យនៅរបស់គ្រួសារ ។ ប៉ុន្តែ ចំពោះទ្រព្យសម្បត្តិដទៃទៀតក្រៅពីនេះ ការការពារម្ចាស់បំណុល ឬ តតិយជន ត្រូវបានធានា ដោយផ្អែកលើការពិនិត្យមើលលើភាពមាន ឬ គ្មាននូវការជូនដំណឹងជាសាធារណៈ ដើម្បីធានាតុល្យភាពនៃភាគីទាំងសងខាង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣២ និង មាត្រា ៣៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

## មាត្រា ៩៧៥.- ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ :

ក- សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និង សោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាល ថែទាំកូន ជាអាទិ៍ ។

ខ- កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តីប្រពន្ធទាំងសងខាងបាន

ព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និង ករណីយកិច្ច ផ្សេងៗទៀត ដែលប្តីប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរ ពីប្រពន្ធ ឬ ប្តីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។[៣]

គ- សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលថា ទោះបីជាកម្ពុជាអនុម័តយកប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធក៏ដោយ ក៏ពុំមានភាពសមរម្យក្នុងការដាក់បន្ទុកឱ្យប្តីប្រពន្ធនីមួយៗនូវកាតព្វកិច្ចដ៏ធ្ងន់ធ្ងរដែរ ហើយមានភាពសមរម្យឱ្យទទួលខុសត្រូវចំពោះកាតព្វកិច្ចរួមគ្នាក្នុងទំហំសមរម្យមួយ ដែលទោះបីជាមើលពីខាងតតិយជនទៅ ក៏ឃើញថា សមរម្យដែរ ។ ចំណុច ខ នៃមាត្រានេះទាមទារជាពិសេសឱ្យមានល័ក្ខខ័ណ្ឌចាំបាច់នៃលិខិតជាលាយល័ក្ខណ៍អក្សរ និង ការព្រមព្រៀងរវាងប្តីប្រពន្ធទាំងសងខាង ដើម្បីជៀសវាងការដាក់បន្ទុកធ្ងន់ធ្ងរទៅដល់ភាគីម្ខាងៗ ។

ប៉ុន្តែ ក្នុងករណីដែលអនុវត្តនូវប្រព័ន្ធទ្រព្យសម្បត្តិរួម ទោះបីជាសហព័ទ្ធម្ខាង ឬ ទាំងសងខាងទទួលបន្ទុកនូវកាតព្វកិច្ចក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ជាគោលការណ៍ បន្ទុកនៃកាតព្វកិច្ចត្រូវជារបស់ទ្រព្យសម្បត្តិរួមដែរ ហើយកាតព្វកិច្ចនោះនឹងក្លាយទៅជាកាតព្វកិច្ចរួមរបស់សហព័ទ្ធទាំងពីរ (មាត្រា ៩១១ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ា) ។ ហេតុដូច្នេះ សិទ្ធិចំពោះទ្រព្យសម្បត្តិរួម (សិទ្ធិលើចំណែកនៃវត្ថុ ឬ សិទ្ធិអវិភាគ) របស់សហព័ទ្ធម្ខាងទៀត មិនត្រូវបានការពារទេ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលសុចរិត ហើយ គ្មានកំហុស លើកលែងតែករណីដែលបានធ្វើការចាត់វិធានការរក្សាការពារចំពោះទ្រព្យសកម្ម ឬ ការកែតម្រូវការចុះបញ្ជីអំពីកម្មសិទ្ធិករ ជាអាទិ៍ ។ ក៏ប៉ុន្តែ ការទទួលខុសត្រូវចំពោះកាតព្វកិច្ចដែលជាទ្រព្យអកម្ម ក៏ត្រូវបានកម្រិតដែរ ហេតុដូច្នេះ មានភាពស៊ីសង្វាក់គ្នា ។ ប្រសិនបើអនុម័តយកប្រព័ន្ធទ្រព្យសម្បត្តិរួមសុទ្ធសាធតែម្តង កាតព្វកិច្ចទាំងឡាយក៏នឹងក្លាយជាកាតព្វកិច្ចរួម និង ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពដែរ ។ ប្រសិនបើទ្រព្យសកម្មទាំងអស់ត្រូវបានចាត់ទុកថាជាទ្រព្យរួម ទោះបីជាចុះបញ្ជីក្នុងនាមរបស់សហព័ទ្ធទាំងពីរ ឬ ម្ខាងក៏ដោយ ចំណែកឯទ្រព្យអកម្មត្រូវបានចាត់ទុកដោយឡែក នោះគ្មានភាពសមហេតុសមផលឡើយ ។

ក្រមរដ្ឋប្បវេណីបារាំង ក៏ចែងដែរថា ម្ចាស់បំណុល ជាគោលការណ៍ គ្មានសិទ្ធិប្រមូលបំណុលពីទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធរបស់កូនបំណុលទេ ក៏ប៉ុន្តែ ទោះបីជាសហព័ទ្ធតែម្ខាងទទួលនូវកាតព្វកិច្ចក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ប្រសិនបើកាតព្វកិច្ចនោះពាក់ព័ន្ធនឹងផលប្រយោជន៍គ្រួសារ កាតព្វកិច្ចនោះជាបន្ទុករបស់ទ្រព្យសម្បត្តិរួម ហើយប្រសិនបើកាតព្វកិច្ចនោះជាផលប្រយោជន៍ឯកជនរបស់សហព័ទ្ធតែម្ខាងទេ សហព័ទ្ធនោះត្រូវទទួលបន្ទុកតែម្នាក់ឯង ។

[៣] ចំណុច ខ នៃមាត្រា ៩៧៥ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ១៤១៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៩៧៦.-** ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

១-បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតបានឡើយ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើក៏ដោយ បើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និង ដើម្បីរក្សាជីវភាពរស់នៅ នោះប្តីប្រពន្ធណាម្ខាង អាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-ក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាង បានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ និង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាទ្រព្យសម្បត្តិផ្សេង ។[៤]

(កំណត់)

ដូចមាត្រា ៣៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារដែរ កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីភាពមិនអាចចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ។ មាត្រានេះបញ្ជាក់ច្បាស់ថា គ្មានទ្រព្យរួមណាមួយអាចត្រូវផ្លាស់ប្តូរ ឬ ចាត់ចែងដោយគ្មានការយល់ព្រមពីសហព័ទ្ធទាំងសងខាងបានទេ ហើយថា គ្មានសហព័ទ្ធម្ខាងណាអាចចាត់ចែងចំណែកនៃទ្រព្យរួមរបស់សហព័ទ្ធនោះ ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតនោះបានទេ ។ កថាខណ្ឌទី ១ ដាក់បញ្ចូលនូវចំណុចទាំងពីរនេះ ។ ការនាំឆ្ពោះទៅដល់ការចាត់ចែងបែបនេះជារឿងធម្មតា ដោយសារតែរបបទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ

---

[៤] កថាខណ្ឌទី ៣ នៃមាត្រា ៩៧៦ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ត្រូវបានធ្វើឱ្យទៅជាប្រព័ន្ធទ្រព្យសម្បត្តិរួមជាគោលការណ៍ ហើយទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ មានលក្ខណៈខុសគ្នាពីកម្មសិទ្ធិអវិភាគធម្មតាដែលបានចែងក្នុងគន្ថីទី ៣ ស្តីពី "សិទ្ធិប្រត្យក្ស" ។

កថាខណ្ឌទី ២ ចែងថា ខណៈដែលកថាខណ្ឌទី ១ ត្រូវរាប់ទុកជាគោលការណ៍ ក៏ប៉ុន្តែ ប្រសិនបើមានមូលហេតុដែលមិនអាចជៀសវាងបាន ប្តី ឬ ប្រពន្ធអាចចាត់ចែងដោយឯកតោភាគី នូវទ្រព្យសម្បត្តិរួម ដោយទទួលការអនុញ្ញាតពីតុលាការ ។

កថាខណ្ឌទី ៣ ផ្តល់នូវការសង្គ្រោះ ដោយបញ្ញត្តិថា សហព័ទ្ធដែលមិនផ្តល់ការយល់ព្រម អាចទាមទារទៅតុលាការឱ្យលុបចោលការចាត់ចែងនោះ ។ ជាពិសេស ចំពោះអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ ក្នុងចំណោមទ្រព្យសម្បត្តិរួម មាត្រានេះកំណត់អំឡុងពេលវែង ដើម្បីឱ្យមានភាពប្រាកដប្រជាចំពោះការការពារការអាស្រ័យនៅ ។ ភាគីម្ខាងទៀតនៃការជួញដូរ ចាំបាច់ត្រូវធ្វើការស្រាវជ្រាវបញ្ជាក់ថា មានសហព័ទ្ធដែលមិនមានឈ្មោះក្នុងបញ្ជីកម្មសិទ្ធិ ។ មាត្រា ១៣៦៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ការពារលំនៅឋានគ្រួសារ និង គ្រឿងសង្ហារិម និង អីវ៉ាន់ក្នុងផ្ទះ ដោយកម្រិតការចាត់ចែងទ្រព្យសម្បត្តិទាំងមូលរបស់សហព័ទ្ធ ។ រីឯមាត្រា ១១០០ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ា ចែងថា សហព័ទ្ធនីមួយៗ មានសិទ្ធិគ្រប់គ្រង (សិទ្ធិចាត់ចែង) ដោយឯករាជ្យនូវចលនវត្ថុដែលជាទ្រព្យរួម (community personal property) ប៉ុន្តែ មិនអាចលក់ ធ្វើអនុប្បទាន ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវគ្រឿងសង្ហារិម ឬ របស់របរក្នុងផ្ទះ ដោយគ្មានការយល់ព្រមជាលាយល័ក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀតទេ ។ ក៏ប៉ុន្តែ ចំពោះអចលនវត្ថុដែលជាទ្រព្យរួម (community real property) សហព័ទ្ធអាចទាមទារទៅតុលាការឱ្យចេញដីការសម្រេចឱ្យបន្ថែមឈ្មោះសហព័ទ្ធដែលមិនមានឈ្មោះក្នុងបញ្ជីកម្មសិទ្ធិ ទៅក្នុងបញ្ជី ឬ លិខិតបញ្ជាក់សិទ្ធិ (មាត្រា ១១០១ នៃក្រមដដែលនេះ) ហើយអ្នកទិញ អ្នកជួលរយៈពេលវែង ឬ អ្នកមានសិទ្ធិប្រាតិភោគដែលបានស្រាវជ្រាវអំពីឈ្មោះម្ចាស់សិទ្ធិក្នុងបញ្ជី ឬ ទំនាក់ទំនងអាស្រ័យនៅ ជាដើម ដោយមិនបានដឹងអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍ទេ អាចធ្វើលទ្ធកម្មនូវសិទ្ធិទាំងនោះបានដោយមានសុពលភាព ។ ជាសរុបមក ពុំមានមធ្យោបាយណាដើម្បីសង្គ្រោះសហព័ទ្ធដែលបាត់បង់ទ្រព្យរួមដែលមិនត្រូវបានជូនដំណឹងជាសាធារណៈជាទ្រព្យរួម ដោយការចុះបញ្ជី ឬ អង្គហេតុអាស្រ័យនៅ លើកលែងតែករណីដែលតតិយជនដែលធ្វើលទ្ធកម្មដោយទុច្ចរិត និង មានកំហុស ឬ ដោយមិនគិតថ្លៃ ហើយបញ្ហានេះត្រូវដោះស្រាយរវាងសហព័ទ្ធ ។

ម្យ៉ាងវិញទៀត កថាខណ្ឌទី ១ នៃមាត្រា ២២១ នៃក្រមរដ្ឋប្បវេណីបារាំង បញ្ញត្តថា ក្នុងករណីដែលសហព័ទ្ធម្ខាងបានគ្រប់គ្រង អាស្រ័យផល ឬ ចាត់ចែងដោយឯករាជ្យ នូវចលនវត្ថុដែលខ្លួនកាន់កាប់ដោយឯកឯង សហព័ទ្ធនោះនឹងត្រូវចាត់ទុកថា មានសិទ្ធិគ្រប់គ្រង និង ចាត់ចែងដោយឯករាជ្យនោះ ចំពោះតតិយជនដែលមិនបានដឹងអំពីហេតុពិតដោយសុចរិត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ១៤២២ មាត្រា ១៤២៤ មាត្រា ១៤២៥ និង មាត្រា ១៤២៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៩៧៧.-** ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

១-ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន ។

២-ក្នុងករណីដែលប្តីប្រពន្ធម្ខាងអាស្រ័យនៅអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះ ទទួលស្គាល់នូវសិទ្ធិអាស្រ័យនៅលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាង ដោយសហព័ទ្ធម្ខាងទៀត ក្នុងករណីដែលទ្រព្យសម្បត្តិដោយឡែកនោះត្រូវបានប្រើប្រាស់ជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់ប្តីប្រពន្ធ ។ ដើម្បីកុំឱ្យមានការភាន់ច្រឡំជាមួយនឹងសិទ្ធិអាស្រ័យនៅរបស់គ្រួសារដែលបានចែងក្នុងគន្ថីស្តីពី "សិទ្ធិប្រត្យក្ស" មាត្រានេះត្រូវបានរៀបចំឡើងជាបញ្ញត្តិពិសេសនៅក្នុងបញ្ញត្តិស្តីពីរបបទ្រព្យសម្បត្តិប្តីប្រពន្ធ ។ ដូចគ្នាដែរ នៅចក្រភពអង់គ្លេស មាត្រា ១ នៃច្បាប់ស្តីពីលំនៅឋានប្តីប្រពន្ធ ឆ្នាំ ១៩៦៧ (Matrimonial Homes Act) ទទួលស្គាល់នូវសិទ្ធិដែលសហព័ទ្ធម្ខាងអាចអាស្រ័យនៅលើទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងទៀតបាន (the right of occupation) ហើយមាត្រា ២ កំណត់ថា សិទ្ធិអាស្រ័យនៅត្រង់នេះគឺជាសិទ្ធិអាទិភាពដែលអាចអះអាងអំពីការបន្តការអាស្រ័យនៅចំពោះតតិយជនបាន ។ មាត្រានេះក៏បញ្ជាក់ផងដែរថា ប្តី ឬ ប្រពន្ធមានសិទ្ធិពិសេសលើទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ដើម្បីធានាការអាស្រ័យនៅ ។

ជាព័ត៌មាន កថាខណ្ឌទី ៣ នៃមាត្រា ២១៥ នៃក្រមរដ្ឋប្បវេណីបារាំង ចែងថា ការចាត់ចែងនូវលំនៅឋានគ្រួសារ និងសម្ភារៈផ្សេងៗទៀតនៅក្នុងផ្ទះ ចាំបាច់ត្រូវមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ហើយប្រសិនបើគ្មានការយល់ព្រមទេ ការចាត់ចែងនោះត្រូវចាត់ទុកជាមោឃៈ ។ តាមមាត្រា ១៣៦៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ រាល់ការចាត់ចែងរបស់របរសម្រាប់ប្រើក្នុងផ្ទះទាំងឡាយ ចាំបាច់ត្រូវមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ។ តាមមាត្រា ៧៥៣ និង មាត្រា ៧៥៤ នៃក្រមគ្រួសាររបស់រដ្ឋកាលីហ្វ័រញ៉ា សហព័ទ្ធនីមួយៗមិនអាចទាមទារឱ្យសហព័ទ្ធម្ខាងទៀតចាកចេញពីលំនៅឋានរបស់ខ្លួនបានទេ ហើយមិនអាចចាត់ចែងអចលនវត្ថុទាំងឡាយដែលកំពុងជាប់ក្នុងបណ្តឹងសុំលែងលះ ឬ បណ្តឹងសុំបែកលំនៅសង្វាស ជាដើម បានទេ លើកលែងតែមានការអនុញ្ញាតពីតុលាការ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៤២៨ និង កថាខណ្ឌទី៣ នៃមាត្រា ២១៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១ និង មាត្រា ២ នៃច្បាប់ស្តីពីលំនៅឋានប្តីប្រពន្ធរបស់ចក្រភពអង់គ្លេស, មាត្រា ១៣៦៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## ផ្នែកទី ៤ ការលែងលះគ្នា

## កថាភាគទី ១ មូលហេតុនៃការលែងលះគ្នា

**មាត្រា ៩៧៨**.- មូលហេតុនៃការលែងលះគ្នា

១-ប្ដី ឬ ប្រពន្ធ អាចដាក់ពាក្យបណ្ដឹងលែងលះគ្នាបាន តែក្នុងករណីដែលកំណត់ខាងក្រោមនេះ :

ក-បើបានប្រព្រឹត្តអំពើផិតក្បត់ ទៅលើសហព័ទ្ធ ។

ខ-បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ។

គ-បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ។

ឃ-បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។

ង-ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ។

២-ទោះបីជាក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្ដាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូន ក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន ។

៣-ក្នុងករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងចំណុច ឃ ឬ ចំណុច ង នៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុចិរត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និង ជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះ ដោយឆន្ទានុសិទ្ធិបាន ។

(កំណត់)

ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជាចែងថា ប្ដី ឬ ប្រពន្ធអាចប្ដឹងសុំលែងលះបាន ប្រសិនបើមានមូលហេតុដែលធ្វើឱ្យពិបាកនឹងបន្តរស់នៅជាមួយគ្នាជាប្ដីប្រពន្ធតទៅទៀត ហើយមូលហេតុសម្រាប់ការលែងលះមានដូចជា ការចុះចោលលំនៅសង្វាស ការវាយដំឃោរឃៅ ការជេរប្រមាថ អពលានុភាពនៃលិង្គ ការរស់នៅបែកគ្នារយៈពេលជាង ១ ឆ្នាំ ជាដើម ។ មាត្រានេះតាក់តែងឡើងដោយយោងទៅលើគម្រោងវិសោធនកម្មមាត្រា ៧៧០ នៃក្រម

រដ្ឋប្បវេណីជប៉ុន ហើយចំពោះចំណុច ក ដល់  ចំណុច ង នៃកថាខណ្ឌទី ១ មាត្រានេះបញ្ជាក់ច្បាស់ និង ថ្លឹងថ្លែងយ៉ាងល្អិតល្អន់ នូវមូលហេតុនៃការលែងលះដែលមានគោលការណ៍បែកបាក់ ។ ព្រមជាមួយគ្នានេះ ដើម្បីទប់ស្កាត់ការលែងលះតាមទំនើងចិត្តដែលជាផលប៉ះពាល់ធ្ងន់ធ្ងរនៃគោលការណ៍បែកបាក់  កថាខណ្ឌទី  ២  ចែងអំពីបញ្ញត្តិកុំឱ្យមានភាពលំបាកយ៉ាងខ្លាំង និង កថាខណ្ឌទី ៣ ចែងអំពីគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, គម្រោងវិសោធនកម្មនៃមាត្រា ១៧៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

## មាត្រា ៩៧៩.- ការលែងលះដោយការព្រមព្រៀង

ភាគីនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងលែងលះ ទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា ។ ប៉ុន្តែ តុលាការអាចឱ្យលែងលះគ្នាបាន ក្រោយពីបានយល់ឃើញថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ។

(កំណត់)

មាត្រា ៤០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជាអនុញ្ញាតឱ្យមានការលែងលះដោយការព្រមព្រៀង ដោយបញ្ញត្តថា ប្តីប្រពន្ធអាចលែងលះគ្នាដោយស្ម័គ្រចិត្តបាន ។ នៅប្រទេសកម្ពុជា ដោយសារការលែងលះដែលជាការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍តាមច្បាប់ គឺជាការផ្លាស់ប្តូរយ៉ាងខ្លាំងសម្បើមនូវទំនាក់ទំនងឋានៈបុគ្គល ការលែងលះចាំបាច់ត្រូវតែផ្អែកលើសេចក្តីសម្រេចរបស់តុលាការ ។ ការលែងលះដោយការដាក់លិខិតជូនដំណឹងទៅសាលាសង្កាត់ ឬ សាលាក្រុង ដូចនៅប្រទេសជប៉ុន (ការលែងលះតាមការពិភាក្សា) មិនត្រូវបានទទួលស្គាល់ទេ ។ វាក្យខណ្ឌទី ២ នៃមាត្រានេះបញ្ញត្តឱ្យតុលាការធ្វើការបញ្ជាក់អំពីឆន្ទៈរបស់ភាគី ដើម្បីជៀសវាងការលែងលះដោយការព្រមព្រៀងដែលផ្សារភ្ជាប់ជាមួយនឹង "ការលែងលះបណ្តេញចេញ" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

## មាត្រា ៩៨០.- ការបែងចែកទ្រព្យសម្បត្តិ

១-ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

២-ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យ

សម្បត្តិ ដោយផ្អែកតាមចំណុចនីមួយៗ ដូចកំណត់ខាងក្រោមនេះ ៖

ក-សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ។

ខ-បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម ។ ប៉ុន្តែ បើមានករណីពិសេស និង មានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍ ។

៣-គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីការបែងចែក និង ការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធក្នុងករណីលែងលះ ។ ទ្រព្យសម្បត្តិប្តីប្រពន្ធ អាចបែងចែកជាបីប្រភេទ គឺទ្រព្យសម្បត្តិរួម ទ្រព្យសម្បត្តិដោយឡែករបស់ប្តី (ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្តី) និង ទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ (ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្រពន្ធ) ។ ប្រសិនបើមានការព្រមព្រៀងគ្នាលើការបែងចែកជាក់លាក់បែបណាមួយក្រោយពីពួកគេបានបញ្ជាក់អំពីទំហំ ប្រភេទ និង តម្លៃនៃទ្រព្យសម្បត្តិរួម និងទ្រព្យដោយឡែក តាមរយៈការពិភាក្សារវាងប្តីប្រពន្ធ ការព្រមព្រៀងនោះត្រូវតែទទួលការគោរព ។ មាត្រានេះបញ្ញត្តថាក្នុងករណីដែលប្តីប្រពន្ធមិនអាចពិភាក្សាគ្នាបានទេ សហព័ទ្ធនីមួយៗត្រូវទទួលនូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ហើយជាគោលការណ៍ ត្រូវទទួលបាននូវទ្រព្យរួមចំនួនពាក់កណ្តាល ។ វាក្យខណ្ឌទី ២ ចំនុច ខ នៃកថាខណ្ឌទី ២ បើកលទ្ធភាពឱ្យបែងចែកទ្រព្យរួមដោយបត់បែនបាន ឧទាហរណ៍ដូចជាករណីដែលសហព័ទ្ធម្ខាងទទួលបានចំណែក ១/៣ ប្រសិនបើប្តីប្រពន្ធនោះទើបរៀបអាពាហ៍ពិពាហ៍រយៈពេលខ្លី ឬ ប្រសិនបើសហព័ទ្ធនោះមិនបានរួមបរិច្ចាកច្រើនចំពោះជីវភាពអាពាហ៍ពិពាហ៍ និង ករណីដែលសហព័ទ្ធម្ខាងទទួលបាន ២/៣ ឬ ៣/៤ ប្រសិនបើសហព័ទ្ធនោះចាស់ ឬ មានវិបត្តិលើរាងកាយ ឬ ស្មារតី ជាដើម ។ ជាពិសេស វាត្រូវបានរំពឹងទុកថា ត្រូវផ្តល់នូវចំណែកមួយចំនួនធំឱ្យដល់ប្រពន្ធ ដើម្បីរក្សាការពារនូវផលប្រយោជន៍នៃការអាស្រ័យនៅរបស់កូន ឬ ប្រពន្ធដែលមិនមានលទ្ធភាពចិញ្ចឹមជីវិតដោយខ្លួនឯង ។ របៀបបែងចែកជាក់លាក់ អាចអនុលោមតាមបញ្ញត្តិស្តីពីកម្មសិទ្ធិអវិភាគក្នុងគន្ថីទី ៣ ស្តីពី "សិទ្ធិប្រត្យក្ស" ដែលមាន

ដូចជាការបែងចែកវត្ថុជាក់ស្តែង ការបែងចែកតាមតម្លៃ ការបែងចែកតាមការសងជំនួស និង ការបែងចែកដោយផ្អែកលើការបង្កើតផលុបភោគ ជាអាទិ៍ ។ មានលទ្ធភាពក្នុងការអនុវត្តវាក្យខណ្ឌទី ២ នេះ ដើម្បីធានានូវស្ថិរភាពនៃជីវភាព និង ភាពចាំបាច់នៃការអាស្រ័យនៅរបស់កូន និង សហព័ទ្ធនីមួយៗ ។

ជាព័តិមាន នៅប្រទេសបារាំង ចំពោះទំនាក់ទំនងនៃការជម្រះបញ្ជី និង ការបែងចែកទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ត្រូវបានធ្វើតាមនីតិវិធីដូចតទៅនេះ ។ ជាបឋម សហព័ទ្ធនីមួយៗ ដកយកមកវិញនូវទ្រព្យដោយឡែករបស់ខ្លួនដែលត្រូវបានលាយឡំជាមួយទ្រព្យសម្បត្តិរួម (ការយកមកវិញនូវទ្រព្យដោយឡែក) ។ បន្ទាប់មក គេធ្វើការគណនាសងរវាងទ្រព្យសម្បត្តិរួម និង ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធនីមួយៗ (recompense) ដែលពាក់ព័ន្ធនឹងការប្រែប្រួលរវាងតម្លៃនៃទ្រព្យសម្បត្តិរួម និង ទ្រព្យសម្បត្តិដោយឡែក ក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍ (ឧទាហរណ៍ដូចជាករណីដែលប្រាក់បានមកពីថ្លៃលក់ទ្រព្យដោយឡែក ចូលទៅក្នុងទ្រព្យសម្បត្តិរួម និង ករណីនៃការប្រើប្រាស់ប្រាក់ដែលជាទ្រព្យសម្បត្តិរួម សម្រាប់ធ្វើការរក្សា កែលម្អទ្រព្យសម្បត្តិដោយឡែក ជាដើម) ។ ភាគីក៏អាចអនុវត្តនីតិវិធីនេះដោយខ្លួនឯងបានដែរ ក៏ប៉ុន្តែ មានករណីជាច្រើនដែលសារការីជាអ្នកអនុវត្តនីតិវិធីនេះ ។ ក្នុងករណីដែលសារការីធ្វើនីតិធីនេះ សារការីនឹងរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ និង ធ្វើរបាយការណ៍ស្តីពីការជម្រះបញ្ជី ។ ប្រសិនបើមានវិវាទចំពោះការជម្រះបញ្ជី ឬ ការបែងចែកនោះ សារការីត្រូវធ្វើកំណត់ហេតុស្តីពីចំណុចវិវាទ និង សេចក្តីថ្លែងការណ៍របស់ភាគីជាលាយល័ក្ខណ៍អក្សរ និង ត្រូវផ្ទេរកំណត់ហេតុនោះទៅឱ្យចៅក្រម (មាត្រា ៨៣៧ នៃក្រមរដ្ឋប្បវេណីបារាំង) ។ ក្នុងករណីនេះ សាលាដំបូង (tribunal de grande instance) ត្រូវសម្រេចសេក្តីចំពោះការជម្រះបញ្ជី ឬ ការបែងចែកនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា, មាត្រា ៧៦៨ នៃក្រមរដ្ឋប្បវេណីជប៉ុន (គម្រោងវិសោធនកម្ម), ចាប់ពីមាត្រា ១៤៦៧ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៩៨១.- ការលែងលះគ្នា និង នាមត្រកូល

ប្តី ឬ ប្រពន្ធ ដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬ អាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន ។

(កំណត់)

នៅប្រទេសកម្ពុជា ចរិតលក្ខណៈតាមច្បាប់នៃនាមត្រកូល មានភាពស្មុគស្មាញ ក៏ប៉ុន្តែ នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ សហព័ទ្ធអាចជ្រើសរើសប្រើនាមត្រកូលរបស់ប្តី ឬ នាមត្រកូលមុនអាពាហ៍ពិពាហ៍ ក៏មិនជាបញ្ហាអ្វីដែរ ដោយបញ្ញត្តិនៃក្រមនេះទទួលស្គាល់នូវសេរីភាពក្នុងការជ្រើសរើសរបស់សហព័ទ្ធ ។ នៅពេលលែងលះក៏ដូចគ្នាដែរ បញ្ញត្តិនេះផ្តល់នូវជម្រើសដោយអនុញ្ញាតឱ្យសហព័ទ្ធអាចត្រឡប់មកប្រើនាមត្រកូលមុនអាពាហ៍ពិពាហ៍ ឬ បន្តប្រើនាមត្រកូល

ដែលខ្លួនប្រើនៅពេលមានចំណងអាពាហ៍ពិពាហ៍ក៏បាន ។

## កថាភាគទី ២ នីតិវិធីនៃការលែងលះគ្នា

**មាត្រា ៩៨២.-** បណ្ដឹងនៃការលែងលះគ្នា

១-ពាក្យបណ្ដឹងលែងលះគ្នា អាចដាក់ទៅតុលាការដែលមានសមត្ថកិច្ច ដោយយោងតាមបញ្ញត្តិមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្ដីពិសេសលើរឿងក្ដីលែងលះគ្នា និង រឿងក្ដីអំពីបុគ្គភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ។

២-ភាគីអាចដាក់ពាក្យសុំលែងលះគ្នា ទៅក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋាន ឬ ទីសំណាក់ ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្ដីពិសេសលើរឿងក្ដីលែងលះគ្នា និង រឿងក្ដីអំពីបុគ្គភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន ។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំសង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្ដឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបញ្ជូនពាក្យបណ្ដឹងនោះ ទៅតុលាការជាបន្ទាន់ ។

(កំណត់)

ដោយអនុលោមតាមមាត្រា ៤១ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា កថាខណ្ឌទី ១ នៃមាត្រានេះ បញ្ញត្តអំពីសមត្ថកិច្ចសាលាជម្រះក្ដីរបស់តុលាការចំពោះរឿងក្ដីលែងលះ ដោយផ្អែកលើមាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ កថាខណ្ឌទី ២ នៃមាត្រានេះក៏ដូចគ្នាផងដែរ ដោយយកមាត្រា ៤២ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជាជាមូលដ្ឋាន កថាខណ្ឌទី ២ ចែងអំពីការបែងចែកតួនាទីរបស់តុលាការដែលមានសមត្ថកិច្ច និង ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងនីតិវិធីលែងលះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤១ និង មាត្រា ៤២ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

**មាត្រា ៩៨៣.-** ការចាត់ចែងរក្សាការពារ

តុលាការដែលទទួលពាក្យបណ្ដឹងលែងលះគ្នា ក្នុងករណីចាំបាច់ អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ ចំពោះការបំបែកលំនៅ ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោហ៊ុយ

អាពាហ៍ពិពាហ៍ និង សោហ៊ុយចិញ្ចឹមបីបាច់កូន ជាអាទិ៍ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

(កំណត់)

តាមមាត្រា ៤៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា តុលាការដែលមានសមត្ថកិច្ចលើរឿងក្តីលែងលះអាចបង្គាប់ឱ្យមានការចាត់ចែងរក្សាការពារ (វិធានការបណ្តោះអាសន្ន) ដែលចាំបាច់ ចំពោះការបីបាច់ថែរក្សាកូន ការសួរសុខទុក្ខកូន ថែរក្សា និង ការគ្រប់គ្រងទ្រព្យសម្បត្តិ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ និងការផ្តល់អាហារកិច្ចដល់កូន ជាដើម បាន នៅក្នុងអំឡុងពេលមុនសាលក្រមអង្គសេចក្តីចូលជាស្ថាពរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២៤០ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា, មាត្រា ៤៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

**មាត្រា ៩៨៤.-** ការសាកល្បងផ្សះផ្សា ដោយតុលាការ

១-ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ។

២-បើការផ្សះផ្សាពុំអាចសម្រេចបានទេ តុលាការត្រូវយកបណ្តឹងលែងលះគ្នា មកធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម ។

(កំណត់)

ដោយអនុលោមតាមមាត្រា ៤៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ទោះជាប្តីប្រពន្ធណាម្ខាងទាមទារលែងលះគ្នាខ្លាំងក្លាយ៉ាងណាក៏ដោយ តុលាការអាចណែនាំឱ្យធ្វើការផ្សះផ្សារបានដោយឆន្ទានុសិទ្ធិ ។ ជាពិសេស តុលាការធ្វើការលើកទឹកចិត្តឱ្យមានការសះជានឹងគ្នា នៅពេលដែលប្តីប្រពន្ធមានកូនជាអនីតិជន ឬ ក្នុងករណីដែលមានស្ថានភាពដែលសហព័ទ្ធម្ខាងនឹងជួបប្រទះនូវភាពលំបាកលំបិនផ្នែកសេដ្ឋកិច្ច ជាដើម ។ ក៏ប៉ុន្តែ ក្នុងករណីដែលភាគីមិនអាចឈានដល់ការសះជាទេ ទោះបីជាតុលាការបានសាកល្បងធ្វើការផ្សះផ្សារហើយក៏ដោយនោះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៥៣ និង មាត្រា ៥៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា កថាខណ្ឌទី ២ នៃមាត្រានេះកំណត់ថា តុលាការត្រូវចេញសាលក្រម ។ ការអនុវត្តបែបនេះ គឺដោយសារតែសិទ្ធិលែងលះរបស់ភាគីមិនគួរត្រូវបានប៉ះពាល់ដោយសារការវិនិច្ឆ័យតាមចិត្តរបស់តុលាការទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៥ មាត្រា ៥៣ និង មាត្រា ៥៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសកម្ពុជា

# ជំពូកទី ៤ ឪពុកម្តាយ និង កូន

## ផ្នែកទី ១ បុត្តភាព

### កថាភាគទី ១ បទប្បញ្ញត្តិទូទៅ

(កំណត់)

បញ្ញត្តិដែលចែងអំពីទំនាក់ទំនងឪពុកម្តាយ និង កូនអាចចែកចេញជាពីរផ្នែក គឺបញ្ញត្តិដែលទាក់ទងទៅនឹងទំនាក់ទំនងរវាងឪពុកម្តាយ និង កូនបង្កើត ចាប់ពីមាត្រា ៩៨៥ ទៅ និង បញ្ញត្តិស្តីពីទំនាក់ទំនងឪពុកម្តាយចិញ្ចឹម និង កូនសុំ ចាប់ពីមាត្រា ១០០៧ ទៅ ។ ទំនាក់ទំនងរវាងឪពុកម្តាយ និង កូនបង្កើត គឺជាទំនាក់ទំនងតាមច្បាប់ដោយផ្អែកលើអត្ថិភាពនៃទំនាក់ទំនងលោហិតរវាងឪពុកម្តាយ និង កូននោះជាមូលដ្ឋាន ។ ក៏ប៉ុន្តែ ទោះបីជាទំនាក់ទំនងរវាងឪពុក និង កូន (បិតុភាព) និង ទំនាក់ទំនងរវាងម្តាយ និង កូន (មាតុភាព) ទាក់ទងគ្នាទៅវិញទៅមកក៏ដោយ ក៏ទំនាក់ទំនងពីរនេះពុំមែនជាទំនាក់ទំនងតែមួយដូចគ្នាទេ ហេតុដូច្នេះ បញ្ញត្តិស្តីពីបិតុភាព និង បញ្ញត្តិស្តីពីមាតុភាព ត្រូវបានរៀបចំដាច់ដោយឡែក ដោយចាត់ទុកជាបុត្តភាពដោយឡែកពីគ្នា ។

**មាត្រា ៩៨៥.-** ករណីយកិច្ចនៃការសុំចុះកំណើត

១-ឪពុក ឬ ម្តាយរបស់កូន ត្រូវសុំចុះកំណើតរបស់កូន នៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ឪពុក ឬ ម្តាយ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលកូននោះកើត ។ ប្រសិនបើឪពុក ឬ ម្តាយមិនអាចសុំចុះបានទេ ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្តាយនៃកូន ត្រូវសុំចុះកំណើតរបស់កូននោះ ឱ្យបានឆាប់រហ័ស ។

២-ក្នុងករណីដែលឪពុកម្តាយបានធ្វេសប្រហែសនឹងករណីយកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយគ្មានមូលហេតុត្រឹមត្រូវ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១០.០០០ (មួយម៉ឺន) រៀល ។

(កំណត់)

វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ កំណត់អំពីករណីយកិច្ចរបស់ឪពុកម្តាយក្នុងការសុំចុះកំណើតរបស់កូន ។ ឪពុកម្តាយមានករណីយកិច្ចនេះ ទោះបីជាឪពុកម្តាយនោះបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ មិនបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ ។ ចំពោះឪពុកម្តាយដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ភាគច្រើនម្តាយមិនអាចទៅសុំចុះកំណើតបានទេ ដោយសារតែម្តាយនោះស្ថិតក្នុងស្ថានភាពទើបនឹងសម្រាលកូនហើយ (សរសៃខ្ចី) ដូច្នេះជាទូទៅ គឺឪពុកជាអ្នកសុំចុះកំណើតនោះ ។

ម៉្យាងវិញទៀត ដោយសារតែលំនៅឋានរបស់ប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍នោះ គឺជាលំនៅឋានរបស់ឪពុកម្តាយតែម្តង ទើបការសុំចុះកំណើតនោះអាចធ្វើនៅទីកន្លែងដែលប្តីប្រពន្ធនោះរស់នៅតែម្តងបាន ។ ចំពោះឪពុកម្តាយដែលមិនបានរៀបអាពាហ៍ពិពាហ៍ ភាគច្រើនគឺម្តាយជាអ្នកសុំចុះកំណើតកូន ។ ដូចដែលនឹងលើកយកមកបង្ហាញនៅខាងក្រោម ក្នុងករណីដែលម្តាយ និង ឪពុកមិនបានរៀបអាពាហ៍ពិពាហ៍ បិតុភាពមិនត្រូវបានកំណត់ ក្នុងពេលតែមួយជាមួយនឹងកំណើតរបស់កូនទេ ទើបការសុំចុះកំណើតត្រូវធ្វើ មិនមែននៅលំនៅឋានរបស់ឪពុកទេ គឺលំនៅឋានរបស់ម្តាយ ។ ដោយហេតុនោះ មានភាពចាំបាច់ដែលត្រូវរៀបចំឱ្យមាននូវនីតិវិធីដែលឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ។ ដោយឡែកចំពោះ "អំឡុងពេល ៣០ ថ្ងៃ" វិញ ការគណនាត្រូវធ្វើឡើងដោយរាប់បញ្ចូលទាំងថ្ងៃដំបូង មានន័យថា ថ្ងៃដែលទារកកើតមកផងដែរ ហើយវិធីគណនានេះខុសពីគោលការណ៍នៃការគណនាអំឡុងពេលតាមក្រមរដ្ឋប្បវេណី ។ គួរឱ្យកត់សម្គាល់ផងដែរថា ទោះបីជាកូនកើតនៅពេលល្ងាចក្រោយពេលដែលសាលាឃុំ សង្កាត់បានបិទទ្វារហើយក៏ដោយ ក៏ថ្ងៃដំបូងនៃការគណនា គឺជាថ្ងៃកំណើតនោះតែម្តង ។ អំឡុងពេល ៣០ ថ្ងៃ ត្រូវបានកំណត់ឱ្យត្រូវគ្នាជាមួយនឹងមាត្រា ១៧ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានដែលចែងថា រយៈពេលនោះគឺ ៣០ ថ្ងៃ ។ ក៏ប៉ុន្តែ បើយើងធ្វើការប្រៀបធៀបជាមួយនឹងច្បាប់ប្រទេសផ្សេងៗវិញ ឧទាហរណ៍ដូចជាមាត្រា ៥៥ នៃក្រមរដ្ឋប្បវេណីបារាំង កំណត់ត្រឹម ៣ ថ្ងៃ ក្រោយកំណើតរបស់កូន រីឯច្បាប់ស្តីពីអត្រានុកូលដ្ឋានរបស់ជប៉ុនវិញ បានកំណត់អំឡុងពេល ១៤ ថ្ងៃ ក្រោយកំណើតរបស់កូន ។ តែទោះបីជាយ៉ាងណាក៏ដោយ ដោយសារយល់ឃើញថា គួរតែកំណត់ឱ្យស៊ីគ្នាជាមួយនឹងប្រព័ន្ធបច្ចុប្បន្ន ទើបអំឡុងពេលសម្រាប់ការសុំចុះកំណើតនេះត្រូវបានកំណត់យក ៣០ ថ្ងៃដូច្នេះ ។ មូលហេតុដែលរាប់បញ្ចូលថ្ងៃដំបូងដែរនោះ គឺដោយសារមាត្រាដដែលនៃអនុក្រឹត្យចែងដោយប្រើឃ្លាថា "មិនឱ្យហួស ៣០ ថ្ងៃ (dans les trente jours/no later than 30 days)" ដែលអាចត្រូវបានបកស្រាយថា ថ្ងៃដំបូងនៃកំណើតក៏ត្រូវរាប់បញ្ចូលដែរនោះ ហើយកថាខណ្ឌទី ១ មាត្រា ៩៨៦ នៃក្រមនេះចែងថា អាយុត្រូវគណនាចាប់ពីថ្ងៃកំណើត និង ដោយសារគួរជំរុញឱ្យសុំចុះកំណើតឱ្យបានឆាប់ ។ ហេតុដូច្នេះ មាត្រានេះបានរាប់បញ្ចូលទាំងថ្ងៃដំបូង ដោយខុសគ្នាពីគោលការណ៍ទូទៅនៃក្រមរដ្ឋប្បវេណី ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ត្រូវបានរៀបចំឡើងសម្រាប់ករណីដែលឪពុកនៅឆ្ងាយ ហើយម្តាយដែលទើបសម្រាលកូនហើយនៅសរសៃខ្ចី ហើយខ្លាចក្រែងមិនអាចទៅសុំចុះកំណើតបានទាន់ពេលវេលា ជាអាទិ៍ ដោយដាក់ឱ្យញាតិដែលជានីតិជន និង រស់នៅជាមួយឪពុកម្តាយរបស់កូននោះ នូវករណីយកិច្ចសុំចុះកំណើតកូននោះ ។ ទោះបីជាពួកគេជាញាតិរបស់កូនក៏ដោយ ក៏ពួកគេមិនមែនជាឪពុកម្តាយរបស់កូននោះទេ ទើបមិនចែងកំណត់ថា "ក្នុងអំឡុងពេល ៣០ ថ្ងៃ" ឡើយ ផ្ទុយទៅវិញ វាក្យខណ្ឌទី ២ នេះចែងថា ត្រូវសុំចុះកំណើតកូននោះ "ឱ្យបានឆាប់រហ័ស" ។ កថាខណ្ឌទី ២ កំណត់ពិន័យស៊ីវិលជាប្រាក់ ១០,០០០ រៀល ទៅលើឪពុកម្តាយណាដែលធ្វេសប្រហែសចំពោះករណីយកិច្ចដែលបានចែងក្នុងកថាខណ្ឌទី ១ ។ កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារបានចែងថា ការចុះកំណើតគឺជាសិទ្ធិរបស់កុមារ ។ លើសពីនេះទៅទៀត ជំពូកទី ៣ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងអំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ហើយការចុះកំណើតកូន គឺជាការដែលត្រូវតែធ្វើ ពីព្រោះការចុះកំណើតវាជាមូលដ្ឋានគ្រឹះដែលកូននោះមានវត្តមាននៅក្នុងសង្គមកម្ពុជាតាមផ្លូវ

ច្បាប់ ហើយនឹងក្លាយទៅជាភាគីនៃសិទ្ធិ និង ករណីយកិច្ចដែលកំណត់ដោយច្បាប់ ។ ដោយឡែកពាក់ព័ន្ធជាមួយនឹងការកំណត់ប្រាក់ពិន័យទាប ឬ ខ្ពស់វិញ ការកំណត់ចំនួនទឹកប្រាក់ពិន័យទាបពេក មិនជំរុញឱ្យប្រជាពលរដ្ឋសុំចុះកំណើតកូនទេ ក៏ប៉ុន្តែ ប្រសិនបើកំណត់ខ្ពស់ពេកទៅ ក៏ជាក់ស្តែងគេមិនអាចបង់បានដែរ ។ មានន័យថា ប្រសិនបើកំណត់ខ្ពស់ពេក ឬ ទាបពេក អត្ថន័យនៃមាត្រានេះត្រូវបាត់បង់ ។ ដូច្នេះ យោងទៅតាមលទ្ធផលនៃការពិភាក្សា ចំនួនមិនលើសពី ១០,០០០ រៀល ត្រូវបានយល់ឃើញថាជាចំនួនសមរម្យ ។ ពាក្យថា "មិនលើសពី" បង្ហាញថា ចំនួននេះអាចមានការប្រែប្រួល ។ បញ្ញត្តិនេះពុំកំណត់ចំនួនកំណត់ជាក់លាក់ ហើយអនុញ្ញាតឱ្យប្រែប្រួលចំនួនក្នុងចន្លោះក្រោម ១០,០០០ រៀល ដោយសារមានអនុសាសន៍ពីក្រសួងមហាផ្ទៃ ជាអាទិ៍ ។ ចំពោះមូលហេតុវិញ ស្ថានភាពសេដ្ឋកិច្ចរបស់ពលរដ្ឋខុសៗគ្នាទៅតាមតំបន់ ដូច្នេះ ការកំណត់ចំនួនទឹកប្រាក់ពិន័យជារួមសម្រាប់ទាំងទីក្រុង និង ជនបទ មិនសមស្របទៅតាមស្ថានភាពជាក់ស្តែង ។ ម៉្យាងវិញទៀត មានគម្រោងតាក់តែងបទដ្ឋានគតិយុត្តមួយដែលកំណត់ចំនួនប្រាក់ពិន័យឱ្យខុសគ្នាទៅតាមតំបន់ ប៉ុន្តែមានភាពមិនច្បាស់លាស់ថា តើបទដ្ឋាននោះត្រូវបានរៀបចំ ឬ ធ្វើវិសោធនកម្មឆាប់ៗនេះ ឬក៏យ៉ាងណានោះទេ ។ លើសពីនេះទៀត ដោយរាប់បញ្ចូលទាំងការពិចារណាឃើញនូវភាពខុសគ្នានៃស្ថានភាពសេដ្ឋកិច្ចរវាងតំបន់នីមួយៗដូចរៀបរាប់ខាងដើមផង ព្រមជាមួយនឹងការពិចារណាទៅដល់ស្ថានភាពសេដ្ឋកិច្ចនៃបុគ្គលដែលត្រូវទទួលការពិន័យផង ទើបមានការសម្រេចថា យកល្អគួរតែកំណត់យកចំនួនទឹកប្រាក់ពិន័យសមរម្យណាមួយឱ្យហើយទៅ ។ ដូច្នេះ ប្រសិនបើមានបទដ្ឋានគតិយុត្ត ចៅក្រមត្រូវសម្រេចទឹកប្រាក់ពិន័យ ទៅតាមការកំណត់ជាក់លាក់របស់បទដ្ឋាននោះ ក៏ប៉ុន្តែ ប្រសិនបើមិនទាន់មានទេ ចៅក្រមត្រូវសម្រេចអំពីចំនួនទឹកប្រាក់ពិន័យ ដោយពិចារណាដល់ភាពខុសគ្នានៃស្ថានភាពសេដ្ឋកិច្ចរវាងតំបន់នីមួយៗ និង ស្ថានភាពជាក់ស្តែងរបស់បុគ្គលដែលត្រូវពិន័យ ជាអាទិ៍ ។ ចំពោះបទដ្ឋានគតិយុត្តដែលនឹងត្រូវបានរៀបចំនាពេលអនាគត ដោយសារតែមិនមែនជាច្បាប់ទេ មានភាពងាយស្រួលជាងច្បាប់ ក្នុងការធ្វើវិសោធនកម្ម ហេតុដូច្នេះ បទដ្ឋានគតិយុត្តនោះ គួរត្រូវបានធ្វើវិសោធនកម្ម ទៅតាមកម្រិតនៃការដោះស្រាយភាពខុសគ្នានៃស្ថានភាពសេដ្ឋកិច្ចរវាងតំបន់ ការផ្លាស់ប្តូរស្ថានភាពនៃថ្លៃទំនិញ និង មាត្រដ្ឋាននៃរូបិយវត្ថុ ជាដើម ។ ម៉្យាងវិញទៀត គ្មានបញ្ហាអ្វីក្នុងការធ្វើវិសោធនកម្ម "មិនលើសពី ១០,០០០ រៀល" នៃមាត្រានេះ ដើម្បីតម្រូវទៅតាមការប្រែប្រួលនៃកម្រិតជីវភាព និង តម្លៃរូបិយវត្ថុ ជាដើម ។ បន្ថែមពីនេះទៀត នៅពេលដែលដឹងច្បាស់ថា មានឪពុកម្តាយ ដូចជាប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឪពុកម្តាយទាំងពីរនាក់នោះ នឹងត្រូវទទួលពិន័យមិនតិចជាង ១០,០០០ រៀលក្នុងម្នាក់ ។ ចំពោះករណីដែលម្តាយ ដែលមិនបានរៀបអាពាហ៍ពិពាហ៍ ហើយមិនស្គាល់ឪពុកថាជាអ្នកណា អ្នកដែលខកខានមិនបានសុំចុះកំណើតកូនគឺម្តាយ ហេតុដូច្នេះ ម្តាយនោះត្រូវទទួលការពិន័យជាប្រាក់មិនលើសពី ១០,០០០ រៀលនោះ ។ ការពិន័យនេះត្រូវបានដាក់ទៅលើឪពុក និង ម្តាយតែប៉ុណ្ណោះ ហើយប្រសិនបើញាតិដែលរស់នៅជាមួយសុំចុះកំណើតកូនក្រោយពេលកំណត់ ៣០ ថ្ងៃ ញាតិនោះនឹងមិនត្រូវទទួលការពិន័យទេ ។ ករណីដែលញាតិសុំចុះកំណើតកូន គឺជាករណីដែលឪពុកម្តាយមិនអាចសុំចុះកំណើត ហេតុដូច្នេះ ច្បាប់នេះក៏មិនទាមទារឱ្យមាននូវ "អលទ្ធភាព" ហើយមិនដាក់ពិន័យចំពោះ "អលទ្ធភាព" នោះដែរ ។

**មាត្រា ៩៨៦.-** វិធីគណនាអាយុ

១-អាយុត្រូវគណនាដោយគិតចាប់ពីថ្ងៃកំណើត ។

២-បញ្ញត្តិនៃមាត្រា ៣៣៥ (ការគណនាអំឡុងពេលតាមប្រតិទិនសុរិយគតិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគណនាអាយុ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រា ៣៣៤ ដែលចែងអំពីវិធីគណនាអំឡុងពេល ចែងថា ថ្ងៃដំបូងមិនត្រូវបានរាប់បញ្ចូលទេ ។ ផ្ទុយពីបញ្ញត្តិនោះ មាត្រានេះបញ្ជាក់ច្បាស់នូវខ្លឹមសារនៃការគណនាអាយុដោយរាប់គិតចាប់ពីថ្ងៃកំណើត ។ ជាឧទាហរណ៍ កូនដែលកើតនៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៥ នឹងមានអាយុមួយឆ្នាំពេញនៅយប់ម៉ោង ០ នៃថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៦ ។ កថាខណ្ឌទី ២ មានន័យថា ត្រូវយកមាត្រា ៣៣៥ មកអនុវត្តដូចគ្នាផងដែរចំពោះករណីនៃឆ្នាំដែលមាន ៣៣៦ ថ្ងៃ ។ ឧទាហរណ៍ថា ដោយសារឆ្នាំ ២០០៤ ជាឆ្នាំដែលមាន ៣៣៦ ថ្ងៃ ដូច្នេះ មានថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ ។ ដូច្នេះ កូនដែលកើតនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៤ មានអាយុមួយឆ្នាំនៅម៉ោង ០ នៃថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០០៥ ។

## កថាភាគទី ២ ការសម្រេចអំពីបុត្តភាព

(កំណត់)

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ បានកំណត់ផ្សេងគ្នានូវវិធីកំណត់អំពីបុត្តភាព ជាពិសេស អំពីបិតុភាព ដោយយកអាពាហ៍ពិពាហ៍របស់ឪពុកម្តាយនៃកូននោះជាមូលដ្ឋាន ដោយផ្នែកទី ១ នៃជំពូកទី ៥ ចែងអំពីកូនមានខាន់ស្លា ហើយផ្នែកទី ២ នៃជំពូកទី ៥ ចែងអំពីកូនឥតខាន់ស្លា ។ ដោយឡែកក្រមនេះមិនធ្វើការបែងចែករវាងកូនមានខាន់ស្លា និង កូនឥតខាន់ស្លាទេ ហើយបង្កើតបញ្ញត្តិអំពីមាតុភាពដែលគ្មាននៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ ។ ដោយផ្អែកលើបញ្ញត្តិអំពីមាតុភាពនេះ ក្រមនេះរៀបចំឱ្យមានបុត្តភាពតាមច្បាប់ និង តាក់តែងអំពីរបៀបកំណត់បុត្តភាព និង របៀបបដិសេធបុត្តភាព ពីទស្សនៈនៃកូនដែលត្រូវបានសន្មតបិតុភាពដោយសារចំណងអាពាហ៍ពិពាហ៍របស់ឪពុកម្តាយ និង កូនដែលមិនត្រូវបានសន្មតបិតុភាព ដោយសារឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍ ។

**មាត្រា ៩៨៧.-** មាតុភាព

ស្ត្រីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន ។

(កំណត់)

បញ្ញត្តិនេះយកគំរូតាមតាមមាត្រា ១៩៨១ នៃក្រមរដ្ឋប្បវេណីរបស់អាល្លឺម៉ង់ ។ បញ្ញត្តិនេះបញ្ជាក់ច្បាស់អំពីមាតុភាពដែលកើតឡើងដោយសារអង្គហេតុនៃការសម្រាលកូន ដែលបើនិយាយយ៉ាងសាមញ្ញទៅថា វាត្រូវតែដូច្នេះហើយ ។ ការបង្កើតឱ្យមាននូវមាតុភាពដោយផ្អែកលើអង្គហេតុស្តីពីការសម្រាលកូនដែលជាអង្គហេតុច្បាស់លាស់យ៉ាង

ជាក់ស្ដែង នាំឱ្យកំណត់ម្ដាយព្រមពេលជាមួយគ្នានឹងកំណើតរបស់កូន ។ ហេតុដូច្នេះ យ៉ាងហោចណាស់ក៏ឪពុក ឬ ម្ដាយម្នាក់របស់កូន ត្រូវបានកំណត់ដែរ ដើម្បីទ្រទ្រង់ដល់សុខុមាលភាពរបស់កូននោះ ។ អ្វីដែលនឹងអាចក្លាយជាបញ្ហា នាពេលអនាគតនោះ គឺការសម្រាលកូនតាមបែបសិប្បនិម្មិត (surrogate) ។ ដោយសារការរីកចម្រើននៃបច្ចេកវិទ្យា វេជ្ជសាស្ត្រក្នុងការផ្ដល់កំណើតទារក ការផ្ដល់កំណើតកូនខាងក្រៅរាងកាយ (in-vitriol fertilization) ត្រូវបានធ្វើឡើង នៅក្នុងប្រទេសខ្លះដោយប្រើសុក្កាណូរបស់ប្ដី និង បប្ឈណ្ឌ (អូវ៉ុល) របស់ប្រពន្ធ ។ ហើយពងដែលបានពីនោះត្រូវបានដាក់ ទៅក្នុងស្បូននៃស្ត្រីផ្សេង ដែលមិនមែនជាប្រពន្ធនោះ ដើម្បីឱ្យមានគភ៌ ហើយផ្ដល់កំណើតឱ្យកូន រីឯប្ដីប្រពន្ធនោះសុំចុះ កំណើតកូននោះថាជាកូនបង្កើតរបស់ខ្លួន ។ ការសម្រាលកូនតាមបែបសិប្បនិម្មិត (surrogate) បែបនេះ ត្រូវបាន ហាមឃាត់នៅប្រទេសបារាំង និង នៅប្រទេសអាល្លឺម៉ង់ ដោយសារតែវាផ្ទុយទៅនឹងសីលធម៌ ។ ដោយសារតែ ការកំណត់ថា ស្ត្រីដែលផ្ដល់កំណើតឱ្យកូនជាម្ដាយរបស់កូននោះ មានន័យថា ប្រពន្ធដែលស្នើសុំឱ្យស្ត្រីផ្សេងបង្កើតកូននោះ នឹងមិនក្លាយជាម្ដាយបង្កើតរបស់កូននោះឡើយ ហើយការណ៍នេះ នឹងបង្អាក់ការអនុវត្តការបង្កើតកូនតាមបែបសិប្បនិម្មិត (surrogate) បែបនេះ ដោយសារដើម្បីបង្កើតបុត្តភាពរវាងប្ដីប្រពន្ធដែលបានស្នើសុំឱ្យស្ត្រីផ្សេងបង្កើតកូន និង កូនដែល កើតពីស្ត្រីនោះ ចាំបាច់ត្រូវបង្កើតសុំកូន ។

**មាត្រា ៩៨៨.-** ការសន្មតបិតុភាព

១-ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្ដី ។

២-កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថា មានគភ៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ ។

៣-ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀតផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៥០ (អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត) នៃក្រមនេះ បានបង្កើតកូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះទេ ត្រូវសន្មតថា កូននោះជាកូនរបស់ប្ដីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ ។

(កំណត់)

កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ គឺជាបញ្ញត្តិដែលទទួលបន្តពីមាត្រា ៨២ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

ឆ្នាំ ១៩៨៩ ។ មានការតាក់តែងបន្ថែមទាក់ទងទៅនឹងចំណុចពីរ ។ ចំណុចទី ១ គឺករណីដែលកូនកើតមុនកាលកំណត់ដោយហួសហេតុ ។ ដោយសារតែការរីកចម្រើននៃវេជ្ជសាស្ត្រក្នុងការថែទាំទារក ទារកដែលកើតក្រោយពេលមានផ្ទៃពោះ ៥ ខែ ក៏អាចរស់រានមានជីវិតដែរ ។ មានន័យថា ក្រោយពេលរៀបអាពាហ៍ពិពាហ៍ភ្លាម ម្តាយមានផ្ទៃពោះភ្លាមៗ ហើយកូននោះកើតក្នុងអំឡុងពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍ ។ ចំណុចទី ២ គឺនៅពេលប្តីស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ តែម្តាយមានគតិដោយសារទំនាក់ទំនងផ្លូវភេទនៅមុនពេលនៃគ្រោះថ្នាក់ចរាចរណ៍ ហើយផ្តល់កំណើតកូនក្រោយពេល ៣០០ ថ្ងៃ គិតចាប់ពីថ្ងៃរំលាយអាពាហ៍ពិពាហ៍ ។ ករណីបែបនេះអាចជាករណីកម្រ ក៏ប៉ុន្តែមិនមែនជារឿងដែលមិនអាចកើតមានឡើងនោះឡើយ ។ បើនិយាយឱ្យតឹងរ៉ឹងទៅ ករណីទាំងពីរខាងលើនេះ ពុំស្ថិតនៅក្នុងក្របខ័ណ្ឌនៃការសន្មតបិតុភាពនៃមាត្រានេះទេ ។ ចំពោះករណីទី ១ កូននឹងត្រូវបានសុំចុះបញ្ជីថាជាកូនរបស់ប្តីប្រពន្ធនោះ ហើយការទទួលការសុំចុះបញ្ជីបែបនោះមិនបង្កផលអាក្រក់អ្វីដែរ ។ ក៏ប៉ុន្តែ ដោយសារតែបិតុភាពមិនត្រូវបានសន្មតទេ ការបដិសេធបិតុភាព ត្រូវតែធ្វើឡើងដោយដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ដោយយោងតាមបញ្ញត្តិចាប់ពីកថាភាគទី ៤ នៃផ្នែកនេះ មិនមែនតាមបញ្ញត្តិចាប់ពីមាត្រា ៩៨៩ នៃក្រមនេះទេ ។ ចំពោះករណីទី ២ ដោយសារតែកូនកើតក្រៅអំឡុងពេលនៃការសន្មតបិតុភាព ជាបឋម កូនគួរតែត្រូវបានចុះកំណើតថាជាកូនរបស់ប្រពន្ធ ហើយបិតុភាពជាមួយប្តីដែលទទួលមរណភាព ត្រូវបានបង្កើតឡើង តាមរយៈបណ្តឹងទាមទារឱ្យទទួលស្គាល់នៅក្រោយមរណភាព ដោយយោងតាមមាត្រា ១០០១ នៃក្រមនេះ ។ ទោះបីជាករណីណាមួយក៏កម្រអាចកើតឡើងក៏ដោយ ក៏ចាំបាច់ត្រូវមានការប្រុងប្រយ័ត្នដែរ ដោយសារតែករណីទាំងពីរនេះជាករណីដែលបិតុភាពមិនត្រូវបានសន្មត ។ កថាខណ្ឌទី ៣ មានអត្ថន័យដូចតទៅ : មាត្រា ៩៥០ នៃក្រមនេះតាក់តែងឡើងដើម្បីជៀសវាងការប្រកួតប្រជែងការសន្មតឪពុក ដោយកំណត់អំឡុងពេល ១២០ ថ្ងៃគិតចាប់ពីពេលរំលាយអាពាហ៍ពិពាហ៍ មុនរហូតដល់ពេលបង្កើតអាពាហ៍ពិពាហ៍ថ្មី ថាជាអំឡុងពេលហាមឃាត់ការរៀបអាពាហ៍ពាហ៍ថ្មី ។ ក៏ប៉ុន្តែ អាចមានករណីដែលស្ត្រីអនុវត្តផ្ទុយនឹងច្បាប់ ដោយបានរៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀតដោយមិនរង់ចាំផុតអំឡុងពេល ១២០ ថ្ងៃ ហើយបានបង្កើតកូនក្នុងអំឡុងពេល ៣០០ ថ្ងៃ ក្រោយពេលដែលអាពាហ៍ពិពាហ៍មុនរលាយ និង ក្នុងអំឡុងពេល ១៨០ ថ្ងៃ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ថ្មី ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍ត្រូវរំលាយដោយសារការលែងលះ ជាដើម កម្រមានករណីដែលសហព័ទ្ធមានទំនាក់ទំនងផ្លូវភេទក្នុងពេលដែលកំពុងរង់ចាំដើម្បីលែងលះគ្នាណាស់ ហើយដោយសារតែគិតដល់ទំនាក់ទំនងផ្លូវភេទនៅមុនពេលរៀបអាពាហ៍ពិពាហ៍របស់ភាគីដែលរៀបអាពាហ៍ពិពាហ៍ប្រឆាំងទៅនឹងអំឡុងពេលហាមឃាត់បែបនោះ កូននោះត្រូវសន្មតថា ជាកូននៃប្តីនៃអាពាហ៍ពិពាហ៍ក្រោយនោះ ។ ប្រសិនបើប្តីនៃអាពាហ៍ពិពាហ៍ក្រោយនោះធ្វើវិវាទចំពោះបិតុភាពនោះ ប្តីនោះអាចបដិសេធបិតុភាព ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៩៨៩ នៃក្រមនេះ ។ ក្នុងករណីដែលការបដិសេធបិតុភាពដោយប្តីនៃអាពាហ៍ពិពាហ៍ក្រោយត្រូវបានទទួលស្គាល់ កូននោះនឹងត្រូវសន្មតថាជាកូនរបស់ប្តីនៃអាពាហ៍ពិពាហ៍មុន ។ ក្នុងករណីនេះ ត្រូវបកស្រាយកថាខណ្ឌទី ២ នៃមាត្រា ៩៩០ ថា អំឡុងពេលដែលប្តីនៃអាពាហ៍ពិពាហ៍មុនអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ត្រូវគិតចាប់ពីពេលដែលខ្លួនបានដឹងអំពីការដែលបិតុភាពរវាងកូនជាមួយប្តីក្រោយនោះ

ត្រូវបានបដិសេធ ។

**មាត្រា ៩៨៩.-** ការបដិសេធបិតុភាព

នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៩៨៨ (ការសន្មតបិតុភាព) ខាងលើនេះ ជនដែលត្រូវបានសន្មតថាជាឪពុក ឬ កូន អាចបដិសេធបិតុភាពបាន ។

(កំណត់)

មាត្រា ៨៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ ចែងអំពីការប្តឹងប្រកែកមិនទទួលស្គាល់បិតុភាពដោយប្តី ចំពោះប្រពន្ធ និង កូន ហើយប្តីជាបុគ្គលតែម្នាក់គត់ដែលមានសិទ្ធិដាក់ពាក្យបណ្តឹងបដិសេធ ។ ប៉ុន្តែច្បាប់នាសម័យទំនើប បានអនុញ្ញាតឱ្យប្រពន្ធ (ម្តាយរបស់កូន) ធ្វើបណ្តឹងបដិសេធបិតុភាពក្នុងករណីជាកំណត់មួយចំនួន ដូចជាមាត្រា ៣៨០ នៃ ក្រមរដ្ឋប្បវេណីបារាំង និង បានអនុញ្ញាតទូលំទូលាយ ដូចកថាខណ្ឌទី ១ នៃមាត្រា ១៦០០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ដែលទទួលស្គាល់យ៉ាងទូលំទូលាយឱ្យប្តី ប្រពន្ធ (ម្តាយរបស់កូន) កូន និង ឪពុកដែលទទួលស្គាល់កូន អាចធ្វើបណ្តឹងបាន ។ យ៉ាងហោចណាស់ក៏កូនត្រូវមានសិទ្ធិដឹងអំពីដើមកំណើតរបស់ខ្លួន (កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ) ។ ដូច្នេះ ដោយសារកូនគួរតែត្រូវបានអនុញ្ញាតឱ្យបង្កើតបិតុភាពជាមួយឪពុកបង្កើត គួរតែពុំមានឱកាសជំទាស់ទៅនឹងការរាប់បញ្ចូលកូនក្នុងបុគ្គលដែលមានសិទ្ធិធ្វើបណ្តឹងដែរនោះទេ ។ ដូច្នេះ ក្រៅពីប្តីដែលធ្លាប់ត្រូវបានទទួលស្គាល់តាមច្បាប់ចាស់ កូនក៏ត្រូវបានបន្ថែមចូលជាបុគ្គលដែលមានសិទ្ធិធ្វើបណ្តឹងដែរ ។

**មាត្រា ៩៩០.-** បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក

១-សិទ្ធិបដិសេធរបស់ជនដែលត្រូវបានសន្មតថាជាឪពុកដែលបានកំណត់នៅក្នុងមាត្រា ៩៨៩ (ការបដិសេធបិតុភាព) ខាងលើនេះ ត្រូវអនុវត្ត ដោយបណ្តឹងចំពោះកូន ។

២-ជនដែលត្រូវបានសន្មតថាជាឪពុក ត្រូវដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងអំពីកំណើតរបស់កូន ។

៣-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបានកន្លងផុត បើជនដែលត្រូវបានសន្មតថាជាឪពុក ជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

(កំណត់)

ក្នុងករណីដែលបិតុភាពត្រូវបានសន្មត ដោយយោងតាមមាត្រា ៩៨៨ បណ្ដឹងដែលបដិសេធបិតុភាពនោះ ដោយអះអាងថា តាមការពិតទៅ មិនមាននូវបិតុភាព ពិតប្រាកដរវាងឳពុក និង កូននោះ ហៅថា "បណ្ដឹងបដិសេធបិតុភាព" ។ មាត្រា ៩៩០ នេះបានចែងកំណត់អំពីល័ក្ខខ័ណ្ឌជាមូលដ្ឋានចំពោះករណីដែលបណ្ដឹងត្រូវបានធ្វើឡើង ដោយប្ដីដែលជាបុគ្គលដែលមានសិទ្ធិប្ដឹង ។ កថាខណ្ឌទី ១ បានបញ្ជាក់ថា "បណ្ដឹងបដិសេធបិតុភាព" ជាវិធីតែមួយគត់ដែលប្ដីអាចបដិសេធបិតុភាពទៅលើកូន ក្នុងករណីដែលបិតុភាពត្រូវបានសន្មតតាមមាត្រា ៩៨៨ ។ កថាខណ្ឌទី ២ កំណត់អំឡុងពេលដែលអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាព ។ មាត្រា ៨៥ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ បានចែងអំពីរយៈពេលដែលអាចដាក់ពាក្យបណ្ដឹង គឺរយៈពេល ២ ខែបន្ទាប់ពីកូនបានកើត ។ អាស្រ័យទៅតាមនីតិកម្មនៃបណ្ដាប្រទេសនីមួយៗ អំឡុងពេលសម្រាប់ការប្ដឹងគឺខុសៗគ្នា ឧទាហរណ៍ មាត្រា ៣១៦ នៃក្រមរដ្ឋប្បវេណីបារាំងចែងថា អំឡុងពេលសម្រាប់ប្ដឹង គឺ ៦ ខែ ក្រោយកំណើតកូន រីឯកថាខណ្ឌទី ១ មាត្រា ១៦០០b នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់បានកំណត់អំឡុងពេល ២ ឆ្នាំ បន្ទាប់ពីប្ដីបានដឹងថា ខ្លួនមិនមែនជាឳពុកបង្កើតរបស់កូន ខណៈពេលដែលមាត្រា ៧៧៧ នៃក្រមរដ្ឋប្បវេណីជប៉ុនវិញ បានកំណត់យកអំឡុងពេល ១ ឆ្នាំ បន្ទាប់ពីប្ដីបានដឹងអំពីកំណើតរបស់កូន ។ ជាលទ្ធផលនៃកិច្ចពិភាក្សា ដោយសារតែអំឡុងពេលតាមច្បាប់មុន គឺ ២ ខែ ទើបយើងកំណត់យកអំឡុងពេលថ្មីនេះ ស្មើនឹងបីដងនៃអំឡុងពេលមុន ពោលគឺ ៦ ខែ ។ កថាខណ្ឌទី ៣ ត្រូវបានរៀបចំឡើង ដោយគិតពិចារណានូវករណីដែល ប្ដីដែលត្រូវធ្វើ "បណ្ដឹងបដិសេធបិតុភាព" ជាជនក្រោមអាណាព្យាបាលទូទៅ នៅពេលដែលអំឡុងពេល ៦ ខែ ដែលអាចដាក់ពាក្យបណ្ដឹង ដែលគិតចាប់ពីកំណើតរបស់កូននោះ ត្រូវផុត ហើយមិនអាចដាក់ពាក្យបណ្ដឹងនោះបាន ។ ក្នុងករណីនេះ អំឡុងពេល ៦ ខែ នោះ ត្រូវគណនាគិតចាប់ពីពេលដែលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅត្រូវបានលុបចោលចំពោះប្ដីនោះ ដែលជាពេលប្ដីនោះអាចដាក់ពាក្យបណ្ដឹង ។ អាចនិយាយម្យ៉ាងទៀតបានថា អ្នកអាណាព្យាបាលទូទៅតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅ ហេតុដូច្នេះ អ្នកអាណាព្យាបាលទូទៅ អាចដាក់ពាក្យ "បណ្ដឹងបដិសេធបិតុភាព" ក្នុងអំឡុងពេល ៦ ខែ ចាប់ពីពេលដឹងអំពីកំណើតកូនតែប៉ុណ្ណោះ ប៉ុន្តែ ទោះបីជាអំឡុងពេល ៦ ខែ បានកន្លងផុតទៅហើយក៏ដោយ បើតាមមាត្រានេះ ប្ដីអាចដាក់ពាក្យ "បណ្ដឹងបដិសេធបិតុភាព" បាន ក្នុងអំឡុងពេល ៦ ខែ គិតចាប់ពីពេលលុបចោលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ ហេតុដូច្នេះ អាចមានករណីដែលពាក្យបណ្ដឹងនោះត្រូវបានដាក់ ទោះបីជាអំឡុងពេលវែងបានកន្លងផុត ក្រោយកំណើតរបស់កូននោះក៏ដោយ ។

**មាត្រា ៩៩១.-** បណ្ដឹងបដិសេធបិតុភាព ពីកូន

១-សិទ្ធិបដិសេធរបស់កូន ដែលបានកំណត់នៅក្នុងមាត្រា ៩៨៩ (ការបដិសេធបិតុភាព) នៃក្រមនេះ ត្រូវអនុវត្តដោយបណ្ដឹងចំពោះជនដែលត្រូវបានសន្មតថាជាឳពុក ។

២-ក្នុងករណីដែលកូនដែលជាអនីតិជន ប្រើសិទ្ធិបដិសេធ បើកូននោះគ្មានម្ដាយដែលអនុវត្តអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ តុលាការត្រូវជ្រើស

តាំងអ្នកតំណាងពិសេស ។

៣-កូន មិនអាចអនុវត្តសិទ្ធិបដិសេធបានឡើយ ប្រសិនបើអំឡុងពេល ៦ (ប្រាំមួយ) ខែ បានកន្លងផុត គិតចាប់ពីពេលដែលខ្លួនបានក្លាយជានីតិជន ។

៤-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ បានកន្លងផុត បើកូនជាជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

(កំណត់)

មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌ ចំពោះករណីដែលកូនក្លាយជាដើមចោទនៃ "បណ្ដឹងបដិសេធបិតុភាព" ។ កថាខណ្ឌទី ២ បានចែងអំពីអ្នកតំណាងក្នុងបណ្ដឹងក្នុងករណីដែលកូននោះជាអនីតិជន ។ តាមសភាពជាក់ស្ដែង ទោះបីជាកូនដែលជាអនីតិជនដាក់ពាក្យបណ្ដឹងក៏ដោយ ក៏ម្ដាយជាអ្នកដែលចង់បដិសេធបិតុភាពរវាងប្ដី និង កូននោះដែរ ។ កថាខណ្ឌទី ៣ គឺជាការកំណត់អំឡុងពេល ។ ទោះបីជាអាចនិយាយបានថា បណ្ដឹងនោះត្រូវបានធ្វើឡើងដោយកូនក៏ដោយ ក៏វាមិនមែនជាការប្រសើរទេដែលអនុញ្ញាតឱ្យកូនអាចដាក់ពាក្យ "បណ្ដឹងបដិសេធបិតុភាព" បានរហូតដល់ពេលណាក៏ដោយនោះ ។ ជាឧទាហរណ៍ កថាខណ្ឌទី ៣ នៃមាត្រា ១៦០០b ចែងថា អំឡុងពេលសម្រាប់ដាក់ពាក្យបណ្ដឹង (២ ឆ្នាំ) មិនចាប់ផ្ដើមនៅមុនពេលដែលកូនបានដល់នីតិភាព និង នៅមុនពេលដែលកូនបានដឹងអំពីហេតុដែលអាចបដិសេធបិតុភាពរបស់ជនដែលត្រូវបានសន្មតថាជាឪពុក ។ ដោយសារមានការគិតគូថា អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងរបស់ប្ដី ត្រូវបានកំណត់ជា ៦ ខែ និង មិនត្រូវចែងអំពីរបៀបគិតអំឡុងពេលដោយមិនច្បាស់លាស់ ដូចជាការចែងថា គិតពីពេលដែលកូនដឹងអំពីហេតុ ប៉ុន្ដែ យកល្អគួរតែចែងឱ្យច្បាស់ៗនោះ ទើបមាត្រានេះកំណត់យកអំឡុងពេល ៦ ខែ គិតចាប់ពីពេលដែលកូនបានឈានចូលដល់នីតិភាព ។ កថាខណ្ឌទី ៤ ចែងអំពីខ្លឹមសារដូចគ្នាទៅនឹងកថាខណ្ឌទី ៣ នៃមាត្រា ៩៩០ (បណ្ដឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) ដែរ ។

**មាត្រា ៩៩២.-** អានុភាពប្រតិសកម្មនៃបណ្ដឹងបដិសេធបិតុភាព

ការបដិសេធបិតុភាព ត្រូវបង្កើតអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន ។

(កំណត់)

ប្រសិនបើបិតុភាពត្រូវបានបដិសេធ វាមានន័យថា ឪពុកមិនមែនជាឪពុករបស់កូនតាំងពីកំណើតរបស់កូនមក ។ ដូច្នេះ សកម្មភាពដែលធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃអត្ថិភាពនៃបិតុភាព ក្នុងអំឡុងពេលរហូតដល់ពេលបិតុភាពត្រូវ

បានបដិសេធ នឹងត្រូវបាត់បង់អានុភាព ។ ជាឧទាហរណ៍ ចំពោះអាហារកាតព្វកិច្ចដែលប្តីបានផ្តល់ចំពោះកូន ទោះបីជាប្តីនោះមិនមែនជាបុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់ក៏ដោយ ក៏ប្តីនោះបានផ្គត់ផ្គង់ទៅហើយ ដូច្នេះ សេចក្តីចម្រើនដោយឥតហេតុ នឹងកើតឡើង ចំពោះម្តាយរបស់កូននោះ ឬ បុគ្គលដែលត្រូវជាឪពុកតាមច្បាប់របស់កូននោះ ។

## កថាភាគទី ៣ ការទទួលស្គាល់

(កំណត់)

ក្នុងករណីដែលបិតុភាពមិនត្រូវបានសន្មត វិធីកំណត់បិតុភាពគឺការទទួលស្គាល់ ។ បញ្ញត្តិតទៅនេះត្រូវបានរៀបចំឡើង ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ៩១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ១៩៨៩ ទៅ ។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចែងអំពីការទទួលស្គាល់ដោយម្តាយដែរ ប៉ុន្តែ ដោយសារមាតុភាពត្រូវបានបង្កើតឡើង ដោយផ្អែកលើហេតុការណ៍កំណើតរបស់កូន ដូច្នោះ បញ្ញត្តិនៃក្រមនេះកំណត់ថា ភាគីនៃការទទួលស្គាល់មានតែឪពុកប៉ុណ្ណោះ ។

### មាត្រា ៩៩៣.- ការទទួលស្គាល់ដោយស្ម័គ្រចិត្ត

ឪពុករបស់កូន អាចទទួលស្គាល់កូនបាន ។ ប៉ុន្តែ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ ។

(កំណត់)

ការទទួលស្គាល់ដោយស្ម័គ្រចិត្ត មានន័យថា បុគ្គលដែលគិតថា ខ្លួនជាឪពុករបស់កូន ទទួលស្គាល់កូននោះ ដោយស្ម័គ្រចិត្ត ។ ចំពោះបែបបទ និង នីតិវិធីលម្អិតនៃការទទួលស្គាល់ គួរតែកំណត់តាមរយៈការពិភាក្សាជាមួយក្រសួងពាក់ព័ន្ធនៅពេលក្រោយ ។ ខ្លឹមសារនៃវាក្យខណ្ឌទី ២ គឺដូចតទៅនេះ ។ មានប្តីប្រពន្ធមួយគូ ហើយកូនបានចាប់កើតមក ។ កូនត្រូវបានចុះសំបុត្រកំណើត ដោយការសុំចុះកំណើតក្នុងនាមជាកូនរបស់ប្តី ដោយសារការសន្មតបិតុភាព ។ ក៏ប៉ុន្តែម្តាយមានទំនាក់ទំនងផ្លូវភេទជាមួយបុរសដទៃ ហើយវាមានលទ្ធភាពខ្ពស់ ឬ ស្ថានភាពច្បាស់លាស់ថា កូននោះជាកូនរបស់បុរសដទៃនោះមែន ។ ក៏ប៉ុន្តែ បើទោះជាក្នុងករណីដូច្នោះក៏ដោយ ដោយសារតែមានកាលៈទេសៈដែលកូនមានឪពុកតាមផ្លូវច្បាប់ដោយសារការសន្មតបិតុភាពរួចហើយ បញ្ញត្តិនេះមិនអនុញ្ញាតឱ្យបុរសដទៃនោះទទួលស្គាល់កូនដោយស្ម័គ្រចិត្តទេ ។ ប្រសិនបើអនុញ្ញាតឱ្យបុរសនោះទទួលស្គាល់ដោយស្ម័គ្រចិត្ត ការណ៍នេះនឹងនាំឱ្យមានទំនាក់ទំនងទ្វេភាពរវាងឪពុក និង កូន ដែលមានឪពុកដោយសារការសន្មតបិតុភាព និង ឪពុកដោយសារការទទួលស្គាល់ដោយស្ម័គ្រចិត្ត ។ ដូច្នេះ ប្រសិនបើបុរសនោះមានបំណងនឹងទទួលស្គាល់កូន បុរសនោះគួរតែលើកទឹកចិត្តឱ្យប្រពន្ធរបស់ប្តី (ម្តាយរបស់កូន) ដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ហើយធ្វើការទទួលស្គាល់ដោយស្ម័គ្រចិត្ត បន្ទាប់ពីបិតុភាពរវាងប្តី និង កូនត្រូវបដិសេធ ។ បញ្ញត្តិដូចគ្នារបៀបនេះក៏មាននៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១៥៩៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ដែរ ។

### មាត្រា ៩៩៤.- សមត្ថភាពក្នុងការទទួលស្គាល់

ដើម្បីទទួលស្គាល់ ទោះបីជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ពុំចាំបាច់មានការយល់ព្រម ពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ ។

(កំណត់)

មាត្រានេះមានន័យថា ទោះជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ឪពុកនោះអាចទទួលស្គាល់កូនដោយស្ម័គ្រចិត្តបានដែរ ដរាបណាគាត់មានសមត្ថភាពខាងឆន្ទៈ ។ មូលហេតុគឺដោយសារតែការទទួលស្គាល់មិនមែនត្រូវតម្រូវទៅតាមការតំណាង ឬ ការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ទេ ។ ជាឧទាហរណ៍ចំពោះនីតិកម្មផ្សេងទៀត មានដូចជាមាត្រា ៧៨០ នៃក្រមរដ្ឋប្បវេណីជប៉ុន និង កថាខណ្ឌទី ១ មាត្រា ១៩៩៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។

**មាត្រា ៩៩៥.-** ការទទួលស្គាល់របស់ឪពុក

១-ឪពុកអាចទទួលស្គាល់កូនដែលជាអនីតិជនបាន ។

២-ទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូននោះបាន ដោយទទួលការយល់ព្រមពីម្ដាយ ។

(កំណត់)

កថាខណ្ឌទី ១ មានន័យថា ក្នុងករណីដែលបុរសម្នាក់ទទួលស្គាល់កូនដែលជាអនីតិជន (ជាការពិតគឺជាកូនដែលគ្មានបិតុភាពតាមច្បាប់ជាមួយបុរសដទៃផ្សេងទៀត) ច្បាប់មិនតម្រូវឱ្យមានការយល់ព្រមពីកូនដែលត្រូវបានទទួលស្គាល់ ឬពីម្ដាយរបស់កូននោះទេ ។ ដោយឡែកមាននីតិកម្មដែលតម្រូវឱ្យមានការយល់ព្រមពីម្ដាយចំពោះគ្រប់ការទទួលស្គាល់ដូចជាកថាខណ្ឌទី ១ នៃមាត្រា ១៥៩៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ជាដើម និង មាននីតិកម្មដែលទាមទារឱ្យមានការយល់ព្រមពីកូន ក្នុងករណីដែលកូននោះបានក្លាយជានីតិជន ដូចកថាខណ្ឌទី ២ នៃមាត្រា ១៥៩៥ ដដែលដែរ ។ ដោយយកគំរូតាមមាត្រា ៧៨២ និង ៧៨៣ នៃក្រមរដ្ឋប្បវេណីជប៉ុន បញ្ញត្តិចាប់ពីមាត្រានេះតម្រូវឱ្យមានការយល់ព្រមពីម្ដាយ ចំពោះការទទួលស្គាល់ទារកក្នុងគភ៌ និង ការយល់ព្រមពីកូន ចំពោះការទទួលស្គាល់កូនដែលជានីតិជន អាស្រ័យទៅតាមប្រភេទនៃការទទួលស្គាល់ ។ កថាខណ្ឌទី ២ នៃមាត្រានេះអនុញ្ញាតឱ្យមានការទទួលស្គាល់ទារកក្នុងគភ៌ ។ ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ ពុំមានបញ្ញត្តិបែបនេះទេ ក៏ប៉ុន្តែ ច្បាប់ប្រទេសផ្សេងៗមានបញ្ញត្តិបែបនេះ ដូចជាកថាខណ្ឌទី ៤ មាត្រា ១៥៩៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង កថាខណ្ឌទី ១ មាត្រា ៧៨៣ នៃក្រមរដ្ឋប្បវេណីជប៉ុន ជាដើម ។ មានតែម្ដាយប៉ុណ្ណោះដែលដឹងថា ឪពុករបស់ទារកក្នុងគភ៌ជានរណា ហើយដោយសារតែកូនក្នុងគភ៌ពុំមានឈ្មោះ ហើយការកំណត់ជាក់លាក់អំពីក្មេងនោះពុំអាចធ្វើទៅបាន ហេតុដូច្នេះ ក្រៅពីការកំណត់អំពីម្ដាយដែលកំពុងមានគភ៌ គ្មានជម្រើសអ្វីផ្សេងទៀតទេ អាស្រ័យហេតុនេះ ឆន្ទៈរបស់ម្ដាយនោះគួរតែត្រូវបាន

គោរព ។ម្យ៉ាងទៀត ទម្រង់បែបបទ ជាដើម សម្រាប់ការទទួលស្គាល់ទារកនៅក្នុងគភ៌ ចាំបាច់ត្រូវកំណត់ជាលម្អិតដាច់ដោយឡែក ។

**មាត្រា ៩៩៦.-** ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព

១-ឪពុកដែលមានបំណងចង់ទទួលស្គាល់កូនដែលជានីតិជន មិនអាចទទួលស្គាល់បានឡើយ បើគ្មានការយល់ព្រមពីកូននោះ ។

២-ឪពុកអាចទទួលស្គាល់កូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ ។ ក្នុងករណីនេះ បើបច្ឆាញាតិផ្ទាល់នោះជានីតិជន ត្រូវទទួលការយល់ព្រមពីជននោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៩៩៧ (ទម្រង់នៃការទទួលស្គាល់) ខាងក្រោមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ ។

(កំណត់)

កថាខណ្ឌទី ១ បានបញ្ញត្តថា ការយល់ព្រមពីកូនគឺជាការចាំបាច់ក្នុងករណីដែលឪពុកទទួលស្គាល់កូនដែលបានក្លាយជានីតិជន ។ បញ្ញត្តិនេះមានគោលបំណងទប់ស្កាត់ការទទួលស្គាល់ដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន ដូចជាករណីនៃការទទួលស្គាល់ដើម្បីទាមទារការផ្គត់ផ្គង់ពីកូន ពីព្រោះកាលពេលដែលកូននៅជាអនីតិជន ឪពុកនោះបានបោះបង់កូនចោល ដោយមិនបានទទួលស្គាល់កូននោះ ។ ម្យ៉ាងវិញទៀត ចំពោះកូនវិញ អាចមានករណីដែលកូនមិនមានបំណងបង្កើតបិតុភាពអ្វីមកដល់ពេលនេះ ដោយសារតាំងពីយូរណាស់មកហើយ កូនបានបង្កើតនូវទំនាក់ទំនងសង្គមជាច្រើនក្នុងឋានៈជាបុគ្គលដែលគ្មានឪពុករួចទៅហើយ ។ បើពិនិត្យមើលលើគំរូនៃនីតិកម្មផ្សេងទៀត មានដូចជាកថាខណ្ឌទី ២ មាត្រា ១៥៩៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ៧៨២ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ម្យ៉ាងទៀត មាត្រា ៣៣៤-២ នៃក្រមរដ្ឋប្បវេណីបារាំងវិញ រាល់ការទទួលស្គាល់កូនដែលមានអាយុចាប់ពី ១៥ ឆ្នាំ (ក្រោយមកបានកែប្រែទៅជាចាប់ពី ១៣ ឆ្នាំវិញ) ចាំបាច់ត្រូវមានការយល់ព្រមពីកូននោះ ក៏ប៉ុន្តែ បច្ចុប្បន្ន បញ្ញត្តិនេះត្រូវបាននិរាករណ៍ហើយ ។ កថាខណ្ឌទី ២ បានបញ្ជាក់ច្បាស់ថា ក្នុងករណីដែលកូនបានទទួលមរណភាពក្នុងអំឡុងពេលដែលមិនទាន់មានការទទួលស្គាល់ ជាគោលការណ៍មិនអនុញ្ញាតឱ្យមានការទទួលស្គាល់ទេ ពីព្រោះភាគីម្ខាងនៃបិតុភាពនោះបានទទួលមរណភាព ដូច្នេះ គ្មានផលប្រយោជន៍អ្វីក្នុងការបង្កើតបិតុភាពនោះទេ ។ ក៏ប៉ុន្តែ ជាករណីលើកលែង ក្នុងករណីដែលកូនដែលបានទទួលមរណភាពនោះមានកូន មានន័យថា ឪពុករបស់កូននោះមានចៅ មានផលប្រយោជន៍ជាក់ស្តែងក្នុងការបង្កើតបិតុភាព ពីព្រោះការបង្កើតបិតុភាពមានន័យថាជាការបង្កើតទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ជាមួយចៅនោះ ។ ហេតុដូច្នេះ ការទទួលស្គាល់កូនដែលបាន

ទទួលមរណភាពអាចអនុញ្ញាតបានតែក្នុងករណីបែបដូច្នេះប៉ុណ្ណោះ ។ ក្នុងករណីនេះ ដូចហេតុផលដែលបានបញ្ជាក់ក្នុងសេចក្តីកំណត់អំពីកថាខណ្ឌទី ១ នៃមាត្រានេះដែរ ប្រសិនបើបច្ឆាញាតិផ្ទាល់ (មានន័យថាជាកូន ក្នុងករណីជាច្រើន) របស់កូនដែលទទួលមរណភាពបានដល់នីតិភាព វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ទាមទារឱ្យមានការយល់ព្រមពីបច្ឆាញាតិផ្ទាល់នោះដូចគ្នា ។ ជាឧទាហរណ៍ កថាខណ្ឌទី ២ មាត្រា ៧៨២ នៃក្រមរដ្ឋប្បវេណីជប៉ុន ក៏បានចែងដូចគ្នាដែរ ។

**មាត្រា ៩៩៧.-** ទម្រង់នៃការទទួលស្គាល់

១-ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ។ ការទទួលស្គាល់ ក៏អាចធ្វើតាមមតកសាសន៍ក៏បានដែរ ។

២-ការយល់ព្រមរបស់ម្តាយ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩៥ (ការទទួលស្គាល់របស់ឪពុក) ខាងលើនេះ អាចធ្វើបាន ដោយចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ ។

(កំណត់)

វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ មានខ្លឹមសារដូចគ្នានឹងការ "ឆ្លើយទទួលស្គាល់ដោយផ្ទាល់មាត់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន" ដែលបានចែងក្នុងមាត្រា ៩១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ ដែរ ។ មាត្រា ៣៣៥ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ១៥៩៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់បានបញ្ញត្តថា ការទទួលស្គាល់កូនដោយស្ម័គ្រចិត្តត្រូវធ្វើឡើងដោយលិខិតយថាភូត ក៏ប៉ុន្តែ ដោយសារតែនៅប្រទេសកម្ពុជា ប្រព័ន្ធនៃលិខិតយថាភូតនៅពុំទាន់ត្រូវបានប្រើយ៉ាងទូលំទូលាយនៅឡើយ ទើបមាត្រានេះចែងដោយមានខ្លឹមសាររាប់បញ្ចូលទាំងការទទួលស្គាល់តាមមតកសាសន៍ដោយលិខិតឯកជនដែរ ដោយដូចគ្នានឹងកថាខណ្ឌទី ២ នៃមាត្រា ៧៨១ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ម្យ៉ាងទៀត នីតិវិធីក្នុងការទទួលស្គាល់កូនដោយផ្អែកលើមតកសាសន៍ ត្រូវធ្វើឡើងដោយអ្នកប្រតិបត្តិមតកសាសន៍ ។

**មាត្រា ៩៩៨.-** អានុភាពនៃការចុះកំណើតនៅក្នុងសៀវភៅកំណើត និង ការទទួលស្គាល់

បើបុគ្គលណាម្នាក់បានសុំចុះកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬ ផ្តិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថាបានទទួលស្គាល់កូននោះ នៅពេលដែលបានសុំចុះកំណើត ។

(កំណត់)

ប្រសិនបើបុរសណាម្នាក់បានអនុវត្តនូវនីតិវិធីតាមលំដាប់លំដោយដូចដែលបានចែងក្នុងមាត្រានេះ ក្នុងឋានៈជាឪពុករបស់កូន ត្រូវចាត់ទុកថា បុរសនោះបានទទួលស្គាល់កូន ដោយពុំចាំបាច់ជូនដំណឹងអំពីការទទួលស្គាល់ជាថ្មីម្តងទៀតទេ ។

ទោះបីជាមានមាត្រា ២៣ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានហើយក៏ដោយ ក៏ក្រមនេះបានបញ្ញត្តថា មាតុភាពត្រូវបាន បង្កើតឡើង ដោយយោងលើហេតុការណ៍ជាក់ស្តែងនៃកំណើតរបស់កូនដែរ ហេតុដូច្នេះ មាត្រានេះបញ្ញត្តពាក់ព័ន្ធតែជាមួយនឹងឪពុកប៉ុណ្ណោះ ។

**មាត្រា ៩៩៩.-** អានុភាពប្រតិសកម្មនៃការទទួលស្គាល់

ការទទួលស្គាល់កូន ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ ការទទួលស្គាល់ ពុំអាចបំពានសិទ្ធិដែលតតិយជនបានធ្វើលទ្ធកម្មរួចហើយឡើយ ។

(កំណត់)

បញ្ញត្តិនៃមាត្រានេះមានន័យថា ឧទាហរណ៍ ប្រសិនបើឪពុកទទួលស្គាល់កូនអាយុ ១០ ឆ្នាំ ម្នាក់ បិតុភាពរវាងឪពុក និង កូននោះ ត្រូវចាត់ទុកថា មានចាប់តាំងពីពេលកំណើតរបស់កូនមក ដោយមានលក្ខណៈប្រតិសកម្ម ។ អានុភាពជាក់លាក់មានដូចជា ទោះបីជាឪពុកទទួលមរណភាពមុនពេលមានការទទួលស្គាល់ (កថាខណ្ឌទី ៥ នៃមាត្រា ១០០១) ក៏ដោយ ក៏ជាលទ្ធផលនៃអានុភាពប្រតិសកម្មនៃការទទួលស្គាល់ កូននោះត្រូវក្លាយជាសន្តតិជនរបស់ឪពុកដែរ ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលមានបុគ្គលណាម្នាក់បានផ្គត់ផ្គង់កូននោះ នៅក្នុងអំឡុងពេលមុនការទទួលស្គាល់ដោយឪពុក ទោះបីជាបុគ្គលនោះគ្មានករណីយកិច្ចសោះដូច្នេះក៏ដោយ បញ្ហានៃការទាមទារឱ្យសងមកវិញនូវសេចក្តីចម្រើនដោយឥតហេតុនឹងកើតឡើង ចំពោះទ្រព្យសម្បត្តិដែលបានប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់ ដោយសារឪពុកដែលបានទទួលស្គាល់កូន ត្រូវផ្គត់ផ្គង់កូននោះ ក្នុងអំឡុងពេលនោះ ។ ករណីដែលកូនត្រូវបានទទួលស្គាល់នៅក្រោយការបែងចែកមតិក គឺជាបញ្ហាទាក់ទងនឹងមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមតិក) ក៏ប៉ុន្តែ ក្នុងករណីដែលដីដែលជាមតិករបស់ឪពុកត្រូវបានលក់ទៅឱ្យតតិយជនរួចហើយ តាមលទ្ធផលនៃការបែងចែកមតិក នោះកូនដែលត្រូវបានទទួលស្គាល់ មិនអាចទាមទារឱ្យតតិយជននោះប្រគល់ដីឱ្យខ្លួនវិញបានទេ ។ ជាឧទាហរណ៍នៃនីតិកម្ម សូមមើលមាត្រា ៧៨៤ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

**មាត្រា ១០០០.-** ការហាមឃាត់មិនឱ្យដកការទទួលស្គាល់ចេញ

ឪពុកដែលបានទទួលស្គាល់កូនហើយ ពុំអាចលុបចោលការទទួលស្គាល់នោះបានឡើយ ។

(កំណត់)

ការទទួលស្គាល់គឺជាសកម្មភាពដែលឪពុកទទួលស្គាល់កូនដោយផ្អែកលើអត្ថិភាពនៃបិតុភាពជាសត្យានុម័ត ឬ អាចនិយាយម្យ៉ាងទៀតបានថា ដោយផ្អែកលើទំនាក់ទំនងលោហិតរវាងឪពុក និង កូន ។ ដោយហេតុនេះ នៅពេលដែលឪពុកទទួលស្គាល់កូនហើយ ហើយដែលការទទួលស្គាល់នោះស្របគ្នាទៅនឹងទំនាក់ទំនងលោហិតពិតប្រាកដ ពុំចាំបាច់ទទួលស្គាល់

ការទាមទារលុបចោលដោយបុគ្គលដែលបានទទួលស្គាល់នោះទេ ទោះបីជាការទទួលស្គាល់នោះត្រូវបានធ្វើឡើងដោយការគំរាម (មាត្រា ៣៥០ នៃក្រមនេះ) ជាអាទិ៍ ក៏ដោយ ។ម្យ៉ាងទៀត ក្នុងករណីដែលបុគ្គលណាម្នាក់បានទទួលស្គាល់ដោយដឹងថា គ្មានបិតុភាពជាសត្យានុម័ត ឬ ក្នុងករណីដែលបានបញ្ជាក់អំពីភាពគ្មានបិតុភាពជាសត្យានុម័ត នៅក្រោយពេលដែលបានទទួលស្គាល់ ការបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពនោះ ត្រូវធ្វើតាមរយៈបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ១០០២ នៃក្រមនេះ ។ សម្រាប់ជាសេចក្ដីយោង សូមមើលមាត្រា ៣៣៨ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ៧៨៥ នៃក្រមប្បវេណីជប៉ុន ។

**មាត្រា ១០០១.-** បណ្ដឹងទាមទារឱ្យទទួលស្គាល់

១-កូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ។ ប៉ុន្តែ កូនដែលមិនបានយល់ព្រម តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៩៦ (ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព) នៃក្រមនេះ ពុំអាចទាមទារឱ្យទទួលស្គាល់បានឡើយ ។

២-ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាឪពុក ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនា គិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុក នៅក្រោយមរណភាពរបស់ឪពុក ។

៦-បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នក

តំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ ជំនួសជនទាំងនោះបាន ។

(កំណត់)

បណ្តឹងទាមទារឱ្យទទួលស្គាល់ គឺជារបបដែលអនុញ្ញាតឱ្យកូនដាក់ពាក្យបណ្តឹងចំពោះឪពុកដែលមិនព្រមទទួលស្គាល់កូននោះ ហើយឱ្យមានការទទួលស្គាល់ដោយបង្ខំ តាមសាលក្រម ។ របបនេះសមស្របទៅនឹងមាត្រា ៩៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ មានន័យថា បណ្តឹងទាមទារឱ្យទទួលស្គាល់ មិនចាំបាច់ត្រូវបានអនុញ្ញាតទេ ចំពោះករណីដូចជាឪពុកមានបំណងទទួលស្គាល់ដោយស្ម័គ្រចិត្ត តែកូនដែលជានីតិជន ឬ បច្ឆាញាតិជានីតិជនរបស់កូនដែលបានទទួលមរណភាព បានបដិសេធមិនយល់ព្រមចំពោះការទទួលស្គាល់នោះរួចហើយ ពីព្រោះករណីនេះមិនខុសគ្នាអ្វីពីការដែលមានការលះបង់ចោលសិទ្ធិទទួលបានការទទួលស្គាល់នោះទេ ។ កថាខណ្ឌទី ២ ទទួលស្គាល់បណ្តឹងទាមទារឱ្យទទួលស្គាល់ដោយបច្ឆាញាតិផ្ទាល់ ក្នុងករណីដែលកូនដែលត្រូវទទួលការទទួលស្គាល់នោះ បានទទួលមរណភាព ហើយកូននោះមានបច្ឆាញាតិផ្ទាល់ ។ បញ្ញត្តិនេះស្របទៅនឹងកថាខណ្ឌទី ២ នៃមាត្រា ៩៥៦ នៃក្រមនេះ ។ កថាខណ្ឌទី ៣ កម្រិតចំពោះអំឡុងពេលដែលអាចដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បាន ។ ចំពោះអំឡុងពេលនេះ មានករណីនីតិកម្មផ្សេងៗ ។ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង ជប៉ុនពុំបានកម្រិតអំឡុងពេលសម្រាប់ការដាក់ពាក្យបណ្តឹងនៅពេលឪពុកនៅរស់ទេ ក៏ប៉ុន្តែ នៅប្រទេសបារាំងវិញ មាត្រា ៣៤០-៤ នៃក្រមរដ្ឋប្បវេណីបារាំង ជាគោលការណ៍ កម្រិតអំឡុងពេល ២ ឆ្នាំ ចាប់ពីកំណើតរបស់កូន ។ ទោះបីយ៉ាងណាក៏ដោយ គ្មានភាពចាំបាច់ក្នុងការទទួលស្គាល់នូវបណ្តឹងទាមទាឱ្យទទួលស្គាល់ទេ ក្នុងករណីដែលកូនបានដឹងអំពីឪពុកយូរមកហើយ តែមិនបានទាមទារឱ្យទទួលស្គាល់ ។ម្យ៉ាងវិញទៀត ប្រសិនបើកំណត់ថា x ឆ្នាំ បន្ទាប់ពីកំណើតរបស់កូន ឬ ក៏ x ឆ្នាំ បន្ទាប់ពីកូនក្លាយជានីតិជនដូច្នេះ ក្នុងករណីដែលកូនមិនដឹងអំពីឪពុក ហើយមិនអាចទាមទារឱ្យទទួលស្គាល់បានទេ បណ្តឹងទាមទារឱ្យទទួលស្គាល់របស់កូននោះ នឹងក្លាយទៅជាមិនត្រឹមត្រូវតាមច្បាប់ ។ ហេតុដូច្នេះ ដោយយកផ្លូវកណ្តាល ទើបមាត្រានេះឱ្យមានការកម្រិតអំឡុងពេលដាក់ពាក្យបណ្តឹង "ក្នុងអំឡុងពេល ១ ឆ្នាំ ដោយគិតចាប់ពីពេលបានដឹងថាជាឪពុក" ។ កថាខណ្ឌទី ៥ គឺជាការកម្រិតអំឡុងពេលដាក់ពាក្យបណ្តឹង ក្នុងករណីដែលឪពុកទទួលមរណភាពរួចហើយ ។ ចំពោះនីតិកម្មនៃប្រទេសដទៃទៀត កថាខណ្ឌទី ២ នៃមាត្រា ១៦០០e នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ពុំមានការកម្រិតចំពោះអំឡុងពេលទេ ប៉ុន្តែ វាក្យខណ្ឌទី ២ នៃមាត្រា ៧៨៧ នៃក្រមរដ្ឋប្បវេណីជប៉ុនចែងកម្រិតអំឡុងពេល ៣ ឆ្នាំ ក្រោយថ្ងៃទទួលមរណភាព ។ ប្រសិនបើឪពុកទទួលមរណភាព ការចិញ្ចឹមកូនដោយឪពុកនោះ មិនអាចធ្វើបានឡើយ ហេតុដូច្នេះ ផលប្រយោជន៍ជាក់ស្តែងនៃការទទួលយកនោះគ្មានអ្វីក្រៅពីសន្តតិកម្មនៃមតិករបស់ឪពុកនោះទេ ។ ក៏ប៉ុន្តែ ការអនុញ្ញាតឱ្យមានការទទួលស្គាល់ក្រោយមរណភាព នៅក្រោយពេលដែលអំឡុងពេលយូរឆ្នាំបានកន្លងផុត បន្ទាប់ពីសន្តតិកម្មបានចាប់ផ្តើមដោយសារមរណភាពរបស់ឪពុក នឹងបង្កឱ្យស្ថិរភាពនៃទំនាក់ទំនងសង្គមបែកបាក់ ។ ដោយយោងលើហេតុផលទាំងនេះ តាមរយៈការពិភាក្សា អំឡុងពេលនៃការដាក់ពាក្យបណ្តឹងត្រូវបានកំណត់យក ១ ឆ្នាំ ក្រោយ

មរណភាពរបស់ឪពុក ។ បណ្តឹងទាមទារឱ្យទទួលស្គាល់ជាបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលមានកូន ឬ បច្ឆាញាតិផ្ទាល់នៃកូនជាដើមចោទ និង មានឪពុកជាចុងចម្លើយ ក៏ប៉ុន្តែ កថាខណ្ឌទី ៦ ទទួលស្គាល់ការតំណាងក្នុងបណ្តឹងដោយអ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ របស់បច្ឆាញាតិផ្ទាល់នោះ ។ នៅក្នុងស្ថានភាពជាក់ស្តែង ភាគច្រើនម្តាយជាអ្នកដាក់ពាក្យប្តឹង នៅពេលដែលកូនជាអនីតិជននៅឡើយ ។

## កថាភាគទី ៤ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

(កំណត់)

បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព គឺជានីតិវិធីក្នុងការទាមទារទៅតុលាការឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព ក្នុងករណីដែលបិតុភាព ឬ មាតុភាពត្រូវបានបង្កើតឡើងដោយផ្ទុយនឹងការពិតជាក់ស្តែង ។ បញ្ញត្តិចាប់ពីមាត្រា ៩៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ បានបញ្ញត្តអំពីការស្វែងរកបិតុភាព ឬ មាតុភាព ប៉ុន្តែពុំបានចែងអំពីនីតិវិធីបដិសេធមាតុភាព ឬ បិតុភាពដែលផ្ទុយនឹងការពិតទេ ។ ដោយសារតែកូនមានសិទ្ធិទាមទារឱ្យមាននូវបុត្តភាពពិតប្រាកដ អត្ថិភាពនៃបុត្តភាពដែលផ្ទុយនឹងការពិតគឺជាការបំពានសិទ្ធិនោះ ។ម្យ៉ាងវិញទៀត ដោយសារតែមានករណីដែលនត្ថិភាពនៃទំនាក់ទំនងលោហិតរវាងឪពុក និង កូន បានស្តែងចេញមក ក្រោយពេលដែលមានការទទួលស្គាល់ដោយស្ម័គ្រចិត្តរួចហើយ ដូច្នេះ ទើបមានភាពចាំបាច់ខ្លាំងណាស់ក្នុងការបដិសេធនូវបុត្តភាពដែលផ្ទុយនឹងការពិតនេះ ។ ដោយសារបញ្ហាដូចគ្នានេះ ត្រូវបានពិចារណាចំពោះក្រមរដ្ឋប្បវេណីជប៉ុនដែរ តាមរយៈការពិភាក្សាដោយក្រុមការងារ បញ្ញត្តិចាប់ពីមាត្រា ១០០២ ត្រូវបានបង្កើតឡើង ។

**មាត្រា ១០០២.-** បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

១-កូន អាចដាក់ពាក្យបណ្តឹងទៅតុលាការ ឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាព ឬ មាតុភាព ចំពោះជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ ឬ ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាគ្មានហេតុដែលបានសម្រាលក៏ដោយ ។

២-ជនដែលត្រូវបានចុះជាឪពុកនៅក្នុងសៀវភៅកំណើត ទោះជាមិនបានទទួលការសន្មតថាជាឪពុកក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាពជាមួយកូនបាន ។

៣-ជនដែលត្រូវបានចុះជាម្តាយនៅក្នុងសៀវភៅកំណើត ទោះជាមិនបានសម្រាលកូននោះក៏ដោយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃមាតុភាពជាមួយកូនបាន ។

៤-បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ពុំអាចដាក់បានឡើយ ប្រសិនបើបិតុភាព ឬ មាតុភាពតាមផ្លូវច្បាប់ កើតឡើងដោយចេតនា ឬកំហុសធ្ងន់ធ្ងររបស់ជនដែលត្រូវបានចុះជាឪពុក ឬ ម្ដាយ នៅក្នុងសៀវភៅ ឬ បើអំឡុងពេល ២០ (ម្ភៃ) ឆ្នាំ បានកន្លងផុត គិតចាប់ពីថ្ងៃកំណើតរបស់កូន ឬ ថ្ងៃដែលអានុភាពនៃការទទួលស្គាល់ បានកើតឡើង ។

៥-ប្រសិនបើកូនជាអនីតិជន ឪពុក ឬ ម្ដាយ ដែលមិនមែនជាភាគីម្ខាងទៀតនៃបណ្ដឹង ត្រូវធ្វើជាតំណាងឱ្យកូន ។ បើគ្មានឪពុកម្ដាយ បើឪពុកម្ដាយមិនអាចធ្វើជាតំណាងបាន ឬ បើបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាពត្រូវបានធ្វើឡើងចំពោះឪពុកម្ដាយទាំងសងខាង ជាភាគីម្ខាងទៀតនៃបណ្ដឹង តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស ។

(កំណត់)

កថាខណ្ឌទី ១ : ក្នុងករណីដែលបិតុភាពត្រូវបានសន្មត វិធីដែលអាចបដិសេធបិតុភាពនោះបាន គឺបណ្ដឹងបដិសេធបិតុភាព តាមមាត្រា ៨៨៩ នៃក្រមនេះ ។ កថាខណ្ឌនេះបញ្ញត្តឡើង ដើម្បីឱ្យកូនអាចធ្វើការទាមទារឱ្យមានការបញ្ជាក់អំពីនត្ថិភាពនៃបិតុភាព ឬ មាតុភាព ចំពោះករណីដែលគ្មានអត្ថិភាពនៃមូលដ្ឋាននៃបុត្តភាពតាមផ្លូវច្បាប់ ដែលមានឧទាហរណ៍ដូចជា (១) បុរសម្នាក់ដែលនៅជាមួយម្ដាយរបស់កូន និង ដែលមិនមែនជាឪពុករបស់កូន បានដាក់ពាក្យសុំចុះសៀវភៅកំណើតកូននៅការិយាល័យអត្រានុកូលដ្ឋាន ក្នុងនាមជាអ្នករស់នៅជាមួយ ហើយក៏ត្រូវបានចុះក្នុងសៀវភៅថាជាឪពុករបស់កូននោះ (២) ការទទួលស្គាល់ដោយក្លែងក្លាយ ដែលបុរសម្នាក់បានទទួលស្គាល់កូនម្នាក់ ទោះបីជាគ្មានទំនាក់ទំនងលោហិតនឹងគ្នាក៏ដោយ ឬ (៣) ស្ត្រីម្នាក់ធ្វើការសុំចុះសៀវភៅកំណើតកូនដោយក្លែងក្លាយ ដោយអះអាងថាគាត់ជាអ្នកបាន សម្រាលកូននោះដែលតាមពិតទៅគាត់មិនបានសម្រាលកូននោះទេ តែជាកូនដែលស្ត្រីផ្សេងបានសម្រាល ។

កថាខណ្ឌទី ២ : កថាខណ្ឌនេះអនុញ្ញាតឱ្យបុរសដែលបានក្លាយទៅជាឪពុកដោយសារការទទួលស្គាល់ក្លែងក្លាយទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបិតុភាព ។ មានន័យដូចគ្នានឹងការទាមទារពីសំណាក់ឪពុកឱ្យចាត់ទុកជាមោឃៈនូវការទទួលស្គាល់ដែលខ្លួនបានធ្វើដែរ ។

កថាខណ្ឌទី ៣ : មាតុភាពមិនត្រូវកើតឡើងទេ ប្រសិនបើគ្មានអង្គហេតុនៃកំណើតកូន ។ បញ្ញត្តិនេះអនុញ្ញាតឱ្យបុគ្គលដែលបានក្លាយជាម្ដាយដោយសារអង្គហេតុក្លែងក្លាយអំពីកំណើតកូន អាចធ្វើការទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃមាតុភាពបាន ។

កថាខណ្ឌទី ៤ : ជាទូទៅ កូនមិនពាក់ព័ន្ធជាមួយនឹងការបង្កើតមាតុភាព និង បិតុភាពក្លែងក្លាយ ដូចបានចែងក្នុងកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ ទេ ។ ហេតុដូច្នេះ វាជាស្ថានភាពមួយធ្ងន់ធ្ងរណាស់សម្រាប់កូន នៅពេលដែល

បុត្តភាពក្លាយទៅជានត្ថិភាព ក្រោយពេលកូននោះបានជឿជាក់អស់រយៈពេលជាយូរមកហើយថា បិតុភាព ឬ មាតុភាពក្លែងក្លាយនោះជាការពិត ។ ដោយហេតុនេះបានជាពាក់ព័ន្ធជាមួយនឹងបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាពដែលធ្វើឡើងដោយឪពុកម្ដាយ លទ្ធភាពដែលអាចប្ដឹងបាននោះត្រូវកម្រិតឱ្យតឹងរ៉ឹងបំផុត ។

**មាត្រា ១០០៣.-** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព

ការបញ្ជាក់នត្ថិភាពនៃបុត្តភាព ត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

(កំណត់)

មាត្រានេះមានខ្លឹមសារដូចគ្នានឹងខ្លឹមសារនៃមាត្រា ៩៩៥ (អានុភាពប្រតិសកម្មនៃការទទួលស្គាល់) នៃក្រមនេះដែរ ។

## កថាភាគទី ៥ បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

(កំណត់)

មាត្រា ៩៨៧ (មាតុភាព) នៃក្រមនេះ បានចែងថា ស្ត្រីដែលផ្ដល់កំណើតឱ្យកូនជាម្ដាយរបស់កូន ។ ក៏ប៉ុន្តែ សម្រាប់ស្ត្រីខ្លះ ទោះបីជាស្ត្រីនោះបានផ្ដល់កំណើតឱ្យកូនក៏ដោយ ក៏មាតុភាពរបស់កូននោះមិនត្រូវបានបង្កើតឡើងដែរក្នុងករណីខ្លះ ។ ឧទាហរណ៍ដែលអាចគិតឃើញបាននោះ មានដូចជាករណីដែលកូនម្នាក់ត្រូវបានបោះបង់ចោល ហើយមិនដឹងអំពីឪពុកម្ដាយរបស់កូននោះ តែក្រោយមក បានដឹងអំពីអត្តសញ្ញាណរបស់ម្ដាយ ។ កូនអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពបាន ដោយយកម្ដាយនោះជាភាគីម្ខាងទៀតនៃបណ្ដឹង ។ ម្យ៉ាងទៀត នៅក្រោយពេលដែលដឹងអំពីឪពុកវិញ កូនអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ។ ឧទាហរណ៍មួយទៀតដែលអាចគិតឃើញបានដែរ មានករណីដែលយកកូនច្រឡំនៅទារកដ្ឋាននៅក្នុងមន្ទីរពេទ្យ ហើយក្រោយមកទើបដឹង ។

**មាត្រា ១០០៤.-** បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីកូន

១-កូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះស្ត្រីដែលបានបង្កើតខ្លួនបាន ។

២-ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពី

ពេលដែលបានដឹងថាជាម្តាយ ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលបានដឹងថាជាម្តាយ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនា ដោយគិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ម្តាយ ប្រសិនបើបានដឹងថាជាម្តាយ នៅក្រោយមរណភាពរបស់ម្តាយ ។

៦-បណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អត្ថិភាពនៃមាតុភាព ជំនួសជនទាំងនោះបាន ។

(កំណត់)

ជាមូលដ្ឋាន បញ្ញត្តិនេះមានខ្លឹមសារដូចគ្នានឹងបញ្ញត្តិដែលចែងអំពីការទទួលស្គាល់ដោយបង្ខំចំពោះឪពុក ។

**មាត្រា ១០០៥.-** បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ពីម្តាយ

១-ម្តាយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ចំពោះកូនដែលខ្លួនបានបង្កើតបាន ។

២-ម្តាយ អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនដែលបានទទួលមរណភាពបាន តែក្នុងករណីដែលកូននោះមានបច្ឆាញាតិផ្ទាល់ ។

៣-ម្តាយ ត្រូវដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលខ្លួនបានដឹងថាជាកូន ។

៤-ម្តាយ អាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់កូន ប្រសិនបើបានដឹងថាជាកូន នៅក្រោយមរណភាពរបស់កូន ។

៥-ប្រសិនបើម្តាយជាជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌ ទី ៣ និង ទី ៤ ខាងលើនេះ បានកន្លងផុត អំឡុងពេលនៃកថាខណ្ឌទី ៣ និង ទី ៤ ខាងលើនេះ ត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៦-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូន ដែលជាភាគីម្ខាងនៃបណ្តឹងជានីតិជន បើគ្មានការយល់ព្រមពីកូន ឬ បច្ឆាញាតិផ្ទាល់នោះទេ ម្តាយមិនអាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បានឡើយ ។

៧-ទោះបីជាក្នុងករណីដែលអង្គហេតុនៃការបង្កើតកូន ត្រូវបានបញ្ជាក់ក៏ដោយ ប្រសិនបើការបញ្ជាក់មាតុភាព ផ្ទុយនឹងផលប្រយោជន៍របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ តុលាការអាចលើកចោលបណ្តឹងរបស់ម្តាយបាន ។

(កំណត់)

កថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៦ មានខ្លឹមសារដូចគ្នានឹងបញ្ញត្តិស្តីពីការទទួលស្គាល់ ។ កថាខណ្ឌទី ៧ មានគោលបំណងដាក់កម្រិតចំពោះការបង្កើតមាតុភាព ដូចគ្នាទៅនឹងការដាក់កម្រិតទៅលើការទទួលស្គាល់ដោយស្ម័គ្រចិត្តពីឪពុក ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ។ ជាឧទាហរណ៍ ក្នុងករណីដែលម្តាយម្នាក់បានបោះបង់កូនចោល ហើយក្រោយមកនៅពេលដែលកូនធំ ម្តាយបានដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព ក្នុងគោលបំណងស្វែងរកការផ្គត់ផ្គង់ពីកូនដូច្នេះ ទោះបីជាអត្ថិភាពនៃទំនាក់ទំនងលោហិតត្រូវបានបញ្ជាក់ច្បាស់តាមរយៈភស្តុតាងក៏ដោយ ក៏តុលាការអាចច្រានចោលការទាមទារលើកបណ្តឹងនោះចោលបានដែរ ។

**មាត្រា ១០០៦.-** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

(កំណត់)

មាត្រានេះមានខ្លឹមសារដូចគ្នាទៅនឹងខ្លឹមសារនៃមាត្រា ៩៩៩ (អានុភាពប្រតិសកម្មនៃការទទួលស្គាល់) និង មាត្រា ១០០៣ (អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព) នៃក្រមនេះដែរ ។

## ផ្នែកទី ២ សុំកូន

### កថាភាគទី ១ សុំកូនពេញលេញ

**មាត្រា ១០០៧.-** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្ដាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបាន ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីសុំកូនពេញលេញដែលកើតឡើងតាមសេចក្ដីសម្រេចរបស់តុលាការ ក្រោមល័ក្ខខ័ណ្ឌយ៉ាងតឹងរ៉ឹងដែលតម្រូវឱ្យមានការពាក់ព័ន្ធពីតុលាការ ដោយខុសពីសុំកូនធម្មតាដែលជាសុំកូនតាមទម្រង់កិច្ចសន្យា និង កើតឡើងតាមការព្រមព្រៀងសុំកូន និង ការដាក់ពាក្យសុំចុះបញ្ជីសុំកូន ។ សុំកូនតាមទម្រង់កិច្ចសន្យា គឺជាករណីដែលភាគច្រើនទំនាក់ទំនងត្រូវបានចង ដោយពិចារណាទៅលើ "ស្ថានភាពរបស់មនុស្សពេញវ័យ" ប៉ុន្តែ ប្រព័ន្ធសុំកូនពេញលេញរបស់កម្ពុជា កំណត់យកអនីតិជនដែលមានស្ថានភាពគ្រួសារមិនអំណោយផលធ្វើជាកម្មវត្ថុ ដោយតម្រូវឱ្យមានការស្រាវជ្រាវ និង វិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់កុមារ ហើយសុំកូនប្រភេទនេះ មានគោលបំណងបង្កើតឡើងនូវទំនាក់ទំនងមួយដែលដូចគ្នាទៅនឹងទំនាក់ទំនងនៃឪពុកម្ដាយ និង កូនបង្កើតដូច្នេះដែរ ។

មាត្រា ៤ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប កំណត់ថា សុំកូនពេញលេញមានសុពលភាព តែក្នុងករណីដែលមានការប្រកាសរបស់អាជ្ញាធរតុលាការ ឬ អាជ្ញាធររដ្ឋបាលប៉ុណ្ណោះ ។ ដោយឡែកមាត្រា ២១ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ក៏ទាមទារឱ្យមានការពិចារណាជាអតិបរមាលើឧត្ដមប្រយោជន៍របស់កុមារ ដោយអាជ្ញាធរមានសមត្ថកិច្ចដែរ ។ សុំកូនពេញលេញ កើតឡើងតាមទម្រង់នៃការផ្ដាច់ទំនាក់ទំនងចាស់ ដោយសាលក្រមរបស់សាលាដំបូង (tribunal de grande instance) ក្នុងករណីប្រទេសបារាំង ឬ តុលាការអាណាព្យាបាល (Vormundshaftsgericht) ក្នុងករណីប្រទេសអាល្លឺម៉ង់ ដោយដីកាសម្រេចរបស់តុលាការអនីតិជន ក្នុងករណីនៃប្រទេសអ៊ីតាលី និង ដោយដីកាសម្រេចរបស់តុលាការក្នុងករណីសហរដ្ឋអាមេរិក និង ប្រទេសអង់គ្លេស ។ មាត្រា ៨១៧-២ នៃក្រមរដ្ឋប្បវេណីជប៉ុន កំណត់ថា សុំកូនពិសេស (ពេញលេញ) ត្រូវបង្កើតឡើងតាមសេចក្ដីសម្រេចរបស់តុលាការគ្រួសារ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប, មាត្រា ២១ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ, មាត្រា ៨១៧-២ នៃ

ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៣-១-២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៥២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣១៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា : "សុំកូនគឺជាកិច្ចសន្យាមួយយ៉ាងឧឡារិកដែលចងបុគ្គលពីរ គឺម្នាក់ ហៅថា ឪពុកសុំ ហើយម្នាក់ទៀត ហៅថា កូនសុំ ឱ្យមានចំណងទាក់ទងគ្នាដូចជាបុត្តភាពមានខាន់ស្លាដែរ" ។

មាត្រា ១០៨ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ : "សុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ហើយម្នាក់ទៀតហៅថា កូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នា ដូចជាបុត្តភាពមានខាន់ស្លា" ។

**មាត្រា ១០០៨.-** សុំកូនដោយសហការរវាងប្ដីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្ដី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្ដាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

(កំណត់)

សុំកូនពេញលេញគឺជាការផ្ដល់នូវគ្រួសារដែលមានឪពុកម្ដាយ និង មានលំនឹងគ្រប់គ្រាន់ ដល់កុមារដែលអភ័ព្វ ដូច្នេះ មាត្រានេះបានអនុម័តយកគោលការណ៍សុំកូនដោយសហការរវាងប្ដីប្រពន្ធ ។ ក៏ប៉ុន្តែ ក្នុងករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ពោលគឺករណីដែលអនាគតកូនចិញ្ចឹមត្រូវជាកូនចុងនោះ សុំកូនមិនចាំបាច់ត្រូវមានការសហការរវាងប្ដីប្រពន្ធទេ ។

មាត្រា ៦ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប ទុកលទ្ធភាពឱ្យច្បាប់របស់ប្រទេសនីមួយៗកំណត់ល័ក្ខខ័ណ្ឌថា ត្រូវទទួលស្គាល់សុំកូន តែចំពោះករណីដែលប្ដី និង ប្រពន្ធសុំដោយសហការគ្នាប៉ុណ្ណោះ ឬ ទទួលស្គាល់សុំកូនដោយសហព័ទ្ធតែម្ខាងដោយគ្រាន់តែទទួលការយល់ព្រមរបស់សហព័ទ្ធម្ខាងទៀត ។ តាមច្បាប់អង់គ្លេស ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ (កថាខណ្ឌទី ៣ នៃមាត្រា ១៧៤១) កថាខណ្ឌទី ១ មាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីបារាំង មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណីបែលហ្សិក ក្រមឯកភាពស្ដីពីសុំកូនរបស់អាមេរិក និង មាត្រា ៩៩ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់រុស្ស៊ី អ្នកនៅលីវក៏ត្រូវបានទទួលស្គាល់ថា មានលក្ខណសម្បត្តិជាឪពុក ឬ ម្ដាយចិញ្ចឹមដែរ ។ ផ្ទុយទៅវិញ ច្បាប់អ៊ីតាលី និង មាត្រា ៨១៧-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន អនុម័តយកគោលការណ៍សុំកូនដោយការសហការរវាងប្ដីប្រពន្ធ ។ ក្រៅពីនេះ ប្រទេសមួយចំនួនទៀតដែលកំណត់យកគោលការណ៍សុំកូនដោយសហការរវាងប្ដី និង ប្រពន្ធ មានដូចជាប្រទេសស្វីស ដាណឺម៉ាក និង ស៊ុយអែត ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៨ និង មាត្រា ៤៤ នៃច្បាប់ស្តីពីសុំកូនជាអនីតិជនរបស់អ៊ីតាលី

មាត្រា ៣២០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា : "ស្ត្រីគ្មានប្តីអាចសុំកូនគេចិញ្ចឹមបានដែរ" ។

## មាត្រា ១០០៩.- អាយុរបស់ឪពុកម្តាយចិញ្ចឹម

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

(កំណត់)

អាយុអប្បបរមារបស់ឪពុកម្តាយចិញ្ចឹមកំណត់ត្រឹម ២៥ ឆ្នាំ ហើយគម្លាតរវាងអាយុនៃឪពុកម្តាយចិញ្ចឹម និង អាយុរបស់កូនសុំ ដើម្បីឱ្យមើលទៅសមជាឪពុកម្តាយ និង កូន គឺ ២០ ឆ្នាំ ។

មាត្រានេះបានបញ្ញត្តនូវអាយុអប្បបរមារបស់ឪពុកម្តាយចិញ្ចឹម និង គម្លាតអាយុសមរម្យរវាងឪពុកម្តាយ និង កូន ដោយបានសិក្សាអំពីទំនៀមទម្លាប់របស់កម្ពុជា ដោយសារមានការចាំបាច់តម្រូវឱ្យមានភាពចាស់ទុំទាំងផ្នែកស្មារតី និង រាងកាយ ដើម្បីបីបាច់ថែរក្សាជាក់ស្តែងនូវទារក ឬ កូនក្មេង ។

កិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប កំណត់យកអាយុលើសពី ២១ ឆ្នាំ និង ក្រោម ៣៥ ឆ្នាំ ធ្វើជាបទដ្ឋាននីតិកម្មទាក់ទងនឹងអាយុអប្បបរមា ។ ប៉ុន្តែ នីតិកម្មនៃបណ្តាប្រទេសផ្សេងៗកំណត់យកខុសៗគ្នា ឧទាហរណ៍ដូចជាការកំណត់យកអាយុអប្បបរមា ១៨ ឆ្នាំ (ជាអាយុឈានដល់នីតិភាពដែលកំណត់ដោយរដ្ឋកាលីហ្វ័រញ៉ានៃសហរដ្ឋអាមេរិក ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសរុស្ស៊ី និង ច្បាប់ស្តីពីសុំកូនជាអនីតិជនរបស់ប្រទេសអ៊ីតាលី) អាយុលើសពី ២១ ឆ្នាំ (ច្បាប់ស្តីពីសុំកូនក្នុងតំបន់រដ្ឋធានីសហព័ន្ធអូស្ត្រាលី) អាយុលើសពី ២៥ ឆ្នាំ (មាត្រា ៨១៧-៤ នៃក្រមរដ្ឋប្បវេណីជប៉ុន កំណត់អាយុលើសពី ២៥ ឆ្នាំ ប៉ុន្តែ ដោយយោងតាមទំនាក់ទំនងជាមួយនឹងគោលការណ៍សុំកូនដោយសហការរវាងប្តីប្រពន្ធផងនោះ បើសហព័ទ្ធម្ខាងមានអាយុលើសពី ២៥ ឆ្នាំ សហព័ទ្ធម្ខាងទៀតមានអាយុលើសពី ២០ ឆ្នាំ គឺជាការគ្រប់គ្រាន់ រីឯក្រមរដ្ឋប្បវេណីបារាំង តម្រូវឱ្យមានអាយុលើសពី ២៨ ឆ្នាំ ហើយត្រូវមានគម្លាតអាយុលើសពី ១៥ ឆ្នាំឡើងទៅ ។ ចំណែកឯក្រមរដ្ឋប្បវេណីបែលហ្ស៊ិកក៏ទាមទារឱ្យមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងហោចណាស់ ១៥ ឆ្នាំ ។ ក្រៅពីនេះ នៅមានមាត្រា ១៧៤៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ច្បាប់ស្តីពីសុំកូនដាណឺម៉ាក ក្រមរដ្ឋប្បវេណីអេស្ប៉ាញ ជាអាទិ៍) ។ ម្យ៉ាងទៀត ដោយហេតុថា គោលបំណងនៃសុំកូនពេញលេញ គឺការបីបាច់ថែទាំកុមារ ដូចគ្នាទៅនឹងឪពុកម្តាយ និង កូនបង្កើត ដូច្នេះ ទើបមានប្រទេសជាច្រើនទាមទារឱ្យមានគម្លាតអាយុប្រហែលចាប់ពី ១០ ទៅ ១៨ ឆ្នាំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៤៣-១-១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៣៤៥ និង មាត្រា ៣៦៨ នៃក្រមរដ្ឋប្បវេណីបែលហ្ស៊ិក, មាត្រា ១៧៤៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣១៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា : "បុរសត្រូវមានអាយុជាង ២៥ ឆ្នាំ, ត្រូវបងកូនសុំ ២០ ឆ្នាំ យ៉ាងតិច និង ត្រូវគ្មានកូនសោះ ទើបអាចសុំកូនគេចិញ្ចឹមបាន" ។

មាត្រា ១០៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា "ឪពុក ឬ ម្តាយចិញ្ចឹម ត្រូវមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០ ឆ្នាំ ។ ឪពុក ឬ ម្តាយចិញ្ចឹមអាចជាពលរដ្ឋកម្ពុជា ឬ ជនបរទេស" ។

## មាត្រា ១០១០.- អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

(កំណត់)

ទាក់ទងនឹងចំនួនកូនសុំ យោងតាមទម្លាប់របស់កម្ពុជា សេចក្តីព្រាងដំបូងនៃក្រមនេះបានកំណត់ថា "(១) ឪពុកម្តាយចិញ្ចឹម អាចសុំកូនបាន ត្រឹម ២ (ពីរនាក់)" ប៉ុណ្ណោះ ។ សេចក្តីព្រាងនោះត្រូវបានរៀបចំឡើង ដោយមានមូលហេតុថា ដើម្បីឱ្យមានការបីបាច់ថែរក្សាកូនសុំឱ្យដូចជាកូនបង្កើត ចាំបាច់ត្រូវកម្រិតចំនួនកុមារដែលជាកូនសុំតាមស្មុំកូនពេញលេញ ។ ចំពោះស្មុំកូនអន្តរប្រទេស កូនសុំត្រូវបានកំណត់ត្រឹមមួយនាក់ប៉ុណ្ណោះ (អនុក្រឹត្យ លេខ ២៩ អនក្រ.បក ស្តីពីការសុំទារកកំព្រា ឬ កុមារកំព្រាទៅចិញ្ចឹមជាកូននៅបរទេស ខែ មីនា ឆ្នាំ ២០០១) ។ម្យ៉ាងវិញទៀត តាមរយៈការបង្កើតស្មុំកូន ដើម្បីកសាងទំនាក់ទំនងដែលយកឪពុកម្តាយចិញ្ចឹមមកជាមេបាតែមួយគូ ដូចគ្នាជាមួយនឹងទំនាក់ទំនងជាមួយកូនបង្កើត កូនសុំនោះគួរមានអាយុក្រោមអាយុចូលរៀន ។ ស្មុំកូនពេញលេញ គឺជាប្រព័ន្ធដែលផ្តល់ឪពុកម្តាយដល់កុមារតូចដែលត្រូវការបីបាច់ថែរក្សា ដូច្នេះ មាត្រានេះ ជាគោលការណ៍ កម្រិតតែចំពោះកុមារដែលមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ប៉ុណ្ណោះ ។

កថាខណ្ឌទី ១ មាត្រា ១២ នៃកិច្ចព្រមព្រៀងស្តីពីស្មុំកូនអឺរ៉ុប ហាមឃាត់ការកម្រិតដោយបញ្ញត្តិច្បាប់លើចំនួនកូនសុំដោយឪពុកម្តាយចិញ្ចឹមតែមួយ ហើយកថាខណ្ឌទី ២ នៃមាត្រាដដែលបញ្ញតថា "ជនដែលមានបំណងសុំកុមារធ្វើជាកូនសុំ មិនត្រូវហាមឃាត់ស្មុំកូននោះដោយបញ្ញត្តិច្បាប់ ដោយសំអាងថា ជននោះមានកូនខាន់ស្លារួច ឬ កូនខាន់ស្លានឹងកើតមកនៅពេលខាងមុខឡើយ" មានន័យថា ហាមឃាត់ផងដែរចំពោះការដាក់ល័ក្ខខ័ណ្ឌលើលក្ខណសម្បត្តិរបស់ឪពុកម្តាយចិញ្ចឹមថា ត្រូវតែគ្មានកូន ។ ក្នុងក្រមរដ្ឋប្បវេណីជប៉ុន ក៏មិនមានកម្រិតចំនួនកូនសុំដែរ ។ មាត្រា ៣១៧ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា កម្រិតចំនួនកូនសុំត្រឹមម្នាក់ប៉ុណ្ណោះ ប៉ុន្តែ មាត្រា ១១០ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ បានកំណត់យកចំនួនត្រឹម ២ នាក់ ។

មាត្រា ៣ នៃកិច្ចព្រមព្រៀងស្តីពីស្មុំកូនអឺរ៉ុប កំណត់ថា កូនសុំត្រូវជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ នៅលីវ ឬ មិនដែលរៀបអាពាហ៍ពិពាហ៍ ។ ចំពោះស្មុំកូនធម្មានុរូបកម្ម (ដែលក្លាយជាកូនមានខាន់ស្លា) នៅប្រទេសបារាំង ពីមុនកំណត់អាយុក្រោម ៥ ឆ្នាំ ប៉ុន្តែ បច្ចុប្បន្នគឺកំណត់អាយុក្រោម ១៥ ឆ្នាំ ។ ម្យ៉ាងទៀត ច្បាប់ស្តីពីស្មុំកូនជាអនីតិជនរបស់ប្រទេសអ៊ីតាលី ឆ្នាំ ១៩៨៣ កំណត់ថា កុមារដែលអាចក្លាយជាកម្មវត្ថុនៃស្មុំកូន ត្រូវតែជាអនីតិជន ប៉ុន្តែ

ពីមុន បានកំណត់យកអាយុក្រោម ៨ ឆ្នាំ ។ មាត្រា ៨១៧-៥ នៃក្រមរដ្ឋប្បវេណីជប៉ុន កំណត់ថា ជាគោលការណ៍ កូនសុំត្រូវមានអាយុក្រោម ៦ ឆ្នាំ នៅពេលដាក់ពាក្យសុំសុំកូន ប៉ុន្តែ ក្នុងករណីដែលកុមារមានអាយុក្រោម ៨ ឆ្នាំ ហើយកុមារនោះបានទទួលការបីបាច់រក្សាពីឪពុកម្តាយចិញ្ចឹមតាំងពីមុនពេលគ្រប់អាយុ ៦ ឆ្នាំ នេះ ជាករណីលើកលែង ទោះបីជាកុមារមានអាយុ ៨ ឆ្នាំ ក៏មិនមានបញ្ហាអ្វីដែរ ។ ច្បាប់ស្តីពីសុំកូនអន្តរប្រទេសរបស់កម្ពុជា ដែលត្រូវបាន តាក់តែងឡើងឆ្នាំ ២០០៩ កំណត់អាយុក្រោម ៨ ឆ្នាំ នៅពេលដាក់ពាក្យសុំសុំកូន (កថាខណ្ឌទី ២ នៃមាត្រា ៤) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៦៧ នៃក្រម រដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣១៧ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "គេអាចសុំបានតែកូនមួយនាក់ប៉ុណ្ណោះ, ប្រសិនបើកូនដែលសុំមក នោះវា ស្លាប់ទៅ ហើយគ្មានកូនទៀតទេ គេអាចសុំកូនមួយនាក់ទៀតបាន" ។

មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "កូនសុំនោះត្រូវមានអាយុតិចជាង ៨ ឆ្នាំ" ។

មាត្រា ១១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "គេអាចសុំកូនបានត្រឹម ២ នាក់ប៉ុណ្ណោះ ។ ប្រសិន បើកូនដែលសុំមកនោះ មានមួយណាស្លាប់ គេអាចសុំកូនមួយនាក់ទៀតបាន ។ កូនចិញ្ចឹមត្រូវមានអាយុតិចជាង ៨ ឆ្នាំ" ។

**មាត្រា ១០១១.-** ការយល់ព្រមរបស់ឪពុកម្តាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នក អាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្តាយនោះ មិនអាចបង្ហាញ ឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូនចោលដោយ គំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយ ជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

(កំណត់)

សុំកូនពេញលេញ គឺជាការផ្តាច់ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត និង មានគោលដៅយកកូនសុំនោះចូលទាំងស្រុង ក្នុងគ្រួសាររបស់ឪពុកម្តាយចិញ្ចឹម ដូច្នេះ ចាំបាច់ត្រូវតែមានការយល់ព្រមពីឪពុកម្តាយបង្កើតដែលមានទំនាក់ទំនងផល ប្រយោជន៍យ៉ាងជ្រាលជ្រៅជាមួយនឹងកុមារនោះ ។ ប៉ុន្តែ ក្នុងករណីដែលមានស្ថានភាពពិបាកនឹងទទួលការយល់ព្រមពី ឪពុកម្តាយបង្កើត ឬ ក្នុងករណីដែលការជំទាស់របស់ឪពុកម្តាយបង្កើតបំពានយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍កុមារដែល នឹងក្លាយជាកូនសុំនោះ ការយល់ព្រមពីឪពុកម្តាយបង្កើត មិនចាំបាច់ឡើយ ។

កថាខណ្ឌទី ១ មាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប បញ្ញត្តថា ចំពោះកូនមានខាន់ស្លា ចាំបាច់ត្រូវមាន

ការយល់ព្រមពីឪពុកម្តាយ ហើយចំពោះកូនឥតខាន់ស្លា ចាំបាច់ត្រូវមានការយល់ព្រមពីម្តាយ ហើយក្នុងករណីដែលគ្មានឪពុកម្តាយ ចាំបាច់ត្រូវមានការយល់ព្រមពីជនដែលអនុវត្តអំណាចមេបាជំនួស ឬ អ្នកអាណាព្យាបាល ឬ ស្ថាប័នដែលអាចជំនួសអ្នកទាំងនេះបាន ។ កថាខណ្ឌទី ៣ នៃមាត្រាដដែលចែងអនុញ្ញាតឱ្យមានការចែងក្នុងច្បាប់ថា មិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយចំពោះសុំកូនឡើយ ក្នុងករណីដែលឪពុកម្តាយត្រូវបានដកហូតអំណាចមេបា ឬ សិទ្ធិបីបាច់ថែរក្សាគ្រប់គ្រងកូន ។

ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ក៏ទាមទារឱ្យមានការយល់ព្រមពីឪពុកម្តាយដែរ (មាត្រា ១៧៤៩) ប៉ុន្តែ ក្នុងករណីដែលឪពុកម្តាយមិនអាចបង្ហាញឆន្ទៈបានជាបន្តឥតដាច់ ឬ ករណីដែលលំនៅឋានរបស់ឪពុកម្តាយមិនច្បាស់លាស់ មិនចាំបាច់មានការយល់ព្រមឡើយ ។ ក្រមរដ្ឋប្បវេណីបារាំងក៏បញ្ញត្តដែរថា ក្នុងករណីដែលសុខភាព និង ស្មារតីរបស់កុមារប្រឈមមុខនឹងគ្រោះថ្នាក់ ហើយឪពុកម្តាយមិនអើពើ ការមិនយល់ព្រមគឺជាការបំពានលើសិទ្ធិយល់ព្រម ដូច្នេះ ក៏មិនចាំបាច់តម្រូវឱ្យមានការយល់ព្រមដែរ (មាត្រា ៣៤៧ និង មាត្រា ៣៤៨-២) ។ មាត្រា ៨១៧-៦ នៃក្រមរដ្ឋប្បវេណីជប៉ុនទាមទារឱ្យមានការយល់ព្រមពីឪពុកម្តាយដើម្បីបង្កើតសុំកូន ហើយក៏ចែងលើកលែងនូវករណីដែលមិនចាំបាច់មានការយល់ព្រមដែរ ។

ម្យ៉ាងទៀត ប្រសិនបើកំណត់អាយុរបស់កូនដែលអាចត្រូវបានសុំបានខ្ពស់ (ដោយវិសោធនកម្មនៃមាត្រា ១១០០) នៅប្រទេសបារាំង ចាំបាច់ត្រូវមានការយល់ព្រមពីក្មេងដែលមានអាយុលើសពី ១៣ ឆ្នាំ (កថាខណ្ឌទី ៣ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង) រីឯរដ្ឋកាលីហ្វ័រញ៉ា តម្រូវឱ្យមានការយល់ព្រមពីក្មេងអាយុលើសពី ១២ ឆ្នាំ (មាត្រា ៨៦០២ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ហើយប្រទេសកម្ពុជាក៏ដូចគ្នាដែរ ទាក់ទងនឹងទស្សនៈដែលការពារសិទ្ធិបញ្ចេញទស្សនៈរបស់ក្មេង (មាត្រា ១២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ) ចាំបាច់ត្រូវមានវិធានការផ្សេងៗនានា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៤៨ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៤៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣២១ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "ឪពុក និង ម្តាយមានខាន់ស្លា ឬ ឥតខាន់ស្លានៃកូនដែលឱ្យគេសុំនោះ ឬ បើគ្មានឪពុកម្តាយទេ, ជនជាអាណាព្យាបាលនៃកូននោះត្រូវឱ្យសេចក្តីព្រមព្រៀងរបស់ខ្លួនក្នុងកិច្ចសន្យាសុំកូននោះ" ។

មាត្រា ១១២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "ដើម្បីឱ្យការសុំកូនសំរេចទៅបាន ត្រូវមានការព្រមព្រៀងពីឪពុកម្តាយ ឬ អ្នកអាណាព្យាបាលនៃកូនដែលសុំនោះ ។ បើជាទារកដែលគេបោះបង់ចោល ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំ ឬ សង្កាត់" ។

## មាត្រា ១០១២.- មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

ស្មុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាង

ខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីមូលដ្ឋានសារធាតុដើម្បីវិនិច្ឆ័យក្នុងករណីដែលតុលាការបង្កើតសុំកូន ។ ប្រសិនបើតុលាការយល់ឃើញថា មិនសមរម្យឱ្យឪពុកម្ដាយគ្រប់គ្រងថែរក្សាកូន ដូចជាករណីដែលឪពុកម្ដាយបាត់ខ្លួន ឬ មានវិបត្តិផ្នែករាងកាយដែលធ្វើឱ្យមានការពិបាកក្នុងការគ្រប់គ្រងថែរក្សាកុមារ ឬ ឪពុកម្ដាយដែលធ្វើបាប ឬ បោះបង់កូនចោល ហើយយល់ឃើញថា ដើម្បីផលប្រយោជន៍កុមារ ចាំបាច់ត្រូវតែបញ្ចប់ញាតិភាពជាមួយឪពុកម្ដាយនោះ ហើយបង្កើតសុំកូនជាមួយឪពុកម្ដាយចិញ្ចឹម ទើបតុលាការអាចសម្រេចឱ្យបង្កើតសុំកូនបាន ។

មាត្រា ៨ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប កំណត់ថា អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការប្រកាសសុំកូនបាន តែក្នុងករណីដែលបានជឿជាក់ថា សុំកូននោះនឹងធានាដល់ផលប្រយោជន៍របស់កុមារប៉ុណ្ណោះ ដោយសង្កត់ធ្ងន់ជាពិសេសថា តាមការប្រកាសសុំកូននេះ នឹងផ្ដល់ឱ្យកុមារនូវគ្រួសារដែលមានស្ថិរភាព និង ភាពសុខដុមរមនា ។ មាត្រា ២១ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ក៏បញ្ញត្តដែរថា ប្រព័ន្ធសុំកូនត្រូវធានាថា ឧត្ដមប្រយោជន៍របស់កុមារត្រូវស្ថិតក្នុងការពិចារណាខ្ពស់បំផុត ។ កថាខណ្ឌទី ១ មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណីបារាំង កថាខណ្ឌទី ១ មាត្រា ១៧៤១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីស្វីស ច្បាប់អង់គ្លេស និង កថាខណ្ឌ C មាត្រា ១៣ នៃក្រមឯកភាពស្ដីពីសុំកូនរបស់អាមេរិក ក៏ទាមទារឱ្យសុំកូនឆ្លើយតបដោយជាក់លាក់ទៅនឹងសុខុមាលភាពកុមារ និង ឧត្ដមប្រយោជន៍របស់កុមារដែរ ។

មាត្រានេះក៏យកលំនាំដូចគ្នាតាមមាត្រា ៨១៧-៧ នៃក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណីបារាំង មាត្រា ៧ មាត្រា ៨ និង មាត្រា ២៥ នៃច្បាប់ស្ដីពីសុំកូនជាអនីតិជនរបស់អ៊ីតាលីដែលចែងថា អាចបង្កើតសុំកូនបានចំពោះកូនដែលត្រូវបានបោះបង់ ដែលមិនអាចទទួលបានការបីបាច់ថែរក្សាឱ្យបានសមរម្យពីឪពុកម្ដាយ ឬ កុមារដែលត្រូវការពារជាចាំបាច់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៣-១ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ១ មាត្រា ១៧៤១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ២១ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ

## មាត្រា ១០១៣.- អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយ

ជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

(កំណត់)

មាត្រានេះបានបញ្ញត្តអំពីអំឡុងពេលកំណត់មួយនៃការសាកល្បងចិញ្ចឹម ដើម្បីពិនិត្យមើលជាក់ស្តែងថា តើឪពុកម្តាយចិញ្ចឹមមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងថែរក្សាកុមារដែរ ឬទេ ហើយតើអាចបង្កើតទំនាក់ទំនងល្អជាមួយកូនសុំដែរ ឬទេ និងថា តើមានភាពចុះសម្រុងគ្នារវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹមដែរ ឬយ៉ាងណា ។

មាត្រា ១៧ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប ចែងថា អាជ្ញាធរមានសមត្ថកិច្ចត្រូវពិនិត្យមើលស្ថានភាពគ្រប់គ្រងថែរក្សាកូនសុំដោយឪពុកម្តាយចិញ្ចឹមថា តើសុំកូនឆ្លើយតបនឹងផលប្រយោជន៍របស់កុមារដែរ ឬទេ ក្នុងអំឡុងពេលសមរម្យចាំបាច់ដើម្បីឱ្យអាចវាយតម្លៃបានគ្រប់គ្រាន់ ។ មាត្រា ៨១៧-៨ នៃក្រមរដ្ឋប្បវេណីជប៉ុន កថាខណ្ឌទី ១ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ១២ នៃក្រមឯកភាពស្តីពីសុំកូនរបស់អាមេរិក ជាដើម បានកំណត់អំឡុងពេលជាគោលការណ៍ ចំនួន ៦ ខែ ប៉ុន្តែ ប្រទេសអ៊ីតាលីកំណត់ ១ ឆ្នាំ រីឯមាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីស្វីស កំណត់ ២ ឆ្នាំ ហើយមាត្រា ១៧៤៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ កំណត់អំឡុងពេលសមរម្យ ។ ក៏ប៉ុន្តែ ប្រសិនបើមានកំណត់ហេតុនៃស្ថានភាពគ្រប់គ្រងថែរក្សាកុមារតាំងពីដើមមក នៅក្នុងមណ្ឌលពិគ្រោះស្តីពីកុមារ ជាអាទិ៍ ហើយតុលាការអាចយកឯកសារទាំងនោះមកធ្វើជាធនធានសម្រាប់ការវិនិច្ឆ័យបាន នោះតុលាការអាចប្រើប្រាស់ឯកសារបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ១ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៤៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ១០១៤.-** ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្តាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្តាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) នៃក្រមនេះ ។

(កំណត់)

របបសុំកូនពេញលេញមានគោលបំណងចិញ្ចឹមកុមារដែលបានសុំ ឱ្យដូចជាកូនបង្កើតក្នុងមជ្ឈដ្ឋានគ្រួសារដែលមានស្ថិរភាពល្អ ដូច្នេះ កូនសុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្តាយចិញ្ចឹម ។ បានសេចក្តីថា ការចូលជ្រៀតជ្រែក ឬ ការរំខានមិនសមស្របពីឪពុកម្តាយបង្កើត ដូចជា ការទាមទារយកកូនវិញ ឬ ការទាមទារចរចាជួបកូន

ជាដើម ត្រូវហាមឃាត់ ហើយអំពើតាមទំនើងដូចជាការទាមទារអាហារកាតព្វកិច្ចពីកូន នៅពេលដែលកូននោះពេញវ័យជាដើម ក៏ចាំបាច់ត្រូវដាក់ការរឹតត្បិតផងដែរ ។ ហេតុដូច្នេះ មាត្រានេះបានកំណត់ឱ្យបញ្ចប់ និង ផ្តាច់ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ តាមរយៈការបង្កើតសុំកូនពេញលេញ ។

ក៏ប៉ុន្តែ ក្នុងករណីដែលសហព័ទ្ធម្ខាងសុំកូនដែលជាកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត ដូចជាកូនសុំដែលជាកូនចុងការសុំកូនដោយសហព័ទ្ធតែម្ខាងជាការគ្រប់គ្រាន់ ហើយចំពោះការគ្រប់គ្រងថែរក្សាក្នុងនាមជាឪពុក ឬ ម្តាយបង្កើតរបស់សហព័ទ្ធម្ខាងទៀត មិនចាំបាច់ឱ្យមានការបញ្ចប់ទំនាក់ទំនងញាតិភាពជាមួយនឹងឪពុក ឬ ម្តាយបង្កើតនោះ និង ជាមួយញាតិលោហិតរបស់ឪពុក ឬ ម្តាយបង្កើតនោះឡើយ ។

កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ មាត្រា ១០ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប បានកំណត់ថា សុំកូនបង្កើតឱ្យមានទំនាក់ទំនងគតិយុត្តរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹម ដូចគ្នានឹងទំនាក់ទំនងរវាងឪពុកម្តាយ និង កូនមានខាន់ស្លាដែរ ហើយជាមួយគ្នានេះ ក៏រំលត់នូវទំនាក់ទំនងញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតផងដែរ ក៏ប៉ុន្តែនៅពេលដែលកូនសុំជាកូនមានខាន់ស្លា ឬ ឥតខាន់ស្លា ឬ កូនសុំរបស់សហព័ទ្ធម្ខាងទៀតរបស់ឪពុក ឬ ម្តាយចិញ្ចឹមបញ្ញត្តិច្បាប់អាចកំណត់ទុកជាមុនថា សហព័ទ្ធម្ខាងទៀតនោះ ត្រូវប្រកាន់ខ្ជាប់នូវសិទ្ធិ និង ករណីយកិច្ចរបស់ខ្លួនដែលមានចំពោះកូនសុំ ។ រាល់បណ្តាប្រទេសដែលអនុម័តយកសុំកូនពេញលេញ ឬ សុំកូនដោយផ្តាច់ទំនាក់ទំនង តែងតែមានបញ្ញត្តិប្រភេទនេះជានិច្ច (មាត្រា ៣៥៦ ក្រមរដ្ឋប្បវេណីបារាំង មាត្រា ១៧៥៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ២៦៧ នៃក្រមរដ្ឋប្បវេណីស្វីស ជាដើម) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៥៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ១០១៥.- អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ

ម្ដាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។

(កំណត់)

មាត្រានេះបញ្ញត្តថា កូនសុំត្រូវបានធ្វើឱ្យដូចជាកូនមានខាន់ស្លាទាំងស្រុង ក្នុងទំនាក់ទំនងរបស់កូនសុំជាមួយនឹងឪពុកម្ដាយចិញ្ចឹម ហើយមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើតដែរ ។ បានសេចក្ដីថា កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម (នាមត្រកូលរបស់ក្មេងនៅកម្ពុជា ជាទម្លាប់ គេអនុញ្ញាតឱ្យជ្រើសរើស) ហើយនៅពេលដែលកូនសុំជាអនីតិជន កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។ ដូចជាកូនបង្កើតដែរ កូនសុំក៏មានសិទ្ធិទទួលអាហារកាតព្វកិច្ច ឬ សន្តតិកម្មពីឪពុកម្ដាយចិញ្ចឹមដែរ ។ សុំកូនពេញលេញ គឺជាប្រព័ន្ធដែលមានបំណងគ្រប់គ្រងថែរក្សាកូនសុំ ដោយកក់ក្ដៅ ដូចជាកូនបង្កើត នៅក្នុងគ្រួសាររបស់ឪពុកម្ដាយចិញ្ចឹម ដូច្នេះ ឋានៈរបស់កូនសុំនោះត្រូវបានធានាឱ្យដូចជាកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម ។

កថាខណ្ឌទី ១ មាត្រា ១០ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប បញ្ញត្តថា សុំកូនផ្ដល់ចំពោះឪពុកម្ដាយចិញ្ចឹមនូវគ្រប់សិទ្ធិ និង ករណីយកិច្ចដែលឪពុកម្ដាយបង្កើតមានចំពោះកូនមានខាន់ស្លា ក្នុងទំនាក់ទំនងចំពោះកូនសុំ ហើយក៏ផ្ដល់ឱ្យកូនសុំនោះនូវគ្រប់សិទ្ធិ និង ករណីយកិច្ចដែលកូនមានខាន់ស្លាមានចំពោះឪពុកម្ដាយបង្កើត ក្នុងទំនាក់ទំនងរបស់កូនសុំនោះចំពោះឪពុកម្ដាយចិញ្ចឹមដែរ ។ សុំកូនពេញលេញ ក្នុងបណ្ដាប្រទេសដូចជា ប្រទេសអ៊ីតាលី អាល្លឺម៉ង់ បារាំង សហរដ្ឋអាមេរិក (មាត្រា ៨៦១៦ ដល់ មាត្រា ៨៦១៨ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ប្រទេសអង់គ្លេស និង ស្វីស ជាដើម សុទ្ធតែមានបញ្ញត្តិបែបនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨០៩ មាត្រា ៨១០ និង កថាខណ្ឌទី ២ មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៥ មាត្រា ៣៥៦ មាត្រា ៣៥៧ និង មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណីបារាំង

មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "សុំកូននេះមានអានុភាពឱ្យកូននោះ ឆ្លងពីភាពជាកូននៃគ្រួសារមានខាន់ស្លា ឬ ឥតខាន់ស្លាមួយ ទៅជាកូននៃគ្រួសាររបស់អ្នកសុំវិញ" ។

មាត្រា ៣២៦ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "កូនសុំត្រូវយកនាមត្រកូលនៃឪពុកសុំ, កូនសុំត្រូវមានកាតព្វកិច្ច និង ករណីយកិច្ច ចំពោះឪពុកសុំ និង គ្រួសាររបស់ឪពុកសុំ ដូចជាកូនបង្កើតដែរ" ។

មាត្រា ៣២៧ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "ឪពុកសុំត្រូវបីបាច់រក្សាកូនសុំ ដូចជាកូនខ្លួនបង្កើតដែរ" ។

មាត្រា ១១៤ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "កូនចិញ្ចឹមត្រូវយកនាមត្រកូលនៃអ្នកសុំ ហើយមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើត" ។

## មាត្រា ១០១៦.- ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ

តុលាការអាចកាត់កាល់ភាតីនៃស្មុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្តាយបង្កើត ឬតំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក- បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ- បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

ស្មុំកូនពេញលេញ មានបំណងផ្តល់នូវការគ្រប់គ្រងថែរក្សាដូចជាកូនបង្កើត ដូច្នេះ ជាគោលការណ៍ ការកាត់កាល់មិនត្រូវបានទទួលស្គាល់ឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលការបន្តទំនាក់ទំនងស្មុំកូនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍កុមារ ឬ ក៏ក្នុងករណីដែលអាចរំពឹងបាននូវការគ្រប់គ្រងថែរក្សាដោយគ្រប់គ្រាន់ដោយឪពុកម្តាយបង្កើត ជាករណីលើកលែង បញ្ញត្តិនេះទទួលស្គាល់ការរំលាយស្មុំកូនបាន ។

កថាខណ្ឌទី ១ មាត្រា ១៣ នៃកិច្ចព្រមព្រៀងស្តីពីស្មុំកូនអឺរ៉ុប កំណត់ថា ក្នុងអំឡុងពេលដែលកូនសុំមិនទាន់ដល់នីតិភាព ស្មុំកូនអាចត្រូវបាបលុបចោលបាន តាមការសម្រេចរបស់អាជ្ញាធរតុលាការ ឬ អាជ្ញាធររដ្ឋបាល តែក្នុងករណីដែលមានមូលហេតុធ្ងន់ធ្ងរប៉ុណ្ណោះ ។ បើមើលជាឧទាហរណ៍នៃបញ្ញត្តិច្បាប់របស់បណ្តាបស្ចឹមប្រទេសដែលមិនទទួលស្គាល់របបកាត់កាល់ មានដូចជាមាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណីបារាំង និង ច្បាប់ប្រទេសអង់គ្លេស ស្វីស អ៊ីតាលី និងស៊ុយអែត ជាដើម ។ ក៏ប៉ុន្តែ មាត្រា ១៧៦០ និង ១៧៦៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ១៨ និង មាត្រា ១៩ នៃច្បាប់ស្តីពីស្មុំកូនដាណឺម៉ាក និង មាត្រា ៨១៧-១០ នៃក្រមរដ្ឋប្បវេណីជប៉ុន ជាដើម បានទទួលស្គាល់ការកាត់កាល់ក្នុងករណីដែលមានស្ថានភាពជាកំណត់មួយ (ដូចជាករណីដែលសមស្របទៅនឹងផលប្រយោជន៍របស់កុមារ ឬ ករណីដែលមានការបំពានករណីយកិច្ចរបស់ឪពុកម្តាយចិញ្ចឹម ដូចជាការវាយធ្វើបាបដោយហិង្សាដោយឪពុកម្តាយចិញ្ចឹម ជាដើម) ។ នៅរដ្ឋកាលីហ្វ័រញ៉ា ការលុបចោលដីកាសម្រេចបង្កើតស្មុំកូនពេញលេញ ដោយយកវិបត្តិក្នុងអភិវឌ្ឍន៍តាំងពីមុនពេលស្មុំកូន ឬ វិបត្តិផ្នែកស្មារតី ជាដើម មកជាមូលហេតុ ត្រូវបានទទួលស្គាល់ ក្នុងអំឡុងពេល ៥ ឆ្នាំ ហើយរបបលុបចោលនេះមានលក្ខណៈសារធាតុជាការកាត់កាល់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-១០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៩ និង មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៦០ និង មាត្រា ១៧៦៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ១១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "តុលាការប្រជាជន អាចបដិសេធកិច្ចសន្យា (សុំកូន) បាន តាមពាក្យប្តឹងសុំរបស់កូនចិញ្ចឹម របស់ជនទាំងឡាយ ឬ របស់អង្គការផ្សេងៗ ដែលធ្វើឡើងដើម្បីផល ប្រយោជន៍របស់កូនចិញ្ចឹមនោះ" ។

## មាត្រា ១០១៧.- អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

(កំណត់)

មាត្រានេះអនុម័តយកទស្សនៈនៃការបង្កើតឡើងវិញដោយស្វ័យប្រវត្តិនូវញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត និង ញាតិភាពជាមួយញាតិលោហិតរបស់ឪពុកម្តាយបង្កើត ដែលត្រូវបានបញ្ចប់ដោយការបង្កើតសុំកូន នៅពេលដែលសុំកូនពេញលេញត្រូវបានរំលាយដោយការកាត់កាល់ ។

នៅក្នុងនីតិកម្មដែលទទួលស្គាល់ការកាត់កាល់ នៅមានការខ្វែងគំនិតគ្នាលើចំណុចថា តើញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត និង គ្រួសាររបស់ឪពុកម្តាយបង្កើតដែលបានបញ្ចប់ដោយការបង្កើតសុំកូន ត្រូវបានបង្កើតឡើងវិញ ដោយស្វ័យប្រវត្តិ ឬ យ៉ាងណានោះ ។ ប្រទេសជប៉ុន អាល្លឺម៉ង់ អូស្ត្រាលី និង រុស្សី ជាដើម ប្រកាន់យកទស្សនៈនៃការបង្កើតឡើងវិញដោយស្វ័យប្រវត្តិ ចំណែកឯប្រទេសដាណឺម៉ាកប្រកាន់យកជំហរផ្សេងៗខុសគ្នា អាស្រ័យទៅតាមអាយុរបស់កុមារ ឬ មូលហេតុនៃការកាត់កាល់ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-១១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៩ និង មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៤៦ និង មាត្រា ១៧៦៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ១០១៨.- ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃសុំកូនពេញលេញ

ប្រសិនបើបានបង្កើតសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីសុំកូនឡើយ ។

(កំណត់)

ក្នុងករណីដែលសុំកូនពេញលេញគឺជាការសង្គ្រោះចំពោះកុមារអភ័ព្វ ការបង្ហាញនូវអង្គហេតុនៃសុំកូន អាចបំពានភាពឯកជន ហើយផ្តល់បច្ច័យអាក្រក់ដល់ការរីកចម្រើនលូតលាស់ដ៏ល្អរបស់កុមារ ។ ម្យ៉ាងទៀត ការបង្ហាញដូច្នេះ

ក៏នាំឱ្យមានហានិភ័យ ដូចជាការមកជ្រៀតជ្រែកដោយគ្មានការរំពឹងទុកពីសំណាក់ឪពុកម្តាយបង្កើត ដែលធ្វើឱ្យស្ថានភាពគ្រួសារកូនសុំ មានភាពច្របូកច្របល់ ឬ មិនអាចរក្សាបាននូវបរិស្ថានរីកចម្រើនល្អូតលាស់ដែលមានលំនឹងសម្រាប់កុមារ ។ ដូច្នេះហើយ មាត្រានេះបានកំណត់ថា បញ្ជីអត្រានុកូលដ្ឋាន និង សំបុត្រកំណើតថ្មី របស់ស្មុំកូនដែលធ្វើឡើងដោយការបង្កើតស្មុំកូនពេញលេញ មិនត្រូវសរសេរអំពីឈ្មោះរបស់ឪពុកម្តាយបង្កើត ឬ ចំណុចស្តីពីស្មុំកូនឡើយ ហើយត្រូវចុះថាឪពុកម្តាយចិញ្ចឹម គឺជាឪពុកម្តាយបង្កើត ។

មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណីបារាំង បញ្ញត្តថា សាលក្រម ឬ សាលដីកាដែលប្រកាសបង្កើតស្មុំកូនពេញលេញត្រូវចុះនៅក្នុងបញ្ជីអត្រានុកូលដ្ឋាននៅកន្លែងកំណើតរបស់កូនសុំ ក្នុងអំឡុងពេល ១៥ ថ្ងៃ តាមពាក្យសុំរបស់ព្រះរាជអាជ្ញាដោយសរសេរនូវថ្ងៃ និង ម៉ោងកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយចិញ្ចឹម ជាអាទិ៍ ដោយមិនចុះអ្វីទាក់ទងនឹងឪពុកម្តាយបង្កើតឡើយ ហើយការចុះបញ្ជីនេះនឹងជំនួសឱ្យសំបុត្រកំណើតរបស់កូនសុំ ។ ក្នុងរដ្ឋកាលីហ្វ័រញ៉ា ក្នុងករណីស្មុំកូនពេញលេញ សំបុត្រកំណើតថ្មីដែលធ្វើឱ្យឪពុកម្តាយចិញ្ចឹមដូចជាឪពុកម្តាយបង្កើត ត្រូវបានចេញ ហើយសំបុត្រកំណើតចាស់ ត្រូវបានបញ្ចូលក្នុងស្រោមសំបុត្រ និង បិទជិត ហើយបោះត្រា (មាត្រា ៨៦១៥ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ, មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ១០១៩.- សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីស្មុំកូនបាន ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិរបស់តុលាការ ។

(កំណត់)

មាត្រា ៩២០០ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា កំណត់ថា ការមើលឯកសារពាក់ព័ន្ធនឹងការសម្រេចស្តីពីស្មុំកូន ដូចជាពាក្យសុំនៃស្មុំកូន លិខិតលះបង់អំណាចមេបា លិខិតយល់ព្រម របាយការណ៍ពីស្ថាប័នសម្របសម្រួលស្មុំកូន ជាដើម មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែមានស្ថានភាពជាពិសេស និង បញ្ជាក់មូលហេតុត្រឹមត្រូវ ។ ក៏ប៉ុន្តែ ប្រព័ន្ធបង្ហាញព័ត៌មានទាក់ទងនឹងកូនសុំ ត្រូវបានរៀបចំដែរ ដោយមានខ្លឹមសារថា ប្រសិនបើមានការយល់ព្រមពីឪពុកម្តាយបង្កើតជាលាយល័ក្ខណ៍អក្សរ និង មានពាក្យសុំរបស់កូនសុំដែលមានអាយុលើសពី ២១ ឆ្នាំ ស្ថាប័នសម្របសម្រួលស្មុំកូន ឬ មន្ទីរសង្គមកិច្ចស្រុក អាចបង្ហាញនូវឈ្មោះ និង អាសយដ្ឋានរបស់ឪពុកម្តាយបង្កើតដល់កូនសុំបាន ហើយប្រសិនបើមានការ

យល់ព្រមពីកូនសុំដែលបានដល់នីតិភាព ស្ថាប័នសម្របសម្រួលសុំកូន ឬ មន្ទីរសង្គមកិច្ចស្រុក ក៏អាចបង្ហាញនូវឈ្មោះ និង អាសយដ្ឋានរបស់កូនសុំដល់ឪពុកម្តាយបង្កើតបានដែរ (មាត្រា ៩២០៣ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។ ក្រៅពីនេះ ក៏មានប្រព័ន្ធរៀបចំឱ្យមានការជួបមុខដោយផ្ទាល់រវាងកូនសុំដែលបានដល់នីតិជន និង ឪពុកម្តាយបង្កើត ឬ បងប្អូនបង្កើត ផងដែរ ប្រសិនបើមានការយល់ព្រមជាលាយល័ក្ខណ៍អក្សរ (មាត្រា ៩២០៤ និង មាត្រា ៩២០៥ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។

យោងតាមការពិភាក្សា មាត្រានេះមិនកំណត់ឱ្យមានការយល់ព្រមពីឪពុកម្តាយបង្កើតជាល័ក្ខខ័ណ្ឌឡើយ ហើយទទួលស្គាល់នូវសិទ្ធិទាមទារឱ្យបង្ហាញនូវសំណុំរឿងស្តីពីសុំកូនដែលតុលាការរក្សាទុក ក្នុងករណីដែលមានភាពចាំបាច់ក្នុងការព្យាបាលជម្ងឺរបស់កូនសុំដែលបានដល់នីតិភាព ការរៀបអាពាហ៍ពិពាហ៍ ឬ គោលបំណងសមស្របផ្សេងទៀត ។ កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ទទួលស្គាល់សិទ្ធិដឹងអំពីប្រភពកំណើតរបស់ខ្លួនរបស់កុមារ ដូច្នេះ បញ្ហាប្រឈមនៅពេលខាងមុខ គឺការថ្លឹងថ្លែងរវាងសិទ្ធិរបស់ឪពុកម្តាយបង្កើតដែលមិនចង់ឱ្យស្គាល់ ឬ ការទាមទារការរក្សាការសម្ងាត់ ជាមួយនឹងសិទ្ធិរបស់កុមារក្នុងការដឹងអំពីអត្តសញ្ញាណរបស់ខ្លួន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២០៣ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា, កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

## កថាភាគទី ២ សុំកូនធម្មតា

**មាត្រា ១០២០.-** ពាក្យសុំនៃសុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតសុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

(កំណត់)

មាត្រានេះមានគោលបំណងបង្កើតប្រព័ន្ធសុំកូនធម្មតា (សុំកូនសាមញ្ញ) នៅប្រទេសកម្ពុជា ជាទម្រង់ដែលសម្រួលសុំកូនពេញលេញដែលជារបបដែលដាក់កូនសុំទៅក្នុងការគ្រប់គ្រងទាំងស្រុងរបស់គ្រួសាររបស់ឪពុកម្តាយចិញ្ចឹម ហើយកាត់ផ្តាច់ទាំងស្រុងនូវទំនាក់ទំនងជាមួយគ្រួសារឪពុកម្តាយបង្កើតនោះ ។ ប្រព័ន្ធសុំកូនធម្មតានេះត្រូវបានបង្កើតឡើង

ដោយតម្រូវឱ្យមានការពាក់ព័ន្ធពីតុលាការ ដើម្បីបង្កើតអានុភាពនៃញាតិលោហិតតាមផ្លូវច្បាប់ (ដូចជាសន្តតិកម្ម និង អាហារកាតព្វកិច្ច ជាដើម) ចំពោះករណីដែលកូនសុំមិនប្រាថ្នាការផ្តាច់ចេញពីគ្រួសាររបស់ឪពុកម្តាយបង្កើតទាំងស្រុង និង ការបញ្ចូលទាំងស្រុងទៅក្នុងគ្រួសាររបស់ឪពុកម្តាយចិញ្ចឹម ។ ប្រទេសបារាំង អាល្លឺម៉ង់ និង អាមេរិក (មាត្រា ៩៣០០(a) នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ក៏មានការទទួលស្គាល់កូនសុំដែលជានីតិជនដែរ ប៉ុន្តែ ច្បាប់នៃប្រទេស ទាំងនោះ អនុម័តយកគោលការណ៍នៃការប្រកាសដោយតុលាការ ។

ក្នុងស្មុំកូនធម្មតា ក៏មានការកម្រិតអាយុឪពុកម្តាយចិញ្ចឹមលើសពី ២៥ ឆ្នាំ ហើយតម្រូវឱ្យមានការចូលរួមរបស់តុលាការ ដើម្បីត្រួតពិនិត្យកុំឱ្យមានការប្រើស្មុំកូនធម្មតាដោយរបៀបបំពាន ។ ស្មុំកូនដែលជានីតិជន ក៏ត្រូវបានទទួលស្គាល់ដែរ ប៉ុន្តែ វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រានេះ ហាមឃាត់មិនឱ្យយកបុព្វញាតិនៃបុគ្គលដែលនឹងក្លាយជាឪពុកម្តាយ ចិញ្ចឹម ឬ ជនដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមកធ្វើជាកូនសុំទេ ។ កថាខណ្ឌទី ២ នៃ មាត្រាដដែលកំណត់ថា ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកមានអំណាចមេបា ឬ អ្នក អាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៩៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៦០ មាត្រា ៣៦១ និង មាត្រា ៣៦២ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ១ មាត្រា ១៧៦៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៣១៦ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា, មាត្រា ១០៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់កម្ពុជា

**មាត្រា ១០២១.-** ករណីដែលបុគ្គលដែលនឹងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមមានសហព័ទ្ធ

បើបុគ្គលដែលមានសហព័ទ្ធ សុំកូនដែលជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំ ដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃស្មុំកូនធម្មតា) ខាងលើនេះ ជាមួយនឹង សហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយក កូនរបស់សហព័ទ្ធ មកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ ខ្លួនបាន ។

(កំណត់)

មាត្រានេះទាមទារឱ្យមានស្មុំកូនដោយសហការរវាងប្តីប្រពន្ធ ក្នុងករណីដែលបុគ្គលដែលមានសហព័ទ្ធសុំកូនដែលជា អនីតិជន ។ ការដែលសុំកូនជាអនីតិជន គឺជាការមួយធំធេងណាស់សម្រាប់សហព័ទ្ធទាំងសងខាង ហើយដើម្បីរក្សា នូវស្ថិរភាពគ្រួសារ និង ធានាបរិស្ថានទំនុកបម្រុងកុមារដែលមានលំនឹងល្អ ត្រូវតែមានការសហការគ្នារវាងប្តីប្រពន្ធ ។ ក៏ប៉ុន្តែ ក្នុងករណីដែលយកកូនរបស់សហព័ទ្ធមកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធគ្មានសមត្ថភាពក្នុងការវិនិច្ឆ័យ ឬ មិនអាចបង្ហាញឆន្ទៈបាន ដោយសារមិនដឹងសហព័ទ្ធនោះនៅទីណា ជាដើម សហព័ទ្ធម្ខាងទៀតអាចសុំកូនដោយឯកឯង

ដោយមិនចាំបាច់មានការសហការ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៩៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០២២.-** ការយល់ព្រមរបស់សហព័ទ្ធ

ចំពោះបុគ្គលដែលមានសហព័ទ្ធ ដើម្បីដាក់ពាក្យសុំនៃសុំកូនធម៌តា ត្រូវទទួលការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម៌តា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

(កំណត់)

ក្នុងករណីបុគ្គលដែលមានសហព័ទ្ធយកបុគ្គលដទៃមកធ្វើសុំកូនធម៌តា បញ្ញត្តិនៃមាត្រានេះទាមទារឱ្យមានការយល់ព្រមពីសហព័ទ្ធនោះ ពីព្រោះការនេះអាចមានឥទ្ធិពលធំធេងដល់សន្តតិកម្ម អាហារកាតព្វកិច្ច នាមត្រកូល និង ជីវភាពជាក់ស្តែង ជាដើម ។ មាត្រានេះខុសពីករណីសុំកូនដែលជាអនីតិជន មិនយកគោលការណ៍សុំកូនដោយសហការគ្នារវាងប្តីប្រពន្ធឡើយ គឺសហព័ទ្ធម្ខាងអាចធ្វើសុំកូនធម៌តាដោយឯកតោភាគី ដោយមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ។ ក៏ប៉ុន្តែ នៅពេលដែលមានការសហការរវាងប្តីប្រពន្ធនៅពេលសុំកូន ឬ ករណីដែលសហព័ទ្ធម្ខាងទៀតនោះមិនអាចបង្ហាញឆន្ទៈបាន ជាដើម មិនចាំបាច់ត្រូវមានការយល់ព្រមឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៩៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០២៣.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនធម៌តា

១-តុលាការ អាចឱ្យបង្កើតសុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ។

២-តុលាការមិនត្រូវឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

(កំណត់)

វាក្យខណ្ឌទី ១ មាត្រា ១៧៦៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ កំណត់ថា តុលាការអាណាព្យាបាលអាចទទួលស្គាល់

ស្មុំកូនដែលជានីតិជន ដោយដីកាសម្រេច ក្នុងករណីដែលយល់ឃើញថា ស្មុំកូននោះសមស្របនឹងសីលធម៌ ។ មានន័យថា តុលាការគ្រាន់តែធ្វើការពិនិត្យទៅលើតែករណីដែលមានការបំពានលើប្រព័ន្ធស្មុំកូនប៉ុណ្ណោះ ។ ក្នុងរដ្ឋកាលីហ្វ័រញ៉ា ស្មុំកូនរវាងនីតិជនត្រូវបានទទួលស្គាល់ ប៉ុន្តែ ទន្ទឹមនឹងនេះ ក៏ត្រូវមានការវិនិច្ឆ័យឱ្យបានគ្រប់ជ្រុងជ្រោយទៅលើកត្តាផ្សេងៗ ដូចជា អំឡុងពេលនៃទំនាក់ទំនងរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំ លក្ខណៈនៃទំនាក់ទំនងនោះ អត្ថិភាពនៃញាតិភាព មូលហេតុ និង គោលបំណងនៃស្មុំកូន ឧត្តមប្រយោជន៍របស់ជនពាក់ព័ន្ធនឹងស្មុំកូន និង ភាពមិនផ្ទុយនឹងផលប្រយោជន៍សាធារណៈ ជាដើម ។ ហើយតុលាការអាចចេញដីកាសម្រេចទទួលស្គាល់ការព្រមព្រៀងស្មុំកូនរវាងភាគីដែលជានីតិជននោះបាន លុះត្រា តែស្មុំកូននោះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់ជនពាក់ព័ន្ធនឹងស្មុំកូន និង ផលប្រយោជន៍សាធារណៈ (មាត្រា ៩៣២១ និង មាត្រា ៩៣២៨ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។

ដូច្នេះ មាត្រានេះក៏ដូចគ្នាដែរ ស្មុំកូនធម្មតាក៏នឹងបង្កើតនូវទំនាក់ទំនងបុត្តភាពតាមផ្លូវច្បាប់ដែរ ដូច្នេះ ជាល័ក្ខខ័ណ្ឌនៃការបង្កើតជាក់ស្តែង ត្រូវមានអត្ថិភាពនៃឆន្ទៈសារធាតុក្នុងការបង្កើតបុត្តភាព ហើយទប់ស្កាត់កុំឱ្យមានការបំពានទៅលើរបបស្មុំកូន សម្រាប់គោលបំណងមិនត្រឹមត្រូវតាមសីលធម៌ ដូចជាស្មុំកូនដើម្បីក្លែងបន្លំបុត្តភាព និង ស្មុំកូនក្នុងគោលបំណងរៀបការរវាងភេទដូចគ្នា ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៧៦៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៩៣២៨ នៃច្បាប់គ្រួសាររដ្ឋកាលីហ្វ័រញ៉ា

**មាត្រា ១០២៤.-** ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន

១-បើបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន តុលាការអាចឱ្យបង្កើតស្មុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជននោះ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន បើឪពុកម្តាយបង្កើតរបស់បុគ្គលនោះបានលែងលះហើយ តុលាការត្រូវសួរយោបល់របស់ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ។

៣-បើអនីតិជនបានដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតស្មុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រានេះបញ្ញត្តថា ទោះបីជាសុំកូនធម្មតាក៏ដោយ ក្នុងករណីសុំកូនដែលជាអនីតិជន ការផ្តល់ផលប្រយោជន៍ដល់កុមារដែលត្រូវក្លាយជាកូនសុំ គឺជាល័ក្ខខ័ណ្ឌនៃការបង្កើតសុំកូននោះ ។ ក្នុងករណីសុំកូនដែលជាអនីតិជនដែលឪពុកម្តាយបានលែងលះគ្នា ការដែលសុំកូនត្រូវបានប្រើប្រាស់ដើម្បីផ្តាច់ប្រាស្រ័យ ការទាក់ទងជាមួយនឹងឪពុក ឬ ម្តាយដែលគ្មានអំណាចមេបាក៏មានមិនតិចដែរ ដូច្នេះ ទោះជាមិនទាមទារឱ្យមានការយល់ព្រមក៏ដោយ ក៏តុលាការចាំបាច់ត្រូវសួរយោបល់ពីឪពុក ឬ ម្តាយដែលគ្មានអំណាចមេបា ឬ ដែលមិនធ្វើការគ្រប់គ្រងថែរក្សាកូនដោយផ្ទាល់នោះដែរ ។

ដោយឡែកប្រទេសបារាំង តម្រូវឱ្យមានការយល់ព្រមពីកូនដែលមានអាយុលើសពី ១៣ ឆ្នាំ (កថាខណ្ឌទី ៣ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង) ខណៈដែលរដ្ឋកាលីហ្វ័រញ៉ា តម្រូវឱ្យមានការយល់ព្រមពីកូនដែលមានអាយុលើសពី ១២ ឆ្នាំ (មាត្រា ៨៦០២ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) រីឯនៅប្រទេសកម្ពុជាក៏ដូច្នេះដែរ ផ្តើមចេញពីទស្សនៈនៃការពារនូវសិទ្ធិបញ្ចេញទស្សនៈរបស់កុមារ (មាត្រា ១២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ) កថាខណ្ឌទី ៣ នៃមាត្រានេះ ក៏កំណត់ឱ្យគោរពឆន្ទៈរបស់កុមារអំពីសុំកូនដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៩៧ និង មាត្រា ៧៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៦០ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ១០២៥.-** សុំកូន រវាងអ្នកអាណាព្យាបាល និង ជននៅក្រោមអាណាព្យាបាល

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួន មកធ្វើជាកូនសុំ ឬ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួន មកធ្វើជាកូនសុំ តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតួនាទីរបស់អ្នកអាណាព្យាបាលបានចប់ តែមិនទាន់បានបញ្ចប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ។

(កំណត់)

ក្នុងករណីដែលអ្នកអាណាព្យាបាលសុំកូនដែលជាជននៅក្រោមអាណាព្យាបាល (អាណាព្យាបាលសម្រាប់អនីតិជន ឬ អាណាព្យាបាលសម្រាប់នីតិជន) អាចមានហានិភ័យដែលអ្នកអាណាព្យាបាលបំពានលើឋានៈដែលមានប្រៀបរបស់ខ្លួនទៅលើការគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល ។ ដូច្នេះហើយ មាត្រានេះ

ថែងថា តុលាការត្រូវពិចារណាលើទំនាក់ទំនងនៃការជឿទុកចិត្តពិសេសរវាងអ្នកអាណាព្យាបាល និង ជននៅក្រោមអាណាព្យាបាល ហើយអនុញ្ញាតឱ្យបង្កើតសុំកូនតែក្នុងករណីដែលអាចបញ្ជាក់បានថា គ្មានភាពមិនត្រឹមត្រូវ ឬ បញ្ហាមិនប្រក្រតីប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៩៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០២៦.-** អានុភាពនៃសុំកូនធម្មតា ចំពោះបុត្តភាព

១-ទោះបីជាមានការបង្កើតសុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ។

២-កូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ។

(កំណត់)

តើត្រូវពិចារណាដូចម្ដេច ចំពោះទំនាក់ទំនងនៃសន្តតិកម្ម ឬ ទំនាក់ទំនងនៃអាហារកាតព្វកិច្ច រវាងកូនសុំ និង ឪពុកម្ដាយបង្កើត ជាដើម ? ក្នុងក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ កូនសុំដែលជានីតិជន មិនត្រូវបង្កើតញាតិភាពរវាងកូនសុំ និង ញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមកូនសុំទេ មានន័យថា អានុភាពនៃសុំកូនកើតឡើងតែរវាងភាគីនៃសុំកូន (ឪពុកម្ដាយចិញ្ចឹម និង កូនសុំ) ប៉ុណ្ណោះ ។ ក្នុងសុំកូនដែលជានីតិជន អានុភាពនៃសុំកូនមិនមានទៅលើទំនាក់ទំនងជាមួយឪពុកម្ដាយបង្កើតឡើយ (កថាខណ្ឌទី ២ នៃមាត្រា ១៧៧០) ក៏ប៉ុន្តែ ករណីយកិច្ចលើអាហារកាតព្វកិច្ចរបស់ឪពុកម្ដាយចិញ្ចឹមចំពោះកូនសុំ ត្រូវមានអាទិភាពជាងករណីយកិច្ចលើអាហារកាតព្វកិច្ចរបស់ឪពុកម្ដាយបង្កើត (កថាខណ្ឌទី ៣ នៃមាត្រាដដែល) ។ មាត្រានេះទទួលស្គាល់នូវសិទ្ធិ និង ករណីយកិច្ចរបស់កូនសុំ ក្នុងការធ្វើសន្តតិកម្ម និង ផ្ដល់ និង ទទួលអាហារកាតព្វកិច្ចចំពោះឪពុកម្ដាយបង្កើត ។ មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណីបារាំង ក៏ទទួលស្គាល់សិទ្ធិចំពោះអាហារកាតព្វកិច្ច និង សន្តតិកម្មជាមួយនឹងឪពុកម្ដាយបង្កើតដែរ ចំពោះសុំកូនធម្មតា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៦៤ និង មាត្រា ៣៦៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ១០២៧.-** អានុភាពនៃសុំកូន ក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ជាអាទិ៍

១-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១០១៥ (អានុភាពនៃសុំកូនពេញលេញ) នៃ

ក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះស្មុំកូនធម្មតា ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនស្មុំកូនបាន ។

៣-ក្នុងករណីដែលកូនសុំ ជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធ មកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្តាយចិញ្ចឹម និង សហព័ទ្ធនោះ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះកំណត់ថា បញ្ញត្តិនៃមាត្រា ១០១៥ ស្តីពីអានុភាពនៃស្មុំកូនពេញលេញ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃស្មុំកូនធម្មតាចំពោះទំនាក់ទំនងរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹម ។ ក្នុងករណីនៃស្មុំកូនធម្មតា ក៏ដូចគ្នានឹងស្មុំកូនពេញលេញដែរ កូនសុំអាចប្រើនាមត្រកូលរបស់ខ្លួនដែលមាននៅមុនពេលក្លាយជាកូនសុំក៏បាន ឬ ប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បានដែរ (កថាខណ្ឌទី ២) ។ កថាខណ្ឌទី ៣ បានបញ្ជាក់ច្បាស់ថា ចំពោះអនីតិជន ឪពុកម្តាយចិញ្ចឹមត្រូវមានអំណាចមេបារួម ។ រីឯវាក្យខណ្ឌទី ២ វិញ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្តាយចិញ្ចឹម និង សហព័ទ្ធនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៦៣ និង មាត្រា ៣៦៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៩៣០៤ និង មាត្រា ៩៣០៥ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា

## មាត្រា ១០២៨.- ពាក្យសុំឱ្យកាត់កាល់ស្មុំកូនធម្មតា

១-ភាគីនៃស្មុំកូន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យកាត់កាល់ស្មុំកូនបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ ។

២-ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ដោយឪពុកម្តាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ។ ប៉ុន្តែ បើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើឪពុកម្ដាយបង្កើតរបស់កូនសុំ បានលែងលះគ្នាហើយ ឪពុកម្ដាយបង្កើតរបស់កូនសុំនោះ ត្រូវពិភាក្សា និង កំណត់ថា ឪពុក ឬ ម្ដាយបង្កើត ជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា នៅក្រោយពេលកាត់កាល់ ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន ។

(កំណត់)

ចំពោះការកាត់កាល់ស៊ុំកូនធម្មតា មាត្រានេះទាមទារឱ្យមានមិនត្រឹមតែការពិភាក្សាជាមួយភាគីប៉ុណ្ណោះទេ តែទាមទារឱ្យមានផងដែរនូវពាក្យសុំទៅតុលាការ និង ដីកាសម្រេចរបស់តុលាការ ។ ក្នុងករណីដែលកូនសុំជាអនីតិជន ឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ជាអ្នកដាក់ពាក្យសុំកាត់កាល់ ហើយប្រសិនបើកូននោះមានអាយុលើសពី ១៥ ឆ្នាំ ចាំបាច់ត្រូវមានការយល់ព្រមពីកូនសុំ ដោយផ្ដើមចេញពីទស្សនៈនៃការគោរពឆន្ទៈរបស់កូនសុំ ។ ដោយពិចារណាដល់គោលបំណងនៃមាត្រា ១២ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ក្នុងករណីកាត់កាល់ដោយការព្រមព្រៀងក៏ដោយ តាមវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រានេះ ក៏តុលាការត្រូវពិចារណាលើសិទ្ធិបញ្ចេញទស្សនៈរបស់ក្មេងដែរ ។ កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ ចែងថា នៅពេលដែលឪពុកម្ដាយបង្កើតលែងលះគ្នា ឪពុកម្ដាយរបស់កូនសុំនោះត្រូវពិភាក្សា និង កំណត់ថា អ្នកណាត្រូវក្លាយជាអ្នកមានអំណាចមេបា ហើយប្រសិនបើការពិភាក្សាគ្នាមិនឈានដល់ការដាច់ស្រេចទេ តុលាការត្រូវសម្រេចអំពីអ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍កុមារ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០២៩.-** ការកាត់កាល់ រវាងប្ដីប្រពន្ធដែលបានសុំកូនដោយសហការ និង កូនសុំជាអនីតិជន

ក្នុងករណីដែលប្ដីប្រពន្ធដែលបានសុំកូនដោយសហការគ្នា ជាឪពុកម្ដាយចិញ្ចឹម ដើម្បីកាត់កាល់កូនសុំជាអនីតិជន ប្ដីប្រពន្ធត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស៊ុំកូនធម្មតា) ខាងលើនេះ ជាមួយគ្នា ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះប្ដីប្រពន្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈរបស់

ខ្លួន ។

(កំណត់)

ដោយសារតែក្នុងករណីសុំកូនដែលជាអនីតិជន ជាគោលការណ៍ ត្រូវមានការសហការគ្នារវាងប្តីប្រពន្ធ ដូច្នេះ មាត្រានេះក៏ទាមទារឱ្យមានការសហការគ្នាចំពោះការកាត់កាល់ដែរ ។ ក៏ប៉ុន្តែ ក្នុងករណីដែលឪពុក ឬ ម្តាយចិញ្ចឹមម្ខាង មិនអាចបង្ហាញឆន្ទៈ ម្តាយ ឬ ឪពុកចិញ្ចឹមម្ខាងទៀតអាចធ្វើការកាត់កាល់សុំកូនដោយឯកឯងបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១១-២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១០៣០.- ការវិនិច្ឆ័យអំពីការកាត់កាល់សុំកូនធម្មតា

បើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) ខាងលើនេះ តុលាការអាចសម្រេចឱ្យកាត់កាល់សុំកូនបាន លុះត្រាតែបានបញ្ជាក់ថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ។

(កំណត់)

មាត្រានេះតម្រូវឱ្យតុលាការបញ្ជាក់អំពីឆន្ទៈកាត់កាល់របស់ភាគី ដើម្បីធានាការពារនូវភាពស្ម័គ្រចិត្តនៃការកាត់កាល់ដែលមិនមែនដោយការបង្ខិតបង្ខំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៣៤០ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា ។

## មាត្រា ១០៣១.- មូលហេតុនៃការកាត់កាល់

១-ភាគីម្ខាងនៃសុំកូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យកាត់កាល់បាន លុះត្រាតែក្នុងករណីខាងក្រោមនេះ :

ក- បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត ។

ខ- បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព ។

គ- បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្តាលឱ្យមានការពិបាកក្នុងការបន្តសុំកូន ។

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្ដាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស្មុំកូនធម្មតា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្ដាយចិញ្ចឹម ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីមូលហេតុនៃការកាត់កាល់តាមផ្លូវបណ្ដឹង ។ មូលហេតុទាំងនេះសំដៅលើករណីនៃការបោះបង់ចោលដោយទុច្ចរិត ភាពមិនច្បាស់ក្នុងអំឡុងពេលយ៉ាងតិច ១ ឆ្នាំ ថា ភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព ឬ ហេតុធ្ងន់ធ្ងរផ្សេងទៀតដែលបណ្ដាលឱ្យមានការពិបាកក្នុងការបន្តស្មុំកូន ដូចជាអំពើហិង្សា ទារុណកម្ម ការជេរប្រមាថ ការប្រព្រឹត្តិអំពើមិនត្រឹមត្រូវធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ដែលជាសត្យានុម័ត ធ្វើឱ្យទំនាក់ទំនងស្មុំកូនវិនាស និង មិនអាចរំពឹងថានឹងស្តារឡើងវិញបាន ។

ចំពោះបណ្ដឹងទាមទារឱ្យកាត់កាល់ពីកូនសុំ ក្នុងករណីដែលកូនសុំជាអនីតិជន បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ជាអ្នកដាក់ពាក្យបណ្ដឹង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៣២.-** អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា

១-អានុភាពទាំងឡាយនៃស្មុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនស្មុំកូនក៏បាន ឬ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីអានុភាពមិនប្រតិសកម្មនៃការកាត់កាល់ ដែលមានខ្លឹមសារថា តាមរយៈការកាត់កាល់ស្មុំកូនធម្មតា អានុភាពនៃស្មុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ។ ចំពោះនាមត្រកូលកូនសុំ ប្រសិនបើបានដូរនាមត្រកូលពេលស្មុំកូន កូនសុំអាចទទួលវិញនូវនាមត្រកូល មុនស្មុំកូនក៏បាន ឬ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ។

ក្នុងប្រទេសកម្ពុជា ការប្រើប្រាស់គោត្តនាម មិនមានអ្វីកំណត់ច្បាស់លាស់ឡើយ ប៉ុន្តែ ដោយមានការលើកឡើងនូវមតិជាច្រើនដែលថា គួរផ្តល់ជម្រើសចំពោះនាមត្រកូល ទើបបញ្ញត្តិដូចកថាខណ្ឌទី ២ នេះត្រូវបានរៀបចំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧០-២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨១៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៣៣.-** ការចុះបញ្ជីនៃសុំកូនធម្មតា និង លិខិតបញ្ជាក់កំណើត

ប្រសិនបើបានបង្កើតសុំកូនធម្មតា ត្រូវសរសេរការបង្កើតសុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

(កំណត់)

ក្នុងករណីសុំកូនធម្មតា មិនមែនជាការផ្តាច់ទំនាក់ទំនងគតិយុត្តជាមួយនឹងឪពុកម្តាយបង្កើតនោះទេ ដូច្នេះ មិនចាំបាច់លាក់បាំងជាសាធារណៈនូវការដែលជាកូនសុំឡើយ ។ រីឯចំពោះសុំកូនពេញលេញវិញ ដោយសារមានមូលហេតុដូចជាហេតុដែលកូនសុំមិនអាចទទួលបានការគ្រប់គ្រងថែរក្សាពីឪពុកម្តាយបង្កើត កូនសុំនឹងស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្តាយចិញ្ចឹម ហេតុដូច្នេះ នៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ច្បាប់ទាមទារឱ្យមានការសរសេរចូលដូចគ្នាទៅនឹងកូនបង្កើតដែរ ។ តាមបញ្ញត្តិមាត្រា ៣៦២ នៃក្រមរដ្ឋប្បវេណីបារាំង សុំកូនធម្មតាត្រូវចុះក្នុងបញ្ជីអត្រានុកូលដ្ឋានដោយបញ្ជាក់អំពីទំនាក់ទំនងរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹម ក្នុងអំឡុងពេល ១៥ ថ្ងៃ ចាប់ពីថ្ងៃដែលសាលក្រម ឬសាលដីកាសម្រេចសុំកូនមានអានុភាពនៃអាជ្ញាអស់ជំនុំ ។ ដោយយកលំនាំតាមក្រមរដ្ឋប្បវេណីបារាំង មាត្រានេះចែងថា ប្រសិនបើបានបង្កើតសុំកូនធម្មតា ត្រូវសរសេរការបង្កើតសុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីអត្រានុកូលដ្ឋានដើម និងសំបុត្រកំណើតដើមរបស់កូនសុំនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៦២ និង មាត្រា ៣៧០-១ នៃក្រមរដ្ឋប្បវេណីបារាំង

## ជំពូកទី ៥ អំណាចមេបា

(កំណត់)

អំណាចមេបា គឺជាវាក្យស័ព្ទរួមមួយនៃសិទ្ធិ និង ករណីយកិច្ចរបស់ឪពុកម្តាយចំពោះកូនរបស់ខ្លួនដែលជាអនីតិជន ។ នាពេលបច្ចុប្បន្ននេះ អំណាចមេបាត្រូវបានចាត់ទុកថា មិនមែនជាសិទ្ធិ និង ករណីយកិច្ចជាឯកជនទេ ប៉ុន្តែ ជាសិទ្ធិ និង ករណីយកិច្ចដែលមានលក្ខណៈជាសាធារណៈ ។ មាត្រា ៤៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ" ហើយមាត្រា ៤៧ នេះបានបញ្ជាក់ច្បាស់នូវលក្ខណៈជាសាធារណៈរបស់អំណាចមេបា ។ មានន័យថា សង្គមបានដាក់បន្ទុកដល់ឪពុកម្តាយក្នុងការផ្តល់ការចិញ្ចឹម

ថែរក្សា និង ការអប់រំចំពោះកូន ។ កថាខណ្ឌទី ១ មាត្រា ៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលកម្ពុជាបានផ្តល់សច្ចាប័នរួចហើយនោះ បានតម្រូវឱ្យអង្គនីតិបញ្ញត្តិយកចិត្តទុកដាក់ជាចម្បងលើផលប្រយោជន៍ល្អបំផុតរបស់កុមារ ក្នុងនីតិកម្ម។

អាស្រ័យដោយហេតុផលដូចខាងលើ នៅពេលរៀបចំជំពូកនេះ ទោះបីជាយើងបានយោងទៅលើបញ្ញត្តិស្តីពីអំណាចមេបានៃក្រមរដ្ឋប្បវេណីជប៉ុនក៏ដោយ ក៏យើងបានបញ្ចូលនូវបញ្ញត្តិដែលមិនមាននៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនដែរ ។ នៅពេលដែលយើងពិនិត្យឡើងវិញនូវបញ្ញត្តិទាំងនេះ យើងក៏បានយោងទៅលើមាត្រាដែលពាក់ព័ន្ធមួយចំនួននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ ផងដែរ ។

## ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ១០៣៤.-** អត្ថន័យនៃអំណាចមេបា

អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ។

(កំណត់)

ជាធម្មតា អ្នកដែលមានអំណាចមេបា គឺជាឪពុកម្តាយបង្កើត ប៉ុន្តែ មានករណីខ្លះពុំដូច្នេះទេ ។ បញ្ញត្តិទាក់ទងនឹងករណីបែបនេះមានដូចខាងក្រោម ។ម្យ៉ាងទៀង កូនដែលត្រូវស្ថិតនៅក្រោមអំណាចមេបា មានតែកូនដែលជាអនីតិជនប៉ុណ្ណោះ ។ ហើយទោះបីជាកូនជាអនីតិជនក៏ដោយ ក៏មានករណីខ្លះដែលកូនដែលជាអនីតិជនមិនស្ថិតក្រោមអំណាចមេបាទេ ដូចជាករណីដែលកូនដែលជាអនីតិជនត្រូវទទួលអត្តាធីនភាព តាមមាត្រា ២១ និង មាត្រា ២២ នៃក្រមនេះ និងករណីដែលកូននោះត្រូវបានចាត់ទុកថា បានដល់នីតិភាព តាមរយៈការចាត់ទុកជានីតិជនដោយអាពាហ៍ពិពាហ៍ ដូចបានចែងក្នុងមាត្រា ៩៦៨ នៃក្រមនេះ ។

"ការបីបាច់រក្សារូបកាយ" មានន័យថា រាល់សកម្មភាពទាំងឡាយដែលចាំបាច់សម្រាប់ការលូតលាស់ និង ការការពារកូនដែលជាអនីតិជន ដោយរួមទាំងការផ្តល់ចំណីអាហារ សម្លៀកបំពាក់ និង កន្លែងស្នាក់នៅ ការផ្តល់ការថែទាំផ្នែកវេជ្ជសាស្ត្រ និង ការព្យាបាលបើសិនជាកូនមានជម្ងឺ និង ការឱ្យកូនចូលរៀន ។ បន្ថែមពីលើនេះទៅទៀត ឪពុកម្តាយក៏ទទួលខុសត្រូវក្នុងការគ្រប់គ្រងកូនដែលជាអនីតិជន ដើម្បីការពារកូនមិនឱ្យប្រព្រឹត្តបទល្មើស និង អំពើមិនត្រឹមត្រូវដែរ ។

ទោះបីជាកម្រមានករណីដែលកូនមានទ្រព្យសម្បត្តិច្រើនក៏ដោយ ក៏អាចមានករណីដែលកូនមានទ្រព្យសម្បត្តិច្រើនតាមរយៈសន្តតិកម្ម ជាអាទិ៍ ។ មាត្រានេះចែងថា អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន រហូតដល់ពេលដែលកូននោះបានដល់នីតិភាព។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា ឆ្នាំ ១៩៨៩, កថាខណ្ឌទី ១ នៃមាត្រា ៨១៨ និងមាត្រា ៨២០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៣៥.-** អំណាចមេបាលើកូនសុំ

អ្នកដែលមានអំណាចមេបាលើកូនសុំ គឺឪពុកម្ដាយចិញ្ចឹម ។

(កំណត់)

ក្រមនេះបញ្ញត្តនូវរបបសុំកូន ២ ប្រភេទ គឺ សុំកូនពេញលេញដែលបានចែងចាប់ពីមាត្រា ១០០៧ និង សុំកូនធម្មតាដែលបានចែងចាប់ពីមាត្រា ១០២០ ។ នៅក្នុងករណីសុំកូនពេញលេញ ដោយសារតែទំនាក់ទំនងគតិយុត្តរវាងឪពុកម្ដាយបង្កើត និង កូនសុំត្រូវបានកាត់ផ្ដាច់ មានតែឪពុកម្ដាយចិញ្ចឹមប៉ុណ្ណោះទេដែលក្លាយជាឪពុកម្ដាយរបស់កូននោះ ដូច្នេះហើយ ឪពុកម្ដាយចិញ្ចឹមក្លាយជាអ្នកដែលមានអំណាចមេបា ។ ផ្ទុយទៅវិញក្នុងករណីសុំកូនធម្មតា ទំនាក់ទំនងរវាងឪពុកម្ដាយបង្កើត និង កូន និង ទំនាក់ទំនងរវាងឪពុកម្ដាយចិញ្ចឹម និង កូន មានអត្ថិភាពព្រមគ្នា ។ ដូច្នេះហើយវាមានភាពចាំបាច់ក្នុងការសម្រេចថា តើឪពុកម្ដាយបង្កើត ឬ ឪពុកម្ដាយចិញ្ចឹមជាអ្នកដែលមានអំណាចមេបា ។ ដោយសារសុំកូនដែលជាអនីតិជន មានគោលបំណងយកកូននោះទៅបីបាច់ថែរក្សាដោយផ្ទាល់ ឪពុកម្ដាយចិញ្ចឹមគួរជាអ្នកដែលមានអំណាចមេបា ។ មាត្រានេះមានន័យយ៉ាងដូច្នេះ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៣៦.-** គោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបា

ឪពុកម្ដាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា ។ ប៉ុន្តែ បើឪពុក ឬ ម្ដាយណាម្ខាង ពុំអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុក ឬ ម្ដាយម្ខាងទៀតត្រូវប្រើអំណាចមេបានោះ ។

(កំណត់)

នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ឪពុកម្ដាយ មានន័យថាជាប្ដីប្រពន្ធ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នាចំពោះកូនដែលជាអនីតិជន ។ ដូច្នេះ ក្នុងករណីដែលមានជម្លោះរវាងឪពុក និង ម្ដាយ ឪពុកម្ដាយនោះត្រូវជ្រើសរើសយកជម្រើសណាមួយដែលល្អបំផុតសម្រាប់កូន ដោយធ្វើការពិចារណាបានហ្មត់ចត់ និង ស្មោះត្រង់ ។

ករណីដែលឪពុក ឬ ម្ដាយ មិនអាចប្រើប្រាស់អំណាចមេបាបានទេ មានករណីដែលការប្រើប្រាស់អំណាចមេបាដោយសហការគ្នា មិនអាចត្រូវធ្វើទៅបាន ដោយសារតែឪពុក ឬ ម្ដាយ បាត់បង់សតិ បាត់ខ្លួន ឬ មិនអាចទាក់ទងបាន ព្រមទាំងករណីដែលបញ្ញត្តិច្បាប់មិនអនុញ្ញាតឱ្យឪពុក ឬ ម្ដាយ មិនអាចប្រើប្រាស់អំណាចមេបា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៥ និង មាត្រា ៤៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១ និង មាត្រា ១១៥ នៃច្បាប់

ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា ឆ្នាំ ១៩៨៩, កថាខណ្ឌទី ៣ មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ២ ការសម្រេចអំពីអ្នកមានអំណាចមេបា ក្នុងករណីលែងលះគ្នា និង ការទទួលស្គាល់

**មាត្រា ១០៣៧.-** ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា

១-បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ ។

២-ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នានៅមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ ។ ប៉ុន្តែ នៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន ។

៣-បើការពិភាក្សានៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ ។

(កំណត់)

នៅពេលដែលឪពុកម្តាយលែងលះគ្នា ជាធម្មតា ឪពុកម្តាយនឹងរស់នៅបែកគ្នា ។ ដូច្នេះ កូនត្រូវទៅរស់នៅជាមួយឪពុកម្តាយណាម្ខាង ។ របបគតិយុត្តស្តីពីអំណាចមេបានៅក្រោយការលែងលះ អាចចែកចេញជាពីរ : របបមួយគឺអំណាចមេបាទោលដែលសម្រេចឱ្យឪពុក ឬ ម្តាយម្ខាងជាអ្នកមានអំណាចមេបា និង របបមួយទៀតគឺអំណាចមេបារួមដែលឪពុក និង ម្តាយ នៅបន្តមានអំណាចមេបារួមគ្នា ។ ក៏ប៉ុន្តែ ទោះបីជាឪពុកម្តាយមានអំណាចមេបារួមក៏ដោយ ក៏ឪពុក ឬ ម្តាយ ដែលរស់នៅជាមួយកូន បីបាច់រក្សារូបកាយ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដែរ ។ ហើយការប្រគល់ឱ្យដូចគ្នានូវអំណាចមេបាទៅឪពុក និង ម្តាយ ដែលបានលែងលះគ្នា អាចធ្វើឱ្យមានឧបសគ្គដល់ការអនុវត្តអំណាចមេបានេះផងដែរ ។ ហេតុដូច្នេះ ក្រមនេះអនុម័តយកអំណាចមេបាទោលតាមរយៈមាត្រានេះ ហើយក៏បានផ្តល់ឱ្យមានការសម្របសម្រួលមួយចំនួន នៅក្នុងមាត្រាមួយចំនួនខាងក្រោមនេះ ដោយបញ្ញត្តឱ្យមានការផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា និង ការផ្តល់សិទ្ធិ និង ករណីយកិច្ចខ្លះដល់ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកដែលមានអំណាចមេបា ។ ម្យ៉ាងទៀត វាជាការពិតណាស់ ទោះបីជាឪពុក ឬ ម្តាយណាម្នាក់លែងជាអ្នកដែលមានអំណាចមេបាក៏ដោយ ក៏ឪពុក ឬ ម្តាយនោះ នៅតែជាឪពុក ឬ ម្តាយតាមច្បាប់ និង មិនបានបាត់បង់នូវទំនាក់ទំនងគតិយុត្តរវាងឪពុក ឬ ម្តាយនោះ និង កូនឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៣៨.-** ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា

១-អ្នកមានអំណាចមេបាលើកូន ដែលម្តាយមិនទាន់បានរៀបអាពាហ៍ពិពាហ៍បានបង្កើត គឺម្តាយ ។

២-ឪពុក អាចប្រើប្រាស់អំណាចមេបា ចំពោះកូនដែលខ្លួនបានទទួលស្គាល់បានតែក្នុងករណីដែលការពិភាក្សារបស់ឪពុកម្តាយ បានកំណត់យកឪពុកនោះ ជាអ្នកមានអំណាចមេបា ។

៣-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សានោះបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា តាមការទាមទាររបស់ឪពុក ឬ ម្តាយ ។

៤-ក្រោយពេលដែលឪពុកបានទទួលស្គាល់កូនហើយ ប្រសិនបើឪពុកម្តាយបានរៀបអាពាហ៍ពិពាហ៍ ឪពុកម្តាយត្រូវអនុវត្តអំណាចមេបា ដោយសហការគ្នា ។

(កំណត់)

មាត្រា ១០៣៨ បញ្ញត្តអំពីអ្នកដែលមានអំណាចមេបា ក្នុងករណីដែលស្ត្រីមិនទាន់បានរៀបអាពាហ៍ពិពាហ៍ផ្តល់កំណើតដល់កូន មានន័យថាជាករណីដែលមិនបានកំណត់ឪពុករបស់កូនព្រមពេលជាមួយគ្នានឹងកំណើតរបស់កូននោះ ដោយសារមិនអាចអនុវត្តការសន្មតបិតុភាព ។

១. ដោយសារមាត្រា ៩៨៧ នៃក្រមនេះ ស្ត្រីដែលសម្រាលកូន គឺជាម្តាយរបស់កូន ហេតុដូច្នេះ វត្តមានរបស់ម្តាយមានភាពច្បាស់លាស់ ។ ដូច្នេះ ប្រសិនបើស្ត្រីមិនទាន់បានរៀបអាពាហ៍ពិពាហ៍ ផ្តល់កំណើតដល់កូន ស្ត្រីនោះក្លាយជាអ្នកដែលមានអំណាចមេបាលើកូននោះ ។

២. ចំពោះកូនដែលត្រូវបានទទួលស្គាល់ ឪពុកអាចក្លាយជាអ្នកដែលមានអំណាចមេបាបាន ក្រោយពេលមានការពិភាក្សារវាងឪពុក និង ម្តាយ ។ គួរឱ្យធ្វើការប្រុងប្រយ័ត្នថា ដោយសារតែឪពុក និង ម្តាយ មិនបានរៀបអាពាហ៍ពិពាហ៍ទេ ដូច្នេះ ទោះបីជាឪពុកក្លាយជាអ្នកដែលមានអំណាចមេបាក៏ដោយ ឬ ម្តាយក្លាយជាអ្នកដែលមានអំណាចមេបាក៏ដោយ ក៏វាមិនមែនជាអំណាចមេបាដោយសហការគ្នាដែរ តែវានៅតែជាអំណាចមេបាទោលដដែល ។

៣. ឧទាហរណ៍ ប្រសិនបើក្រោយពេលស្ត្រីម្នាក់សម្រាលកូនរួច ឪពុកទទួលស្គាល់កូននោះ ហើយស្នើសុំឱ្យមានការពិភាក្សាជាមួយម្តាយដោយសារខ្លួនចង់ក្លាយជាអ្នកដែលមានអំណាចមេបា ប៉ុន្តែ ម្តាយបដិសេធនូវសំណើនេះ ឪពុកនោះអាចទាមទារឱ្យតុលាការកំណត់នូវអ្នកដែលមានអំណាចមេបាបាន ។

៤. នៅពេលដែលឪពុកម្តាយរបស់កូនរៀបអាពាហ៍ពិពាហ៍ និង រួមរស់នៅជាមួយគ្នា នោះគ្មានបញ្ហាក្នុងការផ្តល់

អំណាចមេបារួម ហើយឪពុកម្ដាយនោះគួរតែមានអំណាចមេបារួម ។
(មាត្រាពាក់ព័ន្ធ)
មាត្រា ១០១ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា ឆ្នាំ ១៩៨៩, កថាខណ្ឌទី ៤ និង ទី ៥ នៃមាត្រា ៨១៩ និង មាត្រា ៧៨៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៣៩.-** ការផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា

នៅក្នុងករណីនៃបញ្ញត្តិមាត្រា ១០៣៧ (ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា) និង មាត្រា ១០៣៨ (ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា) ខាងលើនេះ តុលាការអាចផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា តាមការទាមទាររបស់ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់កូនបាន ប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន ។

(កំណត់)
ជាឧទាហរណ៍ ក្នុងករណីដែលម្ដាយបានក្លាយជាអ្នកដែលមានអំណាចមេបាទោលដោយសារការលែងលះគ្នា ឬ ក្នុងករណីដែលឪពុកបានក្លាយជាអ្នកដែលមានអំណាចមេបាទោលចំពោះកូនដែលខ្លួនបានទទួលស្គាល់ ក្រោយពេលមានការពិភាក្សាយោបល់ជាមួយម្ដាយ ប្រសិនបើអ្នកដែលមានអំណាចមេបាទោលនោះធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់កូន ដូចជា បានប្រព្រឹត្តនូវអំពើណាមួយដែលមិនសមជាអ្នកដែលមានអំណាចមេបា ជាអាទិ៍ នោះញាតិណាម្នាក់របស់កូនអាចទាមទារឱ្យតុលាការធ្វើការផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបាបាន ។
(មាត្រាពាក់ព័ន្ធ)
កថាខណ្ឌទី ៦ មាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៤០.-** សិទ្ធិ និង ករណីយកិច្ចរបស់ឪពុកម្ដាយដែលមិនរស់នៅជាមួយកូន

១-ឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ។

២-ឪពុកម្ដាយដែលមានបំណងចង់លែងលះគ្នា ត្រូវពិភាក្សា និង កំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ។

៣-ឪពុកដែលមិនបានរស់នៅជាមួយកូនដែលបានទទួលស្គាល់ អាចពិភាក្សា និង កំណត់ ជាមួយម្តាយ អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនបាន ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្តាយ ។

៥-បើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន តុលាការអាចផ្លាស់ប្តូររបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្តាយ បាន ។

៦-នៅក្នុងការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះ តុលាការត្រូវកំណត់អំពីការចូលជួប ប្រាស្រ័យទាក់ទង ដោយយកផលប្រយោជន៍របស់កូនជាអាទិភាព និង ត្រូវកំណត់អំពីសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និង ស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្តាយ ។

៧-ប្រសិនបើឪពុក ឬ ម្តាយ មិនអាចពិភាក្សា ឬ មិនអាចទាមទារទៅតុលាការបានទេ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះបាន ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិ និង ករណីយកិច្ចរបស់ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកដែលមានអំណាចមេបា ក្នុងករណីដែលឪពុក ឬ ម្តាយម្ខាងទៀតមានអំណាចមេបាទោល ដោយសារឪពុកម្តាយនោះបានលែងលះគ្នា ឬ មិនបានរៀបអាពាហ៍ពិពាហ៍ ។ ដោយសារតែឪពុក ឬ ម្តាយដែលមិនមែនជាអ្នកដែលមានអំណាចមេបា ជាធម្មតា តែងតែមិនស្នាក់នៅជាមួយកូន ឪពុក ឬ ម្តាយនោះត្រូវបានហៅផងដែរថា ឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូន ។ ឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូន អាចចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូនបាន ។ វាគឺជាសិទ្ធិ ហើយជាមួយគ្នា ក៏ជាករណីយកិច្ចរបស់ឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូនដែរ ។ ម្យ៉ាងវិញទៀត កូនក៏មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូនដែរ ។ ទោះបីជាឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយ

កូន មិនមានជាអ្នកដែលអំណាចមេបាក៏ដោយ ដរាបណាគាត់នៅតែជាឪពុក ឬ ម្ដាយ នោះឪពុក ឬ ម្ដាយដែលមិនរស់នៅជាមួយកូន ចាំបាច់ត្រូវចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន ដើម្បីការលូតលាស់ដ៏ប្រសើររបស់កូន ។ ផ្ទុយទៅវិញ ប្រសិនបើឪពុក ឬ ម្ដាយដែលមិនរស់នៅជាមួយកូនធ្លាប់បានរំលោភបំពានទៅលើកូនពីអតីតកាល ឬ ប្រសិនបើការចូលជួប ឬ ប្រាស្រ័យទាក់ទងគ្នា មិនបណ្ដាលឱ្យមានផលប្រយោជន៍ដល់សុខុមាលភាពរបស់កូននោះទេ ឪពុក ឬ ម្ដាយដែលមិនរស់នៅជាមួយកូននោះ អាចនឹងត្រូវហាមឃាត់មិនឱ្យទាក់ទងជាមួយនឹងកូន ។ សុខុមាលភាពរបស់កូនមានអាទិភាពជាងបញ្ហាផ្សេងៗទាំងអស់ ។ ប្រសិនបើការចូលជួប ឬ ការប្រាស្រ័យទាក់ទងគ្នាជាមួយឪពុក ឬ ម្ដាយដែលមិនរស់នៅជាមួយកូន អាចជួយដល់ការរីកលូតលាស់របស់កូន ការចូលជួប ឬ ការប្រាស្រ័យទាក់ទងគ្នានេះ គួរតែត្រូវបានអនុញ្ញាត រីឯប្រសិនបើធ្វើឱ្យមានការរាំងស្ទះ ឬ អាចនឹងបណ្ដាលឱ្យមានការរាំងស្ទះដល់ការរីកលូតលាស់របស់កូន ការចូលជួប ឬ ការប្រាស្រ័យទាក់ទងគ្នានេះ មិនគួរត្រូវបានអនុញ្ញាតឡើយ ។

ម្យ៉ាងវិញទៀត ការចូលជួប និង ការប្រាស្រ័យទាក់ទងគ្នានេះ មិនគួរត្រូវបានផ្សារភ្ជាប់ជាមួយនឹងការបែងចែកបន្ទុកនៃសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគ្មានការគិតគូរហ្មត់ចត់ឡើយ ។ មានន័យថា ទោះបីជាឪពុក ឬ ម្ដាយដែលមិនរស់នៅជាមួយកូន ពុំបានទទួលបន្ទុកនូវចំណែកសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូនក៏ដោយ ក៏រឿងនោះមិនត្រូវយកមកធ្វើជាមូលហេតុក្នុងការហាមឃាត់ឪពុក ឬ ម្ដាយដែលមិនរស់នៅជាមួយកូននោះ មិនឱ្យចូលជួប ឬ ប្រាស្រ័យទាក់ទងជាមួយកូន ឬ ក្នុងការតម្រូវឱ្យឪពុក ឬ ម្ដាយដែលមិនរស់នៅជាមួយកូននោះ បង់ប្រាក់ចំណែកសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូន ដើម្បីជាថ្នូរនឹងការយល់ព្រមឱ្យចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូននោះដែរ ។ ការចូលជួប និង ការប្រាស្រ័យទាក់ទងនេះ មិនត្រូវយកមកប្រើជាមធ្យោបាយក្នុងការចរចាឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧៤ និង មាត្រា ៧៥ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា ឆ្នាំ ១៩៨៩, គម្រោងវិសោធនកម្មក្រមរដ្ឋប្បវេណីជប៉ុនលើកទី ៦ ឆ្នាំ ១៩៩៦

គម្រោងវិសោធនកម្មក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ ១៩៩៦ គឺជាសេចក្ដីព្រាងវិសោធនកម្មនូវគន្ថីស្ដីពីញាតិនៃក្រមរដ្ឋប្បវេណី ដែលត្រូវបានចងក្រងឡើងក្នុងឆ្នាំ ១៩៩៦ ។ សេចក្ដីព្រាងវិសោធនកម្មនោះមិនទាន់សម្រេចបាននៅឡើយ ដោយសារតែមូលហេតុមួយចំនួន ។ ទោះបីជាក្រមរដ្ឋប្បវេណីបច្ចុប្បន្នរបស់ជប៉ុន ពុំមានមាត្រាណាមួយចែងអំពី "ការចូលជួប និង ប្រាស្រ័យទាក់ទង" ក៏ដោយ ក៏ចំណុចនេះត្រូវបានទទួលស្គាល់ដោយយុត្តិសាស្ត្រដែរ ។ សេចក្ដីព្រាងវិសោធនកម្មទី ៦ គឺជាសំណើដែលធ្វើឱ្យ "ការចូលជួប និង ប្រាស្រ័យទាក់ទង" ក្លាយជាលាយល័ក្ខណ៍អក្សរច្បាស់លាស់នៅក្នុងក្រម ។

## **មាត្រា ១០៤១.-** សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន

១-ឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបាលើកូន អាចទាមទារឱ្យអ្នកដែលមាន

អំណាចមេបា រាយការណ៍អំពីស្ថានភាពរបស់កូននោះបាន ។

២-ចំពោះខ្លឹមសារ និង របៀបរបបនៃការរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់តាមការពិភាក្សារវាងឪពុកម្ដាយ ។ ប៉ុន្តែ បើការពិភាក្សាពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការអាចសម្រេចសេចក្ដីជំនួសការពិភាក្សា តាមការទាមទាររបស់ឪពុក ឬ ម្ដាយ បាន ។

៣-ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូនចំពោះអ្នកមានអំណាចមេបាបាន ។

(កំណត់)

ឪពុក ឬ ម្ដាយដែលពុំមានអំណាចមេបា ក៏នៅតែជាឪពុក ឬ ម្ដាយតាមច្បាប់របស់កូនដែរ ។ ជាងនេះទៀត ឪពុក ឬ ម្ដាយដែលមិនរស់នៅជាមួយកូន អាចមានករណីយកិច្ចជាច្រើនក្នុងនាមជាឪពុក ឬ ម្ដាយ ដូចជាករណីយកិច្ចក្នុងការបង់ការចំណាយលើការចិញ្ចឹមកូន ជាដើម ។ ដូច្នេះ ការដឹងពីស្ថានភាពកូនដែលមិនរស់នៅជាមួយខ្លួន គឺជាសិទ្ធិរបស់ឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូន ហើយព្រមជាមួយគ្នានេះ គឺជាករណីយកិច្ចរបស់ឪពុក ឬ ម្ដាយនោះ ដើម្បីធានាឱ្យមានការរីកលូតលាស់បានយ៉ាងល្អរបស់កូន ។ ហេតុផលគឺដោយសារថា ការដឹងអំពីស្ថានភាពរបស់កូន គឺជាការដឹងថាតើអ្នកដែលមានអំណាចមេបាទោលបានអនុវត្តអំណាចមេបានេះបានត្រឹមត្រូវដែរ ឬទេ ។

កថាខណ្ឌទី ៣ ពាក់ព័ន្ធនឹងករណីដូចជាជីដូនជីតារបស់កូន ឬ ញាតិផ្សេងទៀតចង់ដឹងអំពីស្ថានភាពរបស់កូន ។ ដោយសារការធានាឱ្យមានការប្រាស្រ័យទាក់ទងគ្នាជាមួយញាតិ ជួយបង្កើននូវសុខុមាលភាពរបស់កូន ទើបថ្មីៗនេះ ក្រមរដ្ឋប្បវេណីបារាំង បានដាក់បញ្ចូលនូវបញ្ញត្តិប្រហាក់ប្រហែលគ្នានេះដែរ ។ ជាគោលការណ៍ ខ្លឹមសារនៃរបាយការណ៍ និង ភាពញឹកញាប់ក្នុងការរាយការណ៍ គួរតែត្រូវកំណត់ដោយភាគីទាំងពីរ ។ ចំណុចនេះមិនគួរត្រូវកំណត់ដោយច្បាប់ទេ ដោយសារតែមានស្ថានភាព និង ទំនាក់ទំនងផ្សេងៗគ្នារវាងភាគី ។ នៅក្នុងករណីដែលភាគីមិនអាចកំណត់ដោយខ្លួនឯងបាន ខ្លឹមសារ និង ភាពញឹកញាប់ដែលសមរម្យមួយ គួរត្រូវកំណត់ដោយនីតិវិធីសម្រុះសម្រួល (សន្ធានកម្ម) មួយដែលនឹងត្រូវបានរៀបចំនៅពេលអនាគត ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧៣-២-១ និង មាត្រា ៣៧១-៤ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ១០៤២.-** ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងកូន

លើកលែងតែករណីដែលមានភាពចាំបាច់បន្ទាន់ អ្នកដែលមានអំណាចមេបា ត្រូវពិភាក្សាជាមួយឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា អំពីចំណុចដែលទាក់ទងទៅនឹង

កូន ដូចមានកំណត់ខាងក្រោមនេះ ៖

ក-ការអប់រំរបស់កូន ដែលហួសពីកម្រិតនៃកាតព្វកិច្ចអប់រំដែលជាករណីយកិច្ច កំណត់ដោយច្បាប់ ។

ខ-ការផ្លាស់ប្តូរទីសំណាក់របស់កូន ពីរាជធានី ខេត្តមួយ ទៅរាជធានី ខេត្តមួយទៀត ។[៥]

គ-វិជ្ជាជីវៈ ឬ អាជីវកម្មរបស់កូន ។

ឃ-សកម្មភាពព្យាបាល ដែលទាក់ទងដល់អាយុជីវិតរបស់កូន ។

ង-ការចាត់ចែងទ្រព្យសម្បត្តិសំខាន់របស់កូន ។

ច-ចំណុចសំខាន់ៗផ្សេងទៀត ដែលទាក់ទងទៅនឹងការគ្រប់គ្រងថែរក្សាកូន និង ទ្រព្យសម្បត្តិរបស់កូន ។

(កំណត់)

ដើម្បីលើកកម្ពស់សុខុមាលភាពរបស់កូន និង ដើម្បីឱ្យមានប្រសិទ្ធភាពនូវសិទ្ធិ និង ករណីយកិច្ចរបស់ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា ជាគោលការណ៍ អ្នកដែលមានអំណាចមេបា និង ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបាត្រូវតែពិភាក្សាគ្នា អំពីចំណុចដែលបានកំណត់នៅក្នុងមាត្រានេះ ។

ចំណុច ក រួមបញ្ចូលករណីដែលអ្នកដែលមានអំណាចមេបា បញ្ជូនកូនឱ្យសិក្សានៅមហាវិទ្យាល័យ ឬក៏ទៅបរទេស ។ ដោយសារតែការនេះនឹងពាក់ព័ន្ធនឹងការចំណាយដ៏ច្រើននោះ ករណីនេះនឹងមានការប៉ះពាល់ដល់ការបែងចែកបន្ទុកនៃសោហ៊ុយសម្រាប់ការចិញ្ចឹមកូន ។ម្យ៉ាងទៀត ការអប់រំ គឺជាកត្តាសំខាន់សម្រាប់ជីវិត និង អនាគតរបស់កូន ។ ដូច្នេះ គួរតែជាចំណុចដែលត្រូវពិភាក្សាគ្នា ។ទោះបីជាយ៉ាងណាក៏ដោយ ចំណុច ក រួមបញ្ចូលតែការអប់រំជាធម្មតានៅក្នុងសាលា តែមិនមានរាប់បញ្ចូលនូវការសិក្សា ដែលជាឧទាហរណ៍មានដូចជា ការរៀនលេងឧបករណ៍តន្ត្រី ឬ ការហាត់រាំសម្រាប់កែកំសាន្ត ជាដើមនោះឡើយ ។

ពាក់ព័ន្ធនឹងចំណុច ខ ប្រសិនបើកូនផ្លាស់ប្តូរទីសំណាក់ទៅទីឆ្ងាយ ការផ្លាស់ប្តូរនេះអាចបណ្តាលឱ្យមានការលំបាក ឬ ក៏មិនអាចទៅរួចសម្រាប់ឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូន ក្នុងការចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន ហើយមានការលំបាកក្នុងការទទួលសេចក្តីរាយការណ៍អំពីស្ថានភាពរបស់កូន ។ នេះគឺជាប្រការមិនល្អសម្រាប់ទាំងកូន និង ឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូន ។ ដូច្នេះ ករណីដែលទីសំណាក់របស់កូនត្រូវបានផ្លាស់ប្តូរទៅរាជធានី ខេត្តផ្សេងទៀត ក៏ត្រូវបានបញ្ចូលជាចំណុចដែលត្រូវពិភាក្សាដែរ ។ ដោយពុំមានភាពស្រពិចស្រពិល ករណីដែលកូនទៅសិក្សា

[៥] ចំណុច ខ នៃមាត្រា ១០៤២ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

នៅបរទេសនោះ ស្ថិតក្នុងទាំងចំណុច ក និង ចំណុច ខ ។

ពាក់ព័ន្ធនឹងចំណុច គ ជាធម្មតា កូនមិនអាចប្រកបវិជ្ជាជីវៈ ឬ អាជីវកម្ម និង ទទួលការអប់រំនៅក្នុងសាលាក្នុងពេលជាមួយគ្នាបានទេ ។ ហេតុដូច្នេះ ប្រសិនបើកូនប្រកបវិជ្ជាជីវៈ ឬ អាជីវកម្ម មានន័យថា កូនមិនទទួលនូវការអប់រំបន្ថែមលើការអប់រំដែលជាកាតព្វកិច្ច ដូចដែលបានកំណត់ក្នុងចំណុច ក ហើយនឹងត្រូវចាត់ទុកនៅក្នុងសង្គមថា មានភាពឯករាជ្យ ។ បន្ថែមពីនេះ មានវិជ្ជាជីវៈ និង អាជីវកម្មដែលពុំសក្តិសមសម្រាប់អនីតិជនផងដែរ ។ ដូច្នេះ ប្រសិនបើកូនដែលជាអនីតិជនប្រកបវិជ្ជាជីវៈ ឬ ធ្វើអាជីវកម្ម អ្នកដែលមានអំណាចមេបាគួរផ្តល់ការអនុញ្ញាតឱ្យកូន ក្រោយពេលមានការពិភាក្សាជាមួយនឹងឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា ។

ចំណុច ឃ ទាមទារឱ្យមានការពិភាក្សាគ្នារវាងឪពុក និង ម្តាយ ចំពោះសកម្មភាពព្យាបាលដែលទាក់ទងដល់អាយុជីវិតរបស់កូន ។ ប៉ុន្តែ ការពិភាក្សាពុំចាំបាច់ធ្វើឡើយ ប្រសិនបើការព្យាបាលនោះត្រូវធ្វើឡើងជាបន្ទាន់ ។ ឧទាហរណ៍ ប្រសិនបើកូនទទួលរងនូវជម្ងឺមហារីក ហើយវេជ្ជបណ្ឌិតស្នើអ្នកដែលមានអំណាចមេបាឱ្យជ្រើសរើសរវាងការព្យាបាលដោយវះកាត់ និង ការព្យាបាលដោយប្រើថ្នាំ អ្នកដែលមានអំណាចមេបានោះគួរពិភាក្សាជាមួយឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា ។ អ្នកដែលមានអំណាចមេបាចាំបាច់ពិភាក្សាជាមួយឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា ដូចគ្នាដែរ ចំពោះបញ្ហាថា តើគួរបន្ត ឬ បញ្ឈប់ការព្យាបាលរហូតដល់ពេលកូនស្លាប់ ឬ បើបញ្ឈប់តែគួរបញ្ឈប់ការព្យាបាលនៅពេលណា ។

ទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច ង សកម្មភាពនីមួយៗដែលបានកំណត់ក្នុងមាត្រា ៣០ នៃក្រមនេះអាចយកមកធ្វើជាសេចក្តីយោងបាន ។ ទោះបីយ៉ាងណាក៏ដោយ មានការចាំបាច់ក្នុងការពិគ្រោះយោបល់ទាក់ទងនឹងការចាត់ចែងទ្រព្យសម្បត្តិដែលអាចដាក់ទ្រព្យសម្បត្តិរបស់កូនស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ។

ចំណុច ច ទាមទារឱ្យអ្នកដែលមានអំណាចមេបា និង ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា ធ្វើការពិភាក្សាទៅលើចំណុចសំខាន់ៗដែលទាក់ទងនឹងការគ្រប់គ្រងថែរក្សារូបកាយរបស់កូន និង ទ្រព្យរបស់កូន ក្រៅពីចំណុចដែលបានចែងពីចំណុច ក ដល់ ចំណុច ង ។ ដូច្នេះ ប្រសិនបើឪពុក ឬ ម្តាយ គិតថា ចំណុចអ្វីមួយគឺជារឿងចាំបាច់សម្រាប់សុខុមាលភាពរបស់កូន ទោះបីជាមាន ឬ គ្មានអំណាចមេបាក៏ដោយ ក៏ឪពុក ឬ ម្តាយនោះ គួរតែស្នើឱ្យមានការពិភាក្សា ហើយឪពុក ឬ ម្តាយម្ខាងទៀតដែលទទួលសំណើ មានករណីយកិច្ចក្នុងការឆ្លើយតបទៅនឹងសំណើនោះ ដោយស្មោះត្រង់ដែរ ។ ដោយពុំចាំបាច់សង្ស័យ ការផ្លាស់ប្តូរនូវឋានៈបុគ្គលរបស់កូន ដូចជាការរៀបអាពាហ៍ពិពាហ៍ ឬ សុំកូន ស្ថិតនៅក្នុងចំណុច ច ។

ក៏ប៉ុន្តែ មាត្រា ១០៤២ នេះ ពុំមានបញ្ញត្តិអំពីករណីដែលការពិភាក្សារវាងឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា និងអ្នកដែលមានអំណាចមេបាបញ្ចប់ទៅដោយគ្មានជោគជ័យទេ ។ បញ្ញត្តិសម្រាប់ករណីនោះមិនត្រូវបានរៀបចំឡើយ ដោយសារតែបញ្ហាដូចជាថា តើគួរតែឱ្យកូនចូលសិក្សានៅមហាវិទ្យាល័យ ឬទេ មិនសមស្របនឹងការវិនិច្ឆ័យរបស់តុលាការទេ ។ ក្នុងករណីបែបនេះ ឪពុកម្តាយគួរមានការពិភាក្សាយ៉ាងហ្មត់ចត់ជាមួយគ្នា ។ ប្រសិនបើការពិភាក្សានេះបញ្ចប់ទៅដោយ

គ្មានជោគជ័យ នោះការសម្រេចរបស់អ្នកដែលមានអំណាចមេបាត្រូវមានអាទិភាព ។ ក្នុងករណីដែលការសម្រេចរបស់អ្នកដែលមានអំណាចមេបា ប្រឆាំងទៅនឹងសុខុមាលភាពរបស់កូន ឪពុក ឬ ម្ដាយដែលពុំមានអំណាចមេបាគួរទាមទារឱ្យមានការផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៣៩ នៃក្រមនេះ ។

## ផ្នែកទី ៣ សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា

### មាត្រា ១០៤៣.- ការអប់រំកូន

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចអប់រំកូន ។

(កំណត់)

ពាក្យថា "ការអប់រំ" ដែលប្រើក្នុងមាត្រានេះ មានន័យថា ការជំរុញការអភិវឌ្ឍខាងបញ្ញារបស់កូន និង ការផ្ដល់ឱ្យកូនទទួលបាននូវចំណេះដឹង និង ជំនាញដែលចាំបាច់សម្រាប់ដឹកនាំជីវិតនៅក្នុងសង្គមរបស់ខ្លួន ។ ការអប់រំអាចត្រូវបែងចែកជាការអប់រំនៅក្នុងផ្ទះ ដូចជា "វិន័យ" ដែលអ្នកដែលមានអំណាចមេបាបង្រៀននៅក្នុងផ្ទះ និង ការអប់រំនៅក្នុងសាលាដែលជាមូលដ្ឋាន ត្រូវបានបង្រៀននៅក្នុងសាលា ។

អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចក្នុងការអប់រំកូននៅក្នុងគ្រួសារ ។ នាពេលបច្ចុប្បន្ននេះ ដោយផ្អែកលើទស្សនៈដែលថា សង្គមបានផ្ដល់ភារកិច្ចដល់ឪពុកម្ដាយក្នុងការអប់រំកូន ទើបការអប់រំរបស់កូន ត្រូវបានបានចាត់ទុកថាជាករណីយកិច្ចច្រើនជាងជាសិទ្ធិរបស់ឪពុកម្ដាយ ។ ដូច្នេះ ទោះបីជាមាត្រានេះបានផ្ដល់នូវសិទ្ធិក្នុងការអប់រំកូនក៏ដោយ ក៏ច្បាប់មិនអនុញ្ញាតឱ្យលះបង់សិទ្ធិនេះដែរ ។ ភាពជាសិទ្ធិនេះនឹងមានអត្ថន័យ នៅពេលដែលការអនុវត្តនូវករណីយកិច្ចនេះដោយឪពុកម្ដាយ ត្រូវបានរារាំងដោយអំពើរំខានរបស់តតិយជនណាមួយ ។ បន្ថែមពីនេះ ឪពុកម្ដាយ មិនត្រូវបានអនុញ្ញាតឱ្យប្រព្រឹត្តអំពើហិង្សា ដោយហៅអំពើហិង្សាជា "វិន័យ" ឬ "ការអប់រំ" ឬ ផ្ដល់នូវ "ការអប់រំ" ដែលមិនត្រឹមត្រូវសម្រាប់ការរីកលូតលាស់របស់កូន ក្រោមរូបភាពនៃការប្រើប្រាស់សិទ្ធិនេះឡើយ ។ សកម្មភាពទាំងនេះគឺជាការបំពាននូវសិទ្ធិអប់រំ ។ អាស្រ័យទៅតាមស្ថានភាព ការបំពាននេះអាចក្លាយទៅជាមូលដ្ឋាននៃការប្រកាសការព្យួរ ឬ ដកហូតអំណាចមេបា ដោយយោងតាមមាត្រា ១០៤៨ (ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) នៃក្រមនេះ ។

ចំពោះការអបរំនៅក្នុងសាលា តាមរដ្ឋធម្មនុញ្ញ អ្នកដែលមានអំណាចមេបាមានករណីយកិច្ចឱ្យកូនចូលសាលា ដែលជាករណីយកិច្ចរបស់ប្រជាពលរដ្ឋ ហើយរដ្ឋត្រូវផ្ដល់នូវការអប់រំនៅក្នុងសាលាសាធារណៈក្នុងរយៈពេល ៩ ឆ្នាំ នៅថ្នាក់បឋមសិក្សា និង ថ្នាក់អនុវិទ្យាល័យទៅដល់ប្រជាពលរដ្ឋ ក្នុងនាមជាការទទួលខុសត្រូវរបស់រដ្ឋ ។ ដូច្នេះ អ្នកដែលមានអំណាចមេបាត្រូវតែឱ្យកូនទទួលបាននូវការអប់រំយ៉ាងតិច ៩ ឆ្នាំ ។ ការអប់រំក្នុងរយៈពេល ៩ ឆ្នាំនេះ គឺជាករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបាចំពោះរដ្ឋ ហើយព្រមជាមួយគ្នានេះ ជាការសម្រេចបាននូវករណីយកិច្ចរបស់រដ្ឋចំពោះកូន (ដែលជាប្រជាពលរដ្ឋមួយរូប) តាមរយៈអ្នកដែលមានអំណាចមេបា ។ ដូច្នេះ អ្នកដែលមានអំណាចមេបាមិនត្រូវបានអនុញ្ញាតឱ្យហាមឃាត់កូនមិនឱ្យចូលរៀន ដោយពុំមានហេតុផលពិសេសជាក់លាក់ឡើយ ។ ឧទាហរណ៍នៃ

ហេតុផលពិសេស មានដូចជា : កូនមិនអាចទ្រាំទ្រនូវការអប់រំនៅក្នុងសាលា ដោយសារតែបញ្ហាសុខភាព ឬ កូនបានសម្រាកនៅក្នុងមន្ទីរពេទ្យអស់រយៈពេលយូរ ហើយកូនមិនអាចចូលរៀនបាន សូម្បីតែកូនចង់ចូលរៀន ។ ក៏ប៉ុន្តែ វាមិនត្រូវបានចាត់ទុកថាជាហេតុផលពិសេសជាក់លាក់ឡើយ ប្រសិនបើឪពុកម្ដាយឱ្យកូនធ្វើការ ឬ ជួយកិច្ចការផ្ទះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៧ មាត្រា ៤៨ និង មាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា, មាត្រា ១១៥ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា ឆ្នាំ ១៩៨៩, មាត្រា ២៨ និង មាត្រា ២៩ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ, មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២១៣ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ១០៤៤.- ទីសំណាក់របស់កូន

ទីសំណាក់របស់កូន ត្រូវកំណត់នៅទីកន្លែងដែលអ្នកមានអំណាចមេបា បានកំណត់ ។

(កំណត់)

អ្នកដែលមានអំណាចមេបាពិតជាមិនអាចប្រើសិទ្ធិ និង អនុវត្តករណីយកិច្ចរបស់ខ្លួនដោយមានប្រសិទ្ធភាពបានឡើយ លើកលែងតែទីសំណាក់របស់កូនត្រូវបានកំណត់ជាក់លាក់ ។ ដូច្នេះ មាត្រានេះចែងថា អ្នកដែលមានអំណាចមេបាអាចកំណត់ទីសំណាក់របស់កូន ដែលជាសិទ្ធិរបស់អ្នកដែលមានអំណាចមេបា ឬ អាចនិយាយម៉្យាងទៀតបានថាជាករណីយកិច្ចរបស់កូន ។ ដោយសារតែអ្នកដែលមានអំណាចមេបា និង កូន ជាធម្មតា រស់នៅជាមួយគ្នា មាត្រានេះកម្រនឹងក្លាយជាបញ្ហាណាស់ ។ មាត្រានេះអាចក្លាយជាបញ្ហាក្នុងករណីដែលអ្នកមានអំណាចមេបាបញ្ជូនកូនឱ្យចូលរៀនក្នុងសាលាដែលផ្ដល់កន្លែងឱ្យសិស្សស្នាក់នៅ ។ អ្នកដែលមានអំណាចមេបា មិនត្រូវបានអនុញ្ញាតឱ្យកំណត់ទីសំណាក់របស់កូននៅកន្លែងដែលមិនសមរម្យដើម្បីឱ្យកូនរស់នៅនោះឡើយ ។ ម្យ៉ាងទៀត ប្រសិនបើកូនរស់នៅជាមួយតតិយជន ដោយចេញពីអ្នកមានអំណាចមេបា ការទាមទារតាមមាត្រានេះមិនអាចត្រូវបានបង្ខំដោយផ្ទាល់ឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣១៧-៣ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ១០៤៥.- ការដាក់ទណ្ឌកម្មកូន

អ្នកមានអំណាចមេបា អាចដាក់ទណ្ឌកម្មកូន ដោយខ្លួនឯង នៅក្នុងទំហំដែលចាំបាច់បាន ។

(កំណត់)

នៅពេលផ្ដល់ការអប់រំចំពោះកូន អ្នកដែលមានអំណាចមេបាអាចស្ដីបន្ទោស ឬ ដាក់ទណ្ឌកម្មកូននៅក្នុងកម្រិតមួយដែលចាំបាច់បាន ក្នុងករណីដែលកូនប្រព្រឹត្តនូវសកម្មភាពប្រឆាំងនឹងសង្គម ដូចជាការប្រព្រឹត្តអំពើល្មើសដោយអនីតិជន

ជាដើម ។ ដើម្បីជៀសវាងការភាន់ច្រឡំ សូមបញ្ជាក់ថា មាត្រានេះមិនគួរត្រូវបានប្រើប្រាស់ដើម្បីជាលេសក្នុងការបំពាន ឬ ការប្រើប្រាស់ហិង្សាឡើយ ។ ការដាក់ទណ្ឌកម្មត្រូវអនុញ្ញាតឱ្យធ្វើតែនៅក្នុងកម្រិតមួយដែលចាំបាច់សម្រាប់ការអប់រំនៅក្នុងផ្ទះដល់កូនតែប៉ុណ្ណោះ ។ ការដាក់ទណ្ឌកម្មដែលបណ្តាលឱ្យមានការរងគ្រោះផ្នែកផ្លូវចិត្ត ឬ ផ្លូវកាយដល់កូនក្នុងនាមជា "វិន័យ" មិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ បន្ថែមពីលើនេះ ប្រសិនបើអំពើល្មើសរបស់កូន គឺជាបទល្មើសព្រហ្មទណ្ឌ នោះវានឹងជាសមត្ថកិច្ចរបស់អាជ្ញាធរយុត្តិធម៌សម្រាប់កុមារ ឬ ស្ថាប័នហ្វឹកហ្វឺនកុមារ (ដូចជាមជ្ឈមណ្ឌលកែប្រែកុមារ) ហើយអ្នកដែលមានអំណាចមេបាមិនគួរដាក់ទារុណកម្មដោយផ្ទាល់ខ្លួនចំពោះកូនឡើយ ។ ប្រសិនបើអ្នកដែលមានអំណាចមេបាដាក់ទណ្ឌកម្មហួសពីកម្រិតនៃការចាំបាច់ វានឹងក្លាយទៅជាបញ្ហាដែលបានចែងក្នុងមាត្រា ១០៤៨ (ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៤៦.-** ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ និង អាជីវកម្ម

១-កូន មិនអាចប្រកបវិជ្ជាជីវៈបានឡើយ បើមិនបានទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម) នៃក្រមនេះ អ្នកមានអំណាចមេបា អាចលុបចោល ឬ កម្រិតការអនុញ្ញាត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

(កំណត់)

ពាក្យថា "វិជ្ជាជីវៈ" ក្នុងមាត្រានេះមានន័យថា ការធ្វើកិច្ចការជាបន្ត ទោះបីជាមានផលប្រយោជន៍ ឬ ពុំមានផលប្រយោជន៍ និង ទោះបីជាធ្វើជានិយោជិត ឬ និយោជកក៏ដោយ ។ ដូច្នេះ ពាក្យវិជ្ជាជីវៈ មានរួមបញ្ចូលទាំងបុព្វជិត គ្រូបង្រៀន សហគ្រិន និយោជិតសហគ្រាស មន្ត្រីរាជការ ពាណិជ្ជករ ឧស្សាហករ កសិករ និង អ្នកផ្តល់ការកំសាន្តសប្បាយដល់ភ្ញៀវ ជាដើម ។ ផ្ទុយទៅវិញ ពាក្យថា "អាជីវកម្ម" មានន័យថា កិច្ចការដែលមានគោលបំណងយកផលចំណេញ ។ អាជីវកម្មដែលមានជាគំរូនោះគឺហាងលក់ទំនិញផ្ទាល់ខ្លួន ។

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ត្រូវមានការអនុញ្ញាតរបស់អ្នកដែលមានអំណាចមេបា ដើម្បីឱ្យកូនដែលជាអនីតិជនអាចប្រកបវិជ្ជាជីវៈបាន ។ ទោះបីជាសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈត្រូវបានធានាដោយមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាក៏ដោយ ក៏កូនដែលជាអនីតិជនចាំបាច់ត្រូវទទួលការអនុញ្ញាតរបស់អ្នកដែលមានអំណាចមេបា ដើម្បីអាចប្រកបវិជ្ជាជីវៈបានដែរ ដោយសារហេតុផលដូចតទៅ : កូនដែលជាអនីតិជនអាចជួបការខាតបង់ ដូចជាការទទួលកាតព្វកិច្ច ជាអាទិ៍ ដែលបណ្តាលមកពីការប្រកបវិជ្ជាជីវៈ ឬ អនីតិជនអាចចាប់យកវិជ្ជាជីវៈដែលមិនសមស្របសម្រាប់ខ្លួន

ដោយសារការខ្វះបទពិសោធន៍នៅក្នុងសង្គម ។ ដោយសារ ជាធម្មតា អនីតិជនគួរទទួលបាននូវការអប់រំ អ្នកដែលមានអំណាចមេបាទំនងជាគិតថា ការដែលឱ្យកូនទទួលបានការអប់រំ មានសារៈប្រយោជន៍ជាងការឱ្យកូនប្រកបវិជ្ជាជីវៈ ។ ប្រសិនបើទោះបីជាដឹងថា ការប្រកបវិជ្ជាជីវៈហាក់ដូចជាមិនបណ្ដាលឱ្យមានគុណវិបត្តិអ្វីចំពោះកូនក៏ដោយ ក៏អ្នកដែលមានអំណាចមេបានៅតែមានចេតនាមិនផ្ដល់ការអនុញ្ញាតដល់កូនដែលជាអនីតិជនដែរ ករណីនេះជាការបំពានលើសិទ្ធិផ្ដល់ការអនុញ្ញាតនេះ ។ ផ្ទុយទៅវិញ ប្រសិនបើកូនចាប់យកវិជ្ជាជីវៈដែលមិនសមស្របសម្រាប់អនីតិជននៅក្នុងសង្គម ហើយអ្នកដែលមានអំណាចមេបានៅតែផ្ដល់ការអនុញ្ញាត វានឹងបង្កឱ្យមានមន្ទិលកើតឡើងពាក់ព័ន្ធនឹងបញ្ហាថា តើបុគ្គលនោះសមជាអ្នកដែលមានអំណាចមេបា ឬទេ ។

កថាខណ្ឌទី ២ នៃមាត្រានេះផ្ដល់សិទ្ធិដល់អ្នកដែលមានអំណាចមេបាក្នុងការលុបចោលការអនុញ្ញាត ឬ ធ្វើការកម្រិតនូវវិសាលភាពនៃអាជីវកម្ម នៅពេលដែលអ្នកដែលមានអំណាចមេបាផ្ដល់ការអនុញ្ញាតឱ្យកូនប្រកបអាជីវកម្ម ដោយយោងតាមមាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម) ប៉ុន្តែ កូនមិនអាចប្រកបអាជីវកម្មបានជាប្រក្រតីដោយសារខ្វះសមត្ថភាពគ្រប់គ្រង ជាដើម ។

ម្យ៉ាងទៀត ប្រសិនបើមានច្បាប់ការងារទាក់ទងនឹងកុមារ និង ច្បាប់ការងារផ្សេងទៀត នោះច្បាប់ទាក់ទងនឹងការងារដែលជាច្បាប់ពិសេសទាំងនោះ ត្រូវយកមកអនុវត្តមុន ហើយប្រសិនបើពុំមានបញ្ញត្តិដែលពាក់ព័ន្ធទេ ទើបបញ្ញត្តិនៃក្រមរដ្ឋប្បវេណី នឹងត្រូវយកមកអនុវត្ត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១០៤៧.- ការទាមទារឱ្យប្រគល់កូន

១-អ្នកមានអំណាចមេបា អាចទាមទារឱ្យតតិយជន ដែលមិនព្រមប្រគល់កូន ដោយផ្ទុយនឹងច្បាប់ ប្រគល់កូនបាន ។

២-អ្នកមានអំណាចមេបា អាចទាមទារឱ្យឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា ប្រគល់កូនបាន ។

(កំណត់)

ចំពោះការទាមទារឱ្យប្រគល់កូន ស្ថានភាពផ្សេងៗមួយចំនួនអាចកើតឡើង ។

កថាខណ្ឌទី ១ សំដៅរហូតដល់ករណីដែលអ្នកដែលមានអំណាចមេបាទាមទារឱ្យប្រគល់កូន ពីអ្នកដែលបានដាក់កូនក្នុងស្ថានភាពខុសច្បាប់ ដូចជា ឧទាហរណ៍ថា (១) កូនត្រូវបានចាប់ពង្រត់ ឬ (២) កូនត្រូវបានចាប់បង្ខាំងទុក ជាដើម ព្រមទាំងករណីដូចជាករណីដែល (៣) មានការប្រគល់កូនឱ្យមើលថែទាំជាបណ្ដោះអាសន្ន តាមរយៈកិច្ចសន្យា ក៏ប៉ុន្តែបុគ្គលដែលទទួលខុសត្រូវលើកូនជាបណ្ដោះអាសន្នតាមរយៈកិច្ចសន្យា ខកខានក្នុងការប្រគល់កូនមកវិញដោយបំពាន

កិច្ចសន្យា ដូច្នេះ ដោយសារវាជាការរំលោភអំណាចមេបាក្នុងការយកកូនទៅបីបាច់រក្សារូបកាយ និង ចិញ្ចឹម អ្នកដែលមានអំណាចមេបាអាចទាមទារឱ្យបុគ្គលនោះប្រគល់កូនមកវិញបាន ។ ប៉ុន្តែ ប្រសិនបើអនីតិជនដែលមានសមត្ថភាពខាងឆន្ទៈបន្តរស់នៅជាមួយតតិយជន ដោយឆន្ទៈរបស់ខ្លួនផ្ទាល់ នោះមិនមានភាពខុសច្បាប់ឡើយ ។ លើសពីនេះទៅទៀត ប្រសិនបើសិនតតិយជនត្រូវបានគិតថា កំពុងព្យាយាមការពារកូនពីសភាពការណ៍បន្ទាន់ណាមួយ តតិយជននោះត្រូវបានរួចផុតពីភាពខុសច្បាប់ដែរ ។

កថាខណ្ឌទី ២ ទាក់ទងនឹងករណីដូចតទៅ : ករណីដែលឪពុកម្តាយបានលែងលះគ្នា ហើយឪពុក ឬ ម្តាយណាម្ខាងត្រូវបានកំណត់ជាអ្នកដែលមានអំណាចមេបា ប៉ុន្តែ ឪពុក ឬ ម្តាយម្ខាងទៀតមិនព្រមប្រគល់កូន ឬ ករណីដែលឪពុកម្តាយចិញ្ចឹមបានក្លាយទៅជាអ្នកដែលមានអំណាចមេបា ប៉ុន្តែ ឪពុកម្តាយបង្កើតដែលមិនមានអំណាចមេបា មិនព្រមប្រគល់កូនឱ្យឪពុកម្តាយចិញ្ចឹម ជាដើម ។ ប្រសិនបើអនីតិជនដែលមានសមត្ថភាពខាងឆន្ទៈបន្តរស់នៅជាមួយឪពុក ឬ ម្តាយដែលមិនមានអំណាចមេបាដោយឆន្ទៈរបស់ខ្លួនផ្ទាល់ ឆន្ទៈរបស់កូននោះមិនគួរត្រូវបានអើពើទាំងស្រុងទេ ហេតុដូច្នេះ អ្នកដែលមានអំណាចមេបា និង ឪពុក ឬ ម្តាយបង្កើតដែលមិនមានអំណាចមេបា ត្រូវពិភាក្សាគ្នា ដើម្បីដោះស្រាយបញ្ហានេះ ។

នៅក្នុងករណីដែលបានចែងក្នុងកថាខណ្ឌទី ១ អ្នកដែលមានអំណាចមេបាអាចទាមទារសំណងការខូចខាតពីតតិយជន ដោយសារការរំលោភលើអំណាចមេបាក្លាយជាអំពើអនីត្យានុកូល ហើយក៏ត្រូវបានអនុញ្ញាតឱ្យសម្រេចសិទ្ធិទាមទារឱ្យប្រគល់កូន តាមរយៈការបង្ខំដោយផ្ទាល់ផងដែរ ។ នៅក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ទោះបីជាការសម្រេចសិទ្ធិរបស់អ្នកដែលមានអំណាចមេបាជាការសំខាន់ក៏ដោយ ក៏គួរតែមានការដោះស្រាយបញ្ហា ស្របទៅតាមកាលៈទេសៈ ដោយផ្តល់អាទិភាពដល់សុខុមាលភាពរបស់កូន ។

## ផ្នែកទី ៤ ការព្យួរ និង ការដកហូតអំណាចមេបា

**មាត្រា ១០៤៨.-** ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា

បើឪពុក ឬ ម្តាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ បើបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសព្យួរ ឬ ការដកហូតអំណាចមេបា តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

(កំណត់)

មាត្រានេះផ្តល់នូវយន្តការមួយដែលតាមរយៈយន្តការនេះ តុលាការអាចព្យួរ ឬ ដកហូតអំណាចមេបាទាំងស្រុងដោយផ្អែកលើសេចក្តីសម្រេចរបស់ខ្លួន តាមពាក្យសុំរបស់បុគ្គលដែលមានសិទ្ធិដាក់ពាក្យសុំដែលបានកំណត់ក្នុងមាត្រានេះ ក្នុង

ករណីដែលអ្នកដែលមានអំណាចមេបាមិនសក្តិសមជាអ្នកដែលមានអំណាចមេបា ឧទាហរណ៍ដោយសារបុគ្គលនោះរំលោភបំពានលើកូន ជាអាទិ៍ ។ ជាឧទាហរណ៍ ប្រសិនបើកូនមានការរងគ្រោះធ្ងន់ធ្ងរ ដោយសារតែអំពើហិង្សារបស់ឪពុក ហើយកូនត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ករណីដូចតទៅនេះអាចនឹងកើតមានឡើង : វេជ្ជបណ្ឌិតនឹងរាយការណ៍ជូនមន្ត្រីនគរបាល ហើយមន្ត្រីនគរបាលនឹងរាយការណ៍ជូនតំណាងអយ្យការ ហើយតំណាងអយ្យការនឹងដាក់ពាក្យសុំទៅតុលាការ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៩ ដល់ មាត្រា ១២១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា ឆ្នាំ ១៩៨៩, មាត្រា ៨៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៤៩.-** ការលុបចោលនូវការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា

បើមូលហេតុដែលបានកំណត់ក្នុងមាត្រា ១០៤៨ (ការប្រកាសព្យួរ ឬ ការដកហូតអំណាចមេបា) ខាងលើនេះ បានបញ្ចប់ហើយ តុលាការអាចលុបចោលការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា តាមការទាមទាររបស់សាមីជនដែលបានទទួលការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា ឬ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់ជននោះបាន ។

(កំណត់)

ជាឧទាហរណ៍ មានករណីមួយចំនួនដែលអ្នកមានអំណាចមេបាបានប្រព្រឹត្តនូវអំពើហិង្សាទៅលើកូន ដោយសារការញៀនគ្រឿងស្រវឹង ហើយដែលត្រូវបានព្យួរ ឬ ដកហូតនូវអំណាចមេបា ប៉ុន្តែ គាត់បានជំនះនូវការញៀនគ្រឿងស្រវឹង កែប្រែនូវទំនោរនៃការប្រព្រឹត្តិអំពើហិង្សា ហើយមានការសោកស្តាយនូវអ្វីដែលខ្លួនបានប្រព្រឹត្ត និង ចាប់ផ្តើមចង់បានមកវិញនូវអំណាចមេបា ។ នៅក្នុងករណីនេះ តុលាការគួរពិចារណាថា តើបុគ្គលនោះគួរទទួលបានវិញនូវអំណាចមេបាដោយវិនិច្ឆ័យជាចម្បង ទៅលើការសម្រេចឱ្យបាននូវសុខុមាលភាពរបស់កូន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា ឆ្នាំ ១៩៨៩ និង មាត្រា ៨៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

**មាត្រា ១០៥០.-** ការលាឈប់ និង បដិទានរបស់អ្នកមានអំណាចមេបា

១-បើមានមូលហេតុដែលពុំអាចជៀសវាងបាន ឪពុក ឬ ម្តាយ ដែលអនុវត្តអំណាចមេបា អាចលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបញ្ចប់ហើយ ឪពុក ឬ ម្ដាយ ដែលបានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា អាចទទួលបដិទាននូវអំណាចមេបានោះវិញបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

(កំណត់)

មាត្រានេះកម្រត្រូវបានយកមកប្រើណាស់ចំពោះករណីដែលទាំងឪពុក និង ម្ដាយជាអ្នកដែលមានអំណាចមេបា ដោយសារថា ប្រសិនបើឪពុក ឬ ម្ដាយណាម្នាក់មិនអាចអនុវត្តអំណាចមេបាដោយសារការជាប់ពន្ធនាគារ ការសម្រាកនៅមន្ទីរពេទ្យរយៈពេលវែង ឬ ការធ្វើដំណើរទៅបរទេស ឪពុក ឬ ម្ដាយម្នាក់ទៀតអាចអនុវត្តអំណាចមេបាបាន ។ មាត្រានេះត្រូវយកមកអនុវត្តចំពោះករណីដែលមានអ្នកដែលមានអំណាចមេបាតែម្នាក់ ដូចជាក្នុងករណីដែលឪពុក ឬ ម្ដាយបានទទួលមរណភាព ។ ប្រសិនបើអ្នកដែលមានអំណាចមេបាទោល មិនអាចអនុវត្តនូវអំណាចមេបាបានដោយសារកាលៈទេសៈដែលមិនអាចជៀសវាងបាន ដូចជាត្រូវជាប់ពន្ធនាគារ ការសម្រាកនៅមន្ទីរពេទ្យរយៈពេលវែង ឬ ការធ្វើដំណើរទៅបរទេស តុលាការអាចអនុញ្ញាតឱ្យមានការលាឈប់ពីការធ្វើជាអ្នកដែលមានអំណាចមេបា តាមពាក្យសុំរបស់អ្នកដែលមានអំណាចមេបា ។ ក្នុងករណីដែលតុលាការអនុញ្ញាតឱ្យមានការលាឈប់នេះ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវតែងតាំងសម្រាប់អនីតិជន (មាត្រា ១០៥២ នៃក្រមនេះ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១០៥១.- ការផ្លាស់ប្ដូរអ្នកមានអំណាចមេបា

១-ក្នុងករណីដែលឪពុកម្ដាយតែម្ខាង ជាអ្នកមានអំណាចមេបា ហើយកូនបានធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា ដោយសារអ្នកនោះត្រូវបានប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា ឬ បានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា មកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន ។

២-ប្រសិនបើមានការចាំបាច់ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចទាមទារឱ្យធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

៣-នៅពេលលែងលះគ្នា ប្រសិនបើឪពុក ឬ ម្ដាយ ដែលធ្វើជាអ្នកមានអំណាចមេបារបស់កូន តាមការពិភាក្សា បានទទួលមរណភាព ប្រសិនបើកូនពុំមានអ្នកមានអំណាចមេបាទេ ឪពុក ឬ ម្ដាយ ដែលពុំបានធ្វើជាអ្នកមានអំណាចមេបា ត្រូវក្លាយជា

អ្នកមានអំណាចមេបា ។

(កំណត់)

ឧទាហរណ៍ ប្រសិនបើម្ដាយដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍សម្រាលកូន ជាគោលការណ៍ ម្ដាយនោះគឺជាអ្នកដែលមានអំណាចមេបា ទោះបីជាឪពុកធ្វើការទទួលស្គាល់កូន (មាត្រា ១០៣៨ នៃក្រមនេះ) ក៏ដោយ ។ កថាខណ្ឌទី ១ ចែងថា ក្នុងករណីដែលម្ដាយត្រូវបានព្យួរ ឬ ដកហូតនូវអំណាចមេបា ឬ លាឈប់ពីការធ្វើជាអ្នកដែលមានអំណាចមេបា តុលាការអាចយកឪពុកមកធ្វើជាអ្នកដែលមានអំណាចមេបាបាន តាមរយៈការវិនិច្ឆ័យរបស់ខ្លួន ។

កថាខណ្ឌទី ២ ទទួលស្គាល់ឱ្យញាតិក្នុង ៤ (បួន)ថ្នាក់ ដោយរួមបញ្ចូលទាំងឪពុកម្ដាយ (ថ្នាក់ទី ១) របស់កូន មានសិទ្ធិដាក់ពាក្យសុំឱ្យធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះបាន ។ កថាខណ្ឌទី ៣ ចែងថា ប្រសិនបើឪពុកម្ដាយកំណត់អ្នកដែលមានអំណាចមេបាតាមការពិភាក្សានៅពេលលែងលះ ហើយអ្នកដែលមានអំណាចមេបាទោលនោះទទួលមរណភាព កូននឹងមិនត្រូវដាក់ឱ្យស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជនឡើយ ប៉ុន្តែ ឪពុក ឬ ម្ដាយដែលនៅរស់នឹងក្លាយជាអ្នកដែលមានអំណាចមេបា ។ មានន័យថា ឪពុក ឬ ម្ដាយដែលនៅរស់នោះ ត្រូវក្លាយជាអ្នកដែលមានអំណាចមេបា ដោយស្វ័យប្រវត្តិ តាមបញ្ញត្តិច្បាប់ ។ ដូច្នេះ ក្នុងករណីដែលឪពុក ឬ ម្ដាយដែលនៅរស់នោះ មិនអាចបំពេញករណីយកិច្ចជាអ្នកដែលមានអំណាចមេបាបាន ដោយសារមូលហេតុ ដូចជាឪពុក ឬ ម្ដាយដែលនៅរស់នោះ បានរៀបអាពាហ៍ពិពាហ៍សាជាថ្មី ជាអាទិ៍ ឪពុក ឬ ម្ដាយនោះត្រូវលាឈប់ពីការធ្វើជាអ្នកដែលមានអំណាចមេបា ដោយយោងតាមមាត្រា ១០៥០ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៧៣-១ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ១០៥២.-** ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

១-បើមានស្ថានភាពដែលពុំមានអ្នកមានអំណាចមេបាចំពោះកូន តាមបញ្ញត្តិនៃមាត្រា ១០៤៨ (ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) ឬ កថាខណ្ឌទី ១ នៃមាត្រា ១០៥០ (ការលាឈប់ និង បដិទានរបស់អ្នកមានអំណាចមេបា) ហើយ បើពុំបានផ្លាស់ប្ដូរអ្នកមានអំណាចមេបា តាមបញ្ញត្តិនៃមាត្រា ១០៥១ (ការផ្លាស់ប្ដូរអ្នកមានអំណាចមេបា) ខាងលើនេះទេ អាណាព្យាបាលសម្រាប់អនីតិជនចំពោះកូននោះ ត្រូវចាប់ផ្ដើម តាមបញ្ញត្តិនៃមាត្រា ១០៦៧ (មូលហេតុនៃការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន) ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣

មាត្រា ១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង) ។

(កំណត់)

ស្ថានភាពដែលខ្វះអ្នកមានអំណាចមេបាសម្រាប់កូនដែលជាអនីតិជន ជាស្ថានភាពដែលប៉ះពាល់ទៅដល់សុខុមាលភាពរបស់កូន ។ ដូច្នេះ ក្នុងករណីនេះ អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានជ្រើសតាំង ដើម្បីបីបាច់ថែរក្សារូបកាយកូន និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ជំនួសអ្នកមានអំណាចមេបា ។ ខ្លឹមសារជាក់លាក់នៃអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានកំណត់ចាប់ពីមាត្រា ១០៦៧ នៃក្រមនេះ ។

កថាខណ្ឌទី ២ ចែងថា តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។ ដោយសារការព្យួរសិទ្ធិអំណាចរបស់អ្នកដែលមានអំណាចមេបា ត្រូវធ្វើឡើងតាមរយៈតុលាការ តុលាការនឹងអាចដឹងថា អនីតិជននឹងពុំមានអ្នកដែលមានអំណាចមេបា ។ ដូច្នេះ ដើម្បីការបីបាច់ថែទាំកុមារ បញ្ញត្តិនេះតម្រូវឱ្យតុលាការអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនបានភ្លាមៗ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៥ សិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន

**មាត្រា ១០៥៣.-** ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ក្នុងការតំណាងឱ្យកូននោះ ចំពោះសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ បើសកម្មភាពរបស់អ្នកមានអំណាចមេបា បង្កើតកាតព្វកិច្ច ដែលមានកម្មវត្ថុជាសកម្មភាពរបស់កូននោះ អ្នកមានអំណាចមេបា ត្រូវទទួលការយល់ព្រមពីកូននោះ ។

(កំណត់)

ជាធម្មតា កូនដែលជាអនីតិជន ពុំមានទ្រព្យសម្បត្តិច្រើនទេ ។ ប៉ុន្តែ អនីតិជនអាចទទួលបាននូវទ្រព្យសម្បត្តិតាមរយៈសន្តតិកម្ម ប្រទានកម្ម សំណងនៃការខូចខាត ឬ ប្រាក់ដែលបានមកពីការធានារ៉ាប់រង ជាអាទិ៍ ។ ពាក្យ "ទ្រព្យសម្បត្តិ" នៅក្នុងមាត្រានេះ រួមបញ្ចូលទាំងចលនវត្ថុ និង អចលនវត្ថុ សាច់ប្រាក់ និង សិទ្ធិលើបំណុល ជាដើម ។ ប៉ុន្តែ ទ្រព្យសម្បត្តិរបស់កូនជាអនីតិជននៅក្នុងករណីដែលបានកំណត់ក្នុងមាត្រា ១៩ និង មាត្រា ២០ នៃក្រមនេះ មិនត្រូវក្លាយជាកម្មវត្ថុនៃការគ្រប់គ្រងដែលបានចែងក្នុងមាត្រានេះឡើយ ។

ពាក្យថា "ការតំណាងឱ្យកូន" មានន័យថា អ្នកមានអំណាចមេបាធ្វើរាល់សកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់កូន ក្នុងនាមជាកូន ។ ជាធម្មតា សកម្មភាពបែបនេះមានដូចជាការចុះកិច្ចសន្យានានា ជាដើម ។ អ្នកមានអំណាចមេបា អាចធ្វើសកម្មភាពគតិយុត្តដែលមិនត្រឹមតែរួមមានសកម្មភាពគ្រប់គ្រងទ្រព្យសម្បត្តិតែប៉ុណ្ណោះទេ គឺថែមទាំងមានសកម្មភាពថែរក្សា និង សកម្មភាពចាត់ចែងទ្រព្យសម្បត្តិផងដែរ ។

ឧទាហរណ៍ចម្បងនៃវាក្យខណ្ឌទី ២ គឺជាការផ្តល់ពលកម្មដោយអនីតិជនខ្លួនឯងផ្ទាល់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៥៩.-** សកម្មភាពដែលអ្នកមានអំណាចមេបាតែម្ខាងបានធ្វើ ក្នុងនាមជាអ្នកមានអំណាចមេបាទាំងសងខាង

១-បើឪពុក ឬ ម្តាយណាម្ខាង ក្នុងចំណោមអ្នកមានអំណាចមេបារួម ធ្វើសកម្មភាពណាមួយជំនួសកូន ក្នុងនាមជាអ្នកមានអំណាចមេបាទាំងសងខាង ទោះជាសកម្មភាពនោះ ផ្ទុយនឹងឆន្ទៈរបស់ឪពុក ឬ ម្តាយម្ខាងទៀតក៏ដោយ អានុភាពនៃសកម្មភាពនោះ ពុំត្រូវបានរារាំងឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀតនៃសកម្មភាពនោះ មានបំណងទុច្ចរិត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលឪពុក ឬ ម្តាយណាម្ខាង ក្នុងចំណោមអ្នកមានអំណាចមេបារួម បានយល់ព្រមឱ្យកូនធ្វើសកម្មភាពណាមួយ ទោះបីជាសកម្មភាពនោះ ផ្ទុយនឹងឆន្ទៈរបស់ឪពុក ឬ ម្តាយម្ខាងទៀតក៏ដោយ ។

(កំណត់)

ក្នុងករណីដែលឪពុកម្តាយគឺជាអ្នកដែលមានអំណាចមេបារួមគ្នា ប្រសិនបើឪពុកម្តាយមានឆន្ទៈផ្ទុយគ្នា ទាក់ទងនឹងការលក់ដីរបស់កូន ហើយឪពុកបានលក់ដីនោះក្នុងនាមជាអ្នកដែលមានអំណាចមេបារួម ដោយមិនអើពើចំពោះឆន្ទៈរបស់ម្តាយ កិច្ចសន្យានេះនឹងត្រូវចាត់ទុកថាមានអានុភាព ប្រសិនបើភាគីម្ខាងទៀតនៃកិច្ចសន្យាធ្វើកិច្ចសន្យាដោយសុចរិត ។ គោលបំណងនៃកថាខណ្ឌទី ១ នេះ គឺការពារដល់ភាគីម្ខាងទៀតដែលបានទិញដី ។ ដោយសារតែភាគីម្ខាងទៀតមិនងាយនឹងអាចដឹងអំពីឆន្ទៈផ្សេងគ្នារបស់ឪពុកម្តាយ បញ្ញត្តិនេះត្រូវបានចែងដើម្បីធានាស្ថិរភាពនៃប្រតិបត្តិការនានាទាំងឡាយ ។

កថាខណ្ឌទី ២ ក៏មានគោលបំណងការពារភាគីម្ខាងទៀតនៃប្រតិបត្តិការដែរ ចំពោះករណីដែលបានចែងក្នុងមាត្រា ១៨ នៃក្រមនេះ ។ ឧទាហរណ៍ដូចជាករណីឪពុកបានយល់ព្រម ប៉ុន្តែ ម្តាយមិនយល់ព្រម ចំពោះការដែលកូនដែលជា

អនីតិជននឹងចុះកិច្ចសន្យា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៥៥.-** ករណីយកិច្ចប្រុងប្រយ័ត្ន នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ

អ្នកមានអំណាចមេបា ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

(កំណត់)

ទ្រព្យសម្បត្តិរបស់កូន គឺជាកម្មសិទ្ធិរបស់កូនទាំងស្រុង ។ អ្នកដែលមានអំណាចមេបាត្រូវបានបង្គាប់ដោយច្បាប់ឱ្យអនុវត្តនូវសិទ្ធិ និង បំពេញនូវករណីយកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនជាអនីតិជន ។ នាបច្ចុប្បន្ន ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ក៏បញ្ញត្តិច្បាប់នៃប្រទេសនានាសង្កត់ធ្ងន់លើភាពជាករណីយកិច្ច ជាងភាពជាសិទ្ធិដែរ ។ ដូច្នេះ អ្នកដែលមានអំណាចមេបាមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ឬ យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន នូវទ្រព្យសម្បត្តិរបស់កូន សម្រាប់ផលប្រយោជន៍របស់ខ្លួន ឬ របស់តតិយជនឡើយ ហើយក៏មិនត្រូវបានអនុញ្ញាតឱ្យគៃបន្លំធ្វើឱ្យចុះអន់ថយ ឬ ធ្វើឱ្យសឹករេចរឹល តាមរយៈការគ្រប់គ្រងដែលមិនស្មោះត្រង់ឡើយ ។ មាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណីជប៉ុន និង ច្បាប់ជាធរមានផ្សេងទៀតកំណត់នូវកម្រិតនៃករណីយកិច្ចប្រុងប្រយ័ត្នទាបត្រឹម "កម្រិតដែលប្រុងប្រយ័ត្នចំពោះទ្រព្យសម្បត្តិរបស់ខ្លួន" ប៉ុន្តែ ចំណុចនេះគួរត្រូវបានកែសម្រួល ដូច្នេះ មាត្រានេះទាមទារឱ្យមានការប្រុងប្រយ័ត្នដូចគ្នាទៅនឹង "ការប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត" ដូចបានកំណត់ក្នុងមាត្រា ៦៤០ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក) នៃក្រមនេះ ។ ប្រសិនបើអ្នកមានអំណាចមេបាធ្វើសកម្មភាពបំពានករណីយកិច្ចប្រុងប្រយ័ត្ននេះ វានឹងក្លាយទៅជាបញ្ហាដែលបានកំណត់ក្នុងមាត្រា ១០៦១ (ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ។ម្យ៉ាងទៀត ប្រសិនបើអ្នកដែលមានអំណាចមេបាបំពានករណីយកិច្ចប្រុងប្រយ័ត្ន ហើយបណ្ដាលឱ្យមានការខូចខាតចំពោះកូន វានឹងក្លាយជាអំពើអនីត្យានុកូល ហើយបញ្ហានៃសំណងការខូចខាតនឹងកើតឡើង ។

**មាត្រា ១០៥៦.-** ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ

បើកូនបានក្លាយជានីតិជនហើយ អ្នកមានអំណាចមេបា ត្រូវគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ សោហ៊ុយចិញ្ចឹមបីបាច់កូននោះ និង សោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ត្រូវចាត់ទុកថាបានទូទាត់ជាមួយនឹងផលចំណូលពីទ្រព្យសម្បត្តិរបស់កូននោះ ។

(កំណត់)

អំណាចមេបាត្រូវចប់នៅពេលដែលកូនដល់ថ្ងៃកំណើតគម្រប់អាយុ ១៨ ឆ្នាំ ហើយក្លាយជានីតិជន ។ ជាលទ្ធផល ការគ្រប់គ្រងទ្រព្យសម្បត្តិក៏ត្រូវចប់នៅពេលនោះដែរ ។ ក្នុងករណីនេះ អ្នកដែលមានអំណាចមេបាត្រូវគណនានូវចំណូល ចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ធ្វើការជម្រះបញ្ជីប្រសិនបើចាំបាច់ ហើយផ្ទេរការគ្រប់គ្រងទៅឱ្យកូន ។ ឧទាហរណ៍ ប្រសិនបើអ្នកដែលមានអំណាចមេបាលក់ដីរបស់កូនក្រោមការគ្រប់គ្រងរបស់ខ្លួន អ្នកដែលមានអំណាចមេបានោះត្រូវ ប្រគល់ប្រាក់ដែលបានមកពីការលក់នោះ ទៅឱ្យកូន ។

ឃ្លាថា "ដោយគ្មានការយឺតយ៉ាវ" ត្រូវបានប្រើប្រាស់ជាភាសាដែលមានលក្ខណៈអរូបិយ ដែលសំដៅទៅលើការ គណនាក្នុងអំឡុងពេលមួយដែលសមហេតុសមផល ដែលឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ពីព្រោះអំឡុងពេល ចាំបាច់ដើម្បីធ្វើការគណនា មានភាពខុសគ្នាអាស្រ័យទៅលើបរិមាណ និង ស្ថានភាពនៃទ្រព្យសម្បត្តិ និង អំឡុងពេល ដែលការគ្រប់គ្រងនោះបានបន្ត ។

ដោយសារតែអ្នកដែលមានអំណាចមេបាគ្រប់គ្រងទ្រព្យរបស់កូនជំនួសកូន សោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង គួរត្រូវចំណាយចេញពីទ្រព្យសម្បត្តិរបស់កូន ។ ម្យ៉ាងវិញទៀត អ្នកដែលមានអំណាចមេបាប្រហែលជាចង់បង់នូវ សោហ៊ុយក្នុងការចិញ្ចឹមបីបាច់កូន ដោយប្រើទ្រព្យរបស់កូនប្រសិនបើមាន ។ ក៏ប៉ុន្តែ ដោយសារតែការចិញ្ចឹមបីបាច់កូន គឺជាករណីយកិច្ចរបស់ឪពុកម្តាយ វាជាការមិនសមហេតុផលក្នុងការឱ្យកូនបង់នូវសោហ៊ុយទាំងនោះ ។ គោលបំណងនៃ វាក្យខណ្ឌទី ២ គឺការចាត់ទុករាល់ផលចំណូលដែលអ្នកមានអំណាចមេបាទទួលបានពីទ្រព្យសម្បត្តិថាជាសោហ៊ុយដែល ត្រូវបានបង់សម្រាប់ការចិញ្ចឹមបីបាច់កូន និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ។ វាក្យខណ្ឌទី ២ នេះ ត្រូវបានចែង ឡើងដោយហេតុផលថា មានការលំបាកក្នុងការកត់ត្រា និង ជម្រះបញ្ជីនូវរាល់ផលចំណូលដែលបានមកពីទ្រព្យសម្បត្តិ របស់កូន និង សោហ៊ុយសម្រាប់ការគ្រប់គ្រងក្នុងរយៈពេលគ្រប់គ្រងដែលជាធម្មតារយៈពេលនេះវែង ។ ហេតុដូច្នេះ ជាឧទាហរណ៍ ថ្លៃឈ្នួលដែលបានមកពីការជួលអចលនវត្ថុរបស់កូន នឹងក្លាយជាកម្មវត្ថុនៃការទូទាត់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១០៥៧.- បញ្ញត្តិពិសេស

បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៦ (ការគណនានូវចំណូលចំណាយក្នុងការ គ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះទ្រព្យសម្បត្តិដែល ត្រូវបានផ្តល់ដោយមិនគិតថ្លៃទៅឱ្យកូន ដោយតតិយជនដែលបានបង្ហាញឆន្ទៈផ្ទុយនឹង វាក្យខណ្ឌទី ២ នៃមាត្រា ១០៥៦ នោះ ។

(កំណត់)

ជាឧទាហរណ៍ ជីតាបានធ្វើប្រទានកម្មដល់ចៅជាអនីតិជននូវអាគារមួយខ្នង ។ អាគារនោះត្រូវបានដាក់ជួល ហើយ

ជីតាមានបំណងឱ្យប្រាក់ឈ្នួលនោះទៅចៅ ។ ក្នុងករណីបែបនេះ គោលបំណងនៃប្រទានកម្មនេះ មិនអាចសម្រេចបានឡើយ ប្រសិនបើអ្នកមានអំណាចមេបាគ្រប់គ្រងនូវអាគារនោះ ហើយទទួលយកប្រាក់ឈ្នួលនោះ ។ នៅពេលដែលធ្វើប្រទានកម្ម ប្រសិនបើជីតាបានបង្ហាញឆន្ទៈប្រឆាំងទៅនឹងសិទ្ធិអាស្រ័យផលរបស់អ្នកមានអំណាចមេបា អ្នកមានអំណាចមេបានោះ មិនអាចអាស្រ័យផលពីទ្រព្យសម្បត្តិនោះបានឡើយ ។ មាត្រានេះត្រូវបានតាក់តែងឡើងដើម្បីសម្រេចនូវគោលបំណងនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៥៨.-** ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន

១-ប្រសិនបើតតិយជនដែលបានផ្តល់ទ្រព្យសម្បត្តិឱ្យទៅកូនដោយមិនគិតថ្លៃ បានបង្ហាញឆន្ទៈថា មិនឱ្យឪពុកម្តាយណាម្ខាង ឬ ទាំងសងខាង ដែលអនុវត្តអំណាចមេបាគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះ ពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយណាម្ខាង ឬ ទាំងសងខាងឡើយ ។

២-ក្នុងករណីដែលអ្នកមានអំណាចមេបា ពុំបានអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតតិយជនពុំបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ តាមការទាមទាររបស់កូន ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន ឬ តំណាងអយ្យការបាន ។

៣-ទោះបីជាតតិយជនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ នៅក្នុងករណីដែលសិទ្ធិអំណាចរបស់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ បានរលត់ ឬ មានការចាំបាច់ត្រូវផ្លាស់ប្តូរអ្នកនោះ តែតតិយជននោះ មិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត ។

៤-បញ្ញត្តិចាប់ពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) រហូតដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើនេះ ។

(កំណត់)

ជាឧទាហរណ៍ ក្នុងគ្រួសារមួយមានជីដូនជីតា ឪពុកម្តាយ និង កូន ហើយជីដូន ជីតាមានទ្រព្យសម្បត្តិច្រើន ប៉ុន្តែ ឪពុកម្តាយជាមនុស្សខ្ជះខ្ជាយ ។ ជីដូនជីតាមានបំណងធ្វើប្រទានកម្មនូវទ្រព្យរបស់ខ្លួនទៅឱ្យចៅរបស់ខ្លួន ។ ប៉ុន្តែ ប្រសិនបើឪពុកម្តាយរបស់ចៅនោះគ្រប់គ្រងទ្រព្យសម្បត្តិក្នុងនាមជាអ្នកដែលមានអំណាចមេបា ឪពុកម្តាយអាចនឹងប្រើប្រាស់ទ្រព្យសម្បត្តិនោះដើម្បីផលប្រយោជន៍របស់ខ្លួន ។ ដោយសន្និដ្ឋានថា ករណីបែបនេះអាចនឹងកើតមានឡើង មាត្រានេះបានលើកលែងនូវទ្រព្យសម្បត្តិមួយចំនួនពីកម្មវត្ថុនៃការគ្រប់គ្រងដោយអ្នកដែលមានអំណាចមេបា ។ ប្រសិនបើតតិយជនគិតចង់ធ្វើប្រទានកម្មដោយឥតគិតថ្លៃនូវទ្រព្យសម្បត្តិដល់កូនដែលជាអនីតិជន ប៉ុន្តែ មិនចង់ឱ្យអ្នកមានអំណាចមេបាគ្រប់គ្រងទ្រព្យសម្បត្តិនោះ ដោយអនុលោមតាមនីតិវិធីដូចមានក្នុងមាត្រានេះ ទ្រព្យសម្បត្តិនោះ មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកមានអំណាចមេបាទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៣០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១០៥៩.- ការអនុវត្តដូចគ្នានៃបញ្ញត្តិស្តីពីអាណត្តិ

បញ្ញត្តិនៃមាត្រា ៦៥០ (ករណីយកិច្ចសង្គ្រោះបន្ទាន់ របស់អាណត្តិគាហក នៅក្រោយពេលបញ្ចប់អាណត្តិ) និង មាត្រា ៦៥១ (ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកមានអំណាចមេបា ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ករណីដែលបានកំណត់នៅក្នុងមាត្រា ១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) ខាងលើនេះ ។

(កំណត់)

ក្នុងករណីដែលការគ្រប់គ្រងទ្រព្យសម្បត្តិត្រូវចប់ ដោយសារតែកូនបានដល់នីតិភាព ឬ សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបានព្យួរ ឬ ដកហូត ប្រសិនបើអ្នកគ្រប់គ្រងនោះលែងគ្រប់គ្រងទ្រព្យសម្បត្តិភ្លាម មុនពេលដែលកូន ឬ អ្នកគ្រប់គ្រងថ្មីអាចមានលទ្ធភាពចាប់ផ្តើមគ្រប់គ្រងទ្រព្យសម្បត្តិនោះបាន ទ្រព្យសម្បត្តិនឹងស្ថិតនៅក្នុងហានិភ័យ ។ ជាឧទាហរណ៍ បញ្ហានឹងកើតឡើង ប្រសិនបើអ្នកគ្រប់គ្រងលើគោ និង សេះរបស់កូន ឈប់ផ្តល់ចំណី នៅពេលការគ្រប់គ្រងបានចប់ ។ ដើម្បីដោះស្រាយស្ថានភាពបែបនេះ មាត្រានេះកំណត់ថា បញ្ញត្តិដែលទាក់ទងនឹងអាណត្តិត្រូវយកមកអនុវត្តដូចគ្នា ហើយអ្នកគ្រប់គ្រងត្រូវបន្តនូវការគ្រប់គ្រងដែលចាំបាច់ ទោះបីជានៅក្រោយពេលការចប់ការគ្រប់គ្រងក៏ដោយ ។ ដូច្នេះ នៅក្នុងឧទាហរណ៍នេះ អ្នកគ្រប់គ្រងត្រូវតែបន្តផ្តល់ចំណីសម្រាប់គោ និង សេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៣១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៦០.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ រវាងឪពុកម្ដាយ និង កូន

១-សិទ្ធិលើបំណុលដែលកើតឡើងរវាងអ្នកមានអំណាចមេបា និង កូន ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវរលត់ដោយអាជ្ញាយុកាល បើពុំបានអនុវត្តសិទ្ធិនោះ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិអំណាចនៃការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់ ។

២-ក្នុងករណីដែលសិទ្ធិអំណាចក្នុងការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ បានរលត់នៅក្នុងពេលដែលកូនពុំទាន់ក្លាយជានីតិជន បើកូនពុំមានអ្នកតំណាងដែលច្បាប់បានកំណត់ អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាអំឡុងពេល ដោយគិតចាប់ពីពេលដែលកូននោះក្លាយជានីតិជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ ដែលស្នងបន្តនោះ បានឡើងកាន់តំណែង ។

(កំណត់)

ជាឧទាហរណ៍ ប្រសិនបើអ្នកដែលមានអំណាចមេបាបង់នូវសោហ៊ុយក្នុងការរៀបចំដីរបស់កូនជំនួសឱ្យកូន ឬ ប្រសិនបើអ្នកមានអំណាចមេបាមិនបានប្រគល់ឱ្យកូននូវប្រាក់ដែលបានមកពីការលក់ដីរបស់កូន នោះសិទ្ធិរបស់អ្នកមានអំណាចមេបាក្នុងការទាមទារនូវសោហ៊ុយក្នុងការរៀបចំដី និង សិទ្ធិរបស់កូនក្នុងការទាមទារឱ្យប្រគល់ប្រាក់ដែលបានមកពីការលក់ដី នឹងត្រូវរលត់ ដោយអាជ្ញាយុកាល នៅពេលអំឡុងពេល ៣ (បី) ឆ្នាំ កន្លងផុត ។ ដោយសារតែអ្នកមានអំណាចមេបា និង កូន ជាធម្មតា ស្នាក់នៅជាមួយគ្នា ការអនុវត្តសិទ្ធិលើបំណុលនេះមិនមានការលំបាកឡើយ ។ បន្ថែមពីលើនេះទៅទៀត ប្រសិនបើអ្នកដែលមានអំណាចមេបា ឬ កូន មិនអនុវត្តនូវសិទ្ធិនេះក្នុងរយៈពេលដ៏យូរ អ្នកដែលមានអំណាចមេបា ឬ កូន អាចត្រូវបានចាត់ទុកថា មានឆន្ទៈលះបង់នូវសិទ្ធិលើបំណុលនេះ (ការលើកលែងឱ្យរួចពីកាតព្វកិច្ច) ។

កថាខណ្ឌទី ២ ត្រូវបានចែងឡើងដើម្បីធានានូវសិទ្ធិរបស់កូនក្នុងការអនុវត្តសិទ្ធិលើបំណុល ដោយសារជាធម្មតា មានការលំបាកសម្រាប់កូនក្នុងការអនុវត្តសិទ្ធិលើបំណុល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៣២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៦ ការព្យួរ និង ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

**មាត្រា ១០៦១.-** ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

បើអ្នកមានអំណាចមេបា បានធ្វើឱ្យអន្តរាយដល់ទ្រព្យសម្បត្តិរបស់កូន ដោយសារការគ្រប់គ្រងមិនត្រឹមត្រូវ តុលាការអាចប្រកាសព្យួរ ឬ ដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រង តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

(កំណត់)

ខ្លឹមសារនៃអំណាចមេបា រួមមានការបីបាច់រក្សារូបកាយកូន និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ។ មានករណីខ្លះដែលអ្នកមានអំណាចមេបាធ្វើការបីបាច់រក្សារូបកាយកូនដោយមិនមានបញ្ហាអ្វីទេ ប៉ុន្តែ មិនសមរម្យជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ដូចជាការគ្រប់គ្រងទ្រព្យសម្បត្តិមិនត្រឹមត្រូវ ឬ ការប្រើប្រាស់ ឬ យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួននូវទ្រព្យសម្បត្តិរបស់កូន ជាអាទិ៍ ។ មាត្រានេះផ្តល់នូវយន្តការមួយក្នុងការព្យួរ ឬ ដកហូតតែសិទ្ធិអំណាចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ នៅក្នុងករណីបែបនេះ ។

សូមមើលមាត្រា ១០៤៨ (ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៣៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៦២.-** ការលុបចោលការប្រកាសការព្យួរ និង ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ១០៦១ (ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះ បានបញ្ចប់ហើយ តុលាការអាចលុបចោលការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ តាមការទាមទាររបស់សាមីជនដែលបានទទួលការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់ជននោះបាន ។

(កំណត់)

សូមមើលមាត្រា ១០៤៩ (ការលុបចោលនូវការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៦៣.-** ការលាឈប់ និង បដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ

១-បើមានមូលហេតុពុំអាចជៀសវាងបាន អ្នកមានអំណាចមេបា អាចលាឈប់ពីសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បានបញ្ចប់ហើយ អ្នកមានអំណាចមេបាដែលបានលាឈប់ពីសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ អាចទទួលបដិទាននូវសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិនោះវិញបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

(កំណត់)

សូមមើលមាត្រា ១០៥០ (ការលាឈប់ និង បដិទានរបស់អ្នកមានអំណាចមេបា) នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៦៤.-** ករណីដែលពុំមានអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ

បើពុំមានអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ តាមបញ្ញត្តិនៃមាត្រា ១០៦១ (ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ឬ កថាខណ្ឌទី ១ នៃមាត្រា ១០៦៣ (ការលាឈប់ និង បដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះទេ តុលាការត្រូវសម្រេចសេចក្ដីជ្រើសតាំងអ្នកតំណាងពិសេស ឱ្យកូន ។

(កំណត់)

ប្រសិនបើអ្នកដែលមានអំណាចមេបា អាចបីបាច់រក្សារូបកាយកូន ប៉ុន្តែ មិនអាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនបានទេ អាចមានករណីខ្លះដែលពុំមានជនណាគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនឡើយ ហើយជាលទ្ធផល អាចធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានដល់សុខុមាលភាពរបស់កូន ។ ដើម្បីប្រឈមមុខនឹងបញ្ហានេះ មាត្រានេះចែងថា តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេសឱ្យកូន តាមការសម្រេចសេចក្ដី ដោយឆន្ទានុសិទ្ធិ ។

សូមមើលមាត្រា ១០៥២ (ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន) នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ នៃមាត្រា ៨៣៧ និង មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៦៥.-** ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូន មានភាពផ្ទុយគ្នា

១- ចំពោះសកម្មភាពដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូន មានភាពផ្ទុយគ្នា អ្នកមានអំណាចមេបា ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូន ។

២-ក្នុងករណីដែលអ្នកមានអំណាចមេបា អនុវត្តអំណាចមេបាចំពោះកូនច្រើននាក់ ចំពោះសកម្មភាពដែលផលប្រយោជន៍របស់កូនម្នាក់នោះ និង កូនផ្សេងទៀត មានភាពផ្ទុយគ្នា អ្នកមានអំណាចមេបា ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូនណាម្ខាង ។

(កំណត់)

មានករណីផ្សេងៗគ្នាមួយចំនួនដែលទាក់ទងនឹងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ។

ករណីចម្បង គឺមានដូចជាការទិញនូវអចលនវត្ថុរបស់កូនដោយអ្នកមានអំណាចមេបា ឬ ការដាក់អចលនវត្ថុរបស់កូនជាប្រាតិភោគដើម្បីខ្ចីប្រាក់ដោយអ្នកមានអំណាចមេបា ។ នៅក្នុងករណីរបៀបនេះដែលអ្នកមានអំណាចមេបាមានបំណងធ្វើសកម្មភាពដែលបណ្តាលឱ្យ ឬ អាចនឹងបណ្តាលឱ្យមានភាពផ្ទុយគ្នានៃផលប្រយោជន៍រវាងអ្នកដែលមានអំណាចមេបា និង កូន អ្នកដែលមានអំណាចមេបាត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេស ហើយតុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេសដែលពុំធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់កូន ។ អ្នកតំណាងពិសេសគឺជាអ្នកតំណាងរបស់កូន ។ ប្រសិនបើសកម្មភាពដែលបណ្តាលឱ្យមានភាពផ្ទុយគ្នានៃផលប្រយោជន៍ ត្រូវបានធ្វើឡើង ដោយពុំបានជ្រើសតាំងអ្នកតំណាងពិសេសទេ ករណីនេះនឹងក្លាយជាបញ្ហាដែលបានកំណត់នៅក្នុងមាត្រា ៣៦៩ (ការតំណាងដោយគ្មានសិទ្ធិ)នៃក្រមនេះ ហើយសកម្មភាពនោះមិនត្រូវបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិ (កូន) ឡើយ លើកលែងតែម្ចាស់សិទ្ធិ (កូន) ផ្តល់សច្ចានុមតិចំពោះសកម្មភាពនោះ ។ មានន័យថា កូនអាចយកវិញនូវអចលនវត្ថុពីអ្នកដែលមានអំណាចមេបាដោយអះអាងអំពីមោឃភាពនៃកិច្ចសន្យាលក់ទិញ ឬ ទាមទារឱ្យលុបការចុះបញ្ជីអំពីការបង្កើតសិទ្ធិប្រាតិភោគ ដោយអះអាងមោឃភាពនៃការបង្កើតសិទ្ធិប្រាតិភោគបាន ។

កថាខណ្ឌទី ២ ទាក់ទងនឹងករណីដូចតទៅ : មានបងប្អូនប្រុសពីររូបដែលជាអនីតិជន ។ ឪពុករបស់បងប្អូនបានស្លាប់ហើយម្តាយក្លាយជាអ្នកមានអំណាចមេបាទោល ។ ក្នុងករណីនេះ ម្តាយត្រូវយល់ព្រម ឬ បោះបង់សន្តតិកម្មក្នុងនាមបងប្អូនប្រុសទាំងពីរនាក់ដែលជាអនីតិជននោះ ។ ប្រសិនបើម្តាយយល់ព្រមសន្តតិកម្មក្នុងនាមកូនបង ប៉ុន្តែ បោះបង់សន្តតិកម្មក្នុងនាមកូនប្អូន នោះភាពផ្ទុយគ្នានៃផលប្រយោជន៍ នឹងកើតឡើង រវាងបងប្អូនប្រុសទាំងពីរ ។ នៅក្នុងករណីនេះ ម្តាយអាចតំណាងឱ្យកូនណាម្នាក់ ហើយត្រូវទាមទារឱ្យជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូនម្នាក់ទៀតដែលមានភាព

ផ្ទុយគ្នានឹងផលប្រយោជន៍របស់កូនដែលម្ដាយតំណាងឱ្យ ។
(មាត្រាពាក់ព័ន្ធ)
មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៧ ការយកមកអនុវត្តដូចគ្នានៃជំពូកនេះ

**មាត្រា ១០៦៦.-** អ្នកជំនួសអំណាចមេបា

ចំពោះកូនរបស់អនីតិជនដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍ អ្នកមានអំណាចមេបារបស់អនីតិជននោះ ត្រូវអនុវត្តអំណាចមេបាជំនួស ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (អំណាចមេបា) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះអ្នកដែលអនុវត្តអំណាចមេបាជំនួស ។

(កំណត់)

ប្រសិនបើអនីតិជនដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍សម្រាលកូន អំណាចមេបាលើកូននោះមិនអាចត្រូវប្រគល់ឱ្យអនីតិជននោះបានឡើយ ដោយសារតែអនីតិជនខ្លួនឯងកំពុងស្ថិតនៅក្រោមអំណាចមេបា ហើយពុំមានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាពឡើយ ។ ដើម្បីដោះស្រាយបញ្ហានេះ មាត្រានេះចែងថា អ្នកដែលមានអំណាចមេបាលើអនីតិជន ត្រូវអនុវត្តអំណាចមេបាលើកូននោះដែរ ។ ការអនុវត្តអំណាចមេបាជំនួសនេះនឹងចប់នៅពេលដែលអនីតិជនដល់នីតិភាព ។ នៅក្នុងករណីជាច្រើន នៅពេលដែលអនីតិជនបង្កើតកូន ជីដូនជីតារបស់កូននោះក្លាយជាអ្នកដែលមានអំណាចមេបាលើចៅ ។

វាជាការពិតដែលបុរសដែលជាអនីតិជន ហើយមិនទាន់បានរៀបអាពាហ៍ពិពាហ៍ អាចទទួលស្គាល់កូន (មាត្រា ៩៩៣ និង មាត្រា ៩៩៤ នៃក្រមនេះ) ហើយក្លាយជាអ្នកដែលមានអំណាចមេបាបាន (មាត្រា ១០៣៨ នៃក្រមនេះ) ។ នៅក្នុងករណីនេះផងដែរ ដោយសារតែបុរសនោះខ្លួនឯងកំពុងស្ថិតក្រោមអំណាចមេបា អ្នកដែលមានអំណាចមេបាលើបុរសនោះ ត្រូវអនុវត្តអំណាចមេបាលើកូន ជំនួសឱ្យបុរសនោះ ។
(មាត្រាពាក់ព័ន្ធ)
មាត្រា ៨៣៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ៦ អាណាព្យាបាល

(កំណត់)

អាណាព្យាបាលមាន ២ ប្រភេទ ។ អាណាព្យាបាលសម្រាប់អនីតិជនដែលបានចែងនៅក្នុងផ្នែកទី ១ នៃជំពូកនេះ

គឺជារបបការពារអនីតិជន ។ បញ្ញត្តិទាក់ទងនឹងអនីតិជនដែលរួមមាននិយមន័យនៃអនីតិជន ជាអាទិ៍ ត្រូវបានបញ្ជាក់ចាប់ពីមាត្រា ១៧ ដល់ មាត្រា ២៣ នៃក្រមនេះ ។ អាណាព្យាបាលទូទៅដែលបានចែងនៅក្នុងផ្នែកទី ២ នៃជំពូកនេះ គឺជារបបការពារបុគ្គល ទោះបីជាអនីតិជន ឬ នីតិជនក៏ដោយ ឱ្យតែជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។ បញ្ញត្តិទាក់ទងនឹងជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលរួមមាននិយមន័យនៃជននៅក្រោមអាណា-ព្យាបាលទូទៅ មានចាប់ពីមាត្រា ២៤ ដល់ មាត្រា ២៧ នៃក្រមនេះ ។ ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ មិនមានបញ្ញត្តិទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន និង អាណាព្យាបាលទូទៅទេ ។ ហេតុដូច្នេះហើយ បញ្ញត្តិទាក់ទងនឹងអាណាព្យាបាលនៅក្នុងជំពូកនេះ ត្រូវបានរៀបចំឡើង បន្ទាប់ពីបានពិភាក្សាដោយក្រុមការងារ ដោយផ្អែកលើបញ្ញត្តិចាប់ពីមាត្រា ៨៣៨ ដល់មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ដោយសារតែបញ្ញត្តិទាក់ទងនឹងអាណាព្យាបាល នៃក្រមរដ្ឋប្បវេណីជប៉ុន ត្រូវបានធ្វើវិសោធនកម្មយ៉ាងច្រើនសម្បើមនៅឆ្នាំ ២០០០ ។ ជំពូកនេះឆ្លុះបញ្ចាំងពីលទ្ធផលនៃវិសោធនកម្មនៃក្រមជប៉ុន ។

## ផ្នែកទី ១ អាណាព្យាបាលសម្រាប់អនីតិជន

### កថាភាគទី ១ ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៦៧.-** មូលហេតុនៃការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើគ្មានអ្នកអនុវត្តអំណាចមេបាចំពោះអនីតិជនទេ អាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាប់ផ្ដើម ។

(កំណត់)

ជាគោលការណ៍ បុគ្គលដែលមានសិទ្ធិ និង ករណីយកិច្ចក្នុងការបីបាច់រក្សារូបកាយរបស់អនីតិជន និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជន គឺជាឪពុកម្ដាយរបស់អនីតិជននោះដែលជាអ្នកមានអំណាចមេបា (មាត្រា ១០៣៤ នៃក្រមនេះ និង មាត្រា ១១៥ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩) ។ ក៏ប៉ុន្តែ ប្រសិនបើឪពុកម្ដាយទាំងពីរនាក់ទទួលមរណភាពដោយសារជម្ងឺ ឬ គ្រោះថ្នាក់ ឬ អ្នកមានអំណាចមេបាត្រូវបានព្យួរ ឬ ដកហូតអំណាចមេបា (មាត្រា ១០៤៨ នៃក្រមនេះ) នោះនឹងមិនមានបុគ្គលណាម្នាក់ដែលអនុវត្តអំណាចមេបាទេ ហើយស្ថានភាពនេះនាំឱ្យលទ្ធភាពការពារអនីតិជនមិនគ្រប់គ្រាន់ ។ ហេតុដូច្នេះ អ្នកអាណាព្យាបាលសម្រាប់អនីតិជន នឹងត្រូវបានជ្រើសតាំងសម្រាប់ការពារអនីតិជននោះ ដោយអនុលោមតាមនីតិវិធីដែលបានចែងខាងក្រោម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ២ អ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៦៨.-** អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង

១-អ្នកដែលអនុវត្តអំណាចមេបាចុងក្រោយបង្អស់ចំពោះអនីតិជន អាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមមតកសាសន៍បាន ។

២-ប្រសិនបើគ្មានអ្នកត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះទេ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជន មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

៣-ដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការត្រូវគិតពិចារណាអំពីស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត និង ស្ថានភាពជីវភាព និង ទ្រព្យសម្បត្តិរបស់អនីតិជន វិជ្ជាជីវៈ និង ប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងអ្នកធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជន យោបល់របស់អនីតិជន និង ស្ថានភាពផ្សេងទៀតទាំងស្រុង ។

(កំណត់)

មាត្រា ១០៦៨ បញ្ជាក់អំពីរបៀបនៃការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង លក្ខណៈវិនិច្ឆ័យដែលត្រូវប្រើប្រាស់សម្រាប់ការជ្រើសតាំង ។

កថាខណ្ឌទី ១ ប្រមើលមើលពីស្ថានភាពដូចតទៅនេះ ឪពុករបស់អនីតិជនម្នាក់បានទទួលមរណភាព ហើយម្ដាយបានក្លាយជាអ្នកមានអំណាចមេបាតែម្នាក់ឯង ។ ដោយសារតែម្ដាយមានជម្ងឺដែរ ដូច្នេះ គាត់អាចទទួលមរណភាពនៅពេលណាមួយ ។ នៅក្នុងស្ថានភាពបែបនេះ ដើម្បីរៀបចំទុកជាមុនសម្រាប់ស្ថានភាពដែលគ្មានអ្នកមានអំណាចមេបា ម្ដាយត្រូវបានផ្ដល់សិទ្ធិឱ្យកំណត់បុគ្គលម្នាក់ដែលសមរម្យដើម្បីឱ្យធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ ការកំណត់

នេះត្រូវតែធ្វើឡើង ដោយអនុលោមទៅតាមទម្រង់នៃមតកសាសន៍ដែលបានចែងចាប់ពីមាត្រា ១១៦៨ នៃក្រមនេះ ។ ប្រសិនបើបុគ្គលដែលត្រូវបានកំណត់តាមមតកសាសន៍បដិសេធមិនព្រមធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនិតិជនទេ ការកំណត់នេះនឹងមិនមានន័យឡើយ ពីព្រោះគេមិនអាចចាប់បង្ខំឱ្យបុគ្គលនោះធ្វើជាអ្នកអាណាព្យាបាលបានឡើយ ។

ប្រសិនបើគ្មានការកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជនតាមរយៈមតកសាន៍ទេ ឬ បុគ្គលដែលត្រូវបានកំណត់បដិសេធចំពោះកិច្ចការនោះ អនីតិជននឹងស្ថិតនៅក្នុងស្ថានភាពដែលគ្មានអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ កថាខណ្ឌទី ២ ចែងថា ក្នុងករណីបែបនេះ តុលាការត្រូវចាប់ផ្ដើមនីតិវិធីនៃការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនតាមការទាមទាររបស់បុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលដែលបានកំណត់ ។ ជាឧទាហរណ៍ ប្រសិនបើអ្នកជិតខាងម្នាក់ដឹងថា ប្ដីប្រពន្ធដែលនៅក្បែរផ្ទះខ្លួនបានទទួលមរណភាព ហើយកូនតូចរបស់ពួកគេនៅរស់ អ្នកជិតខាងនោះមិនមានសិទ្ធិទាមទារឱ្យជ្រើសតាំងបានទេ ប៉ុន្តែ អ្នកជិតខាងនោះធ្វើសេចក្ដីរាយការណ៍ទៅមេឃុំ ឬ ចៅសង្កាត់ ហើយមេឃុំ ឬ ចៅសង្កាត់នោះដែលមានសិទ្ធិធ្វើការទាមទារ អាចទាមទារឱ្យតុលាការចាប់ផ្ដើមនីតិវិធីបាន ។ ពីទស្សនៈការពារដល់អនីតិជន សិទ្ធិទាមទារនេះមានវិសាលភាពចំពោះបុគ្គលជាច្រើន ។

កថាខណ្ឌទី ៣ បញ្ជាក់អំពីមូលដ្ឋានសម្រាប់វិនិច្ឆ័យ នៅពេលតុលាការធ្វើការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ បញ្ហាថា តើតុលាការត្រូវធ្វើការពិចារណាលើយោបល់របស់អនីតិជនដែរ ឬយ៉ាងណានោះ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ដោយសារមិនអាចកំណត់ថា តើអនីតិជនមានអាយុប៉ុន្មានដែលតុលាការត្រូវស្ដាប់យោបល់នោះ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ នៃមាត្រា ៨៣៩ មាត្រា ៨៤០ និង កថាខណ្ឌទី ៤ នៃមាត្រា ៨៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៦៩.-** ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១០៥២ (ការចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន) នៃក្រមនេះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ឱ្យបានឆាប់រហ័ស ។

(កំណត់)

មាត្រា ១០៦៩ បញ្ញត្តបង្គាប់ឱ្យតុលាការប្រើប្រាស់ឆន្ទានុសិទ្ធិជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មី ក្នុងករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង ដោយសេចក្ដីសម្រេចរបស់តុលាការដែលបានចែងក្នុងកថាខណ្ឌទី ២ មាត្រា ១០៥២ នៃក្រមនេះ ។ ទោះបីជាតុលាការមិនត្រូវបានរាប់បញ្ចូលទៅក្នុងចំណោមបុគ្គលដែលមានសិទ្ធិទាមទារដូចបានរៀបរាប់ក្នុងមាត្រា ១០៦៨ នៃក្រមនេះក៏ដោយ ក៏តុលាការអាចចាប់ផ្ដើមនីតិវិធីដោយឆន្ទានុសិទ្ធិរបស់ខ្លួន ស្របតាមមាត្រានេះបានដែរ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៨៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៧០.-** ចំនួននៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានតែម្នាក់ ។ ប៉ុន្តែ ចំពោះអនីតិជន នៅក្រោមអាណាព្យាបាលដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការ យល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមាន វិបត្តិផ្នែកបញ្ញាស្មារតី បើត្រូវចាប់ផ្តើមអាណាព្យាបាលទូទៅ តាមមាត្រា ២៤ (ការប្រកាស ការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ អ្នកអាណាព្យាបាលទូទៅម្នាក់អាចត្រូវ បានជ្រើសតាំងបាន ក្រៅពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

២-បញ្ញត្តិស្តីពីអាណាព្យាបាលទូទៅ នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាណាព្យាបាលទូទៅសម្រាប់អនីតិជន លើកលែងតែមាត្រា ១១២០ (ករណីដែល អ្នកអាណាព្យាបាលទូទៅ មានច្រើននាក់) ។

(កំណត់)

វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រា ១០៧០ កំណត់អំពីចំនួននៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានតួនាទីដូចជាឪពុកម្តាយ ។ ប្រសិនបើមានអ្នកអាណាព្យាបាលសម្រាប់អនីតិជន ពីរនាក់ ឬ ច្រើននាក់ ហើយមានយោបល់ខុសគ្នា នោះមានការពិបាកដើម្បីដោះស្រាយនូវយោបល់ខុសគ្នានោះ ។ ដោយសារតែបញ្ហានេះហើយ ទើបជាគោលការណ៍ អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវមានតែម្នាក់ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ទាក់ទងនឹងករណីដែលទាំងអាណាព្យាបាលសម្រាប់អនីតិជន និង អាណាព្យាបាល ទូទៅត្រូវចាប់ផ្តើមចំពោះអនីតិជន ។ ករណីនេះមិនបង្កឱ្យមានការភាន់ច្រឡំច្រើនដូចករណីដែលបានពន្យល់ចំពោះវាក្យ ខណ្ឌទី ១ ខាងលើទេ ពីព្រោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ទទួលខុសត្រូវក្នុងការបីបាច់រក្សារូបកាយអនីតិជន ចំណែកឯអ្នកអាណាព្យាបាលទូទៅ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជន ។

កថាខណ្ឌទី ២ ចែងអំពីការយកមកអនុវត្តដូចគ្នាផងដែរនៃបញ្ញត្តិស្តីពីអាណាព្យាបាលទូទៅ និង វិសាលភាពនៃ ការយកមកអនុវត្តដូចគ្នាផងដែរនោះ ចំពោះអាណាព្យាបាលទូទៅចំពោះអនីតិជនដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៧១.-** ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើមានមូលហេតុត្រឹមត្រូវ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលាឈប់បាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

(កំណត់)

មាត្រា ១០៧១ ចែងអំពីការលាឈប់ដោយហេតុផលត្រឹមត្រូវ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានតំណត់តាមមតកសាសន៍ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងដោយតុលាការ ។ ហេតុផលត្រឹមត្រូវរួមមានដូចជា ជម្ងឺ វ័យចំណាស់ និង ការផ្លាស់ទីលំនៅទៅឆ្ងាយ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណីប្រទេសជប៉ុន

**មាត្រា ១០៧២.-** ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានលាឈប់ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ឱ្យបានឆាប់រហ័ស ។

(កំណត់)

ពីព្រោះតែការលាឈប់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលបានចែងក្នុងមាត្រា ១០៧១ តម្រូវឱ្យមានការអនុញ្ញាតពីតុលាការ នៅពេលដែលបុគ្គលម្នាក់លាឈប់ពីអាណាព្យាបាលសម្រាប់អនីតិជន តុលាការដឹងថា អនីតិជនគ្មានអ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ ។ ក្នុងករណីនេះ ដូចក្នុងមាត្រា ១០៦៩ ដែរ មាត្រា ១០៧២ នេះចែងបង្គាប់ឱ្យតុលាការប្រើប្រាស់ឆន្ទានុសិទ្ធិជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុនចែងថា អ្នកអាណាព្យាបាលដែលលាឈប់ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកអាណាព្យាបាលថ្មីទៅតុលាការ ប៉ុន្តែ ពីព្រោះតែវាជាដំណោះស្រាយដែលមិនចំច្បាស់ យើងបានកែសម្រួលមាត្រានេះ ។

**មាត្រា ១០៧៣.-** ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានធ្វើអំពើពុំត្រឹមត្រូវ ឬ មានហេតុផ្សេងទៀតដែលមិនសមរម្យនឹងភារកិច្ចជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការអាចបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបាន តាមការទាមទាររបស់អ្នកត្រួត

ពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជន នៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ អាចបញ្ឈប់ដោយឆន្ទានុសិទ្ធិបាន ។

(កំណត់)

មាត្រានេះបញ្ជាក់អំពីបុគ្គលទាំងឡាយដែលមានសិទ្ធិទាមទារឱ្យបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបានប្រព្រឹត្តអំពើមិនសមរម្យជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដូចជាការបន្លំលួចទ្រព្យសម្បត្តិអនីតិជន ឬ ការបំពានលើអនីតិជន ។ សូមមើលសេចក្តីកំណត់នៃមាត្រា ១០៦៨ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៧៤.-** បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន

បុគ្គលដែលកំណត់ក្នុងចំណុចខាងក្រោមនេះ ពុំអាចធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានឡើយ :

ក-អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

ខ-អ្នកតំណាងដែលច្បាប់បានកំណត់ និង ហិតូបត្ថម្ភកៈ ព្រមទាំងអ្នកត្រួតពិនិត្យជនទាំងនោះ ដែលធ្លាប់ត្រូវបានតុលាការដកចេញ ។

គ-ជនដែលក្ស័យធន ។

ឃ-ជនដែលគ្មានដំណឹងអំពីទីរស់នៅ ។

(កំណត់)

មាត្រា ១០៧៤ លើកឡើងនូវល័ក្ខខ័ណ្ឌនៃបុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ ប្រសិនបើមានបុគ្គលណាដែលត្រូវនឹងល័ក្ខខ័ណ្ឌសូម្បីតែមួយក្នុងចំណោមល័ក្ខខ័ណ្ឌទាំងនេះ បុគ្គលនោះមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ ។ ជាឧទាហរណ៍ ទោះបីជាមានបុគ្គលម្នាក់ដែលត្រូវបានកំណត់ធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនតាមរយៈមតកសាសន៍ក៏ដោយ ក៏បុគ្គលនោះមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានដែរ ប្រសិនបើបុគ្គលដែលត្រូវបានកំណត់នោះក៏ជាអនីតិជនដែរ ឬ ប្រសិនបើកន្លែងរស់នៅរបស់បុគ្គលនោះមិនត្រូវបានដឹង ។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការក៏

មិនអាចជ្រើសតាំងយកបុគ្គលណាម្នាក់ដែលត្រូវនឹងល័ក្ខខ័ណ្ឌណាមួយដែលបានលើកឡើងក្នុងមាត្រានេះ មកធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានឡើយ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ៣ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៧៥.-** អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ និង អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង

១-អ្នកមានអំណាចមេបាដែលអាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចកំណត់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមមតកសាសន៍បាន ។

២-ប្រសិនបើទទួលស្គាល់ថាចាំបាច់ នៅក្នុងករណីដែលគ្មានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលត្រូវបានកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះទេ តុលាការអាចជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់របស់អនីតិជននៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ ដោយឆន្ទានុសិទ្ធិបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

( កំណត់)

អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន គឺជាអ្នកដែលត្រូវត្រួតពិនិត្យកិច្ចការរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានជ្រើសតាំងតែនៅពេលដែលមានភាពចាំបាច់តែប៉ុណ្ណោះ ពីព្រោះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនត្រូវការចាំបាច់ជានិច្ចកាលទេ ។ ដូចកថាខណ្ឌទី ១ នៃមាត្រា ១០៦៨ ដែរ កថាខណ្ឌទី ១ នៃមាត្រា ១០៧៥ ចែងថា អ្នកដែលអនុវត្តអំណាចមេបាចុងក្រោយបង្អស់សម្រាប់អនីតិជន អាចកំណត់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនតាមមតកសាសន៍បាន ។

មតកជនអាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនទាំងពីរនាក់ក៏បាន កំណត់តែអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនម្នាក់ប៉ុណ្ណោះក៏បាន ។ ក្នុងករណីដែលមតកជនកំណត់តែអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនប៉ុណ្ណោះ តុលាការនឹងជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ កថាខណ្ឌទី ២ បញ្ជាក់អំពីបុគ្គលដែលមានសិទ្ធិទាមទារឱ្យជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ ទោះបីជាមានការទាមទារឱ្យជ្រើសតាំងក៏ដោយ ក៏តុលាការអាចបដិសេធការជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលបានសម្រាប់អនីតិជនបានដែរ ប្រសិនបើតុលាការយល់ឃើញថា ការជ្រើសតាំងមិនមានការចាំបាច់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៨ និង មាត្រា ៨៤៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១០៧៦.- បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានឡើយ ។[៦]

(កំណត់)

ប្រសិនបើបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនឹងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានជ្រើសតាំងជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ការត្រួតពិនិត្យអាចនឹងក្លាយទៅជាគ្មានប្រសិទ្ធភាព ។ ដោយសារតែមូលហេតុនេះហើយ មាត្រានេះចែងថា ញាតិក្នុងទំហំជាកំណត់មួយ មិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១០៧៧.- តួនាទីរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានតួនាទីដូចកំណត់ខាងក្រោមនេះ :

ក-ត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

[៦] មាត្រា ១០៧៦ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ខ-ទាមទារឱ្យតុលាការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ដោយគ្មានការយឺតយ៉ាវ ក្នុងករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

គ-ធ្វើការចាត់ចែងចាំបាច់ ចំពោះការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ ក្នុងករណីដែលមានស្ថានភាពបន្ទាន់ ។

ឃ-តំណាងឱ្យអនីតិជននៅក្រោមអាណាព្យាបាល ចំពោះសកម្មភាពដែលផលប្រយោជន៍របស់អនីតិជននៅក្រោមអាណាព្យាបាល និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានភាពផ្ទុយគ្នា ។

(កំណត់)

មាត្រា ១០៧៧ កំណត់តួនាទីរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ ចំណុច គ ទទួលស្គាល់នូវសិទ្ធិរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ក្នុងការធ្វើការចាត់ចែងដែលចាំបាច់សម្រាប់អនីតិជននៅក្រោមអាណាព្យាបាល ជាឧទាហរណ៍ ក្នុងករណីដែលអនីតិជនត្រូវការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬ ត្រូវការវះកាត់ដោយសារតែជម្ងឺភ្លាមៗ នៅពេលអ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនអាចធ្វើកិច្ចការរបស់ខ្លួនដោយសារនៅបរទេស ។ ចំណុច គ នេះមានគោលបំណងអនុញ្ញាតឱ្យអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ធ្វើកិច្ចការបន្ទាន់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនជាបណ្តោះអាសន្ន ជំនួសអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីការពារអនីតិជន ។ ចំណុច ឃ ទាក់ទងនឹងករណីដូចតទៅ : នៅពេលដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនទិញអចលនវត្ថុដែលអនីតិជនទទួលជាមតិកពីឪពុកម្តាយ អ្នកអាណាព្យាបាលអាចប្រើសិទ្ធិអំណាចដោយបំពាន ដើម្បីទិញអចលនវត្ថុនោះក្នុងតម្លៃទាបដែលមិនសមរម្យ ។ ក្នុងស្ថានភាពដែលមានភាពផ្ទុយគ្នានៃផលប្រយោជន៍រវាងអនីតិជន និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនមែនអ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ ប៉ុន្តែ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលគួរតំណាងឱ្យអនីតិជន ដើម្បីកុំឱ្យផលប្រយោជន៍របស់អនីតិជនត្រូវរងការខូចខាត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៧៨.-** បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា

បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង

មូលដ្ឋាននៃការជ្រើសតាំង) មាត្រា ១០៧១ (ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៧៣ (ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៧៤ (បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន) កថាខណ្ឌទី ២ នៃមាត្រា ១០៨៧ (គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១០៩៣ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា ១១០០ (ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន) និង មាត្រា ១១០១ (ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

(កំណត់)

មាត្រានេះចែងថា បញ្ញត្តិផ្សេងៗដែលទាក់ទងនឹងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥២ នៃក្រមរដ្ឋប្បវេណីជប៉ុន

### កថាភាគទី ៤ តួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៧៩.-** សិទ្ធិ និង ករណីយកិច្ចនៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងអ្នកមានអំណាចមេបា ចំពោះចំណុចដែលបានកំណត់នៅក្នុងផ្នែកទី ៣ (សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា) ជំពូកទី ៥ នៃគន្ថីទី ៧ នេះ ។ ប៉ុន្តែ ដើម្បីផ្លាស់ប្តូរវិធីអប់រំ និង ទីសំណាក់ដែលត្រូវបានកំណត់ដោយអ្នកមានអំណាចមេបា ដាក់ទណ្ឌកម្មលើអនីតិជននៅក្រោមអាណាព្យាបាល អនុញ្ញាតឱ្យប្រកបអាជីវកម្ម លុបចោលការអនុញ្ញាតឱ្យប្រកបអាជីវកម្ម ឬ កម្រិតអាជីវកម្ម បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់

អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណា-ព្យាបាលសម្រាប់អនីតិជន ត្រូវពិភាក្សាជាមួយនឹងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ចំពោះចំណុចដែលបានកំណត់នៅក្នុងមាត្រា ១០៤២ (ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងនឹងកូន) នៃក្រមនេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានភាពចាំបាច់បន្ទាន់ ។

(កំណត់)

មាត្រា ១០៧៩ បញ្ជាក់អំពីសិទ្ធិ និង ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ កថាខណ្ឌទី ១ ចែងថា អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងអ្នកមានអំណាចមេបា ។ អាចនិយាយបានថា អ្នកអាណាព្យាបាល គឺជាអ្នកជំនួសឪពុកម្តាយ ។ ទោះបីជាយ៉ាងនេះក៏ដោយ ជាឧទាហរណ៍ ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនម្នាក់ត្រូវបានជ្រើសតាំង ដោយសារមរណភាពរបស់ឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវគោរពនូវឆន្ទៈរបស់ឪពុកម្តាយនោះ ប្រសិនបើឪពុកម្តាយនោះបានកំណត់អំពីវិធីអប់រំ ឬបញ្ហាដទៃទៀតកាលដែលនៅរស់ ។ ហេតុដូច្នេះហើយ ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន ផ្លាស់ប្តូរបញ្ហាណាមួយក្នុងចំណោមបញ្ហាដែលបានកំណត់ក្នុងមាត្រានេះ ខុសពីអ្វីដែលអ្នកមានអំណាចមេបាបានកំណត់កាលពីអតីតកាលនោះ អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីការពារឆន្ទៈរបស់អ្នកមានអំណាចមេបា និង របស់អនីតិជន ។ កថាខណ្ឌ ទី ២ ចែងអំពីគោលការណ៍ថា ប្រសិនបើអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានជ្រើសតាំង អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវពិភាក្សាជាមួយនឹងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន នៅពេលដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនធ្វើការវិនិច្ឆ័យអំពីបញ្ហាដែលកំណត់នៅក្នុងមាត្រា ១០៤២ ។ កថាខណ្ឌនេះអនុវត្តចំពោះករណីដូចតទៅនេះ : ឧទាហរណ៍ ពីព្រោះតែអនីតិជនមានជម្ងឺធ្ងន់ធ្ងរ ហើយវិធីព្យាបាលមានច្រើនប្រភេទ មានការចាំបាច់ណាស់ក្នុងការសម្រេចចិត្តដើម្បីជ្រើសរើសវិធីព្យាបាលមួយពីក្នុងចំណោមមធ្យោបាយដែលមានច្រើន ។ ករណីនេះទាក់ទងនឹងចំណុច ឃ នៃមាត្រា ១០៤២ ។ ក៏ប៉ុន្តែ ការពិភាក្សានឹងមិនអាចធ្វើទៅបានទេ នៅពេលដែលអនីតិជនមានគ្រោះថ្នាក់ ហើយទាមទារឱ្យមានការជ្រើសរើសភ្លាមៗ នូវរបៀបព្យាបាលតាមវេជ្ជសាស្ត្រ ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ នេះចែងថា មិនចាំបាច់មានកិច្ចពិភាក្សាទេ ក្នុងករណីមានភាពចាំបាច់បន្ទាន់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៨០.-** ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ហើយត្រូវធ្វើជាតំណាងឱ្យអនីតិជននៅក្រោមអាណាព្យាបាល ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់អនីតិជននោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រា ១០៨០ ចែងអំពីតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជន ។ ជាធម្មតា អាណាព្យាបាលសម្រាប់អនីតិជនចាប់ផ្ដើមដោយសារមរណភាពរបស់ឪពុកម្ដាយរបស់អនីតិជន ។ ក្នុងករណីនេះ អនីតិជននោះនឹងមានទ្រព្យសម្បត្តិមួយចំនួន ដោយធ្វើសន្តតិកម្មចំពោះទ្រព្យសម្បត្តិរបស់ឪពុកម្ដាយ ឬ ដោយទទួលបាននូវសំណងការខូចខាត ឬ ផលប្រយោជន៍ធានារ៉ាប់រងផ្សេងៗ ។ ប្រសិនបើបញ្ញត្តិអំពីការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជនក្នុងករណីបែបនេះ មិនត្រូវបានរៀបចំឱ្យបានត្រឹមត្រូវទេ ករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនរំលោភបំពានលើទ្រព្យសម្បត្តិរបស់អនីតិជន អាចកើតឡើង ។ ហេតុដូច្នេះ កថាខណ្ឌទី ១ ចែងថា អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជន និង ធ្វើការតំណាងជាសកលឱ្យអនីតិជន នៅពេលអនុវត្តសកម្មភាពទាំងឡាយទាក់ទងនឹងទ្រពសម្បត្តិរបស់អនីតិជន ដូចជាការចុះកិច្ចសន្យាលក់ទិញ ឬ ភតិសន្យា ជាដើម ។ ជាឧទាហរណ៍ ប្រសិនបើផ្ទះដែលជាកម្មសិទ្ធិរបស់អនីតិជន ត្រូវបានជួល ភតិបតីត្រូវបានបញ្ជាក់សរសេរថា "ឈ្មោះ 0000 ដែលជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឈ្មោះ.........." នៅក្នុងភតិសន្យានោះ ។ កថាខណ្ឌទី ២ ចែងថា វាក្យខណ្ឌទី ២ នៃមាត្រា ១០៥៣ ដែលតម្រូវឱ្យមានការយល់ព្រមរបស់អនីតិជន ក្នុងករណីដែលធ្វើកិច្ចសន្យាដែលមានគោលបំណងឱ្យអនីតិជនធ្វើសកម្មភាព ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។ ឧទាហរណ៍ ប្រសិនបើអ្នកអាណាព្យាបាលចុះកិច្ចសន្យាការងារជាមួយបុគ្គលណាម្នាក់ដើម្បីឱ្យអនីតិជនធ្វើការ អ្នកអាណាព្យាបាលត្រូវទទួលការយល់ព្រមពីអនីតិជន ។ ប្រសិនបើអនីតិជនមិនអាចយល់ព្រមចំពោះកិច្ចព្រមព្រៀងនោះ ឬ មិនអាចយល់អំពីអត្ថន័យត្រឹមត្រូវនៃការយល់ព្រមទេ គេមិនអាចនិយាយបានថា អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទទួលបាននូវការយល់ព្រមនេះឡើយ ។ ដូច្នេះ អ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនអាចចុះកិច្ចសន្យាការងារនោះបានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៨១.-** ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាប់ផ្ដើមស្រាវជ្រាវទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលបានកាន់តំណែង ហើយត្រូវបញ្ចប់ការស្រាវជ្រាវនោះ នៅក្នុងអំឡុងពេល ៣ (បី) ខែ និង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាននៅតុលាការ ។

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ការស្រាវ-ជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ពុំមានអានុភាពឡើយ បើគ្មានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ ។

(កំណត់)

មាត្រា ១០៨១ តម្រូវឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនរៀបចំបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់អនីតិជន ។ មានករណីជាច្រើនដែលអនីតិជន និង អ្នកអាណាព្យាបាលសម្រាប់អនីតិជនរស់នៅជាមួយគ្នា ។ ការរស់នៅជាមួយគ្នានេះអាចធ្វើឱ្យមានការលាយឡំគ្នារវាងទ្រព្យសម្បត្តិរបស់អនីតិជន និង ទ្រព្យសម្បត្តិរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយកើតឡើងនូវស្ថានភាពមិនច្បាស់លាស់ចំពោះកម្មសិទ្ធិលើទ្រព្យសម្បត្តិទាំងនោះ ។ ទ្រព្យសម្បត្តិរបស់អនីតិជន គឺជារបស់អនីតិជន រីឯអ្នកអាណាព្យាបាលសម្រាប់អនីតិជនគ្រាន់តែគ្រប់គ្រងប៉ុណ្ណោះ ។ កថាខណ្ឌទី ១ បង្គាប់ឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនធ្វើការស្រាវជ្រាវទ្រព្យសម្បត្តិរបស់អនីតិជន និង រៀបចំបញ្ជីសារពើភ័ណ្ឌ ។ ប្រសិនបើការស្រាវជ្រាវ និង ការរៀបចំបញ្ជីសារពើភ័ណ្ឌមិនអាចបញ្ចប់ក្នុងអំឡុងពេល ៣ ខែ ដោយសារអនីតិជនមានទ្រព្យសម្បត្តិច្រើនពេក ឬ អនីតិជនមានទ្រព្យសម្បត្តិនៅបរទេស ឬ ការបែងចែកមត៌ករបស់ឪពុកម្ដាយដែលទទួលមរណភាពមិនទាន់ចប់សព្វគ្រប់ ជាអាទិ៍ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចដាក់ពាក្យសុំឱ្យតុលាការពន្យារពេលបាន ។ តុលាការនឹងសួរហេតុផលពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយសម្រេចថា តើត្រូវអនុញ្ញាតឱ្យពន្យារពេលដែរ ឬយ៉ាងណា ។ ប្រសិនបើតុលាការអនុញ្ញាតឱ្យពន្យារពេល តុលាការត្រូវកំណត់អំឡុងពេលដែលពន្យារនោះ ។ កថាខណ្ឌទី ២ ចែងថា ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវចូលរួមក្នុងការស្រាវជ្រាវទ្រព្យសម្បត្តិរបស់អនីតិជន និង ការរៀបចំបញ្ជីសារពើភ័ណ្ឌ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៨២.-** សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ

រហូតដល់ពេលបញ្ចប់ការធ្វើបញ្ជីសារពើភ័ណ្ឌ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិអំណាច ចំពោះតែសកម្មភាពដែលមានភាពចាំបាច់បន្ទាន់ប៉ុណ្ណោះ ។ ប៉ុន្តែ សកម្មភាពនេះមិនអាចតតាំងនឹងតតិយជនដែលសុចរិតបានឡើយ ។

(កំណត់)

វិសាលភាពនៃទ្រព្យសម្បត្តិរបស់អនីតិជនដែលត្រូវគ្រប់គ្រងដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចកំណត់បានឡើយ រហូតដល់ការបញ្ចប់ការរៀបចំបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ។ ក៏ប៉ុន្តែ ឧទាហរណ៍ថា ប្រសិនបើដំបូលផ្ទះរបស់អនីតិជនត្រូវការជួសជុលមុនរដូវវស្សាមកដល់ ប៉ុន្តែ ការរៀបចំនូវបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ មិនទាន់ចប់សព្វគ្រប់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចត្រូវបានអនុញ្ញាតឱ្យរកជាងឈើមកជួសជុលដំបូលផ្ទះនោះ និង បង់ថ្លៃជួសជុលដំបូលផ្ទះនោះ ដោយដកប្រាក់ចេញពីទ្រព្យសម្បត្តិរបស់អនីតិជន មុនការបញ្ចប់ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។ វាក្យខណ្ឌទី ២ ចែងថា ចំពោះសកម្មភាពដែលធ្វើដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជន ទោះបីជាសកម្មភាពនោះមិនមានភាពចាំបាច់បន្ទាន់ក៏ដោយ ក៏អនីតិជនមិនត្រូវបានអនុញ្ញាតឱ្យអះអាងថា សកម្មភាពនោះជាសកម្មភាពតំណាងដែលគ្មានសិទ្ធិ ប្រសិនបើតតិយជនសុចរិត ។ ជាធម្មតា តតិយជនមិនដឹងថា តើបញ្ជីសារពើភ័ណ្ឌត្រូវបានរៀបចំហើយ ឬនៅនោះទេ ពីព្រោះការរៀបចំបញ្ជីសារពើភ័ណ្ឌគឺជាបញ្ហារវាងអនីតិជន និង អ្នកអាណាព្យាបាលតែប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៨៣.-** ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលមានចំពោះអនីតិជននៅក្រោមអាណាព្យាបាល

១-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិលើបំណុល ឬ កាតព្វកិច្ច ចំពោះអនីតិជននៅក្រោមអាណាព្យាបាល ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវរាយការណ៍

ជូនអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនអំពីសិទ្ធិលើបំណុល ឬ កាតព្វកិច្ច នោះ នៅមុនពេលចាប់ផ្តើមការស្រាវជ្រាវទ្រព្យសម្បត្តិ ។

២-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានដឹងថាមានសិទ្ធិលើបំណុល ចំពោះអនីតិជននៅក្រោមអាណាព្យាបាល តែបើមិនបានរាយការណ៍ទេ អ្នកអាណាព្យាបាល នោះ ត្រូវបាត់បង់សិទ្ធិលើបំណុលនោះ ។

(កំណត់)

សូមយកស្ថានភាពដូចតទៅនេះជាឧទាហរណ៍ : អាណាព្យាបាលសម្រាប់អនីតិជនបានចាប់ផ្តើម ដោយសារឪពុកម្តាយរបស់អនីតិជនបានទទួលមរណភាព ហើយមិត្តភក្តិរបស់ឪពុកម្តាយម្នាក់ត្រូវបានជ្រើសតាំងជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ ឪពុកម្តាយបានខ្ចីលុយពីមិត្តភក្តិនោះ ។ ក្នុងស្ថានភាពបែបនេះ អនីតិជនបានទទួលបន្តនូវកាតពកិច្ច តាមសន្តតិកម្ម ។ មានន័យថា អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសិទ្ធិលើបំណុលចំពោះអនីតិជន ។ ស្ថានភាពផ្ទុយពីករណីនេះ (អនីតិជនឹងក្លាយទៅជាម្ចាស់បំណុលចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន) ក៏អាចកើតឡើងដែរ ។ ដោយសារតែអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានដឹងអំពីស្ថានភាពនេះយ៉ាងច្បាស់ ក្នុងករណីដែលអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលត្រូវបានជ្រើសតាំង មាត្រានេះតម្រូវឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនរាយការណ៍ជាបឋមអំពីសិទ្ធិលើបំណុល ឬ កាតព្វកិច្ច ទៅអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីទំនាក់ទំនងនៃទ្រព្យសម្បត្តិរវាងភាគី ។ នេះជាខ្លឹមសារនៃកថាខណ្ឌទី ១ ។ កថាខណ្ឌទី ២ ចែងថា ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនបានរាយការណ៍ដូចបានចែងក្នុងកថាខណ្ឌទី ១ ទេ សិទ្ធិលើបំណុលរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនចំពោះអនីតិជន (កាតព្វកិច្ចរបស់អនីតិជន) ត្រូវរលត់ ។ កថាខណ្ឌនេះមានគោលបំណងទប់ស្កាត់អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនពីការរំលោភលើទ្រព្យសម្បត្តិរបស់អនីតិជន ដោយក្លែងបន្លំសិទ្ធិលើបំណុល បន្ទាប់ពីដឹងថាអនីតិជនមានទ្រព្យសម្បត្តិច្រើន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៨៤.-** ការយកមកអនុវត្តដូចគ្នា ចំពោះករណីដែលអនីតិជននៅក្រោមអាណាព្យាបាល បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល

បញ្ញត្តិនៃមាត្រា ១០៨១ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ) មាត្រា ១០៨២ (សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ) និង មាត្រា ១០៨៣ (ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់

អនីតិជន ដែលមានចំពោះអនីតិជននៅក្រោមអាណាព្យាបាល) ខាងលើនេះ ត្រូវយកមក អនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអនីតិជននៅក្រោមអាណាព្យាបាល បានធ្វើលទ្ធកម្ម នូវទ្រព្យសម្បត្តិសកល នៅក្រោយពេលដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានកាន់តំណែង ។

(កំណត់)

មាត្រា ១០៨៤ ទាក់ទងនឹងករណីដូចតទៅ : បន្ទាប់ពីអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានកាន់តំណែង ជីតារបស់អនីតិជនទទួលមរណភាព ហើយអនីតិជនធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ជីតា ។ ក្នុងករណីបែបនេះ មាត្រា ១០៨១ ដល់មាត្រា ១០៨៣ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។ ហេតុដូច្នេះ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវស្រាវជ្រាវអំពីទ្រព្យសម្បត្តិដែលអនីតិជនធ្វើលទ្ធកម្មថ្មី និង រៀបចំបញ្ជីសារពើភ័ណ្ឌចំពោះទ្រព្យសម្បត្តិនោះ ហើយ ត្រូវរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចដែលពាក់ព័ន្ធជាមួយទ្រព្យសម្បត្តិថ្មីៗទាំងនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៨៥.-** ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ដើម្បីលក់ ជួល រំលាយភតិសន្យា បង្កើតហ៊ីប៉ូតែក ឬ ធ្វើការចាត់ចែងផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា នូវអចលនវត្ថុដែលប្រើជាលំនៅឋានរបស់អនីតិជន នៅក្រោមអាណាព្យាបាល ជំនួសអនីតិជននៅក្រោមអាណាព្យាបាល អ្នកអាណាព្យាបាល សម្រាប់អនីតិជន ត្រូវទទួលការអនុញ្ញាតពីតុលាការ ។

(កំណត់)

ប្រសិនបើមានការចុះកិច្ចសន្យាដូចជាកិច្ចសន្យាលក់ទិញ ជាដើម ចំពោះអចលនវត្ថុដែលអនីតិជនកំពុងប្រើប្រាស់ជា លំនៅឋាន ការណ៍នេះនឹងបង្កនូវអស្ថិរភាពចំពោះលំនៅរបស់អនីតិជននោះ ។ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនគួរធ្វើសកម្មភាពណាដែលនឹងធ្វើឱ្យអន្តរាយដល់មូលដ្ឋានគ្រឹះនៃជីវិតរបស់អនីតិជនឡើយ ។ ក៏ប៉ុន្តែ ប្រសិនបើតម្លៃនៃ ទ្រព្យសម្បត្តិរបស់អនីតិជនមានតិចតួច ហើយចាំបាច់មានចំណាយសម្រាប់សោហ៊ុយអប់រំ ឬ ថ្លៃព្យាបាលជម្ងឺ ស្ថានភាព ដែលចាំបាច់លក់លំនៅឋានរបស់អនីតិជនដើម្បីទប់ទល់ការចំណាយនោះ ឬ បង្កើតហ៊ីប៉ូតែកលើលំនៅឋានរបស់អនីតិជន ដើម្បីខ្ចីប្រាក់ អាចកើតឡើងអាស្រ័យទៅតាមកាលៈទេសៈ ។ ហេតុដូច្នេះ ចំពោះការចាត់ចែងអចលនវត្ថុដែលជា លំនៅឋានបែបដូច្នេះ មាត្រានេះតម្រូវឱ្យមានការចូលរួមពីតុលាការ ដើម្បីកុំឱ្យអចលនវត្ថុនោះអាចត្រូវបានចាត់ចែង ដោយងាយៗពេក ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៩-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៨៦.-** សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល មានភាពផ្ទុយគ្នា

បញ្ញត្តិនៃមាត្រា ១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូន មានភាពផ្ទុយគ្នា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

(កំណត់)

ឧទាហរណ៍ថា អនីតិជនត្រូវជាក្មួយប្រុស រីឯអ្នកអាណាព្យាបាលសម្រាប់អនីតិជនគឺជាពូ ហើយបុរសម្នាក់ដែលត្រូវជាជីតារបស់អនីតិជន និង ត្រូវជាឪពុករបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន បានទទួលមរណភាព ដូច្នេះ សន្តតិកម្មក៏បានចាប់ផ្តើម ។ ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជនបោះបង់សន្តតិកម្មក្នុងនាមអនីតិជន នោះចំណែកមតិករបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននឹងកើនឡើង ។ ករណីនេះ គឺជាស្ថានភាពមួយដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជន មានភាពផ្ទុយគ្នា ហេតុដូច្នេះ មាត្រា ១០៦៥ នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនេះ ដើម្បីតម្រូវឱ្យជ្រើសតាំងអ្នកតំណាងពិសេសដែលជាបុគ្គលដែលធ្វើការវិនិច្ឆ័យជំនួសអនីតិជនដោយអព្យាក្រឹតថា តើត្រូវបោះបង់សន្តតិកម្ម ឬយ៉ាងណា ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានជ្រើសតាំងហើយនោះ ចំណុច ឃ មាត្រា ១០៧៧ នៃក្រមនេះចែងថា អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវតំណាងឱ្យអនីតិជន ហេតុដូច្នេះ ការជ្រើសតាំងអ្នកតំណាងពិសេសមិនចាំបាច់ទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៨៧.-** គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវធ្វើគម្រោងចំនួនប្រាក់ដែលត្រូវចំណាយជារៀងរាល់ឆ្នាំ ដើម្បីគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ នៅជំហានដំបូងនៃពេលដែលបានចាប់ផ្តើមកាន់

តំណែង ។

២-សោហ៊ុយចាំបាច់ ដើម្បីអ្នកអាណាព្យាបាលសម្រាប់អនីតិជនបំពេញតួនាទីអាណាព្យាបាលសម្រាប់អនីតិជន ត្រូវចំណាយចេញពីទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ។

(កំណត់)

នៅពេលអ្នកអាណាព្យាបាលសម្រាប់អនីតិជនកាន់តំណែង អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវពិចារណា និង ធ្វើគម្រោងអំពីចំនួនទឹកប្រាក់ដែលត្រូវចំណាយជារៀងរាល់ឆ្នាំសម្រាប់ការបីបាច់ថែរក្សារូបកាយរបស់អនីតិជន និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជន ។ ប្រាក់ដែលត្រូវចំណាយប្រចាំឆ្នាំរួមមានការចំណាយសម្រាប់សម្លៀកបំពាក់ ម្ហូបអាហារ ការស្នាក់នៅ និង ការអប់រំរបស់អនីតិជន និង ការជួសជុលផ្ទះរបស់អនីតិជន ជាដើម ។ កថាខណ្ឌទី ១ រារាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ក្នុងការកាត់បន្ថយទ្រព្យសម្បត្តិរបស់អនីតិជនដោយធ្វេសប្រហែស ។ កថាខណ្ឌទី ២ កំណត់ថា សោហ៊ុយដែលចាំបាច់សម្រាប់សម្លៀកបំពាក់ ម្ហូបអាហារ ការស្នាក់នៅ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជន ត្រូវចំណាយចេញពីទ្រព្យសម្បត្តិរបស់អនីតិជន ។ អាណាព្យាបាលសម្រាប់អនីតិជន មិនមែនជារបបដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនធ្វើទានដល់អនីតិជនទេ ។ ដោយសារតែអាណាព្យាបាលសម្រាប់អនីតិជន គឺជាករណីយកិច្ចតាមផ្លូវច្បាប់ដើម្បីចិញ្ចឹមបីបាច់រក្សាអនីតិជន ដោយប្រើទ្រព្យសម្បត្តិរបស់អនីតិជននោះ វាជារឿងធម្មតាទេ ដែលសោហ៊ុយសម្រាប់អាណាព្យាបាលសម្រាប់អនីតិជនត្រូវចំណាយចេញពីទ្រព្យសម្បត្តិរបស់អនីតិជន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១០៨៨.- កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

តុលាការ អាចផ្តល់កម្រៃសមរម្យ ពីក្នុងចំណោមទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ឱ្យទៅអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល ព្រមទាំងស្ថានភាពផ្សេងទៀតបាន ។

(កំណត់)

អាណាព្យាបាលសម្រាប់អនីតិជនអាចតម្រូវឱ្យចំណាយពេលវេលាជាច្រើន ឬ តម្រូវឱ្យយកចិត្តទុកដាក់យ៉ាងខ្លាំង អាស្រ័យទៅលើស្ថានភាពសុខភាព ឬ ស្ថានភាពទ្រព្យសម្បត្តិរបស់អនីតិជន ។ ក្នុងករណីខ្លះ អ្នកជំនាញផ្នែកច្បាប់ ដូចជាមេធាវី ឬ អ្នកជំនាញផ្នែកផ្សេងទៀតទទួលតួនាទីអាណាព្យាបាលសម្រាប់អនីតិជន ។ ក្នុងករណីនេះ តុលាការ

អាចវិនិច្ឆ័យអំពីការផ្ដល់កម្រៃដែលត្រូវបង់ឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយដកចេញពីទ្រព្យសម្បត្តិរបស់អនីតិជន ដោយគិតពិចារណាទៅលើកាលៈទេសៈផ្សេងៗ ។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនត្រូវបានអនុញ្ញាតឱ្យធ្វើការចាយវាយប្រាក់ដោយដកចេញពីទ្រព្យសម្បត្តិរបស់អនីតិជន តាមចិត្តរបស់ខ្លួនឯងដោយយកលេសថា ប្រាក់ដែលចាយនោះគឺជាកម្រៃដែលត្រូវបង់មកខ្លួនឡើយ ។

**មាត្រា ១០៨៩.-** ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ តុលាការ អាចទាមទារឱ្យអ្នកអាណាព្យាបាលនោះ រាយការណ៍អំពីតួនាទីរបស់ខ្លួន ឬ ដាក់បញ្ជីសារពើភ័ណ្ឌ ឬ អាចស្រាវជ្រាវអំពីអនីតិជននៅក្រោមអាណាព្យាបាល ឬ ស្ថានភាពទ្រព្យសម្បត្តិរបស់អនីតិជននោះ នៅពេលណាក៏បាន ។

២-តុលាការ អាចបង្គាប់ឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ធ្វើការចាត់ចែងចាំបាច់ ដែលទាក់ទងនឹងការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល ឬ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ ឬ ការចាត់ចែងចាំបាច់ផ្សេងទៀតដែលទាក់ទងទៅនឹងអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណា-ព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននោះ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននោះ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ ឬ ដោយឆន្ទានុសិទ្ធិបាន ។

(កំណត់)

មាត្រា ១០៨៩ ចែងថា អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ តុលាការអាចត្រួតពិនិត្យការអនុវត្តកិច្ចការអាណាព្យាបាលរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនបាន ។ កថាខណ្ឌទី ១ ចែងថា អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ តុលាការអាចទាមទារឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនរាយការណ៍ ឬ ដាក់បញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ នៅពេលណាក៏បាន ហើយអ្នកត្រួតពិនិត្យអាណាព្យាបាលសម្រាប់អនីតិជន ឬ តុលាការអាចស្រាវជ្រាវអំពីស្ថានភាពរបស់អនីតិជនដោយឯកឯងនៅពេលណាក៏បាន ។ ក៏ប៉ុន្តែ តាមសភាពជាក់ស្ដែង តុលាការមិនអាចមានលទ្ធភាពដឹងច្បាស់អំពីស្ថានភាពរបស់អនីតិជនជានិរន្តរ៍ទេ ។ ហេតុដូច្នេះហើយ នៅពេលមានការទាមទាររបស់បុគ្គលណាម្នាក់ ក្នុងចំណោមបុគ្គលដែលកំណត់ក្នុងកថាខណ្ឌទី ២ តុលាការអាចបង្គាប់ឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ធ្វើការចាត់ចែងចាំបាច់ទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន ។ "ការចាត់ចែងចាំបាច់" នេះ រួមមានការបង្គាប់ឱ្យដាក់របាយការណ៍លម្អិត និង បញ្ជីសារពើភ័ណ្ឌលម្អិតនៃទ្រព្យសម្បត្តិ ការព្យួរនូវសកម្មភាពរបស់អ្នក

អាណាព្យាបាលសម្រាប់អនីតិជនដែលមិនសមស្របនឹងតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ក្នុងករណីដែលមានការបារម្ភថា នឹងមានសកម្មភាពនោះ និង ការបង្គាប់ឱ្យប្រគល់មកវិញនូវទ្រព្យសម្បត្តិដែលបានគៃបន្លំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៩០.-** ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម

ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ ជំនួសអនីតិជននៅក្រោមអាណាព្យាបាល ឬ ដើម្បីយល់ព្រមឱ្យអនីតិជននៅក្រោមអាណាព្យាបាល ប្រកបអាជីវកម្ម ឬ ធ្វើសកម្មភាពនោះ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការទទួលប្រាក់ដើម ។

(កំណត់)

មាត្រា ២០ នៃក្រមនេះចែងថា អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចអនុញ្ញាតឱ្យអនីតិជនធ្វើអាជីវកម្ម ប៉ុន្តែ ដើម្បីការពារអនីតិជន មាត្រានេះចែងថា នៅពេលដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យអនីតិជនចាប់ផ្ដើមធ្វើអាជីវកម្មថ្មី អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ប្រសិនបើអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានជ្រើសតាំង ។ ប្រសិនបើអនីតិជនធ្វើសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលបានកំណត់ក្នុងមាត្រា ៣០ នៃក្រមនេះ មានន័យថាសកម្មភាពសំខាន់ៗទាក់ទងនឹងទ្រព្យសម្បត្តិ មាត្រានេះតម្រូវឱ្យមានការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះជាមុនសិន ប្រសិនបើអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានជ្រើសតាំង លើកលែងតែសកម្មភាពនៃការទទួលប្រាក់ដើមចេញ ។ ឧទាហរណ៍ ក្នុងករណីដែលមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ប្រសិនបើអនីតិជនលក់អចលនវត្ថុរបស់ខ្លួន ដោយមានការយល់ព្រមពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ចាំបាច់មានការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែរ ។ ប៉ុន្តែ ឧទាហរណ៍ ប្រសិនបើអនីតិជនទទួលបាននូវការសងប្រាក់កម្ចីពីកូនបំណុលមកវិញ ការការពារអនីតិជន កម្រនឹងកើតជាបញ្ហាណាស់ ហើយកូនបំណុលត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ប្រសិនបើកូនបំណុលមិនអាចសងបានទេ ។ ហេតុដូច្នេះហើយ វាក្យខណ្ឌទី ២ ចែងថា ការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនចាំបាច់ទេ ចំពោះការទទួលប្រាក់ដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៩១.-** អានុភាពនៃការអនុវត្តផ្ទុយនឹងមាត្រា ១០៩០

១-សកម្មភាពដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានធ្វើ ឬ សកម្មភាពដែលបានផ្តល់ការយល់ព្រម ដោយផ្ទុយនឹងបញ្ញត្តិនៃមាត្រា ១០៩០ (ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម) ខាងលើនេះ មានតែអនីតិជននៅក្រោមអាណាព្យាបាល ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ ដែលអាចលុបចោលបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងក្នុងការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះឡើយ ។

(កំណត់)

ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជនផ្តល់ការយល់ព្រមចំពោះអាជីវកម្មរបស់អនីតិជន ឬ ចំពោះសកម្មភាពទាំងឡាយដែលកំណត់ក្នុងមាត្រា ៣០ នៃក្រមនេះ លើកលែងតែសកម្មភាពទទួលប្រាក់ដើម ដោយគ្មានការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ទោះបីជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានជ្រើសតាំងក៏ដោយ អនីតិជន ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោលអាជីវកម្ម ឬ សកម្មភាពទាំងអស់នោះបាន ។ មូលហេតុគឺដោយសារតែសកម្មភាពណាមួយដែលធ្វើឡើងដោយគ្មានការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចបង្កគ្រោះថ្នាក់យ៉ាងខ្ពស់ចំពោះអនីតិជន ។ ប្រសិនបើការលុបចោលមិនត្រូវបានអនុញ្ញាតទេ វាគ្មានប្រយោជន៍អ្វីដែលត្រូវមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ ។ ក៏ប៉ុន្តែ ដោយសារមានការចាំបាច់ត្រូវគិតគូរដល់ការការពារភាគីម្ខាងទៀតដែលជាដៃគូជួញដូររបស់អនីតិជន ទើបបញ្ញត្តិនេះចែងថា ភាគីម្ខាងទៀតនោះអាចធ្វើការដាស់តឿនទៅអនីតិជននោះ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបាន តាមបញ្ញត្តិនៃមាត្រា ៣២ នៃក្រមនេះ ។ កថាខណ្ឌទី ២ ចែងថា បញ្ញត្តិពាក់ព័ន្ធនៅក្នុងក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះវិធីលុបចោល និង ផ្តល់សច្ចានុមតិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៩២.-** ការទទួលអនុប្បទាននូវទ្រព្យសម្បត្តិ ជាអាទិ៍ ពីអនីតិជននៅក្រោមអាណាព្យាបាល

១-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានទទួលអនុប្បទាននូវទ្រព្យសម្បត្តិរបស់អនីតិជននៅក្រោមអាណាព្យាបាល ឬ សិទ្ធិរបស់តតិយជនចំពោះអនីតិជននៅក្រោមអាណាព្យាបាល អនីតិជននៅក្រោមអាណាព្យាបាលនោះ អាចលុបចោលនូវអនុប្បទាននោះបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងនូវការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះឡើយ ។

(កំណត់)

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនទទួលអនុប្បទាននូវទ្រព្យសម្បត្តិរបស់អនីតិជនពីអនីតិជន ឬ សិទ្ធិលើបំណុលរបស់អនីតិជនចំពោះតតិយជន ទោះបីជាអនីតិជនបានបង្ហាញឆន្ទៈធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិ ឬ ធ្វើអនុប្បទាននូវសិទ្ធិលើបំណុលក៏ដោយ ដោយសារអាណាព្យាបាលសម្រាប់អនីតិជនជាទំនាក់ទំនងពិសេស ក៏មានករណីជាច្រើនដែលសកម្មភាពទាំងនោះបានធ្វើឡើងដោយគ្មានឆន្ទៈពិតប្រាកដរបស់អនីតិជន ឬ ដោយអនីតិជនមិនបានយល់ដឹងគ្រប់គ្រាន់អំពីស្ថានភាព ។ បន្ថែមពីលើនេះទៅទៀត ពីព្រោះតែសកម្មភាពទាំងនេះកាត់បន្ថយនូវទ្រព្យសម្បត្តិរបស់អនីតិជន ហើយបង្កើនទ្រព្យសម្បត្តិរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ក្នុងពេលដំណាលគ្នាដែរ សកម្មភាពនេះគឺជាសកម្មភាពដែលផលប្រយោជន៍របស់អនីតិជន និង ផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានភាពផ្ទុយគ្នា ។ ដើម្បីដោះស្រាយករណីនេះ មាត្រានេះចែងថា អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចធ្វើការដាស់តឿនដល់អនីតិជនតាមមាត្រា ៣២ នៃក្រមនេះ ។ ដូចមាត្រា ១០៩២ ដែរ កថាខណ្ឌទី ២ នៃមាត្រានេះចែងយ៉ាងច្បាស់ថា មាត្រាដែលពាក់ព័ន្ធនៅក្នុងក្រមនេះ ត្រូវអនុវត្តចំពោះវិធីលុបចោល និង ការផ្តល់សច្ចានុមតិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៩៣.-** ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានករណីយកិច្ចបំពេញតួនាទីអាណាព្យាបាលសម្រាប់អនីតិជន ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានធ្វើឱ្យមានការខូចខាតដល់អនីតិជននៅក្រោមអាណាព្យាបាល ដោយធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អនីតិជននៅក្រោមអាណាព្យាបាល អាចទាមទារសំណងនៃការខូចខាតនោះ ពីអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះបាន ។

(កំណត់)

មាត្រា ១០៩៣ បញ្ជាក់អំពីករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អានុភាពនៃការបំពានករណីយកិច្ចនេះ ។ កថាខណ្ឌទី ១ ចែងថា អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានករណីយកិច្ចបំពេញតួនាទីដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។ ករណីយកិច្ចនេះមានខ្លឹមសារដូចគ្នានឹងករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហកដែលបានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៦៤០ នៃក្រមនេះ ។ ក៏ប៉ុន្តែ តាមកិច្ចសន្យាអាណត្តិ ករណីយកិច្ចប្រុងប្រយ័ត្នអាចត្រូវបានសម្រាល ដោយការយល់ព្រមព្រៀងរវាងភាគីទាំងពីរ ប៉ុន្តែ ការព្រមព្រៀងបែបនេះមិនត្រូវបានអនុញ្ញាតឡើយចំពោះអាណាព្យាបាលសម្រាប់អនីតិជន ។ កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនបំពានករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ហើយជាលទ្ធផលធ្វើឱ្យអនីតិជនរងការខូចខាត អនីតិជនអាចទាមទារសំណងនៃការខូចខាតពីអ្នកអាណាព្យាបាលសម្រាប់អនីតិជនបាន ។ ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងការខូចខាត សូមមើលមាត្រា ១១០២ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៩ និង មាត្រា ៦៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៩៤.-** ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល

១-ប្រសិនបើតតិយជនដែលបានផ្តល់ទ្រព្យសម្បត្តិឱ្យទៅអនីតិជននៅក្រោមអាណាព្យាបាល ដោយមិនគិតថ្លៃ បានបង្ហាញឆន្ទៈថា មិនឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ពុំបានអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតតិយជនពុំបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជននៅក្រោមអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជននោះ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

៣-ទោះបីជាតតិយជនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសិទ្ធិអំណាចរបស់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ បានរលត់ ឬ មានការចាំបាច់ត្រូវផ្លាស់ប្តូរអ្នកនោះ តែតតិយជនមិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត ។

៤-បញ្ញត្តិចាប់ពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) រហូតដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើនេះ ។

(កំណត់)

មាត្រា ១០៩៤ ចែងអំពីការគ្រប់គ្រងទ្រព្យសម្បត្តិដែលអនីតិជននៅក្រោមអាណាព្យាបាល បានទទួលពីតតិយជន ។ កថាខណ្ឌទី ១ ចែងថា ក្នុងករណីដែលតតិយជនម្នាក់បានឱ្យទ្រព្យសម្បត្តិទៅអនីតិជន ដោយមិនគិតថ្លៃ ដោយបង្ហាញឆន្ទៈថា មិនឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះមិនត្រូវក្លាយទៅជាកម្មវត្ថុនៃការគ្រប់គ្រងដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ ។ បញ្ញត្តិនេះគោរពឆន្ទៈរបស់ទាយក ។ ក៏ប៉ុន្តែ ដោយសារតែអនីតិជនមិនអាចគ្រប់គ្រងទ្រព្យសម្បត្តិបានទេ ទ្រព្យសម្បត្តិនោះត្រូវបានគ្រប់គ្រងដោយបុគ្គលម្នាក់ទៀត ។ ដោយផ្អែកលើការសន្និដ្ឋានថា ទាយកអាចកំណត់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិម្នាក់ដោយខ្លួនឯង កថាខណ្ឌទី ២ ចែងថា តុលាការអាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិម្នាក់ ប្រសិនបើទាយកមិនបានកំណត់អ្នកគ្រប់គ្រង ។ កថាខណ្ឌទី ៣ ផ្អែកលើការសន្និដ្ឋានថា ទាយកអាចកំណត់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិថ្មីបាន ប្រសិនបើអ្នកគ្រប់គ្រងទ្រព្យសម្បត្តិបច្ចុប្បន្ន ដែលត្រូវបានកំណត់ដោយទាយក បាត់បង់សិទ្ធិក្នុងការគ្រប់គ្រងដោយសារមរណភាព ជាអាទិ៍ ឬ ប្រសិនបើចាំបាច់

ត្រូវផ្លាស់ប្តូរអ្នកគ្រប់គ្រងទ្រព្យសម្បត្តិបច្ចុប្បន្នទៅបុគ្គលម្នាក់ទៀត ក្នុងករណីដែលទាយកមិនបានកំណត់អ្នកគ្រប់គ្រងថ្មីទេ តុលាការអាចជ្រើសតាំងអ្នកគ្រប់គ្រងថ្មីបាន ។ កថាខណ្ឌទី ៤ ចែងថា បញ្ញត្តិពីមាត្រា ៣៧ ដល់មាត្រា ៤០ នៃក្រមនេះ ដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រានេះ ។ សូមមើលមាត្រា ១០៥៨ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៩ និង មាត្រា ៨៣០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ៥ ការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន

(កំណត់)

អាណាព្យាបាលសម្រាប់អនីតិជន ត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ នៅពេលអនីតិជនដល់នីតិភាព ។ ដូចដែលបានចែងនៅក្នុងមាត្រា ១៧ អនីតិជនដល់នីតិភាពនៅពេលអនីតិជននោះដល់អាយុ ១៨ ឆ្នាំ ។ កថាភាគទី ៥ នេះ បញ្ញត្តថា ទោះបីជាអនីតិជនមិនទាន់ដល់អាយុ ១៨ ឆ្នាំ ក៏ដោយ ក៏អនីតិជនត្រូវរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជនដែរ ប្រសិនបើបំពេញល័ក្ខខ័ណ្ឌជាកំណត់មួយចំនួន ។ សូមមើលមាត្រា ២១ នៃក្រមនេះ ។ ក្រមរដ្ឋប្បវេណីជប៉ុនមិនបានរៀបចំបញ្ញត្តិអំពីការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ដោយមានលក្ខណៈជាប្រព័ន្ធទេ ។ សូមមើលមាត្រា ៤៧៦ ដល់ មាត្រា ៤៨៧ នៃក្រមរដ្ឋប្បវេណីបារាំង ។

**មាត្រា ១០៩៥.-** ល័ក្ខខ័ណ្ឌនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន

១-ក្នុងករណីដែលអនីតិជននៅក្រោមអាណាព្យាបាលដែលបានគ្រប់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯង ដោយឯករាជ្យបាន តុលាការអាចប្រកាសឱ្យរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន តាមពាក្យសុំរបស់អនីតិជននៅក្រោមអាណា-ព្យាបាលបាន បើយល់ឃើញថា ការរួចផុតនោះស្របនឹងផលប្រយោជន៍របស់អនីតិជននៅក្រោមអាណាព្យាបាលនោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកអាណា-ព្យាបាលសម្រាប់អនីតិជន ។ បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការក៏ត្រូវសួរយោបល់ពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលនោះផងដែរ ។

២-អនីតិជននៅក្រោមអាណាព្យាបាលដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ដោយគ្មានការប្រកាសរបស់តុលាការ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីជាភាគីបានលែងលះនៅពេលក្រោយក៏ដោយ ក៏អានុភាពនៃការរួចផុតពីអាណាព្យាបាលសម្រាប់

អនីតិជន មិនត្រូវរលត់ឡើយ ។

(កំណត់)

មាត្រា ១០៩៥ ចែងអំពីល័ក្ខខ័ណ្ឌនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ។ កថាខណ្ឌទី ១ ចែងថា តុលាការអាចសម្រេចអំពីការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ដោយអនុលោមទៅតាមមាត្រានេះ ។ កថាខណ្ឌទី ២ បង្ហាញថា អនីតិជនត្រូវរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជនដោយស្វ័យប្រវត្តិ នៅពេលអនីតិជននោះរៀបអាពាហ៍ពិពាហ៍ ។ មាត្រា ៩៤៨ នៃក្រមនេះចែងថា ជាគោលការណ៍ គ្មានបុគ្គលណាម្នាក់អាចរៀបអាពាហ៍ពិពាហ៍បានទេ រហូតដល់បុរស ឬ នារីនោះមានអាយុគ្រប់ ១៨ ឆ្នាំ ដែលជាអាយុដែលអនីតិជនម្នាក់ក្លាយជានីតិជន ។ ក៏ប៉ុន្តែ មាត្រា ៩៤៨ នេះអនុញ្ញាតឱ្យដោយលើកលែងចំពោះអាពាហ៍ពិពាហ៍ដោយអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ទៅ ១៨ ឆ្នាំ ។ ហេតុដូច្នេះហើយ ប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ ១៨ ឆ្នាំ ហើយដែលស្ថិតនៅក្រោមអាណាព្យាបាលសម្រាប់អនីតិជន រៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ។ ទោះបីជាសេចក្តីសន្និដ្ឋានដូចគ្នានេះអាចត្រូវធ្វើឡើង ដោយការបកស្រាយមាត្រា ៩៦៨ ដែលចែងអំពីការចាត់ទុកជានីតិជនដោយអាពាហ៍ពិពាហ៍ក៏ដោយ ក៏យើងសម្រេចឱ្យតាក់តែងបញ្ញត្តិជាក់លាក់ដែរ ។ កថាខណ្ឌទី ៣ បញ្ជាក់អំពីករណីដែលអនីតិជនដែលបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជនដោយសារអាពាហ៍ពិពាហ៍ បានលែងលះ ។ ដោយសារតែអានុភាពនៃអាពាហ៍ពិពាហ៍ ត្រូវបាត់បង់ដោយសារការលែងលះ យើងអាចគិតថា បុគ្គលនោះគួរក្លាយជាអនីតិជននៅក្រោមអាណាព្យាបាលសម្រាប់អនីតិជនវិញ ។ ផ្ទុយទៅវិញ យើងក៏អាចគិតបានផងដែរថា ប្រសិនបើអនីតិជនដែលត្រូវបានចាត់ទុកថាជានីតិជន ហើយក្លាយមកជាអនីតិជនម្តងទៀតនោះ បញ្ហានេះមានភាពស្មុគស្មាញណាស់ និង អាចប៉ះពាល់ដល់ស្ថិរភាពនៃការជួញដូរនានាជាច្រើន ។ ហេតុដូច្នេះហើយ យើងបានអនុម័តយកនូវទស្សនៈចុងក្រោយនេះ ហើយបានបញ្ជាក់យ៉ាងច្បាស់ថា បុគ្គលដែលបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជនដោយសារអាពាហ៍ពិពាហ៍ហើយ មិនត្រូវត្រឡប់មកជាអនីតិជនក្រោមអាណាព្យាបាលវិញដោយសារការលែងលះទេ ។ ដើម្បីសម្រេចនូវគោលបំណងនៃកថាខណ្ឌនេះ ទោះបីជាមាត្រានេះប្រើពាក្យ "ការលែងលះ" ក៏ដោយ ក៏កថាខណ្ឌទី ៣ នេះ គួរត្រូវបានបកស្រាយដោយរាប់បញ្ចូលទាំងករណីដែលអាពាហ៍ពិពាហ៍ត្រូវបានរំលាយដោយសារមរណភាពរបស់សហព័ទ្ធផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៧៦ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ១០៩៦.-** អានុភាពនៃការរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន

អនីតិជននៅក្រោមអាណាព្យាបាល ដែលបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

(កំណត់)

យោងតាមមាត្រា ១០៩៦ នេះ អនីតិជនដែលបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន មានសមត្ថភាពដូចគ្នានឹងនីតិជនដែរ ហើយអាចធ្វើសកម្មភាពតាមនីតិឯកជនដោយសេរី ដូចជាការចុះកិច្ចសន្យា ជាដើម ។ ក៏ប៉ុន្តែ សកម្មភាពដែលអនីតិជននោះអាចធ្វើដោយសេរី ត្រូវបានកម្រិតត្រឹមតែសកម្មភាពតាមនីតិឯកជនប៉ុណ្ណោះ ។ អនីតិជនមិនត្រូវបានចាត់ទុកថាជានីតិជន តាមនីតិសាធារណៈទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៨១ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ១០៩៧.-** ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ វត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-ប្រសិនបើបានបញ្ចប់តួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនហើយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកនោះ ត្រូវធ្វើការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់តួនាទីនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាន នៅតុលាការ ។

២-បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ការគណនាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវអនុវត្តដោយមានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

(កំណត់)

មាត្រា ១០៩៧ ចែងថា អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានករណីយកិច្ចត្រូវគណនាចំណូលចំណាយនៃការគ្រប់គ្រងទ្រព្យសម្បត្តិ នៅពេលបញ្ចប់តួនាទីជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ មាត្រានេះត្រូវយកមកអនុវត្តចំពោះករណីដែលអាណាព្យាបាលសម្រាប់អនីតិជនត្រូវបញ្ចប់នៅពេលដែលអនីតិជនក្លាយជានីតិជន និង ករណីដែលអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ។ មាត្រានេះក៏ត្រូវយកមកអនុវត្តដែរ ចំពោះករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានផ្លាស់ប្តូរ និង ករណីដែលអាណាព្យាបាលសម្រាប់អនីតិជនបញ្ចប់ ដោយសារអនីតិជនទទួលមរណភាព ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទទួលមរណភាព ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧០ និង មាត្រា ៨៧១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៩៨.-** ការលុបចោលកិច្ចសន្យារវាងអនីតិជននៅក្រោមអាណាព្យាបាល

និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អនីតិជននៅក្រោមអាណាព្យាបាល អាចលុបចោលកិច្ចសន្យាដែលខ្លួនបានធ្វើជាមួយនឹងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ នៅក្រោយពេលដែលខ្លួនបានក្លាយជានីតិជនហើយ និង នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាលបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពឯកតោភាគីដែលអនីតិជននោះបានធ្វើចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អាណាព្យាបាលសម្រាប់អនីតិជននោះ ។

២-បញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រា ១០៩៨ ចែងថា ទោះបីជាអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបញ្ចប់នៅពេលដែលអនីតិជនក្លាយជានីតិជនក៏ដោយ ក៏អតីតអនីតិជនអាចលុបចោលកិច្ចសន្យាជាមួយអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ជាមួយសន្តតិជនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយនៃការគ្រប់គ្រងទ្រព្យសម្បត្តិបានដែរ ។ មូលហេតុ គឺដោយសារអនីតិជនអាចចុះកិច្ចសន្យាដែលខូចដល់ផលប្រយោជន៍ខ្លួន ដោយសារខ្លួនមិនបានដឹងអំពីស្ថានភាពនៃទ្រព្យសម្បត្តិរបស់ខ្លួននៅមុនការគណនាចំណូលចំណាយ ឬ ដោរសារអនីតិជនអាចចុះកិច្ចសន្យាដែលខូចប្រយោន៍ដល់ខ្លួន ដោយសារទំនាក់ទំនងជាមួយអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ ចំពោះ "សកម្មភាពឯកតោភាគី" នៅក្នុងកថាខណ្ឌទី ១ នេះ ឧទាហរណ៍ចម្បងគឺជាការលើកលែងកាតព្វកិច្ច ។ កថាខណ្ឌទី ២ បង្ហាញអំពីមាត្រាដែលនឹងត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះករណីលុបចោលកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១០៩៩.-** ករណីយកិច្ចបង់ការប្រាក់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល

១-ចំនួនទឹកប្រាក់ដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវសងទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល និង ចំនួនទឹកប្រាក់ដែលអនីតិជននៅក្រោមអាណាព្យាបាលត្រូវសងទៅឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានបញ្ចប់ការគណនាទូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាលសម្រាប់អនីតិជនរួចហើយ ។

២-ប្រសិនបើអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានប្រើប្រាស់ប្រាក់របស់អនីតិជននៅក្រោមអាណាព្យាបាល ដើម្បីខ្លួនឯងផ្ទាល់នោះ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានប្រើប្រាស់ប្រាក់នោះ ។ បើមានការខូចខាត អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតនោះ ។

(កំណត់)

អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវគណនាចំណូលចំណាយនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជនឱ្យបានឆាប់រហ័ស ហើយត្រូវប្រគល់ទ្រព្យសម្បត្តិទៅអនីតិជនឱ្យបានឆាប់រហ័ស នៅពេលបញ្ចប់ការគណនាចំណូលចំណាយ ។ ដើម្បីជួយសម្រួលដល់ការប្រគល់ឱ្យបានឆាប់រហ័សនេះ កថាខណ្ឌទី ១ ចែងថា ទ្រព្យសម្បត្តិដែលត្រូវប្រគល់នោះ ត្រូវបង្កើតការប្រាក់ ចាប់ពីពេលបញ្ចប់ការគណនាចំណូលចំណាយរហូតដល់ពេលប្រគល់ទ្រព្យសម្បត្តិនោះ ។ អត្រាការប្រាក់ប្រចាំឆ្នាំ គឺ ៥% ដូចបានបញ្ជាក់ក្នុងមាត្រា ៣១៨ នៃក្រមនេះ ។ ដើម្បីជាទណ្ឌកម្មលើការគៃបន្លំប្រាក់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជន កថាខណ្ឌទី ២ ចែងថា ការប្រាក់ត្រូវគិតចាប់ពីពេលដែលមានការគៃបន្លំ ។ ប្រសិនបើការគៃបន្លំធ្វើឱ្យអនីតិជនទទួលការខូចខាត អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវសងសំណងនៃការខូចខាតនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១០០.-** ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន

១-ប្រសិនបើមានស្ថានភាពបន្ទាន់ នៅក្នុងករណីដែលបានបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជនហើយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នក

អាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវធ្វើការចាត់ចែងចាំបាច់ រហូតដល់ពេលដែលអនីតិជននៅក្រោមអាណាព្យាបាល សន្តតិជនរបស់អនីតិជននៅក្រោមអាណាព្យាបាលនោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់អនីតិជននៅក្រោមអាណាព្យាបាលនោះ អាចចាត់ការកិច្ចការនោះបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានកំណត់ ឬ ជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) ។

(កំណត់)

កថាខណ្ឌទី ១ កំណត់ករណីយកិច្ចជាក់លាក់ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ សន្តតិជនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ទោះបីជាក្រោយពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជនហើយក៏ដោយ ។ ឧទាហរណ៍ថា អនីតិជនមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ រាងកាយ ហើយត្រូវស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ក្រោយពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជនហើយ ប៉ុន្តែ អ្នកអាណាព្យាបាលទូទៅមិនទាន់ត្រូវបានជ្រើសតាំងទៀត ។ ក្នុងករណីនេះ អ្នកអាណាព្យាបាលសម្រាប់អនីតិជនគួរតែបន្តការបីបាច់រក្សារូបកាយនៃអតីតអនីតិជន រហូតដល់អ្នកអាណាព្យាបាលទូទៅត្រូវបានជ្រើសតាំង ។ ប្រសិនបើអាណាព្យាបាលសម្រាប់អនីតិជន បានបញ្ចប់ដោយមរណភាពរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន សន្តតិជនរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវចាត់វិធានការចាំបាច់សម្រាប់អនីតិជន រហូតដល់អ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីត្រូវបានជ្រើសតាំង ។ បន្ថែមពីលើនេះទៅទៀត ក្នុងករណីដែលអាណាព្យាបាលសម្រាប់អនីតិជនត្រូវបញ្ចប់ដោយសារអនីតិជនក្លាយជានីតិជន ប្រសិនបើអតីតអនីតិជនកំពុងស្នាក់នៅបរទេស អតីតអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបន្តគ្រប់គ្រងទ្រព្យសម្បត្តិ រហូតដល់អតីតអនីតិជនត្រឡប់មកប្រទេសវិញ ដោយសារអតីតអ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនអាចប្រគល់ទ្រព្យសម្បត្តិទៅឱ្យអតីតអនីតិជនបានឡើយ ។ ថ្វីបើអាចមានករណីច្រើនកើតឡើង ទោះក្នុងករណីណាមួយក៏ដោយ ក៏កថាខណ្ឌទី ១ កំណត់ករណីយកិច្ចបណ្តោះអាសន្ន ចំពោះអតីតអ្នកអាណាព្យាបាលសម្រាប់អនីតិជន ក្នុងការបីបាច់រក្សារូបកាយ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អតីតអនីតិជនដែរ ដើម្បីសម្រេចឱ្យបាននូវប្រសិទ្ធភាពនៃប្រព័ន្ធអាណាព្យាបាលសម្រាប់អនីតិជន ។ សូមមើលមាត្រា ៦៥០ និង មាត្រា ១០៥៩ នៃក្រមនេះ ។

កថាខណ្ឌទី ២ ចែងអំពីអានុភាពដូចគ្នានៃកថាខណ្ឌទី ១ ក្នុងករណីដែលមានអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានកំណត់ ឬ ជ្រើសតាំង ។ សូមមើលមាត្រា ៦៥០ មាត្រា ១០៥៨ និង មាត្រា ១០៥៩ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៤ និង មាត្រា ៦៥៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១០១.-** លក្ខខណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ជាអាទិ៍

១-មូលហេតុនៃការបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ទោះបីជាមូលហេតុនោះកើតឡើងចំពោះអនីតិជនជននៅក្រោមអាណាព្យាបាលក៏ដោយ ឬ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏ដោយ ពុំអាចយកទៅតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ បើមិនបានជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ឬ បើភាគីម្ខាងទៀត ពុំបានដឹងអំពីមូលហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) នៃក្រមនេះ ។

(កំណត់)

កថាខណ្ឌទី ២ ចែងអំពីអានុភាពដូចគ្នានឹងកថាខណ្ឌទី ១ ក្នុងករណីដែលអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានកំណត់ ឬ ជ្រើសតាំង ។ សូមមើលមាត្រា ៦៥០ មាត្រា ១០៥៨ និងមាត្រា ១០៥៩ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៤ និង មាត្រា ៦៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១០២.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន

១-បញ្ញត្តិនៃមាត្រា ១០៦០ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ រវាងឪពុកម្តាយ និង កូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន រវាងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជននៅក្រោមអាណាព្យាបាល ។

២-ក្នុងករណីដែលបានលុបចោលសកម្មភាព ដោយបញ្ញត្តិនៃមាត្រា ១០៩៨ (ការ

លុបចោលកិច្ចសន្យារវាងអនីតិជននៅក្រោមអាណាព្យាបាល និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន) នៃក្រមនេះ អាជ្ញាយុកាលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលបានលុបចោលនោះ ។

(កំណត់)

កថាខណ្ឌទី ១ ចែងអំពីការអនុវត្តដូចគ្នាផងដែរនូវមាត្រា ១០៦០ នៃក្រមនេះ ដើម្បីកំណត់អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរវាងអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជន ឬ រវាងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជន ជារយៈពេល ៣ ឆ្នាំ ចាប់ពីពេលបញ្ចប់អាណាព្យាបាលសម្រាប់អនីតិជន ។ ជាឧទាហរណ៍ ករណីនេះអនុវត្តចំពោះប្រាក់កម្រៃដែលអនីតិជនត្រូវបង់ឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។ កថាខណ្ឌទី ២ បញ្ជាក់ឱ្យច្បាស់អំពីទំនាក់ទំនងរវាងពេលចាប់ផ្តើមគិត អំឡុងពេលនៃអាជ្ញាយុកាលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ការលុបចោល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ៦ ការយកមកអនុវត្តដូចគ្នា ចំពោះកូនរបស់អនីតិជននៅក្រោមអាណាព្យាបាល

**មាត្រា ១១០៣.-** ការអនុវត្តអំណាចមេបាជំនួសអនីតិជននៅក្រោមអាណាព្យាបាល

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវអនុវត្តអំណាចមេបា ចំពោះកូនរបស់អនីតិជននៅក្រោមអាណាព្យាបាល ជំនួសអនីតិជននៅក្រោមអាណាព្យាបាលនោះ ។

២-បញ្ញត្តិចាប់ពីមាត្រា ១០៧៩ (សិទ្ធិ និង ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) រហូតដល់មាត្រា ១១០២ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រា ១១០៣ ចែងថា អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវអនុវត្តអំណាចមេបាលើកូនរបស់អនីតិជនជំនួសអនីតិជន ។ មានន័យថា អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើរតួជាឪពុកម្តាយជំនួសរបស់អនីតិជន ហើយប្រសិនបើអនីតិជនមានកូន អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវដើរតួជាឪពុកម្តាយរបស់កូននោះផងដែរ ។ សូមមើលមាត្រា ១០៦៦ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៧ និង មាត្រា ៨៣៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ២ អាណាព្យាបាលទូទៅ

(កំណត់)

ដូចដែលបានចែងក្នុងមាត្រា ២៤ នៃក្រមនេះ អាណាព្យាបាលទូទៅ គឺជារបបមួយដែលជនម្នាក់ធ្វើសកម្មភាពគតិយុត្ត ជំនួសជនម្នាក់ទៀតដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារវិបត្តិផ្នែកបញ្ញាស្មារតី និង ការពារជននោះនៅក្នុងការធ្វើការជួញដូរ ។ បុគ្គលដែលត្រូវបានការពារដោយរបបនេះ ហៅថា "ជននៅក្រោមអាណាព្យាបាលទូទៅ" ហើយបុគ្គលដែលផ្តល់ការការពារ ហៅថា "អ្នកអាណាព្យាបាលទូទៅ" ។ នៅខណៈពេលដែលអាណាព្យាបាលសម្រាប់អនីតិជនគឺជារបបដែលការពារអនីតិជនដែលមានអាយុក្រោម ១៨ ឆ្នាំ អាណាព្យាបាលទូទៅការពារបុគ្គលដែលមានវិបត្តិផ្នែកបញ្ញាស្មារតីទោះបីជាបុគ្គលនោះមានអាយុប៉ុន្មានក៏ដោយ ។ ហេតុដូច្នេះហើយ អាណាព្យាបាលទូទៅអនុវត្តស្មើគ្នាចំពោះនីតិជន និង អនីតិជន ។ បញ្ញត្តិស្តីពីអាណាព្យាបាលទូទៅ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន ក៏ត្រូវបានធ្វើវិសោធនកម្មយ៉ាងច្រើន នៅឆ្នាំ ២០០០ ដែរ ។ ផ្នែកនេះឆ្លុះបញ្ចាំងពីលទ្ធផលនៃវិសោធនកម្មក្រមជប៉ុន ដោយឆ្លងកាត់តាមការពិភាក្សាដោយក្រុមការងារ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧ ដល់មាត្រា ១០ និង មាត្រា ៨៣៨ ដល់មត្រា ៨៧៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

### កថាភាគទី ១ ការចាប់ផ្តើមអាណាព្យាបាលទូទៅ

**មាត្រា ១១០៤.-** ការចាប់ផ្តើមអាណាព្យាបាលទូទៅ

អាណាព្យាបាលទូទៅ ត្រូវចាប់ផ្តើម ដោយបញ្ញត្តិនៃមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

(កំណត់)

មាត្រា ១១០៤ ចែងអំពីការចាប់ផ្តើមអាណាព្យាបាលទូទៅ ។ ការចាប់ផ្តើមអាណាព្យាបាលទូទៅត្រូវប្រកាសដោយតុលាការ តាមពាក្យសុំរបស់បុគ្គលដែលស្ថិតនៅក្នុងលំដាប់មួយជាក់លាក់ ។ សូមមើលមាត្រា ២៤ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

ចំណុចទី ២ មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ២ អ្នកអាណាព្យាបាលទូទៅ

**មាត្រា ១១០៥.-** ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

១-បើប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ដោយឆន្ទានុសិទ្ធិ ។

២-ប្រសិនបើខ្វះអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិ ។

៣-ទោះបីជាបានជ្រើសតាំងអ្នកអាណាព្យាបាលទូទៅហើយក៏ដោយ បើយល់ឃើញថាចាំបាច់ តុលាការអាចជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថែមទៀត តាមការទាមទាររបស់បុគ្គលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ឬ អ្នកអាណាព្យាបាលទូទៅ ឬ ដោយឆន្ទានុសិទ្ធិបាន ។

៤-ដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវគិតពិចារណាអំពីស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត និង ស្ថានភាពជីវភាព និង ទ្រព្យសម្បត្តិ របស់ជននៅក្រោមអាណាព្យាបាលទូទៅ វិជ្ជាជីវៈ និង ប្រវត្តិរូប របស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលទូទៅ និង អត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងអ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ និង យោបល់របស់ជននៅក្រោមអាណាព្យាបាលទូទៅ និង ស្ថានភាពផ្សេងទៀតទាំងស្រុង ។ ប្រសិនបើអ្នកអាណាព្យាបាលទូទៅ ជានីតិបុគ្គល តុលាការត្រូវគិតពិចារណាផងដែរ អំពីប្រភេទ និង ខ្លឹមសារនៃកិច្ចការរបស់នីតិបុគ្គល និង អត្ថិភាពឬនត្ថិភាពនៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងនីតិបុគ្គល និង អ្នកតំណាងរបស់នីតិបុគ្គលនោះ និង ជននៅក្រោមអាណាព្យាបាលទូទៅ ។

៥-ក្នុងករណីដែលជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ចំពោះអនីតិជន តុលាការអាចយកអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មកជ្រើសតាំង

ជាអ្នកអាណាព្យាបាលទូទៅបាន ។ ក្នុងករណីដែលតុលាការយកជន ក្រៅពីអ្នកមានអំណាចមេបារបស់អនីតិជន ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មកជ្រើសតាំងជាអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវកំណត់អំពីការបែងចែកកិច្ចការរបស់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អ្នកអាណាព្យាបាលទូទៅ ។

(កំណត់)

មាត្រា ១១០៥ ចែងអំពីការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ។

កថាខណ្ឌទី ២ តាក់តែងឡើងសម្រាប់ករណីដែលអាចគិតឃើញដូចជា ឧទាហរណ៍ថា អ្នកអាណាព្យាបាលទូទៅដែលត្រូវបានជ្រើសតាំងកាលពីអតីតកាលបានទទួលមរណភាព ហើយមានការចាំបាច់ត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថ្មី ។

ចំនួនអ្នកអាណាព្យាបាលទូទៅ មិនត្រូវបានកម្រិតត្រឹមតែម្នាក់នោះទេ ។ កថាខណ្ឌទី ៣ ចែងថា អ្នកអាណាព្យាបាលទូទៅពីរនាក់ ឬច្រើននាក់អាចត្រូវបានជ្រើសតាំងបាន ប្រសិនបើចាំបាច់សម្រាប់ជននៅក្រោមអាណាព្យាបាលទូទៅ ។

យោងតាមកថាខណ្ឌទី ៤ មិនត្រឹមតែរូបវន្តបុគ្គលទេ សូម្បីតែនីតិបុគ្គលក៏អាចក្លាយជាអ្នកអាណាព្យាបាលទូទៅបានដែរ ។ មន្ទីរពេទ្យ ស្ថាប័នសង្គមកិច្ច និង អង្គការក្រៅរដ្ឋាភិបាលអាចក្លាយជាអ្នកអាណាព្យាបាលទូទៅ ប្រសិនបើមាននីតិបុគ្គលភាព ។ ហេតុដូច្នេះហើយ កថាខណ្ឌនេះអនុញ្ញាតឱ្យអាចជ្រើសតាំងដូចជា អ្នកអាណាព្យាបាលទូទៅម្នាក់ដែលជារូបវន្តបុគ្គល និង ម្នាក់ទៀតដែលជានីតិបុគ្គលបាន ។

យោងតាមកថាខណ្ឌទី ៥ នៅពេលដែលចំបាច់ត្រូវមានអ្នកអាណាព្យាបាលទូទៅសម្រាប់អនីតិជន អ្នកមានអំណាចមេបាអាចក្លាយជាអ្នកអាណាព្យាបាលទូទៅបាន ។ បន្ថែមពីលើនេះទៀត ពីព្រោះតែចំនួនអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានកម្រិតត្រឹមតែម្នាក់ នៅពេលដែលអ្នកអាណាព្យាបាលទូទៅចាំបាច់ត្រូវបានជ្រើសតាំងសម្រាប់អនីតិជនដែលស្ថិតនៅក្រោមអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងរួចហើយ អាចត្រូវបានជ្រើសតាំងជាអ្នកអាណាព្យាបាលទូទៅបានដែរ ។ ក៏ប៉ុន្តែ ក្នុងករណីដែលជ្រើសតាំងបុគ្គលក្រៅពីអ្នកមានអំណាចមេបា និង អ្នកអាណាព្យាបាលសម្រាប់អនីតិជន ធ្វើជាអ្នកអាណាព្យាបាលទូទៅ ការបែងចែកកិច្ចការនឹងមិនច្បាស់លាស់ ហើយវានឹងកើតនូវផលលំបាកដែលមិនចាំបាច់ ហើយវាមិនក្លាយទៅជាផលល្អចំពោះអនីតិជនដូច្នេះ ទើបតុលាការត្រូវកំណត់អំពីកិច្ចការនីមួយៗនោះ ។ ជាឧទាហរណ៍ តុលាការអាចសម្រេចថា អ្នកអាណាព្យាបាលទូទៅ ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងអចលនវត្ថុរបស់អនីតិជន ចំណែកឯអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិដទៃទៀត និង ការបីបាច់រក្សារូបកាយរបស់អនីតិជន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១០៦.-** ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ

ប្រសិនបើមានមូលហេតុត្រឹមត្រូវ អ្នកអាណាព្យាបាលទូទៅ អាចលាឈប់បាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

(កំណត់)

សូមមើលមាត្រា ១០៧១ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១០៧.-** ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានលាឈប់ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថ្មីទៀតឱ្យបានឆាប់រហ័ស ។

(កំណត់)

សូមមើលមាត្រា ១០៧២ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១០៨.-** ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ

ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានធ្វើសកម្មភាពពុំត្រឹមត្រូវ ឬ មានហេតុផ្សេងទៀតដែលមិនសមរម្យនឹងភារកិច្ចជាអ្នកអាណាព្យាបាលទូទៅ តុលាការអាចបញ្ឈប់អ្នកអាណាព្យាបាលទូទៅនោះបាន តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិបាន ។

(កំណត់)

សូមមើលមាត្រា ១០៧៣ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១០៩.-** បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅ

បុគ្គលដែលកំណត់ក្នុងចំណុចខាងក្រោមនេះ ពុំអាចធ្វើជាអ្នកអាណាព្យាបាលទូទៅបានឡើយ :

ក-អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

ខ-អ្នកតំណាងដែលច្បាប់បានកំណត់ និង ហិតូបត្ថម្ភកៈ ព្រមទាំងអ្នកត្រួតពិនិត្យជនទាំងនោះ ដែលធ្លាប់ត្រូវបានតុលាការដកចេញ ។

គ-ជនដែលក្ស័យធន ។

ឃ-ជនដែលគ្មានដំណឹងអំពីទីរស់នៅ ។

(កំណត់)

សូមមើលមាត្រា ១០៧៤ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ៣ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

**មាត្រា ១១១០.-** អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ តាមការទាមទាររបស់អ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ។

(កំណត់)

សូមមើលកថាខណ្ឌទី ២ មាត្រា ១០៧៥ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៤៩-២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១១១.-** បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

សហព័ទ្ធ និង ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អ្នកអាណាព្យាបាលទូទៅ ពុំអាចធ្វើជាអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅបានឡើយ ។[៧]

(កំណត់)

សូមមើលមាត្រា ១០៧៦ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១១២.-** តួនាទីរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ មានតួនាទីដូចកំណត់ខាងក្រោមនេះ ៖

ក-ត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលទូទៅ ។

ខ-ទាមទារឱ្យតុលាការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថ្មីទៀត ដោយគ្មានការយឺតយ៉ាវ ក្នុងករណីដែលខ្វះអ្នកអាណាព្យាបាលទូទៅ ។

គ-ធ្វើការចាត់ចែងចាំបាច់ ចំពោះជីវភាព ការថែទាំព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិ របស់ជននៅក្រោមអាណាព្យាបាលទូទៅ ក្នុងករណីដែលមានស្ថានភាពបន្ទាន់ ។

ឃ-តំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅ ចំពោះសកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលទូទៅ ឬ ជនដែលអ្នកអាណាព្យាបាលទូទៅនោះធ្វើតំណាងឱ្យ និង ជននៅក្រោមអាណាព្យាបាលទូទៅ មានភាពផ្ទុយគ្នា ។

(កំណត់)

សូមមើលមាត្រា ១០៧៧ នៃក្រមនេះ ។

---

[៧] មាត្រា ១១១១ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១១៣.-** បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា

បញ្ញត្តិកថាខណ្ឌទី ៤ នៃមាត្រា ១១០៥ (ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៩ (បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅ) មាត្រា ១១២០ (ករណីដែលអ្នកអាណាព្យាបាលទូទៅមានច្រើននាក់) មាត្រា ១១២១ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) កថាខណ្ឌទី ២ នៃមាត្រា ១១២៣ (គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលទូទៅ) មាត្រា ១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១២៩ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១៣៣ (ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលទូទៅ ជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលទូទៅ) និង មាត្រា ១១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលទូទៅ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ។

(កំណត់)

សូមមើលមាត្រា ១០៧៨ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ៤ តួនាទីរបស់អ្នកអាណាព្យាបាលទូទៅ

**មាត្រា ១១១៤.-** ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

១-អ្នកអាណាព្យាបាលទូទៅ ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវធ្វើជាតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅ ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានតួនាទីជំនួសឪពុកម្ដាយរបស់អនីតិជន ចំណែកឯអ្នកអាណាព្យាបាលទូទៅ មានតួនាទីគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ និង តំណាងយ៉ាងទូលំទូលាយឱ្យជននៅក្រោមអាណាព្យាបាលទូទៅ ចំពោះសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ។ ហេតុដូច្នេះហើយ អ្នកអាណាព្យាបាលទូទៅ មិនត្រូវបានរំពឹងទុកថា នឹងមើលថែទាំជននៅក្រោមអាណាព្យាបាលទូទៅ ឬ ផ្ដល់អាហារដល់បុគ្គលនោះទេ ។ ករណីយកិច្ចរបស់អ្នកអាណាព្យាបាលទូទៅ គឺធ្វើកិច្ចសន្យាដែលចាំបាច់សម្រាប់ការថែទាំសុខភាព ឬ ព្យាបាលជម្ងឺ និង បង់ថ្លៃចំណាយដែលចាំបាច់ផ្សេងៗ ។ សូមមើលមាត្រា ១០៨០ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១១៥.-** ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ

១-អ្នកអាណាព្យាបាលទូទៅ ត្រូវចាប់ផ្ដើមស្រាវជ្រាវទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលបានកាន់តំណែង ហើយត្រូវបញ្ចប់ការស្រាវជ្រាវនោះ នៅក្នុងអំឡុងពេល ៣ (បី) ខែ និង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាន នៅតុលាការ ។

២-ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ ពុំមានអានុភាពឡើយ បើគ្មានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅនោះទេ ។

(កំណត់)

សូមមើលមាត្រា ១០៨១ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១១៦.-** សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ

រហូតដល់ពេលបញ្ចប់ការធ្វើបញ្ជីសារពើភ័ណ្ឌ អ្នកអាណាព្យាបាលទូទៅមានសិទ្ធិអំណាច ចំពោះតែសកម្មភាពដែលមានភាពចាំបាច់បន្ទាន់ប៉ុណ្ណោះ ។ ប៉ុន្តែ សកម្មភាពនេះមិនអាចតតាំងនឹងតតិយជនដែលសុចរិតបានឡើយ ។

(កំណត់)

សូមមើលមាត្រា ១០៨២ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១១៧.-** ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលទូទៅ ដែលមានចំពោះជននៅក្រោមអាណាព្យាបាលទូទៅ

១-ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ មានសិទ្ធិលើបំណុល ឬ កាតព្វកិច្ចចំពោះជននៅក្រោមអាណាព្យាបាលទូទៅ ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅនោះ ត្រូវរាយការណ៍ជូនអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ អំពីសិទ្ធិលើបំណុល ឬ កាតព្វកិច្ចនោះ នៅមុនពេលចាប់ផ្តើមធ្វើការស្រាវជ្រាវទ្រព្យសម្បត្តិ ។

២-ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានដឹងថាមានសិទ្ធិលើបំណុលចំពោះជននៅក្រោមអាណាព្យាបាលទូទៅ តែមិនបានធ្វើការរាយការណ៍ទេ អ្នកអាណាព្យាបាលទូទៅនោះ ត្រូវបាត់បង់សិទ្ធិលើបំណុលនោះ ។

(កំណត់)

សូមមើលមាត្រា ១០៨៣ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១១៨.-** ការយកមកអនុវត្តដូចគ្នា ចំពោះករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល

បញ្ញត្តិនៃមាត្រា ១១១៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និង ការធ្វើបញ្ជីសារពើភ័ណ្ឌ)

មាត្រា ១១១៦ (សិទ្ធិអំណាចនៅមុនពេលធ្វើបញ្ជីសារពើភ័ណ្ឌ) និង មាត្រា ១១១៧ (ការរាយការណ៍អំពីសិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់អ្នកអាណាព្យាបាលទូទៅ ដែលមានចំពោះជននៅក្រោមអាណាព្យាបាលទូទៅ) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល នៅក្រោយពេលដែលអ្នកអាណាព្យាបាលទូទៅ បានកាន់តំណែង ។

(កំណត់)

សូមមើលមាត្រា ១០៨៤ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១១៩.-** ការគោរពឆន្ទៈរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ជាអាទិ៍

១-ក្នុងការអនុវត្តកិច្ចការដែលទាក់ទងទៅនឹងជីវភាព ការថែទាំព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅត្រូវគោរពឆន្ទៈរបស់ជននៅក្រោមអាណាព្យាបាលទូទៅ និង ត្រូវគិតពិចារណាដល់ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត និង ស្ថានភាពជីវភាពរបស់ជននោះ ។

២-អ្នកអាណាព្យាបាលទូទៅ គប្បីថែទាំព្យាបាលជននៅក្រោមអាណាព្យាបាលទូទៅតាមទ្រព្យធនរបស់ជននៅក្រោមអាណាព្យាបាលទូទៅ និង អ្នកអាណាព្យាបាលទូទៅព្រមទាំងទំនាក់ទំនងរវាងអ្នកទាំងពីរនោះ ។

(កំណត់)

មាត្រា ១១១៩ នោះចែងអំពីគោលការណ៍ជាមូលដ្ឋាននៃការអនុវត្តកិច្ចការអាណាព្យាបាលរបស់អ្នកអាណាព្យាបាលទូទៅ ។ យោងតាមកថាខណ្ឌទី ១ កិច្ចការដែលអាណាព្យាបាលទូទៅត្រូវបំពេញ គឺជាសកម្មភាពទាក់ទងនឹងជីវភាពប្រចាំថ្ងៃដែលចាំបាច់សម្រាប់ជននៅក្រោមអាណាព្យាបាលទូទៅ ដូចជាការទិញរបស់របរចាំបាច់ប្រចាំថ្ងៃ ការបង់ និង ការទទួលប្រាក់ឈ្នួល និង ការធ្វើកិច្ចសន្យាវេជ្ជសាស្ត្រនានា ។ នៅពេលធ្វើសកម្មភាពទាំងនេះ អ្នកអាណាព្យាបាលទូទៅត្រូវគោរពនូវឆន្ទៈរបស់ជននៅក្រោមអាណាព្យាបាលទូទៅឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។ ការធ្វើបែបនេះជាការគោរពនូវសិទ្ធិធ្វើសេចក្ដីសម្រេចដោយខ្លួនឯងរបស់បុគ្គល ។ ប្រសិនបើអ្នកអាណាព្យាបាលទូទៅមិនអាចយល់អំពីឆន្ទៈរបស់ជននៅក្រោមអាណាព្យាបាលទូទៅទេ ជាឧទាហរណ៍ ដោយសារតែបុគ្គលនោះសន្លប់បាត់ស្មារតី ជាអាទិ៍

អ្នកអាណាព្យាបាលទូទៅ គួរព្យាយាមឱ្យអស់ពីលទ្ធភាពដើម្បីរក្សានូវជីវភាពដែលប្រហែលជាបុគ្គលនោះនៅតែប្រាថ្នារស់ ដោយធ្វើការស្រាវជ្រាវអំពីអ្វីដែលបុគ្គលនោះបាននិយាយ និង បានធ្វើនៅពេលដែលបុគ្គលនោះនៅដឹងខ្លួន ជាដើម ។ យោងតាមកថាខណ្ឌទី ២ ដោយសារតែសោហ៊ុយសម្រាប់ការចំណាយចាំបាច់ប្រចាំថ្ងៃ ការថែទាំព្យាបាលជននៅក្រោមអាណាព្យាបាលទូទៅ និង សោហ៊ុយសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ត្រូវចំណាយចេញពីទ្រព្យរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅត្រូវថែទាំព្យាបាលជននៅក្រោមអាណាព្យាបាលឱ្យបានត្រឹមត្រូវសមស្របទៅតាមតម្លៃនៃទ្រព្យសម្បត្តិ ។ ដោយសារតែអ្នកអាណាព្យាបាលទូទៅត្រូវបានជ្រើសរើសចេញពីក្នុងចំណោមបុគ្គលផ្សេងៗ ដូចជាញាតិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ មេធាវី អ្នកជំនាញការច្បាប់ដទៃទៀត ឬ បុគ្គលដែលទាក់ទងនឹងផ្នែកសង្គមកិច្ច ជាអាទិ៍ ទើបទំនាក់ទំនងរវាងជននៅក្រោមអាណាព្យាបាលទូទៅ និង អ្នកអាណាព្យាបាលទូទៅខុសគ្នាពីមួយទៅមួយយ៉ាងខ្លាំង ហើយច្បាប់មិនអាចតម្រូវឱ្យមានការថែទាំព្យាបាលដែលមានកម្រិតណាមួយជាក់លាក់ ចំពោះករណីផ្សេងៗទាំងនេះបានឡើយ ។ ដោយហេតុនេះបានជាកថាខណ្ឌទី ២ តម្រូវឱ្យអ្នកអាណាព្យាបាលទូទៅប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីផ្តល់ការថែទាំព្យាបាល ឱ្យស្របតាមទំនាក់ទំនងរវាងអ្នកទាំងពីរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២០.-** ករណីដែលអ្នកអាណាព្យាបាលទូទៅ មានច្រើននាក់

១-ប្រសិនបើអ្នកអាណាព្យាបាលទូទៅមានច្រើននាក់ តុលាការអាចកំណត់ដោយឆន្ទានុសិទ្ធិ តម្រូវឱ្យអ្នកអាណាព្យាបាលទូទៅដែលមានច្រើននាក់នោះ ប្រើសិទ្ធិអំណាចដោយសហការគ្នា ឬ បែងចែកកិច្ចការគ្នាបាន ។

២-តុលាការ អាចលុបចោលការកំណត់ដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយឆន្ទានុសិទ្ធិបាន ។

៣-ប្រសិនបើអ្នកអាណាព្យាបាលទូទៅមានច្រើននាក់ ចំពោះការបង្ហាញឆន្ទៈរបស់តតិយជន ដែលបានធ្វើចំពោះជនណាម្នាក់នោះ គឺជាការគ្រប់គ្រាន់ ។

(កំណត់)

ដូចដែលបានពន្យល់នៅក្នុងកំណត់នៃមាត្រា ១១០៥ នៃក្រមនេះ ចំនួនអ្នកអាណាព្យាបាលទូទៅមិនត្រូវបានកម្រិតត្រឹមម្នាក់ប៉ុណ្ណោះទេ ។ ហេតុដូច្នេះហើយ មាត្រានេះចែងអំពីការបែងចែកកិច្ចការរវាងអ្នកអាណាព្យាបាលទូទៅ និង អំពីទំនាក់ទំនងរវាងអ្នកអាណាព្យាបាលទូទៅ និង តតិយជន ក្នុងករណីដែលបុគ្គលពីរនាក់ ឬ ច្រើននាក់ត្រូវបាន

ជ្រើសតាំងជាអ្នកអាណាព្យាបាលទូទៅ ។ កថាខណ្ឌទី ៣ ត្រូវបានតាក់តែងឡើង ដើម្បីធានានូវស្ថិរភាពនៃការជួញដូរ ។ ជាឧទាហរណ៍ ប្រសិនបើអ្នកអាណាព្យាបាលទូទៅ A ធ្វើសំណើបង្កើតកិច្ចសន្យាទៅភាគីម្ខាងទៀត ហើយមួយរយៈពេលខ្លីក្រោយមក ភាគីម្ខាងទៀតធ្វើស្ទីការចំពោះសំណើនោះទៅអ្នកអាណាព្យាបាលទូទៅម្នាក់ទៀត B ស្ទីការនេះមានសុពលភាព ហើយកិច្ចសន្យាត្រូវបង្កើតអានុភាព ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៩-២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២១.-** ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ដើម្បីលក់ ជួល រំលាយភតិសន្យា បង្កើតហ៊ីប៉ូតែក ឬ ធ្វើការចាត់ចែងផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ជំនួសជននៅក្រោមអាណាព្យាបាលទូទៅ ចំពោះអាគារដែលប្រើជាលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ឬ ដីដែលអាគារនោះតាំងនៅ អ្នកអាណាព្យាបាលទូទៅ ត្រូវទទួលការអនុញ្ញាតពីតុលាការ ។

(កំណត់)

សូមមើលមាត្រា ១០៨៥ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៥៩-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២២.-** សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ មានភាពផ្ទុយគ្នា

បញ្ញត្តិនៃមាត្រា ១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូន មានភាពផ្ទុយគ្នា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអាណាព្យាបាលទូទៅ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ។

(កំណត់)

សូមមើលមាត្រា ១០៨៦ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២៣.-** គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលទូទៅ

១-អ្នកអាណាព្យាបាលទូទៅ ត្រូវធ្វើគម្រោងចំនួនប្រាក់ដែលត្រូវចំណាយជារៀងរាល់ឆ្នាំ ដើម្បីជីវភាព ការថែទាំព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ នៅជំហានដំបូងនៃពេលដែលបានចាប់ផ្តើមកាន់តំណែង ។

២-សោហ៊ុយចាំបាច់ ដើម្បីអ្នកអាណាព្យាបាលទូទៅបំពេញតួនាទីអាណាព្យាបាលទូទៅ ត្រូវចំណាយចេញពីទ្រព្យសម្បត្តិ របស់ជននៅក្រោមអាណាព្យាបាលទូទៅ ។

(កំណត់)

សូមមើលមាត្រា ១០៨៧ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២៤.-** កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ

តុលាការ អាចផ្តល់កម្រៃសមរម្យ ពីក្នុងចំណោមទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ឱ្យទៅអ្នកអាណាព្យាបាលទូទៅ ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធនរបស់អ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ ព្រមទាំងស្ថានភាពផ្សេងទៀតបាន ។

(កំណត់)

សូមមើលមាត្រា ១០៨៨ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២៥.-** ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលទូទៅ

១-អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ឬ តុលាការ អាចទាមទារឱ្យអ្នកអាណាព្យាបាលទូទៅ រាយការណ៍អំពីតួនាទីរបស់ខ្លួន ឬ ដាក់បញ្ជីសារពើភ័ណ្ឌ ឬ អាចស្រាវជ្រាវអំពីជីវភាព ការថែទាំព្យាបាល ឬ ស្ថានភាពទ្រព្យសម្បត្តិរបស់ជននៅក្រោម

អាណាព្យាបាលទូទៅ នៅពេលណាក៏បាន ។

២-តុលាការ អាចបង្គាប់ឱ្យអ្នកអាណាព្យាបាលទូទៅ ធ្វើការចាត់ចែងចាំបាច់ដែលទាក់ទងនឹងជីវភាព ការថែទាំព្យាបាល ឬ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ឬ ការចាត់ចែងចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងអាណាព្យាបាលទូទៅ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅនោះ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិបាន ។

(កំណត់)

សូមមើលមាត្រា ១០៨៩ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២៦.-** ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម

ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ដើម្បីធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ ជំនួសជននៅក្រោមអាណាព្យាបាលទូទៅ ឬ ដើម្បីយល់ព្រមឱ្យជននៅក្រោមអាណាព្យាបាលទូទៅ ប្រកបអាជីវកម្ម ឬ ធ្វើសកម្មភាពនោះ អ្នកអាណាព្យាបាលទូទៅ ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការទទួលប្រាក់ដើម ។

(កំណត់)

សូមមើលមាត្រា ១០៩០ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២៧.-** អានុភាពនៃការអនុវត្តផ្ទុយនឹងមាត្រា ១១២៦

១-សកម្មភាពដែលអ្នកអាណាព្យាបាលទូទៅបានធ្វើ ឬ បានផ្តល់ការយល់ព្រមដោយផ្ទុយនឹងបញ្ញត្តិនៃមាត្រា ១១២៦ (ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិយល់ព្រម) ខាងលើនេះ មានតែជននៅក្រោមអាណាព្យាបាលទូទៅ ឬ អ្នកអាណា-ព្យាបាលទូទៅទេ ដែលអាចលុបចោលបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌ ១ ខាងលើនេះ ពុំរារាំងក្នុងការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពីមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការវិលត់សិទ្ធិលុប ចោល) នៃក្រមនេះឡើយ ។

(កំណត់)

សូមមើលមាត្រា ១០៩០ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២៨.-** ការទទួលអនុប្បទាននូវទ្រព្យសម្បត្តិ ជាអាទិ៍ ពីជននៅក្រោមអាណា-ព្យាបាលទូទៅ

១-ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានទទួលអនុប្បទាននូវទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ឬ សិទ្ធិរបស់តតិយជនចំពោះជននៅក្រោមអាណា-ព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅនោះ អាចលុបចោលនូវអនុប្បទាននោះបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៣២ (សិទ្ធិដាស់តឿន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងនូវការអនុវត្តបញ្ញត្តិនៃមាត្រា ៣៥៨ (សកម្មភាពដែលអាចលុបចោលបាន) និង បញ្ញត្តិចាប់ពមាត្រា ៣៦០ (វិធីនៃការលុបចោល ឬ សច្ចានុមតិ) រហូតដល់មាត្រា ៣៦៣ (អាជ្ញាយុកាលនៃការវិលត់សិទ្ធិលុបចោល) នៃក្រមនេះឡើយ ។

(កំណត់)

សូមមើលមាត្រា ១០៩២ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១២៩.-** ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកអាណាព្យាបាលទូទៅ

១-អ្នកអាណាព្យាបាលទូទៅ មានករណីយកិច្ចបំពេញតួនាទីអាណាព្យាបាលទូទៅ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ បានធ្វើឱ្យមានការខូចខាតដល់ជននៅក្រោមអាណាព្យាបាលទូទៅ ដោយធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជននៅក្រោមអាណាព្យាបាលទូទៅ អាចទាមទារសំណងនៃការខូចខាតនោះ ពីអ្នកអាណាព្យាបាលទូទៅបាន ។

(កំណត់)

សូមមើលមាត្រា ១០៩៣ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៩ និង មាត្រា ៦៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៣០.-** ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្ដល់ទៅឱ្យជននៅក្រោមអាណាព្យាបាលទូទៅ

១-ប្រសិនបើតតិយជនដែលបានផ្ដល់ទ្រព្យសម្បត្តិឱ្យទៅជននៅក្រោមអាណាព្យាបាលទូទៅ ដោយមិនគិតថ្លៃ បានបង្ហាញឆន្ទៈថា មិនឱ្យអ្នកអាណាព្យាបាលទូទៅគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកអាណាព្យាបាលទូទៅឡើយ ។

២-ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ពុំបានអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតតិយជនពុំបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ

នោះ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅនោះ ឬ តំណាងអយ្យការបាន ។

៣-ទោះបីជាតតិយជនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសិទ្ធិអំណាចរបស់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ បានរលត់ ឬ មានការចាំបាច់ត្រូវផ្លាស់ប្តូរអ្នកនោះ តែតតិយជនមិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត ។

៤-បញ្ញត្តិចាប់ពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) រហូតដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើនេះ ។

(កំណត់)

សូមមើលមាត្រា ១០៩៤ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៦៩ និង មាត្រា ៨៣៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## កថាភាគទី ៥ ការបញ្ចប់អាណាព្យាបាលទូទៅ

**មាត្រា ១១៣១.-** ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ

១-ប្រសិនបើបានបញ្ចប់តួនាទីរបស់អ្នកអាណាព្យាបាលទូទៅហើយ អ្នកអាណាព្យាបាលទូទៅ ឬ សន្តតិជនរបស់អ្នកនោះ ត្រូវធ្វើការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិនោះ នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់តួនាទីនោះ ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារបាន នៅតុលាការ ។

២=បើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ការគណនាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវអនុវត្តដោយមានវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅនោះ ។

(កំណត់)

សូមមើលមាត្រា ១០៩៧ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៣២.-** ករណីយកិច្ចបង់ការប្រាក់ របស់អ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ

១-ចំនួនទឹកប្រាក់ដែលអ្នកអាណាព្យាបាលទូទៅត្រូវសងទៅឱ្យជននៅក្រោមអាណាព្យាបាលទូទៅ និង ចំនួនទឹកប្រាក់ដែលជននៅក្រោមអាណាព្យាបាលទូទៅត្រូវសងទៅឱ្យអ្នកអាណាព្យាបាលទូទៅ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាលទូទៅរួចហើយ ។

២-ប្រសិនបើអ្នកអាណាព្យាបាលទូទៅ បានប្រើប្រាស់ប្រាក់របស់ជននៅក្រោមអាណាព្យាបាលទូទៅ ដើម្បីខ្លួនឯងផ្ទាល់នោះ ត្រូវគិតការប្រាក់ ចាប់ពីពេលដែលបានប្រើប្រាស់ប្រាក់នោះ ។ បើមានការខូចខាត អ្នកអាណាព្យាបាលទូទៅ ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតនោះ ។

(កំណត់)

សូមមើលមាត្រា ១០៩៩នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៣៣.-** ករណីយកិច្ចសង្គ្រោះបន្ទាន់របស់អ្នកអាណាព្យាបាលទូទៅ ជាអាទិ៍ នៅក្រោយពេលបញ្ចប់អាណាព្យាបាលទូទៅ

១-ប្រសិនបើមានស្ថានភាពបន្ទាន់ នៅក្នុងករណីដែលបានបញ្ចប់អាណាព្យាបាលទូទៅហើយ អ្នកអាណាព្យាបាលទូទៅ ឬ សន្តតិជនរបស់អ្នកអាណាព្យាបាលទូទៅនោះ ឬ

អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកអាណាព្យាបាលទូទៅនេះ ត្រូវធ្វើការចាត់ចែងដែលចាំបាច់ រហូតដល់ពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ សន្តតិជនរបស់ជននៅក្រោមអាណាព្យាបាលទូទៅនោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់ជននៅក្រោមអាណាព្យាបាលទូទៅនោះ អាចចាត់ការកិច្ចការនោះបាន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់ ឬ ជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យជននៅក្រោមអាណាព្យាបាលទូទៅ) ។

(កំណត់)

សូមមើលមាត្រា ១១០០ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៤ និង មាត្រា ៦៥៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៣៤.-** ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណាព្យាបាលទូទៅ ជាអាទិ៍

១-មូលហេតុនៃការបញ្ចប់អាណាព្យាបាលទូទៅ ទោះបីជាមូលហេតុនោះកើតឡើងចំពោះជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ឬ ចំពោះអ្នកអាណាព្យាបាលទូទៅក៏ដោយ ពុំអាចយកទៅតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ បើមិនបានជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ឬ បើភាគីម្ខាងទៀតពុំបានដឹងអំពីមូលហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យជននៅក្រោមអាណាព្យាបាលទូទៅ) ។

(កំណត់)

សូមមើលមាត្រា ១១០១ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៤ និង មាត្រា ៦៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៣៥.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងទៅនឹងអាណាព្យាបាលទូទៅ

បញ្ញត្តិនៃមាត្រា ១០៦០ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ រវាងឪពុកម្តាយ និង កូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើបំណុល ដែលបានកើតឡើង ដោយទាក់ទងនឹងអាណាព្យាបាលទូទៅ រវាងអ្នកអាណាព្យាបាលទូទៅ ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ និង ជននៅក្រោមអាណាព្យាបាលទូទៅ ។

(កំណត់)

សូមមើលកថាខណ្ឌទី ១ មាត្រា ១១០២ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ មាត្រា ៨៧៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ៧ ហិតូបត្ថម្ភ

(កំណត់)

ដូចមាននៅក្នុងកថាខណ្ឌទី ១ មាត្រា ២៨ នៃក្រមនេះ ហិតូបត្ថម្ភជាប្រព័ន្ធមួយសម្រាប់ការពារបុគ្គលដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។ ជនដែលស្ថិតក្រោមការការពារ ត្រូវហៅថា "ជននៅក្រោមហិតូបត្ថម្ភ" រីឯជនដែលការពារជននៅក្រោមហិតូបត្ថម្ភ ត្រូវហៅថា "ហិតូបត្ថម្ភកៈ" ។ ហិតូបត្ថម្ភមានលក្ខណៈខុសពីអាណាព្យាបាលទូទៅត្រង់ថា ជននៅក្រោមអាណាព្យាបាលទូទៅស្ថិតក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងវិនិច្ឆ័យ រីឯជននៅក្រោមហិតូបត្ថម្ភមានសមត្ថភាពមិនគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ ។ អាស្រ័យហេតុនេះ ស្ថានភាពស្មារតីរបស់ជននៅក្រោមអាណាព្យាបាលទូទៅ មានលក្ខណៈធ្ងន់ធ្ងរជាងស្ថានភាពស្មារតីរបស់ជននៅក្រោមហិតូបត្ថម្ភ ។ លើសពីនេះទៀត ដោយសារវិបត្តិនានាទាំងឡាយនេះ ជននៅក្រោមអាណាព្យាបាលទូទៅស្ថិតក្នុងស្ថានភាពដែលមានការបង្កការរំខានដល់ជីវភាពប្រចាំថ្ងៃ និង ស្ថានភាពដែលទាមទារឱ្យមានការបីបាច់ថែរក្សារូបកាយរបស់ខ្លួន ។ ផ្ទុយទៅវិញ ជននៅក្រោមហិតូបត្ថម្ភទទួលហិតូបត្ថម្ភចំពោះសកម្មភាពជាក់លាក់មួយចំនួនដែលទាមទារឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងតែប៉ុណ្ណោះ ដោយផ្អែកលើមូលដ្ឋានថា ជននៅក្រោមហិតូបត្ថម្ភ អាចដឹកនាំជីវភាពប្រចាំថ្ងៃដោយផ្ទាល់ខ្លួនបាន ។ នៅឆ្នាំ ២០០០ បញ្ញត្តិស្តីពីហិតូបត្ថម្ភ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន ក៏ត្រូវបានធ្វើវិសោធនកម្មដ៏ធំមួយផងដែរ ។ ជំពូកនេះត្រូវបានរៀបចំឡើង ដោយឆ្លុះបញ្ចាំងពីលទ្ធផលនៃវិសោធនកម្មនៃក្រមជប៉ុន បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់មក ។ សូមមើលមាត្រា ២៨ ដល់

មាត្រា ៣១ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១ ដល់មាត្រា ១៣ និង មាត្រា ៨៧៦ ដល់មាត្រា ៨៧៦-៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៣៦.-** ការចាប់ផ្តើមហិតូបត្ថម្ភ

ហិតូបត្ថម្ភ ត្រូវចាប់ផ្តើមដោយបញ្ញត្តិនៃមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមនេះ ។

(កំណត់)

មាត្រានេះបញ្ជាក់ថា តុលាការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់បុគ្គលម្នាក់ក្នុងចំណោមបុគ្គលទាំងឡាយដែលរៀបរាប់នៅក្នុងមាត្រា ២៨ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៦ របស់ក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៣៧.-** ការជ្រើសតាំងហិតូបត្ថម្ភកៈ

១-ប្រសិនបើប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ តុលាការត្រូវជ្រើសតាំងហិតូបត្ថម្ភកៈដោយឆន្ទានុសិទ្ធិ ។

២-បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ រហូតដល់កថាខណ្ឌទី ៤ នៃមាត្រា ១១០៥ (ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) និង បញ្ញត្តិចាប់ពីមាត្រា ១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) រហូតដល់មាត្រា ១១០៩ (បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះហិតូបត្ថម្ភកៈ ។

៣-ចំពោះសកម្មភាពដែលផលប្រយោជន៍របស់ហិតូបត្ថម្ភកៈ ឬ ជនដែលហិតូបត្ថម្ភកៈនោះធ្វើតំណាងឱ្យ និង ជននៅក្រោមហិតូបត្ថម្ភ មានភាពផ្ទុយគ្នា ហិតូបត្ថម្ភកៈត្រូវទាមទារឱ្យតុលាការជ្រើសតាំងហិតូបត្ថម្ភកៈជាបណ្តោះអាសន្ន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា រវាងជននៅក្រោមហិតូបត្ថម្ភច្រើននាក់ ដែលស្ថិតនៅក្រោមហិតូបត្ថម្ភកៈដូចគ្នា ។

(កំណត់)

មាត្រា ១១៣៧ នេះបញ្ញត្តអំពីបទដ្ឋានសម្រាប់តុលាការក្នុងការជ្រើសតាំងហិតូបត្ថម្ភកៈ ។ ដូចដែលបានចែងក្នុងកថាខណ្ឌទី ២ បទដ្ឋាននៃការជ្រើសតាំងអាណាព្យាបាលទូទៅត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ។ កថាខណ្ឌទី ៣ ប្រមើលមើលនូវករណីដូចតទៅ : ជាបឋម សកម្មភាពដែលផលប្រយោជន៍របស់ហិតូបត្ថម្ភកៈ និង ជននៅក្រោមហិតូបត្ថម្ភមានភាពផ្ទុយគ្នា សំដៅលើករណីដូចជា ការលក់ទិញរវាងជននៅក្រោមហិតូបត្ថម្ភ និង ហិតូបត្ថម្ភកៈ ត្រូវបានធ្វើឡើងចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ជននៅក្រោមហិតូបត្ថម្ភ ។ ចំណែកឯសកម្មភាពដែលផលប្រយោជន៍របស់ជនដែលហិតូបត្ថម្ភកៈធ្វើតំណាងឱ្យ និង ជននៅក្រោមហិតូបត្ថម្ភមានភាពផ្ទុយគ្នា មានដូចជាករណីដែលហិតូបត្ថម្ភកៈមានកូនដែលជាអនីតិជន និង ហិតូបត្ថម្ភកៈក្លាយជាអ្នកតំណាងរបស់កូននោះ តាមការអនុវត្តអំណាចមេបា ហើយការលក់ទិញអចលនវត្ថុរវាងកូននោះ និង ជននៅក្រោមហិតូបត្ថម្ភត្រូវបានធ្វើឡើង ។ ក្នុងករណីនេះ តាមភាពជាក់ស្ដែង ការលក់ទិញនេះអាចត្រូវបានវាយតម្លៃថាជាប្រតិបត្តិការរវាងហិតូបត្ថម្ភកៈ និង ជននៅក្រោមហិតូបត្ថម្ភ ។ ក្នុងករណីបែបនេះ ដើម្បីការពារផលប្រយោជន៍របស់ជននៅក្រោមហិតូបត្ថម្ភ ចំពោះប្រតិបត្តិការនេះ បញ្ញត្តិនេះតម្រូវឱ្យជ្រើសតាំងហិតូបត្ថម្ភកៈជាបណ្ដោះអាសន្ន ហើយដកហិតូបត្ថម្ភកៈពីតួនាទីចំពោះប្រតិបត្តិការនោះមួយរយៈសិន ។ កថាខណ្ឌទី ៤ គឺជាការដោះស្រាយចំពោះករណីដូចជា នៅពេលដែលហិតូបត្ថម្ភកៈមួយរូបអនុវត្តហិតូបត្ថម្ភ ចំពោះជនដែលនៅក្រោមហិតូបត្ថម្ភ A និង B ប្រតិបត្តិការរវាង A និង B នឹងត្រូវទទួលការវិនិច្ឆ័យ ពីហិតូបត្ថម្ភកៈមួយរូបនោះ ។ ស្ថានភាពនេះស្រដៀងនឹងការតំណាងទាំងសងខាង ដែលបានចែងក្នុងកថាខណ្ឌទី ៣ មាត្រា ៣៦៧ នៃក្រមនេះ ដូច្នេះ បុគ្គល A ឬ B អាចទទួលរងការខូចខាតផលប្រយោជន៍ ។ ក្នុងករណីបែបនេះ ក៏ចាំបាច់ត្រូវមានហិតូបត្ថម្ភកៈជាបណ្ដោះអាសន្នដែរ ប៉ុន្តែ ការជ្រើសតាំងហិតូបត្ថម្ភកៈជាបណ្ដោះអាសន្នសម្រាប់តែភាគី A ឬ B ម្ខាង ជាការគ្រប់គ្រាន់ហើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៦-២ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១១៣៨.- អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ

១-ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចជ្រើសតាំងអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ តាមការទាមទាររបស់ហិតូបត្ថម្ភកៈ ជននៅក្រោមហិតូបត្ថម្ភ សហព័ទ្ធរបស់ជននៅក្រោមហិតូបត្ថម្ភ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមហិតូបត្ថម្ភ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមហិតូបត្ថម្ភ តំណាងអយ្យការ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

២-បញ្ញត្តិកថាខណ្ឌទី ៤ នៃមាត្រា ១១០៥ (ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) មាត្រា ១១០៩ (បុគ្គលដែលមិនអាចក្លាយជាអ្នកអាណា-ព្យាបាលទូទៅ) មាត្រា ១១១១ (បុគ្គលដែលមិនអាចក្លាយជាអ្នកត្រួតពិនិត្យអ្នកអាណា-ព្យាបាលទូទៅ) មាត្រា ១១២០ (ករណីដែលអ្នកអាណាព្យាបាលទូទៅ មានច្រើននាក់) កថាខណ្ឌទី ២ នៃមាត្រា ១១២៣ (គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលទូទៅ) និង មាត្រា ១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

៣-អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ អាចយល់ព្រមឱ្យជននៅក្រោមហិតូបត្ថម្ភធ្វើសកម្ម-ភាព ចំពោះសកម្មភាពដែលផលប្រយោជន៍របស់ហិតូបត្ថម្ភកៈ ឬ ជនដែលហិតូបត្ថម្ភកៈនោះធ្វើតំណាងឱ្យ និង ជននៅក្រោមហិតូបត្ថម្ភ មានភាពផ្ទុយគ្នា ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា រវាងជននៅក្រោមហិតូបត្ថម្ភច្រើននាក់ ដែលស្ថិតនៅក្រោមហិតូបត្ថម្ភកៈដូចគ្នា ។

(កំណត់)

ដើម្បីត្រួតពិនិត្យកិច្ចការរបស់ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈអាចត្រូវបានជ្រើសតាំងបាន ដូចជាការជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ការជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ដើម្បីត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលទូទៅដែរ ។ កថាខណ្ឌទី ២ ចែងថា បញ្ញត្តិទាំងឡាយទាក់ទងនឹងការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ និង ការជ្រើសតាំងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការជ្រើសតាំងអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។ ម្យ៉ាងទៀត ហិតូបត្ថម្ភកៈជាបណ្ដោះអាសន្នដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ១១៣៧ អាចនិយាយបានថាជាអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈជាបណ្ដោះអាសន្ន ។ ផ្ទុយទៅវិញ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈត្រង់នេះ ត្រូវធ្វើការងារពេញម៉ោង ដូច្នេះ ប្រសិនបើអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈត្រូវបានជ្រើសតាំងរួចហើយ ការជ្រើសតាំងហិតូបត្ថម្ភកៈជាបណ្ដោះអាសន្នមិនមានភាពចាំបាច់ឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៦-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៣៩.-** តួនាទីរបស់ហិតូបត្ថម្ភកៈ

១-ហិតូបត្ថម្ភកៈ មានសិទ្ធិអំណាចក្នុងការយល់ព្រមឱ្យជននៅក្រោមហិតូបត្ថម្ភ ធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ ឬ លុបចោលសកម្មភាពទាំងនោះ ដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ។

២-ក្នុងការអនុវត្តកិច្ចការដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហិតូបត្ថម្ភកៈត្រូវគោរពឆន្ទៈរបស់ជននៅក្រោមហិតូបត្ថម្ភ និង ត្រូវគិតពិចារណាដល់ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត និង ស្ថានភាពជីវភាពរបស់ជននោះ ។

៣-បញ្ញត្តិនៃមាត្រា ១១២០ (ករណីដែលអ្នកអាណាព្យាបាលទូទៅ មានច្រើននាក់) កថាខណ្ឌទី ២ នៃមាត្រា ១១២៣ (គម្រោងនៃចំនួនប្រាក់ចំណាយ និង សោហ៊ុយនៃអាណាព្យាបាលទូទៅ) មាត្រា ១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) និង មាត្រា ១១២៥ (ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលទូទៅ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតួនាទីរបស់ហិតូបត្ថម្ភកៈ ។

៤-បញ្ញត្តិនៃមាត្រា ១០៦០ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ រវាងឪពុកម្ដាយ និង កូន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងហិតូបត្ថម្ភ រវាងហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ និង ជននៅក្រោមហិតូបត្ថម្ភ ។

(កំណត់)

មាត្រា ១១៣៩ នេះ បញ្ញត្តអំពីតួនាទីរបស់ហិតូបត្ថម្ភកៈ ។ នៅក្នុងហិតូបត្ថម្ភ អ្នកធ្វើសកម្មភាព គឺជននៅក្រោមហិតូបត្ថម្ភផ្ទាល់ខ្លួនឯង ។ ក៏ប៉ុន្តែ នៅពេលដែលសកម្មភាពនោះ គឺជាសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ នៃក្រមនេះ មានន័យថា សកម្មភាពចាត់ចែងទ្រព្យសម្បត្តិដែលសំខាន់ៗ ដើម្បីធ្វើឱ្យសកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភមានសុពលភាព ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ ។ បានសេចក្តីថា ប្រសិនបើជននៅក្រោមហិតូបត្ថម្ភបានធ្វើសកម្មភាពដែលចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ ហិតូបត្ថម្ភកៈ ឬ ជននៅក្រោមហិតូបត្ថម្ភ អាចលុបចោលសកម្មភាពនោះបាន ។ ប៉ុន្តែ ហិតូបត្ថម្ភកៈមិនគួរអនុវត្តសិទ្ធិ

លុបចោលសកម្មភាពដោយគ្រាន់តែគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈប៉ុណ្ណោះទេ ក្នុងករណីដែលជននៅក្រោមហិតូបត្ថម្ភចង់ធ្វើសកម្មភាពនោះ ហើយសកម្មភាពនោះមិនប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ជននៅក្រោមហិតូបត្ថម្ភផងនោះ ។ ដូច្នេះហើយ កថាខណ្ឌទី ២ បញ្ញត្តថា ហិតូបត្ថម្ភកៈត្រូវអនុវត្តសិទ្ធិយល់ព្រម ឬ សិទ្ធិលុបចោល ដោយត្រូវគោរពដល់សិទ្ធិស្វ័យសម្រេចរបស់ជននៅក្រោមហិតូបត្ថម្ភ និង ត្រូវគិតគូរពិចារណាដល់រាល់ស្ថានភាពផ្សេងៗរបស់ជននៅក្រោមហិតូបត្ថម្ភ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៦-៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

# ជំពូកទី ៨ អាហារកាតព្វកិច្ច

(កំណត់)

អាហារកាតព្វកិច្ច គឺជាជំនួយផ្នែកហិរញ្ញវត្ថុ ដល់បុគ្គលដែលមិនអាចទ្រទ្រង់ជីវភាពដោយសមត្ថភាពខ្លួនឯងបាន ។ បុគ្គលដែលត្រូវការអាហារកាតព្វកិច្ច ហៅថា "ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច" រីឯជនដែលត្រូវផ្តល់អាហារកាតព្វកិច្ច ហៅថា "ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច" ។ តាមក្រមរដ្ឋប្បវេណី ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវបានកំណត់ពីក្នុងចំណោមជនដែលមានញាតិភាពជាក់លាក់ជាមួយជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ។ អាហារកាតព្វកិច្ចប្រភេទនេះ ហៅថា "អាហារកាតព្វកិច្ចឯកជន" រីឯអាហារ-កាតព្វកិច្ច ដែលរដ្ឋាភិបាលផ្តល់ឱ្យជនស្ថិតក្នុងភាពក្រីក្រ ក្នុងនាមជាការឧបត្ថម្ភសង្គមកិច្ច ហៅថា "អាហារកាតព្វកិច្ចសាធារណៈ" ។

ម្យ៉ាងទៀត ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចរវាងសហព័ទ្ធ គឺជាអានុភាពនៃអាពាហ៍ពិពាហ៍ ហើយករណីយកិច្ចនេះមានមូលដ្ឋាននៅក្នុងមាត្រា ៩៦៦ នៃក្រមនេះ ។ ម្យ៉ាងវិញទៀត ករណីយកិច្ចផ្តល់អាហារកាតព្វកិច្ចរបស់ឪពុកម្តាយចំពោះកូនដែលជាអនីតិជន គឺជាអានុភាពនៃអំណាចមេបា ហើយករណីយកិច្ចនេះមានមូលដ្ឋាននៅក្នុងមាត្រា ១០៣៤ នៃក្រមនេះ ។ អាស្រ័យហេតុនេះ អាហារកាតព្វកិច្ចដែលចែងក្នុងជំពូកនេះ សំដៅលើអាហារកាតព្វកិច្ចតែរវាងញាតិ ដោយមិនរាប់បញ្ចូលនូវទំនាក់ទំនងរវាងសហព័ទ្ធ និង ទំនាក់ទំនងរវាងឪពុកម្តាយ និង កូនដែលជាអនីតិជនឡើយ ។

ដូចបានបញ្ជាក់នៅក្នុងមាត្រានីមួយៗ អាទិភាពនៃការផ្គត់ផ្គង់ និង ការទទួលការផ្គត់ផ្គង់ អាស្រ័យតាមការពិភាក្សារវាងភាគី ដោយហេតុថា មាត្រាទាំងនេះទាក់ទងនឹងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងញាតិ ។ តុលាការធ្វើសេចក្តីសម្រេចអំពីទំនាក់ទំនងអាហារកាតព្វកិច្ច តែក្នុងករណីដែលភាគីមិនអាចសម្រេចតាមការពិភាក្សាប៉ុណ្ណោះ ។ ដោយហេតុថាច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩ ពុំមានបញ្ញត្តិណាយោងឡើយ បញ្ញត្តិដែលទាក់ទងនឹងអាហារកាតព្វកិច្ចនៅក្នុងជំពូកនេះ ត្រូវបានរៀបចំឡើង ដោយផ្អែកតាមបញ្ញត្តិចាប់ពីមាត្រា ៨៧៧ ដល់មាត្រា ៨៨១ នៃក្រមរដ្ឋប្បវេណីជប៉ុន បន្ទាប់ពីមានការពិភាក្សាដោយក្រុមការងារ ។

**មាត្រា ១១៤០.-** ទំហំ និង លំដាប់ នៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច

១-ញាតិ ក្លាយជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច តាមទំហំ និង លំដាប់ ដូចខាងក្រោមនេះ :

ទី ១ ញាតិដែលរស់នៅជាមួយគ្នា ។

ទី ២ ញាតិលោហិតខ្សែផ្ទាល់ ។

ទី ៣ បងប្អូនបង្កើត ។

២-ក្រៅពីជនដែលបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចឱ្យញាតិនៅក្នុងថ្នាក់ទី ៣ (បី) ទទួលបន្ទុកករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន បើមានស្ថានភាពពិសេស ។ នៅក្នុងករណីដែលអាពាហ៍ពិពាហ៍បានរលាយ ដោយសារមរណភាពរបស់សហព័ទ្ធម្ខាង បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាហារកាតព្វកិច្ចរវាងសហព័ទ្ធដែលនៅរស់ និង ញាតិរបស់សហព័ទ្ធដែលបានទទួលមរណភាព ។

៣-ក្រោយពីបានសម្រេចសេចក្ដីតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ បើមានការផ្លាស់ប្ដូរស្ថានភាព តុលាការអាចលុបចោលនូវសេចក្ដីសម្រេចនោះបាន ។

(កំណត់)

មាត្រានេះចែងអំពីទំហំ និង លំដាប់ នៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ។

កថាខណ្ឌទី ១ ចែងអំពីគោលការណ៍នៃទំហំ និង លំដាប់ នៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ។

ជាដំបូង ជនដែលទទួលបន្ទុកនូវករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺជាញាតិដែលរស់នៅជាមួយជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ។ ទំហំរបស់ញាតិត្រូវបានកំណត់នៅក្នុងមាត្រា ៩៣៨ នៃក្រមនេះ ។

ឧទាហរណ៍ថា ឪពុកមារបស់ប្រពន្ធ បានបាត់បង់ផ្ទះរបស់ខ្លួនដោយសារទឹកជំនន់ ហើយឪពុកមារបស់ប្រពន្ធនោះបានចាប់ផ្ដើមមករស់នៅជាបណ្ដោះអាសន្នជាមួយគ្រួសារក្មួយស្រី ។ ចំពោះប្ដី ឪពុកមារបស់ប្រពន្ធនោះ គឺជាញាតិពន្ធថ្នាក់ទី ៣ ។ អាស្រ័យហេតុនេះ នៅពេលឪពុកមារបស់ប្រពន្ធកំពុងរស់នៅជាមួយប្ដី ប្ដីត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ដល់ឪពុកមានោះ ។

ម្យ៉ាងវិញទៀត ឧទាហរណ៍ថា កូនប្រុសទី១ ទី២ និង ទី៣ ព្រមទាំងប្រពន្ធរបស់កូន ៣ នាក់នោះ រស់នៅជាមួយគ្នាក្នុងផ្ទះមួយ ហើយកូនប្រុសទី ៣ និង ប្រពន្ធរបស់កូនប្រុងទី ៣ នោះ ក្លាយជាជនមិនអាចធ្វើការងារបាន ។ ក្នុងករណីនេះ អាហារកាតព្វកិច្ចត្រូវផ្គត់ផ្គង់ ជាបឋម ដោយញាតិដែលរស់នៅជាមួយគ្នា ពោលគឺដោយកូនប្រុសទី ១ និង

ទី ២ ព្រមទាំងប្រពន្ធរបស់កូនទាំង ២ នាក់នោះ ។

មានករណីមួយចំនួនដែលជនម្នាក់រស់នៅជាមួយជនម្នាក់ទៀត ក្រៅទំហំញាតិ ហើយទទួលជំនួយផ្នែកហិរញ្ញវត្ថុពីជនម្នាក់ទៀត ឬ ផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុដល់ជនណាម្នាក់ទៀត ។ កថាខណ្ឌទី ១ នេះ មិនបដិសេធការជួយគ្នាទៅវិញទៅមកផ្នែកសង្គម និង ការមានសន្តានចិត្តបែបនោះទេ ។ ក៏ប៉ុន្តែ ដោយសារតែអាហារកាតព្វកិច្ចតាមក្រមរដ្ឋប្បវេណី គឺជាទំនាក់ទំនងនៃសិទ្ធិ និង ករណីយកិច្ច ដែលកំណត់ដោយច្បាប់ ដូច្នេះ មានការចាំបាច់ក្នុងការកំណត់ទំហំ និង លំដាប់នៃសិទ្ធិ និង ករណីយកិច្ច ។

ជនលំដាប់ទី ២ ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺញាតិលោហិតខ្សែផ្ទាល់របស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ។ វាពុំមានបញ្ហាថា តើជននោះរស់នៅ ឬ មិនរស់នៅជាមួយគ្នានោះទេ ។ ញាតិលោហិតខ្សែផ្ទាល់ គឺ ឪពុកម្តាយ ជីដូនជីតា ជីទួត បុព្វញាតិថ្នាក់ខ្ពស់ជាងនេះ និង កូន ចៅ ចៅទួត បច្ឆាញាតិផ្ទាល់ទាបជាងនេះ ។ រវាងញាតិលោហិតខ្សែផ្ទាល់ ទោះបីជាមិនរស់នៅជាមួយគ្នាក៏ដោយ ក៏ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចត្រូវកើតឡើងទៅវិញទៅមកដែរ ។ ទំនាក់ទំនងរវាងញាតិដែលរស់នៅជាមួយជនមានសិទ្ធិទទួលអាហារកាតព្វកិច្ច (ជនលំដាប់ទី ១ ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច) និង ញាតិលោហិតខ្សែផ្ទាល់ (ជនលំដាប់ទី ២ ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច) អាចត្រូវបានបកស្រាយដូចតទៅ : ឧទាហរណ៍ថា ឪពុកម្តាយមានកូនស្រី ៣ នាក់ ហើយឪពុកម្តាយនោះកំពុងរស់នៅជាមួយកូនស្រីទី ៣ និង ប្តីរបស់នាងនោះ រីឯកូនស្រីទី ១ និង ទី ២ រស់នៅជាមួយប្តីរៀងៗខ្លួនផ្សេងពីផ្ទះឪពុកម្តាយ ។ ក្នុងករណីនេះ ជនដែលទទួលបន្ទុកនូវករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ឪពុកម្តាយនោះ គឺជាកូនស្រីទី ៣ និង ប្តីរបស់នាងដែលរស់នៅជាមួយឪពុកម្តាយនោះ ។ មូលហេតុនេះ គឺដោយសារញាតិរស់នៅជាមួយគ្នា គឺជាជនលំដាប់ទី ១ ដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ។

ទំនាក់ទំនងរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំ ដែលបង្កើតឡើងដោយសុំកូន ដោយយោងតាមកថាខណ្ឌទី ១ មាត្រា ១០៥១ និង កថាខណ្ឌទី ១ មាត្រា ១០២៧ នៃក្រមនេះ ត្រូវបង្កើតនូវសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងសិទ្ធិ និង ករណីយកិច្ចនៃទំនាក់ទំនងរវាងកូន និង ឪពុកម្តាយបង្កើត ។ ហេតុដូច្នេះ ទំនាក់ទំនងរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំ ត្រូវបានចាត់ទុកថាជាទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ ហើយករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ក៏ត្រូវកើតឡើងរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំដែរ ។

ជនលំដាប់ទី ៣ ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺបងប្អូនបង្កើតរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ។ បញ្ហាមិនស្ថិតនៅត្រង់ថា តើបងប្អូននោះរស់នៅ ឬ មិនរស់នៅជាមួយជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចនោះទេ ។ ទំនាក់ទំនងរវាងជនលំដាប់ ទី ១ ដែលជាញាតិដែលរស់នៅជាមួយគ្នា ជនលំដាប់ទី ២ ដែលជាញាតិលោហិតខ្សែផ្ទាល់ និង ជនលំដាប់ទី ៣ ដែលជាបងប្អូន មានដូចតទៅ ។ ឧទាហរណ៍ថា ក្នុងករណីមានបងប្អូនប្រុស ៣ នាក់ ប្អូនប្រុសៗរស់នៅជាមួយគ្នា រីឯបងប្រុសច្បងរស់នៅផ្សេង ហើយប្រសិនបើប្អូនប្រុសពៅក្លាយជាជនដែលមិនអាចធ្វើការបាន ដោយសារតែមានជម្ងឺ ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺបងប្រុសទី ២ ដែលរស់នៅជាមួយ

ប្អូនប្រុសពៅនោះ ។ ឧទាហរណ៍មួយផ្សេងទៀត គឺ ប្រសិនបើបុរសចំណាស់ម្នាក់រស់នៅជាមួយប្អូនស្រីរបស់ខ្លួន ហើយកូន និង ចៅរបស់បុរសនោះរស់នៅផ្សេង ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់បុរសចំណាស់នោះ គឺប្អូនស្រីរបស់បុរសនោះដែលជាញាតិរស់នៅជាមួយគ្នា ។

កថាខណ្ឌទី ២ ពាក់ព័ន្ធនឹងករណីលើកលែងនៃកថាខណ្ឌទី ១ ។ សូមយកស្ថានភាពដូចតទៅ ជាឧទាហរណ៍ ដោយសារភាពក្រីក្រ មនុស្សម្នាក់នៅតែមិនរៀបការ ដូច្នេះ ពុំមានកូន ឬ ចៅ ហើយឪពុកម្ដាយ ជីដូនជីតា និង បងប្អូនរបស់ជននោះក៏បានទទួលមរណភាពអស់ដែរ ហើយនៅសល់តែញាតិដែលកំណត់ដោយច្បាប់តែម្នាក់ប៉ុណ្ណោះ គឺក្មួយប្រុសម្នាក់ (កូនរបស់បងប្រុស) ដែលរស់នៅឆ្ងាយ ។ ថ្វីត្បិតតែឪពុកមា និង ក្មួយប្រុស គឺជាញាតិតាមច្បាប់ ក៏ប៉ុន្តែជនទាំងពីរនេះមិនស្ថិតក្នុងទំនាក់ទំនងនៃជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច និង ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចឡើយ ដោយសារក្មួយប្រុសមិនស្ថិតនៅក្នុងទំហំដែលកំណត់ក្នុងកថាខណ្ឌទី ១ ឡើយ ។ ក្នុងករណីនេះ តាមកថាខណ្ឌទី ២ តុលាការអាចដាក់បន្ទុកករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ទៅលើក្មួយប្រុសដែលជាញាតិស្ថិតនៅក្នុងថ្នាក់ទី ៣ នៃទំនាក់ទំនងញាតិ តាមពាក្យសុំរបស់ឪពុកមាបាន ។ តាមរយៈមធ្យោបាយនេះ មានករណីមួយចំនួនដែលតាមការសម្រេចសេចក្ដីរបស់តុលាការ ទំនាក់ទំនងរវាងជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច និង ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច អាចត្រូវបានបង្កើតឡើងទៅវិញទៅមក រវាងឪពុកមា ឬ ម្ដាយមីង ជាមួយក្មួយប្រុស ឬ ក្មួយស្រី ដែលជាញាតិស្ថិតនៅក្នុងថ្នាក់ទី ៣ ។

"ស្ថានភាពពិសេស" មានករណីផ្សេងៗជាច្រើន ។ ជាឧទាហរណ៍ ទោះបីជាមានជនលំដាប់ទី ១ ដល់ លំដាប់ទី៣ ដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចក៏ដោយ ក៏ជនទាំងនោះស្ថិតក្នុងស្ថានភាពក្រីក្រ ហើយពុំមានសាធនភាពគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់អាហារកាតព្វកិច្ចដែរ ។ ឧទាហរណ៍មួយទៀត ដោយហេតុថា ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារ-កាតព្វកិច្ច បានបាត់ខ្លួន ទោះបីជាមិនទាន់ច្បាស់ថា បានទទួលមរណភាពក៏ដោយ ក៏ពុំមានសង្ឃឹមថា ជននោះអាចនឹងបំពេញករណីយកិច្ចនេះបានដែរ ។

កថាខណ្ឌទី ៣ មានន័យថា ក្នុងករណីប្រហាក់ប្រហែលនឹងករណីកថាខណ្ឌទី ២ ដូចបានរៀបរាប់ខាងលើ ប្រសិនបើបន្ទាប់ពីតុលាការបង្គាប់ឱ្យក្មួយប្រុសផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ឪពុកមាហើយ ឪពុកមាបានរកឃើញកន្លែងរស់នៅរបស់កូនប្រុសរបស់ខ្លួន ដែលជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចលំដាប់ទី ២ តុលាការអាចលុបចោលសេចក្ដីសម្រេចដែលបង្គាប់ឱ្យក្មួយប្រុសផ្គត់ផ្គង់ដល់ឪពុកមានោះបាន ដោយសន្និដ្ឋានថា មានការផ្លាស់ប្ដូរនូវស្ថានភាព ។ ការផ្គត់ផ្គង់អាហារកាតព្វកិច្ចដោយក្មួយប្រុស ចំពោះឪពុកមា គឺជាករណីលើកលែង ។ ប្រសិនបើជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមច្បាប់ អាចផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន គួរតែឱ្យជននោះផ្គត់ផ្គង់អាហារកាតព្វកិច្ច ដោយត្រឡប់មករកគោលការណ៍នៃកថាខណ្ឌទី ១ វិញ ។ ជាទូទៅ ជនដែលតុលាការបង្គាប់ឱ្យផ្គត់ផ្គង់អាហារកាតព្វកិច្ច ដាក់ពាក្យសុំឱ្យលុបចោល ក៏ប៉ុន្តែ វាក៏ពុំមានបញ្ហាចោទដែរ ប្រសិនបើជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ឬ ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចពិតប្រាកដ ដាក់ពាក្យសុំឱ្យលុប

ចោលដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៤១.-** ការកំណត់ជាក់លាក់ អំពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និង ជនដែលទទួលអាហារកាតព្វកិច្ច

១-ប្រសិនបើជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មានច្រើននាក់ ជនទាំងនោះត្រូវកំណត់ជាក់លាក់ អំពីជនម្នាក់ ឬ ច្រើននាក់ ដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ដោយការពិភាក្សា ។

២-បើការពិភាក្សារវាងភាគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធន អាយុ ស្ថាន-ភាពផ្លូវកាយ និង ផ្លូវចិត្ត របស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទំនាក់ទំនងបុគ្គលរបស់ភាគី និង ស្ថានភាពផ្សេងទៀតទាំងអស់ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់ជាក់លាក់អំពីជនដែលត្រូវទទួលអាហារកាតព្វកិច្ច នៅពេលដែលជនមានសិទ្ធិទទួលអាហារកាតព្វកិច្ចមានចំនួនច្រើននាក់ ហើយលទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ពុំគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ ចំពោះជនទាំងអស់នោះទេ ។

(កំណត់)

មាត្រា ១១៤១ ចែងអំពីការសម្របសម្រួលនូវទំនាក់ទំនង ក្នុងករណីដែលជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មានចំនួនច្រើននាក់ ឬ ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចមានចំនួនច្រើននាក់ ។

កថាខណ្ឌទី ១ ពាក់ព័ន្ធនឹងស្ថានភាពដែលចំនួនជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចមានម្នាក់ រីឯជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចមានចំនួនច្រើននាក់ ។ ជាឧទាហរណ៍ ប្រសិនបើឪពុកម្តាយស្ថិតក្នុងភាពក្រីក្រ ហើយរស់នៅផ្សេងពីកូនប្រុសទាំងបីរបស់ខ្លួន ។ ក្នុងករណីនេះ កូនប្រុសទាំងបីនោះគឺជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ។ ក្នុងករណីនេះ តើកូនប្រុសច្បង កូនប្រុសទី ២ ឬ កូនប្រុសពៅត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច

ដល់ឪពុកម្តាយ ? ក្រមរដ្ឋប្បវេណីចែងថា ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មានន័យថាជាកូនប្រុសទាំងបីក្នុងឧទាហរណ៍ខាងលើនេះ ត្រូវកំណត់ជនដែលត្រូវផ្គត់ផ្គង់ដល់ឪពុកម្តាយ តាមការពិភាក្សាគ្នា ។ មានន័យថាក្រមរដ្ឋប្បវេណីបានសម្រេចយកគោលការណ៍នៃការពិភាក្សាគ្នាទៅវិញទៅមក ។ ជាលទ្ធផលនៃការពិភាក្សាគ្នានេះ កូនប្រុសទាំងបីនេះអាចសម្រេចថា កូនទី ២ គួរថែរក្សាឪពុកម្តាយតែម្នាក់ឯង ឬ កូនប្រុសទាំងបី គួររួមចំណែកស្មើគ្នាសម្រាប់ការចំណាយចាំបាច់ ។ ដោយហេតុថា ចង់ឱ្យមានការសម្រេចចិត្ត ដោយសន្តិវិធីតាមរយៈការពិភាក្សា ទើបក្រមនេះសម្រេចយកការពិភាក្សាក្នុងចំណោមជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ធ្វើជាគោលការណ៍ ។

ម្យ៉ាងទៀត ការពិភាក្សាបែបនេះមិនត្រូវបានកម្រិតតែរវាងជនដែលមានករណីយកិច្ចត្រូវផ្គង់ផ្គង់អាហារកាតព្វកិច្ចក្នុងលំដាប់ដូចគ្នាប៉ុណ្ណោះទេ ។ ជាឧទាហរណ៍ ប្រសិនបើមានកូនជាជនលំដាប់ទី ២ ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ក៏ប៉ុន្តែ កូននោះស្ថិតនៅក្នុងស្ថានភាពក្រីក្រ ហើយពុំមានសាធនភាពគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់ឪពុកម្តាយ កូននោះគួរពិភាក្សាជាមួយបងប្អូនរបស់ឪពុកម្តាយ ដែលជាជនស្ថិតនៅក្នុងលំដាប់ទី ៣ នៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ដើម្បីកំណត់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ឪពុកម្តាយ ។ ក្រមនេះអនុញ្ញាតឱ្យមានការពិភាក្សាក្នុងចំណោមជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចក្នុងលំដាប់ដូចគ្នា និង ការពិភាក្សាក្នុងចំណោមជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចក្នុងលំដាប់ខុសគ្នាផងដែរ ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ដោយគិតពិចារណាទៅលើស្ថានភាពផ្សេងៗ ។ ឧទាហរណ៍ថា ក្នុងករណីដែលកូនបីនាក់ជាជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ឪពុកម្តាយ កូនប្រុសទី ១ និងទី ២ ព្រមព្រៀងថា ម្នាក់ៗត្រូវទទួលបន្ទុកចំណែកស្មើៗគ្នាចំពោះចំណាយចាំបាច់ ប៉ុន្តែ កូនប្រុសទី ៣ វិញ បដិសេធការចូលរួមពិភាក្សា ឬ មិនរួមចំណែកក្នុងការចំណាយ ហើយជាលទ្ធផល ពុំអាចឈានដល់ការព្រមព្រៀង ។ ក្នុងករណីបែបនេះ តាមពាក្យសុំរបស់ភាគី តុលាការអាចកំណត់ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ដោយគិតពិចារណាទៅលើស្ថានភាពទាំងឡាយ ដូចជាលទ្ធភាពទ្រព្យធនរបស់កូនទាំងបី ជាដើម ។ តុលាការអាចបង្គាប់ឱ្យកូនណាម្នាក់ក្នុងចំណោមកូនទាំងអស់ ផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន ឬ បង្គាប់ឱ្យកូនទាំងអស់រួមចំណែកផ្គត់ផ្គង់អាហារកាតព្វកិច្ចបានដែរ ។

កថាខណ្ឌទី ៣ ពាក់ព័ន្ធនឹងស្ថានភាពដែលមានជនក្រីក្រ ២ នាក់ ឬ ច្រើននាក់ រីឯជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មានតែម្នាក់ ។ ឧទាហរណ៍ថា មានបងប្អូនប្រុសបួននាក់ ដែលបងប្អូនប្រុសបីនាក់ ក្រៅពីបងប្រុសច្បង គឺជនក្រីក្រ ហើយបងប្រុសច្បងពុំមានសាធនភាពគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ប្អូនប្រុសទាំងអស់ទេ ។ ក្នុងករណីបែបនេះ មានបញ្ហាត្រង់ចំណុចថា តើជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច គួរបែងចែកធនធានដែលមានកម្រិតរបស់ខ្លួនទៅអ្នកណា ។ គោលការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ត្រូវអនុវត្តចំពោះករណីនេះ

ផងដែរ ។ មានន័យថា ជាបឋម ប្រសិនបើអាចដោះស្រាយបញ្ហាតាមការពិភាក្សារវាងភាគី ដំណោះស្រាយចំពោះបញ្ហានោះ ត្រូវទុកឱ្យការពិភាក្សាដោះស្រាយ ក៏ប៉ុន្តែ ប្រសិនបើការពិភាក្សាពុំបានសម្រេច ត្រូវទុកឱ្យតុលាការសម្រេចសេចក្តី ។ ម្យ៉ាងទៀត ទោះបីជាជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ចមានច្រើននាក់ក៏ដោយ ប្រសិនបើមានស្ថានភាពបែបនោះ ក៏ការចាត់ចែងត្រូវបានធ្វើដូចគ្នាដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ១១៤២.- កម្រិត ឬ របៀបនៃការផ្តត់ផ្គង់អាហារកាតព្វកិច្ច

បើការពិភាក្សាមិនបានសម្រេច ឬ បើពុំអាចពិភាក្សាអំពីកម្រិត ឬ របៀបនៃការផ្តត់ផ្គង់អាហារកាតព្វកិច្ចបានទេ តុលាការត្រូវកំណត់ ដោយគិតពិចារណាទៅលើសេចក្តីត្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច និង ស្ថានភាពផ្សេងទៀតទាំងអស់ ។

(កំណត់)

មាត្រា ១១៤២ ចែងអំពីកម្រិត និង របៀបនៃការផ្តត់ផ្គង់អាហារកាតព្វកិច្ច ។

ជាគោលការណ៍ កម្រិត និង របៀបនៃការផ្តត់ផ្គង់អាហារកាតព្វកិច្ច ត្រូវកំណត់តាមរយៈការពិភាក្សារវាងភាគី ។ ក៏ប៉ុន្តែ មានករណីដែលការពិភាក្សាពុំបានជោគជ័យ ។ ក្នុងករណីនេះ ការកំណត់ត្រូវទុកឱ្យតុលាការសម្រេច ។ មាត្រានេះបញ្ជាក់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការសម្រេចសេចក្តីរបស់តុលាការ ។

ជាបឋម តុលាការត្រូវគិតអំពីកម្រិតនៃការផ្តត់ផ្គង់អាហារកាតព្វកិច្ច មានន័យថា តើជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច ត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច ដល់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចត្រឹមកម្រិតណា ។ វាមិនមានបញ្ហាទេចំពោះករណីដែលអ្នកដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច សម្បូរធនធាន ហើយផ្តល់នូវជំនួយច្រើនទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ដោយសារនេះជាសេរីភាពរបស់បុគ្គលឯកជន ។ ក៏ប៉ុន្តែ មានករណីជាច្រើនដែលជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច មិនសូវមានណាស់ទេ ហើយក៏ពុំអាចផ្តល់ជំនួយនូវចំនួនដ៏ច្រើនដែរ ។ ជាធម្មតា ជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ចចង់ផ្តល់ជំនួយដ៏តិចតួចប្រសិនបើអាច ខណៈដែលជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចចង់ទទួលបានច្រើនតាមដែលអាចទទួលបាន ។

លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច មានលក្ខណៈខុសគ្នា ។ ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច មិនគួរស្នើសុំជំនួយពីជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច លើសពីកម្រិត

ចាំបាច់សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅជាអប្បបរមាទេ ។ ប៉ុន្តែ ជីវភាពរស់នៅជាអប្បបរមា ក៏ខុសគ្នាអាស្រ័យទៅតាមស្ថានភាពដែលជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចស្ថិតនៅដែរ ។ អាស្រ័យហេតុនេះ វាពុំអាចទៅរួចទេក្នុងការសម្រេចឱ្យមានលក្ខណៈជាឯកសណ្ឋានថា អាហារកាតព្វកិច្ចត្រូវផ្តល់ឱ្យត្រឹមកម្រិតណា ឬ ជីវភាពកម្រិតអប្បបរមានោះយ៉ាងម្តេច ។ ដោយសារមានហេតុផលនេះហើយ ទើបមានការលំបាកក្នុងការកំណត់កម្រិតនៃអាហារកាតព្វកិច្ចនៅក្នុងមាត្រាច្បាប់ ។ ដោយហេតុនោះ សម្រាប់សេចក្តីយោង សូមណែនាំអំពីការបកស្រាយនៃកម្រិតអាហារកាតព្វកិច្ចនៃក្រុមរដ្ឋប្បវេណីជប៉ុន ។

ជាបឋម អាហារកាតព្វកិច្ចរវាងសហព័ទ្ធដែលកើតពីអានុភាពនៃអាពាហ៍ពិពាហ៍ និង អាហារកាតព្វកិច្ចរបស់អ្នកដែលមានអំណាចមេបាចំពោះកូនដែលជាអនីតិជនដែលកើតពីអានុភាពនៃអំណាចមេបា ហៅថា "ករណីយកិច្ចរក្សាផ្គត់ផ្គង់ជីវភាពរស់នៅ" ។ មានន័យថាជាករណីយកិច្ចដែលត្រូវធ្វើឱ្យសហព័ទ្ធ ឬ កូន រស់នៅក្នុងកម្រិតដូចគ្នាទៅនឹងកម្រិតជីវភាពរបស់អ្នកមានកាតព្វកិច្ច ។ ក៏ប៉ុន្តែ ជាធម្មតា សហព័ទ្ធរស់នៅជាមួយគ្នា ហើយអ្នកមានអំណាចមេបារស់នៅជាមួយកូនដែលជាអនីតិជន ដូច្នេះ ជាទូទៅ ជនទាំងនេះមានកម្រិតជីវភាពដូចគ្នា ។

ផ្ទុយទៅវិញ ចំពោះអាហារកាតព្វកិច្ចរវាងញាតិដែលបានចែងក្នុងជំពូកនេះ ត្រូវបានបកស្រាយថា ជាបឋម ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ត្រូវធ្វើឱ្យប្រពន្ធ និង កូនជាអនីតិជនរបស់ខ្លួន រស់នៅក្នុងកម្រិតដូចគ្នានឹងជីវភាពរបស់ខ្លួន និង រក្សាកម្រិតនៃការរស់នៅរបស់ខ្លួនឱ្យសមរម្យទៅនឹងមុខរបរ និង ឋានៈក្នុងសង្គមរបស់ខ្លួន បន្ទាប់ពីនេះ ប្រសិនបើនៅសល់លទ្ធភាពទ្រព្យធន ទ្រព្យធននៅសល់គួរត្រូវបានប្រើសម្រាប់ផ្គត់ផ្គង់ដល់ញាតិក្រីក្រ ។ ករណីយកិច្ចបែបនេះ ហៅថា "ករណីយកិច្ចទ្រទ្រង់ជីវភាព" ។ តុលាការមិនគួរចេញសេចក្តីសម្រេចដែលបង្គាប់ឱ្យជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចណា ដែលធ្វើឱ្យមានការពិបាកដល់ជីវិភាពរបស់ជនដែលមានករណីយ-កិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចឡើយ ។ លើសពីនេះទៅទៀត ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចមិនចាំបាច់ធ្វើឱ្យជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច មានជីវភាពរស់នៅលើសពីកម្រិតដែលចាំបាច់នោះទេ ទោះបីជាជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ស្នើសុំនូវកម្រិតជីវភាពរស់នៅបែបនោះក៏ដោយ ។

របៀបផ្គត់ផ្គង់អាហារកាតព្វកិច្ច ជាគោលការណ៍ គឺជាការផ្តល់តាវកាលិកនូវប្រាក់ ពីជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ។ ជាការពិតណាស់ ប្រសិនបើអាចដោះស្រាយភាពចាំបាច់នៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច តាមការផ្តល់តាវកាលិកនូវវត្ថុក្រៅពីប្រាក់ ការផ្តល់តាវកាលិកនូវវត្ថុនោះក៏អាចធ្វើទៅបានបន្ទាប់ពីការពិភាក្សារវាងភាគី ឬ តាមសេក្តីសម្រេចរបស់តុលាការ ។ ជាឧទាហរណ៍ អាចផ្តល់ជាអាហារបរិក្ខារពេទ្យ ឬ ទីជម្រក ជាដើម ។ម្យ៉ាងទៀត អាចមានករណីដែលជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ពុំមានប្រាក់សម្រាប់ចំណាយលើអាហារកាតព្វកិច្ច ប៉ុន្តែ ជននោះមានបន្ទប់ទំនេរ និង អាចផ្តល់អាហារសម្រាប់បុគ្គលម្នាក់ ហេតុដូច្នេះ ឱ្យជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច រស់នៅជាមួយជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ។ អាហារកាតព្វកិច្ចបែបនេះហៅថា "ការផ្គត់ផ្គង់ដោយឱ្យរស់នៅជាមួយគ្នា" ។

ក៏ប៉ុន្តែ ទោះបីជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ស្នើសុំផ្តល់ "ការផ្គត់ផ្គង់ដោយឱ្យរស់នៅជាមួយគ្នា" ក៏ដោយ ក៏អាចមានករណីដែលជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចអាចបដិសេធអំពីការរស់នៅជាមួយគ្នានោះបានដែរ ។ ផ្ទុយមកវិញ អាចមានករណីផ្សេងទៀតដែលជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ស្នើសុំ "ការផ្គត់ផ្គង់ដោយឱ្យរស់នៅជាមួយគ្នា" តែជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច បដិសេធការរស់នៅជាមួយគ្នានោះបានដែរ ។ ប្រសិនបើជនម្នាក់បដិសេធការរស់នៅជាមួយជនម្នាក់ទៀត ច្បាប់មិនអាចបង្ខំឱ្យជនទាំងនោះរស់នៅជាមួយគ្នាបានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៧៩ ក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៨៣.-** ការផ្លាស់ប្តូរ ឬ លុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច

១-ប្រសិនបើមានការផ្លាស់ប្តូរស្ថានភាព ក្រោយពីបានពិភាក្សា ឬ ក្រោយពីមានការសម្រេចសេចក្តី ចំពោះជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ឬ ជនដែលទទួលអាហារកាតព្វកិច្ចជាក់លាក់ ឬ កម្រិត ឬ របៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច ភាគីអាចផ្លាស់ប្តូរទំនាក់ទំនងនៃអាហារកាតព្វកិច្ច ដោយការពិភាក្សាបាន ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីអាចទាមទារទៅតុលាការឱ្យលុបចោល ឬ ផ្លាស់ប្តូរការពិភាក្សា ឬ ការសម្រេចសេចក្តីដែលធ្វើមុនបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ១១៨១ (ការកំណត់ជាក់លាក់អំពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និង ជនដែលទទួលអាហារកាតព្វកិច្ច) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតុលាការបង្គាប់ឱ្យលុបចោល ឬ ផ្លាស់ប្តូរ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ ។

(កំណត់)

មាត្រា ១១៨៣ កំណត់អំពីការចាត់ចែង ក្នុងករណីដែលមានការផ្លាស់ប្តូរនៃស្ថានភាព បន្ទាប់ពីទំនាក់ទំនងនៃអាហារកាតព្វកិច្ចត្រូវបានកំណត់ តាមការពិភាក្សា ឬ សេចក្តីសម្រេចរបស់តុលាការ ដូចបានចែងក្នុងមាត្រា ១១៨១ និង មាត្រា ១១៨២ ។

កថាខណ្ឌទី ១ ចែងថា ទោះបីជាទំនាក់ទំនងនៃអាហារកាតព្វកិច្ច ត្រូវបានកំណត់តាំងពីដំបូង តាមរយៈការពិភាក្សា ឬ តាមរយៈសេចក្តីសម្រេចរបស់តុលាការហើយក៏ដោយ ក៏ភាគីអាចធ្វើការផ្លាស់ប្តូរខ្លឹមសារដែលបានសម្រេច តាំងពីដំបូង

នោះ តាមការពិភាក្សាបានដែរ ។

កថាខណ្ឌទី ២ ចែងថា ប្រសិនបើការពិភាក្សាដែលបានចែងក្នុងកថាខណ្ឌទី ១ មិនបានសម្រេច ភាគីអាច ទាមទារឱ្យតុលាការលុបចោល ឬ ធ្វើការផ្លាស់ប្តូរកិច្ចព្រមព្រៀង ឬ សេចក្តីសម្រេចរបស់តុលាការដែលបានធ្វើពីមុននោះ បាន ។

កថាខណ្ឌទី ៣ ចែងថា លក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ៣ នៃមាត្រា ១១៤១ ត្រូវយក មកអនុវត្ត ចំពោះករណីដែលតុលាការសម្រេចឱ្យលុបចោល ឬ ផ្លាស់ប្តូរកិច្ចព្រមព្រៀង ឬ សេចក្តីសម្រេចរបស់តុលាការ ដែលបានធ្វើពីមុន ដោយយោងតាមតាមកថាខណ្ឌទី ២ នៃមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨៨០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១១៤៤.-** ការហាមឃាត់នូវការចាត់ចែងសិទ្ធិទាមទារអាហារកាតព្វកិច្ច

សិទ្ធិទាមទារអាហារកាតព្វកិច្ច គឺជាសិទ្ធិផ្តាច់មុខរបស់បុគ្គលដែលត្រូវការចាំបាច់ នូវអាហារកាតព្វកិច្ច ហើយពុំអាចយកមកធ្វើជាកម្មវត្ថុនៃអនុប្បទាន ប្រទានកម្ម ឬ ការ បង្កើតសិទ្ធិប្រាតិភោគសម្រាប់តតិយជន ឬ ជំនួញផ្សេងៗទៀត បានឡើយ ។

(កំណត់)

មាត្រា ១១៤៤ ចែងថា សិទ្ធិរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ចំពោះជនដែលត្រូវផ្គត់ផ្គង់ អាហារកាតព្វកិច្ច (សិទ្ធិទាមទារអាហារកាតព្វកិច្ច) គឺជាកម្មសិទ្ធិផ្តាច់មុខរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ហើយមិនអាចក្លាយទៅជាកម្មវត្ថុនៃការជួញដូរណាមួយឡើយ ។ នៅក្នុងកំណត់នៃមាត្រា ១១៤២ មានការពន្យល់ថា ជាគោលការណ៍ អាហារកាតព្វកិច្ចត្រូវបានផ្តល់តាមរយៈការបង់ប្រាក់ទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ដោយ ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ។ បើមើលតាមទស្សនៈមួយ សិទ្ធិទាមទារអាហារកាតព្វកិច្ច មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ដែលជនដែលមានសិទ្ធិទទួល អាហារកាតព្វកិច្ចមានចំពោះជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ។ ក៏ប៉ុន្តែ សិទ្ធិទទួលអាហារកាតព្វកិច្ច និង កាតព្វកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច មិនមែនកើតចេញពីកិច្ចសន្យាទេ គឺកើតចេញពីទំនាក់ទំនងជាក់លាក់មួយ រវាងញាតិ ។ អាស្រ័យហេតុនេះ ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច មិនអាចធ្វើអនុប្បទានសិទ្ធិទទួល អាហារកាតព្វកិច្ចនោះទៅតតិយជន ឬ បង្កើតសិទ្ធិលើការបញ្ចាំសិទ្ធិទទួលអាហារកាតព្វកិច្ចនោះ ដើម្បីខ្ចីប្រាក់ពីអ្នករកស៊ី ចងការប្រាក់ ដូចសិទ្ធិលើបំណុលដទៃនោះបានទេ ហើយមិនគួរឱ្យមានហេតុការណ៍ដូច្នេះទេ ។ ដោយហេតុថា អាហារកាតព្វកិច្ច គឺជាជំនួយសម្រាប់តែជនក្រីក្រប៉ុណ្ណោះ អាហារកាតព្វកិច្ចបែបនេះ មិនគួរអាចត្រូវបានប្រើសម្រាប់ គោលបំណងផ្សេងទៀតបានឡើយ ។ ថ្វីត្បិតតែបញ្ញត្តិនេះច្បាស់លាស់ហើយក៏ដោយ ក៏ចាំបាច់ត្រូវបន្ថែមការពន្យល់ ដើម្បី

ឱ្យកាន់តែច្បាស់លាស់បន្ថែមទៀតដែរ ។

( កំណត់បញ្ចប់)

មានបញ្ហាពិបាកជាច្រើនពាក់ព័ន្ធនឹងអាហារកាតព្វកិច្ច ។ ដោយហេតុថា មិនមានភាពច្បាស់លាស់អំពីស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា ហើយមានភាពមិនងាយស្រួលក្នុងការរៀបចំបញ្ញត្តិជាក់លាក់ ដូច្នេះ យើងគ្រាន់តែលើកយកមកបង្ហាញថា ចំណុចខាងក្រោមនេះជាបញ្ហាដែលត្រូវទុកធ្វើការបកស្រាយ ។

១. ការទាមទារឱ្យសងប្រាក់ចំណាយសម្រាប់អាហារកាតព្វកិច្ចកាលពីអតីតកាល ចំពោះអតីតជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ដោយអតីតជនដែលមានករណីយកិច្ចត្រូវផ្តត់ផ្គង់អាហារកាតព្វកិច្ច : ឧទាហរណ៍ថា មានបងប្អូនប្រុស ២ នាក់ ដែលប្អូនប្រុសបានផ្គត់ផ្គង់អាហារកាតព្វកិច្ច ដល់បងប្រុស ក្នុងអំឡុងពេលបងប្រុសមានជម្ងឺ ។ ក្រោយមក បងប្រុសបានជាសះស្បើយពីជម្ងឺឡើងវិញ ចាប់ផ្តើមប្រកបការងារសាជាថ្មី និង ជោគជ័យក្នុងរបររកស៊ីរបស់ខ្លួន ហើយនាពេលបច្ចុប្បន្ន បងប្រុសបានក្លាយជាអ្នកមានជាងប្អូនប្រុស ។ ក្នុងករណីនេះ តើប្អូនប្រុសអាចទាមទារមកវិញនូវសោហ៊ុយដែលបានចំណាយសម្រាប់អាហារកាតព្វកិច្ចសម្រាប់បងប្រុសនាពេលអតីតកាល ចំពោះបងប្រុសបានដែរ ឬទេ ? បើគិតថាអាចទាមទារបាន វាហាក់ដូចជាការផ្គត់ផ្គង់អាហារកាតព្វកិច្ចនឹងត្រូវបានចាត់ទុកដូចជាកិច្ចសន្យាខ្ចីបរិភោគប្រាក់ ។ ក៏ប៉ុន្តែនឹងមានការពិបាកចំពោះប្អូនប្រុសក្នុងការទប់អារម្មណ៍ចង់ទាមទារឱ្យបងប្រុសរបស់ខ្លួន សងវិញនូវការចំណាយសម្រាប់ការផ្គត់ផ្គង់អាហារកាតព្វកិច្ចកាលពីពេលមុន ។

២. ការទាមទារសំណងនៃប្រាក់ចំណាយសម្រាប់អាហារកាតព្វកិច្ចនាពេលអតីតកាល រវាងជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច : ឧទាហរណ៍ថា មានបងប្អូនប្រុសបីនាក់ ហើយប្អូនប្រុសទី ២ ផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់បងប្រុសច្បង ក្នុងអំឡុងពេលដែលបងប្រុសច្បងមានជម្ងឺ នៅខណៈដែលអ្វីដែលប្អូនប្រុសពៅអាចធ្វើបាន គឺត្រឹមតែផ្គត់ផ្គង់ជីវភាពរស់នៅរបស់ខ្លួនប៉ុណ្ណោះ ។ បងប្រុសច្បងបានជាសះស្បើយពីជម្ងឺ និង មិនចាំបាច់ទទួលអាហារកាតព្វកិច្ចទៀតឡើយ ។ ក្រោយមក ប្អូនប្រុសពៅក្លាយជាអ្នកមាន ។ ក្នុងករណីនេះ តើប្អូនប្រុសទី ២ អាចទាមទារឱ្យប្អូនប្រុសពៅសងចំនួនពាក់កណ្តាលនៃការចំណាយដែលខ្លួនបានធ្វើសម្រាប់បងប្រុសច្បងកាលពីពេលមុនបានដែរឬទេ? បើគិតថា អាចទាមទារបាន វាហាក់ដូចជាកាតព្វកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចនឹងត្រូវបានចាត់ទុកដូចជាកាតព្វកិច្ចដោយសាមគ្គីភាព ។ ក៏ប៉ុន្តែ នឹងមានការពិបាកចំពោះប្អូនប្រុសទី ២ ក្នុងការទប់អារម្មណ៍ចង់និយាយអំពីបញ្ហានេះទៅប្អូនប្រុសពៅរបស់ខ្លួន ។

៣. ការទាមទារប្រាក់ចំណាយសម្រាប់អាហារកាតព្វកិច្ច ដោយតតិយជន ចំពោះជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច : ឧទាហរណ៍ថា មានបុរសចំណាស់ម្នាក់រស់នៅក្នុងស្ថានភាពក្រីក្រតែម្នាក់ឯង ហើយអ្នកជិតខាងបានផ្តល់ប្រាក់ អាហារ និង ការចំណាយដើម្បីព្យាបាលនៅមន្ទីរពេទ្យ ជាដើម ។ ថ្ងៃមួយ កូនប្រុសរបស់បុរសនោះដែលគេគិតថា បានស្លាប់ហើយ បានលេចមុខឡើង ។ ក្នុងករណីនេះ តើអ្នកជិតខាងអាចទាមទារនូវប្រាក់ចំណាយផ្សេងៗដែលបានចំណាយពីអតីតកាល ចំពោះកូនប្រុសនោះបានដែរ ឬទេ ? ប្រសិនបើអំពើរបស់អ្នកជិតខាងត្រូវបានយល់ឃើញថាធ្វើដោយសារតែសេចក្តីមេត្តា និង ចិត្តសប្បុរស បញ្ហានេះមិនស៊ីសង្វាក់គ្នាជាមួយនឹងការទាមទារតាមផ្លូវច្បាប់ទេ ។ ក៏ប៉ុន្តែ

ជាការពិតដែលក្នុងអំឡុងពេលមុននោះ កូនប្រុសបានរួចផុតពីការបំពេញករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ។ ដូច្នេះ មានបញ្ហាត្រង់ចំណុចថា ការរួចផុតពីករណីយកិច្ចរបស់កូននោះ អាចត្រូវបានបកស្រាយថាជាសេចក្ដីចម្រើនដោយឥតហេតុ ឬយ៉ាងណា ។